# ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១

## នគរបាលឃាត់ខ្លួនមេខ្យល់ ប្តីប្រពន្ធ ២នាក់ ករណីប៉ុនប៉ងនាំមនុស្សឆ្លងដែន ដោយខុសច្បាប់

https://postnews.com.kh/ ថ្ងៃសៅរ៍, ទី30 ខែខែតុលា, 2021 08:19 ព្រឹក 0 Comments

**ដំបង:** សមត្ថកិច្ចនគរបាលស្រុកថ្មគោលស្រាវជ្រាវ បង្ក្រាបករណីប៉ុនប៉ងនាំឆ្លងដែន ដោយខុសច្បាប់មួយករណី ឃាត់ខ្លួនមុខសញ្ញាជាមេខ្យល់ចំនួន ០២នាក់ និងនាំជនរងគ្រោះក្នុងករណីនេះចំនួន ១០នាក់ធ្វើការសាកសួរស្រាវជ្រាវ៖ នៅថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំឆ្លូវត្រីស័កព. ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២១ វេលាម៉ោង០៦និង៣០នាទី នៅចំណុចផ្ទះសំណាក់ ឃីហោហេង២ ស្ថិតក្នុងក្រុមទី០៦ ភូមិគោកគ្រប់ ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង អនុវត្តតាមបទបញ្ជាដឹកនាំរបស់លោក សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ក៏ដូចយោបល់របស់លោកស្រី រស់ ជីវី ស្នងការរងផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារ យេនឌ័រ លោកវរសេនីយ៍ទោ សេង លុច អធិការ នគរបាលស្រុកថ្មគោល បានដឹកនាំ លោកស្រីអនុសេនីយ៍ឯក ផៃ ចាន់សុដាវី អធិការរងទទួល ការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ នៃអធិការដ្ឋាននគរបា លស្រុកថ្មគោល ជាមួយផ្នែកនគរបាលយុត្តិធម៌ ដឹកនាំដោយលោកវរសេនីយ៍ទោ ហៀង ប៊ុនថា អធិការរងទទួលការងារនគរបាលយុត្តិធម៌ ធ្វើបច្ចុប្បន្នភាពតាមផ្ទះសំណាក់ក្នុងភូមិសាស្ត្រស្រុកថ្មគោល ដើម្បីត្រួតពិនិត្យស្រាវជ្រាវ រកប្រជា ពលករមកស្នាក់នៅក្នុងគោលបំណងធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅក្រៅប្រទេសដោយខុសច្បាប់។

ជាលទ្ធផលពិនិត្យនិងបង្ក្រាបឃាត់ខ្លួនជនសង្ស័យចំនួន ២នាក់គឺ៖

១-ឈ្មោះ តា ញ៉ែន ហៅ ភាព ភេទប្រុស អាយុ ៣៦ឆ្នាំ រស់នៅភូមិតាគ្រាប់ ឃុំព្នៅទី១ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

២-ឈ្មោះ ហាន ស្រីណុច ភេទស្រី អាយុ ៣១ឆ្នាំ រស់នៅភូមិតាគ្រាប់ ឃុំព្នៅទី១ ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង (ប្តីប្រពន្ធ) ដែលពួកគាត់ទាំងពីរនាក់នេះ ពាក់ព័ន្ធក្នុងករណីការនាំយក ចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែនទៅកាន់ប្រទេសថៃ ។

ជាមួយនេះបាននាំប្រជាពលរដ្ឋរងគ្រោះចំនួន ១០នាក់ ដែលត្រូវបានអ្នកទាំងពីរនាំមកបម្រុងលបលួចឆ្លងដែនចូលទៅក្នុងប្រទេសថៃក្នុងនោះគឺ៖

១-ឈ្មោះ សាត ចិត ភេទប្រុស អាយុ ៣៧ឆ្នាំរស់ នៅភូមិដូង ឃុំថ្មពេជ្រស្រុកត្បូងឃ្មុំខេត្តត្បូងឃ្មុំ ។

២-ឈ្មោះ ហាន ណេត ភេទប្រុស អាយុ ២៥ឆ្នាំ រស់នៅភូមិតាគ្រាប ឃុំព្នៅទី១ ស្រុកស៊ីធរ កណ្តា លខេត្តព្រៃវែង ។

៣-ឈ្មោះ វ៉ វ៉ ជីវ៉ា ភេទប្រុស អាយុ២៥ឆ្នាំ រស់នៅភូមិព្រែកន្លោង ឃុំព្រែកន្លោង ស្រុកពោធិរៀង ខេត្តព្រៃវែង។

៤-ឈ្មោះ ស វិធាន ភេទប្រុស អាយុ ៣៨ឆ្នាំ រស់នៅភូមិព្រែកន្លោង ឃុំព្រែកន្លោង ស្រុកពោធិ៍រៀង ខេត្តព្រៃវែង។

៥-ឈ្មោះ ស វិជ្ជ័យ ភេទប្រុស អាយុ ៤០ឆ្នាំ រស់នៅភូមិវាល ឃុំកញ្ចំ ស្រុកពារាំង ខេត្តព្រៃវែង។

៦-ឈ្មោះ អ៊ឹម មឿន ភេទប្រុស អាយុ ៤៥ឆ្នាំ រស់នៅភូមិព្រៃព្នៅ ឃុំព្រៃព្នៅ ស្រុកពារាំងខេត្តព្រៃវែង។

៧-ឈ្មោះ សុខ ហៃ ភេទប្រុស អាយុ ៣៥ឆ្នាំ រស់នៅភូមិវាល ឃុំកញ្ចំស្រុកពារាំង ខេត្តព្រៃវែ ង។

៨-ឈ្មោះ ស៊ូ សារឿន ភេទប្រុស អាយុ ៣៩ឆ្នាំ រស់នៅភូមិតាក្រៀម ឃុំញ៉ោទី១ ស្រុកស៊ីធរ កណ្ដាលខេត្តព្រៃវែង។

៩-ឈ្មោះ ញ៉ សុខុម ភេទប្រុស អាយុ ៤១ឆ្នាំ រស់នៅភូមិតាគ្រាប ឃុំញ៉ោទី១ ស្រុកស៊ីធរ កណ្ដាល ខេត្តព្រៃវែង។

១០-ឈ្មោះ ជួប កុយ ភេទប្រុស អាយុ ២២ឆ្នាំ រស់នៅភូមិព្រៃឈរ ឃុំព្រៃឈរ ស្រុកព្រៃឈរខេត្តកំពង់ចាម។ នៅពេលនេះជនសង្ស័យ និងជនរងគ្រោះ នគរបាលនគរស្រុកថ្មគោល បាននិងកំពុងធ្វើការសាក សួរស្រាវជ្រាវ៕

## ប៉ូលិសថៃបង្ខាប់ឲ្យពលករខ្មែរ៧នាក់ រកលុយបង់ធ្វើប័ណ្ណការងារ ជាថ្នូរនឹងការដោះលែងនៅសប្ដាហ៍ក្រោយ

https://www.rfa.org/ ដោយ យន់ សាមៀន 2021-10-31

ប៉ូលិសថៃសន្យាជាមួយពលករថា នឹងដោះលែងពលករខ្មែរចំនួន៧នាក់ នៅថ្ងៃច័ន្ទសប្ដាហ៍ក្រោយ តែតម្រូវឲ្យពួកគេបង់លុយដើម្បីធ្វើប័ណ្ណការងារស្របច្បាប់ ទើបព្រមដោះលែងវិញ។ អ្នកឃ្លាំមើល ជំរុញឲ្យអាជ្ញាធរថៃយោគយល់ចំពោះពលករ ព្រោះពួកគាត់គ្មានការងារធ្វើ និងគ្មានប្រាក់ចំណូលច្រើនខែមកហើយ។ ប៉ូលិសថៃ បានបញ្ជូនពលករខ្មែរចំនួន៧នាក់ ទៅឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារ នៃការិយាល័យប៉ូលិសអន្តោប្រវេសន៍ ទីក្រុងបាងកក (IDC Prison - immigration detention center) តាំងពីរសៀលថ្ងៃទី២៩ តុលា មក។

ពលករធ្វើសំណង់ជាមួយក្រុមពលករដែលត្រូវអាជ្ញាធរថៃចាប់ខ្លួន គឺលោក ធៃ លឿង ប្រាប់អាស៊ីសេរីថា អ្នកត្រូវចាប់ខ្លួន មានប្រុស ៣នាក់ ស្រី៤នាក់។ លោកថា ការឆ្មក់ចាប់នេះ ធ្វើឡើងនៅមុខក្រសួងការងារថៃ ក្នុងពេលពួកគេកំពុងដាក់ញត្តិស្នើសុំដំណោះស្រាយផ្នែកការងារ។ លោក ធៃ លឿង រៀបរាប់ថា ប៉ូលិសថៃមួយក្រុមបានចុះមកត្រួតពិនិត្យពលករទាំងអស់ដែលឈរដាក់ញត្តិនៅខាងមុខក្រសួងការងារ កាលពីថ្ងៃទី២៩ តុលា ដើម្បីរកឯកសារបញ្ជាក់ការងារ ហើយប៉ូលិសថៃបានចាប់ពលករ៧នាក់ បញ្ជូនទៅប៉ុស្តិ៍ប៉ូលិស រួចហើយបញ្ជូនបន្តទៅពន្ធនាគារនៃការិយាល័យអន្តោប្រវេសន៍ទីក្រុងបាងកក។ ក្រោយមកពលករជាច្រើននាក់ បានទៅសុំអង្វរប៉ូលិសថៃឲ្យដោះលែងពលករទាំង៧នាក់វិញ និងបានប្រាប់ហេតុផលថា ពួកគាត់គ្មានប្រាក់ចំណូល ហើយគ្មានការងារធ្វើច្រើនខែហើយ ទើបពួកគាត់គ្មានលទ្ធភាពធ្វើប័ណ្ណការងារស្របច្បាប់។ ពលករឲ្យដឹងថា ការធ្វើប័ណ្ណការងារម្ដងមានសុពលភាព២ឆ្នាំ ត្រូវចំណាយលុយសរុបទាំងថ្លៃរត់ការ និងថ្លៃសេវារដ្ឋ ជាងមួយម៉ឺន (១២.០០០) បាត ឬប្រហែលបួនរយ(៤០០)ដុល្លារ។ លោក ធៃ លឿង បន្តថា ប៉ូលិសបានសន្យាថា នឹងដោះលែងពលករទាំង៧នាក់វិញ តែតម្រូវឲ្យពួកគេបង់លុយក្នុងម្នាក់ជាងពីរម៉ឺន(២១.០០០)បាត ឬស្មើ៧០០ដុល្លារ ដើម្បីយកទៅធ្វើប័ណ្ណការងារស្របច្បាប់ ទើបព្រមដោះលែងវិញនៅដើមសប្ដាហ៍ក្រោយ៖ «អ្នកចាប់ហ្នឹង មានចាស់ មានក្មេង។ មានម្នាក់គាត់មានកូនតូចនៅឯហាង់(បន្ទប់ជួល) ហើយម្ដាយជាប់នៅឯនោះឯង។ ម្នាក់ហ្នឹង គាត់រាងពិការជើងផង គាត់មានលេបថ្នាំរាល់ថ្ងៃផង។ ចង់ឲ្យបងប្អូនយើងទៅមើលគាត់ផង»។

តំណាងពលករប្រមាណ៥០នាក់ បានប្រមូលផ្ដុំគ្នាដាក់ញត្តិជាថ្មីទៀត កាលពីថ្ងៃទី២៩ តុលា ទាមទារឲ្យថៅកែថៃបញ្ឈប់ការកិបកេងកម្លាំងពលកម្ម និងត្រូវផ្ដល់ផលប្រយោជន៍ឲ្យពលករ ឲ្យបានត្រឹមត្រូវតាមច្បាប់។ ក្រុមពលករអះអាងថា ថៅកែជនជាតិថៃជាច្រើននៅតែបន្តគេចវេះពីការទទួលខុសត្រូវលើពលករ ដោយមិនបានផ្ដល់ប្រាក់ឧបត្ថម្ភ៥០ភាគរយ និងថ្លៃអាហារហូបចុក៣ពេលឲ្យពលករទេ ក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ១៩ (Covid-19) នេះ។ ពលករថា បញ្ហានេះ គឺបណ្ដាលមកពីក្រសួងការងារថៃចុះធ្វើអធិការកិច្ចគ្មានប្រសិទ្ធភាព។

ពលករផ្នែកសំណង់ម្នាក់ ធ្វើការនៅទីក្រុងបាងកក ដែលបានចូលរួមការដាក់ញត្តិកាលពីថ្ងៃទី២៩ តុលា គឺលោក ម៉ុត មុល ឲ្យដឹងថា ក្នុងពេលប្រទេសថៃជួបវិបត្តិជំងឺកូវីដ១៩ធ្ងន់ធ្ងរច្រើនខែមកនេះ អាជ្ញាធរថៃបានបិទតំបន់

មួយចំនួន ហើយរដ្ឋាភិបាលថៃ បានបង្គាប់ឲ្យថៅកែផ្តល់ប្រាប់ឧបត្ថម្ភឲ្យពលករពាក់កណ្តាលក្នុងមួយខែ ផ្តល់ជូនកន្លែងស្នាក់នៅឲ្យបានសមរម្យ និងផ្តល់អាហារសមរម្យក្នុងមួយថ្ងៃ៣ពេលឲ្យពលករ។ លោកអះអាងថា ថៅកែភាគច្រើនមិនគោរពកាតព្វកិច្ចនេះទេ ហើយឆ្លៀតឱកាសកូវីដ១៩នេះ លែងរវល់ និងដោះដៃចោលពលករតែម្តង៖ «បិទខ្ទប់យើង អត់មានការងារធ្វើ ប្រកាន់សង្គម(ធានារ៉ាប់រង) គេជួយយើង៥០ភាគរយ ប៉ុន្តែកន្លែងខ្លះបានតែ២៥ភាគរយ ដូចកន្លែងខ្ញុំអ៊ីចឹងណាបង។ កន្លែងគេដទៃខ្លះណាអត់អ៊ីចឹងទៅ បានយើងដាក់សំណើទៅកាន់ក្រសួងដើម្បីឲ្យជួយត្រួតពិនិត្យបញ្ហាត្រង់នេះបន្តិចណាបង ខ្លាចមានករណីពុករលួយកើតឡើង ឬថៅកែឲ្យយើង ឬក៏ក្រសួងគេចេញមកហើយ តែថៅកែគេកាត់យកពីយើង អត់ឲ្យយើងអ៊ីចឹងណា»។

នេះគឺជាលើកទី៣ហើយ ដែលតំណាងមូលនិធិពលករខ្មែរនៅប្រទេសថៃ នាំគ្នាដាក់ញត្តិទៅក្រសួងការងារថៃ ចាប់តាំងពីថៃជួបវិបត្តិជំងឺកូវីដ១៩ ពីខែមីនាមក។ ការដាក់ញត្តិនៅក្រសួងការងារថៃទាំង៣លើកនេះ ក្នុងគោលបំណងតែមួយគត់ គឺសុំរដ្ឋាភិបាលថៃគិតគូរដល់ពលករខ្មែរផង។ ទោះជាយ៉ាងណា តំណាងពលករមិនបានទៅរកកិច្ចអន្តរាគមន៍ ឬក៏ទៅដាក់ញត្តិនៅស្ថានទូតខ្មែរនៅទីក្រុងបាងកកនោះឡើយ ចាប់តាំងពីជួបវិបត្តិជំងឺកូវីដ១៩មក ព្រោះពួកគាត់បារម្ភខាតពេលវេលា ដោយសារមន្ត្រីស្ថានទូតខ្មែរមិនព្រមជួយពលករ។

ពាក់ព័ន្ធនឹងករណីនេះ វិទ្យុអាស៊ីសេរី មិនអាចសុំការបញ្ជាក់ពីឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃលោក អ៊ុក សោភ័ណ បានទេនៅថ្ងៃទី៣០ តុលា។ ចំណែកបណ្តាញសង្គម(Facebook)របស់ស្ថានទូតខ្មែរនៅប្រទេសថៃក៏មិនបានបង្ហោះសារទាក់ទងនឹងស្ថានភាពរបស់ពលករដែរ ក្នុងរយៈពេល២សប្តាហ៍ចុងក្រោយនេះ។

កាលពីចុងខែមិថុនា ក្រុមមូលនិធិពលករខ្មែរក៏ធ្លាប់បានដាក់ញត្តិទៅរដ្ឋសភាថៃ និងគណៈរដ្ឋមន្ត្រីថៃដែរ ដើម្បីស្នើសុំឲ្យមានដំណោះស្រាយជុំវិញបញ្ហាប្រឈមនៃវិបត្តិជំងឺកូវីដ-១៩ ដែលជះឥទ្ធិពលធ្ងន់ធ្ងរមកលើក្រុមពលករខ្មែរធ្វើការក្នុងប្រទេសថៃ។ ស្ថាប័នរដ្ឋរបស់ថៃទាំងអស់ តែងតែចេញមកទទួលញត្តិ និងអញ្ជើញតំណាងពលករចូលជជែករកដំណោះស្រាយ ហើយសន្យាជាមួយតំណាងកម្មករនឹងជួយដោះស្រាយឲ្យជានិច្ច។

ប្រធានមូលនិធិពលករខ្មែរប្រចាំប្រទេសថៃ លោក ស៊ុន សីហា សង្កេតឃើញថា ថ្វីត្បិតតែខាងក្រសួងបានសន្យាថា ជួយពលករមែន តែច្រើនខែមកនេះ មន្ត្រីក្រសួងការងារថៃចុះធ្វើអធិការកិច្ច បានផលតិចតួចបំផុត។ លោកបន្ត ថៅកែខ្លះបានបាំងព័ត៌មានស្តីពីស្ថានភាពពលករ ហើយថៅកែខ្លះទៀតយកពលករទៅលាក់បំពួននៅពេលក្រុមអធិការកិច្ចចុះមកពិនិត្យ ជាហេតុធ្វើឲ្យការធ្វើអធិការកិច្ចមានភាពទន់ខ្សោយ។ លោកបន្តទៀតថា ក្រុមពលករស្ទើរទាំងអស់ កំពុងជួបការលំបាកក្នុងការធ្វើប័ណ្ណការងារ និងបន្តសុពលភាពប័ណ្ណការងារ ព្រោះតែការអូសបន្លាយនៃវិបត្តិជំងឺកូវីដ១៩ និងបញ្ហាគ្មានប្រាក់ចំណូល៖ «ពួកយើងបានទៅធ្វើហ្នឹង គឺចង់ផ្សព្វផ្សាយទៅដល់អន្តរជាតិ ក៏ដូចជាអង្គការILO ជាអង្គការគ្រប់គ្រងសិទ្ធិពលករអន្តរជាតិក្តីហ្នឹង ឲ្យបានដឹងថា នៅក្នុងប្រទេសថៃហ្នឹង អត់បានគោរពទៅតាមគោលការណ៍ច្បាប់អន្តរជាតិ ពាក់ព័ន្ធនឹងការគាំពារសិទ្ធិពលករ»។

របាយការណ៍របស់អង្គការសង់ត្រាល់ (CENTRAL) បង្ហាញថា មុនពេលប្រទេសថៃជួបវិបត្តិជំងឺកូវីដ១៩ មានពលករខ្មែរធ្វើការនៅក្នុងប្រទេសនេះជិតពីរលាន(២លាន)នាក់ គឺរាប់បញ្ចូលទាំងពលករមានប័ណ្ណការងារ និងពលករគ្មានប័ណ្ណការងារ។ ចំណែកអគ្គនាយកដ្ឋានអន្តោប្រវេសន្តវិញធ្លាប់បង្ហាញថា មានពលករយ៉ាងតិចណាស់ជាងបួនម៉ឺន(៤៤.០០០)នាក់ បានចូលមកកម្ពុជា ក្នុងចន្លោះពីធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃខែមិថុនា ឆ្នាំ២០២១។ ទន្ទឹមនេះ ពលករដែលបានវិលត្រឡប់មកព្យាបាលជំងឺកូវីដ១៩នៅប្រទេសកម្ពុជាវិញ និងពលរដ្ឋគ្មានការងារធ្វើមួយចំនួន កំពុងរកវិធីលបចូលទៅរកការងារធ្វើ នៅក្នុងប្រទេសថៃវិញ៕

# ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១

## សម្ដេចតេជោ ហ៊ុន សែន ណែនាំឱ្យបញ្ជូនវ៉ាក់សាំង ទៅចាក់ជូនពលករខ្មែរនៅថៃ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ១ វិច្ឆិកា ២០២១ដោយ KC Virak

សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានធ្វើការណែនាំឱ្យអាជ្ញាធរកម្ពុជាធ្វើទំនាក់ទំនងជាមួយរាជរដ្ឋាភិបាលថៃ ដើម្បីបញ្ជូនវ៉ាក់សាំងទៅចាក់ជូនពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសថៃ ខណៈពលករខ្មែរមួយចំនួនត្រូវបានអាជ្ញាធរថៃចាក់ជូនរួចហើយ។ ថ្លែងនៅក្នុងពិធីប្រកាសបិទ យុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជុំទី១ សម្រាប់ក្រុមអាយុចាប់ពី ៦ឆ្នាំឡើង ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងការប្រកាសបើកយុទ្ធនាការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់កុមារអាយុ ៥ឆ្នាំ ចាប់ផ្ដើមពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១នេះ សម្ដេចតេជោ បានមានប្រសាសន៍ថា ការស្នើសុំទៅអាជ្ញាធរថៃដើម្បីជួយសម្របសម្រួលឱ្យកម្ពុជាបានបញ្ជូនវ៉ាក់សាំងចាក់ឱ្យពលករខ្មែរនេះ ខណៈនៅថៃមានប្រជាជនចំនួនច្រើនទៀតដែលមិនទាន់បានចាក់វ៉ាក់សាំងនៅឡើយ។ សម្ដេចតេជោ ហ៊ុន សែន បានបន្តថា នេះជាការបង្ហាញពីការគិតគូររបស់រាជរដ្ឋាភិបាលចំពោះសុខភាពប្រជាពលរដ្ឋ មិនត្រឹមតែអ្នករស់នៅក្នុងប្រទេសនោះទេ បើទោះបីប្រជាពលរដ្ឋកម្ពុជារស់នៅទីណាក៏ដោយ ក៏រាជរដ្ឋាភិបាលតែងបានយកចិត្តទុកដាក់គិតគូរនៅគ្រប់កាលៈទេសៈ។

យ៉ាងណាក៏ដោយ សម្ដេចតេជោ បានថ្លែងអំណរគុណដល់បណ្ដាប្រទេសនានាដែលមានប្រជាពលរដ្ឋខ្មែរទៅធ្វើការងារ ហើយត្រូវបានរដ្ឋាភិបាលនៃប្រទេសទាំងនោះបានចាក់វ៉ាក់សាំងជូន ដូចជានៅកូរ៉េខាងត្បូង និងជប៉ុន ពលករខ្មែរ ១០០% បានទទួលវ៉ាក់សាំងនៅថៃ ម៉ាឡេស៊ី និងប្រទេសផ្សេងៗទៀត ដែលមានពលករខ្មែរទៅធ្វើការក៏បានទទួលវ៉ាក់សាំងមួយចំនួនហើយដែរ។ ជុំវិញពលរដ្ឋកម្ពុជាដែលមិនទាន់បានចាក់វ៉ាក់សាំង សម្ដេចតេជោ បានណែនាំដល់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងទូទាំងប្រទេស និងអាជ្ញាធររាជធានីខេត្តទាំងអស់ ត្រូវរក្សាទុកវ៉ាក់សាំងដើម្បីចាក់ជូនប្រជាពលរដ្ឋដែលមិនទាន់បានចាក់។ សម្ដេចបានបន្តថា ប្រជាពលរដ្ឋដែលមិនទាន់បានចាក់អាចទៅរកចាក់បាននៅតាម មន្ទីរពេទ្យ និងនៅតាមស្រុក នៃបណ្ដារាជធានី ខេត្តនៅទូទាំងប្រទេស ហើយសម្រាប់ការចាក់នេះ ក៏មិនតម្រូវឱ្យមានការបញ្ជាក់អ្វីទាំងអស់។

សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ដោយឡែកមន្ត្រីសុខាភិបាលក៏មិនចាំបាច់សួរនាំថា ប្រជាពលរដ្ឋដែលមិនទាន់បានចាក់វ៉ាក់សាំងនោះមកពីណា ឬរស់នៅទីណានោះទេ។ ជារួមប្រជាពលរដ្ឋដែលមិនទាន់បានចាក់វ៉ាក់សាំង គាត់អាចទៅចាក់ទីណាក៏បាន ឱ្យតែនៅកៀកកន្លែងដែលគាត់ស្នាក់នៅ៕ អត្ថបទ៖ សំអឿន

## កូរ៉េខាងត្បូងនឹងបន្ធូរបន្ថយបម្រាមពលករចំណាកស្រុកពីកម្ពុជាក្នុងខែនេះ ដើម្បីដោះស្រាយវិបត្តិការងារ

https://www.khmertimeskh.com/ Khmer Times November 1, 2021

ពលករបរទេសទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង គឺមកពីប្រទេសចំនួនប្រាំមួយ រួមមានកម្ពុជា ថៃ និងវៀតណាម ប៉ុន្តែចំនួនពលករអន្តោប្រវេសន៍ថ្មីនៅក្នុងប្រទេសកូរ៉េខាងត្បូងធ្លាក់ចុះ ៩០% បើធៀបនឹងកម្រិតខ្ពស់បំផុតមុនមានជំងឺកូវីដ កាលពីឆ្នាំ២០១៩។ ប្រទេសកូរ៉េខាងត្បូងកំពុងរៀបចំអនុញ្ញាតឱ្យពលករបរទេសកាន់តែច្រើនត្រឡប់ទៅប្រទេសខ្លួនវិញ ដើម្បីជួយដល់ការងារផ្នែកកសិដ្ឋានក្នុងស្រុក រោងចក្រ និងការដ្ឋានសំណង់ ដែលពឹងផ្អែកខ្លាំងលើពលករចំណាកស្រុក បន្ទាប់ពីប្រទេសនេះបានកំណត់ការចេញទិដ្ឋាការការងារមិនមែនអាជីតអស់រយៈពេលជិតពីរឆ្នាំក្នុងអំឡុងពេលវិបត្តជំងឺរាតត្បាតកូវីដ – ១៩ ។

សារព័ត៌មាន Pulseបានរាយការណ៍ថា យោងតាមមន្ត្រីក្រសួងការងារកាលពីថ្ងៃពុធ រដ្ឋាភិបាលកំពុងស្វែងរកការអនុញ្ញាតបើកអោយជនបរទេសចូលបន្ថែមទៀតដោយមានទិដ្ឋាការការងារមិនវិជ្ជាជីវៈ ប្រភេទ E-9 ដែលត្រូវបានចេញសម្រាប់ពលករដែលចូលមកធ្វើការក្នុងវិស័យការងារដោយប្រើកំលាំង។ វិធានការនេះកំពុងត្រូវបានអនុវត្តរួមជាមួយនឹងផែនការប្តូរវេនរបស់រដ្ឋាភិបាលចំពោះ "ការរស់នៅជាមួយវិធានកូវីដ-១៩" នៅក្នុងខែវិច្ឆិកា ហើយព័ត៌មានលម្អិតបន្ថែមស្តីពីការពង្រីកកម្លាំងពលកម្មបរទេសត្រូវបានគេរំពឹងថានឹងប្រកាសនៅខែក្រោយ។

ទិដ្ឋាការ E-9 ត្រូវបានចេញជាចម្បងដល់ពលករមកពី១៦ ប្រទេស ដែលភាគច្រើននៅអាស៊ីអាគ្នេយ៍ ប៉ុន្តែការចូលមកកាន់ប្រទេសកូរ៉េត្រូវបានហាមឃាត់ទាំងស្រុង បន្ទាប់ពីជំងឺរាតត្បាតបានវាយប្រហារប្រទេសនេះនៅដើមឆ្នាំ២០២០។ ដើម្បីឆ្លើយតបទៅនឹងការតវ៉ាដែលកំពុងកើនឡើងអំពីកង្វះកម្លាំងពលកម្ម អាជ្ញាធរមូលដ្ឋានបានលើកបម្រាម លើប្រទេសមួយក្នុងខែវិច្ឆិកាឆ្នាំមុន និង៥ប្រទេសទៀតក្នុងខែមេសាឆ្នាំនេះ។ កម្ពុជា និងថៃ គឺជាប្រទេសប្រភពដ៏សំខាន់សម្រាប់ពលករក្នុងប្រព័ន្ធអនុញ្ញាតការងារ EPS នៅក្នុងប្រទេសកូរ៉េ ដែលរួមមានជាងពីរភាគបីនៃចំនួនសរុប។ ប្រទេសផ្សេងទៀតបញ្ជូនកម្មករក្រោម១.០០០នាក់ក្នុងមួយឆ្នាំ៕

## កុងស៊ុលកម្ពុជា ជួយសម្រួលបញ្ជូន ពលករខ្មែរ១៨នាក់ ត្រឡប់មកមាតុប្រទេសវិញ

https://dap-news.com/national/ ByPH104 Posted on November 1, 2021

ភ្នំពេញ ៖ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងថា នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ នេះ មានពលករខ្មែរចំនួន១៨នាក់ (ស្រី ៥នាក់ និងកូនក្មេង ២នាក់) ដែលបានធ្វើដំណើរមកពីបណ្តាខេត្តនានា និងទីក្រុងបាងកក នៃប្រទេសថៃ មកស្នើសុំស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ ដើម្បីឲ្យជួយបញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញ ហើយក៏បានធ្វើតាមសំណូមពរពួកគាត់ ។ ការស្នើសុំពីសំណាក់ពលករខ្មែរ គឺដោយសារពួកគាត់ពុំមានការងារធ្វើ ហើយចង់វិលត្រឡប់ទៅស្រុកកំណើតវិញ។ ស្ថានអគ្គកុងស៊ុលបានអន្តរាគមន៍ បញ្ជូនពលករខ្មែរខាងលើ ត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិ ខ្លងលឹក-ប៉ោយប៉ែត យកទៅប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាម នីតិវិធីសុខាភិបាល ៕

# ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១

## ឃាត់ខ្លួនជនសង្ស័យម្នាក់ ជាមេខ្យល់បម្រុងនាំពលករ០៥ នាក់ ឆ្លងដែនចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់

https://cen.com.kh/ Posted ByPen Srey NeatNovember 1, 2021

បាត់ដំបង ៖ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០២១ ម៉ោង ០០ និង ៤៥ នាទី នៅចំណុច ក្រុមទី០៧ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ជាប់មាត់អូរព្រំដែនកម្ពុជា-ថៃ កម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន សហការជាមួយ កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ , កម្លាំងវរៈលេខ១ , និងកម្លាំងវរៈសេនាតូច៥៣៣ ប្រចាំការតាមមាត់អូរព្រំដែនចំណុចខាងលើ បង្ក្រាបករណីការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (បម្រុងចូលទៅក្នុងប្រទេសថៃ ) ០១ ករណី បានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន ០១ នាក់ និងពលករ០៥ នាក់។

ជនសង្ស័យជាមេខ្យល់ ឈ្មោះ គឹម សុខខឿន ហៅ ង៉ា ភេទប្រុស អាយុ ២៩ ឆ្នាំ មានទីលំនៅស្នាក់ ភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង (ឃាត់ខ្លួនបាន) និងជនសង្ស័យម្នាក់ទៀតឃាត់ខ្លួនមិនបាន បានធ្វើសកម្មភាព ទាក់ទងគ្នា លួចនាំពលករចំនួន ០៥ នាក់ ប្រុស ០១ នាក់ (ក្នុងនោះក្មេង ចំនួន ០១

នាក់ ស្រី) រួមមាន ៖ ១-ឈ្មោះ ស៊ុយ សុគន្ធា ភេទប្រុស អាយុ ៣៤ ឆ្នាំ ២- ឈ្មោះ យន់ ម៉ាលី ភេទស្រី អាយុ ២៤ ឆ្នាំ ៣-ឈ្មោះ ច្រឹក វិច្ឆិកា ភេទស្រីអាយុ ១៦ ឆ្នាំ ៤-ឈ្មោះ សេង លីដា ភេទស្រី អាយុ ១៤ ឆ្នាំ ៥- ឈ្មោះ ច្រឹក ស្រីណៃ ភេទស្រី អាយុ ០៩ ឆ្នាំ អ្នកទាំងប្រាំនាក់ មានទីលំនៅភូមិភ្នំធំ ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ដោយយកប្រាក់ថ្លៃធ្វើដំណើរពីពលករ ក្នុងម្នាក់ ៦,០០០ បាត ។

ប្រតិបត្តិការបង្ក្រាបនេះដោយអនុវត្តតាមមតិដឹកនាំរបស់ ឯកឧត្តម ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នឹងក្រោមការដឹកនាំបញ្ជាផ្ទាល់យ៉ាងយកចិត្តទុកដាក់របស់លោកវរសេនីយ៍ទោ ទឹម រិធ័យ អធិការនគរបាលស្រុកសំពៅលូន ។ បច្ចុប្បន្ន ករណីខាងលើ កម្លាំងជំនាញបានកសាងសំណុំរឿង ដើម្បីបញ្ជូនទៅការិយាល័យជំនាញខេត្តចាត់ការបន្តតាមនីតិវិធី។ ដោយឡែកពលករទាំង ០៥ នាក់ សមត្ថកិច្ចបាន ធ្វើការអប់រំណែនាំ និងឱ្យវិលត្រឡប់ទៅមូលដ្ឋានវិញ៕ រក្សាសិទ្ធិដោយ ៖ កូលាប

## ពលករខ្មែរ៨នាក់ បម្រុងឆ្លងដែនទៅប្រទេសថៃត្រូវបានកម្លាំងប៉ុស្តិ៍នគរបាលការពារព្រំដែនភ្នំប្រាក់ឃាត់ខ្លួន

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 01/11/2021

ខេត្តបន្ទាយមានជ័យ៖លោកវរសេនីយ៍ឯក ឡុង សំណាង មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា នៅថ្ងៃចន្ទថ្ងៃទី ០១ ខែ វិច្ឆិការ ឆ្នាំ ២០២១នេះ វេលាម៉ោង ៦ និង ៣០នាទីព្រឹក កម្លាំងប៉ុស្តិ៍ភ្នំប្រាក់ របស់វរសេនាតូចលេខ៨០៧ ដឹកនាំដោយ លោកវរសេនីយ៍ទោ ឡៅ ពេជ្រ មេបញ្ជាការរងទទួលទិសប៉ុស្តិ៍ភ្នំប្រាក់ បានចុះដើរល្បាត ត្រួតពិនិត្យ នៅបន្ទាត់ព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រ រហូតមកដល់ចំណុចគំនរសំរាម មាននិយាមការ TA (62716-39574) ក៏ប្រទះឃើញ និងបានឃាត់ខ្លួន ពលករបម្រុងឆ្លងដែនទៅប្រទេសថៃសរុបចំនួន ០៨នាក់ នៅលើផ្លូវជាតិលេខ៥៨ ស្ថិតនៅ ភូមិ ក្តិបថ្ម ឃុំគោកមៀត ស្រុក ថ្មពួក ខេត្តបន្ទាយមានជ័យ។ បន្ទាប់មកកម្លាំងប៉ុស្តិ៍ភ្នំប្រាក់ ក៏បានរៀបចំបញ្ជូនពលករចំនួន ០៨នាក់ ទៅអោយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំគោករមៀត របស់អធិការដ្ឋាននគរបាលស្រុកថ្មពួក ដើម្បី ធ្វើការសួរនាំ និង អនុវត្តន៍ទៅតាមនីតិវិធី។

លោកវរសេនីយ៍ឯក ឡុង សំណាង សូមអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋ កុំបាញ់បោកមេខ្យល់ ដែតែងតែបញ្ចុះបញ្ចូល នាំពលករឆ្លងដែនខុសច្បាប់ ទាំងប្រថុយប្រថាន ដោយមិនគិតពីសុខសុវត្ថិភាព និង ខាតបង់ប្រាក់កាសជាបន្តបន្ទាប់ ជាពិសេសអនុវត្តន៍វិធានការ ៣កុំ-៣ការពារ ដើម្បីខ្លួនយើង គ្រួសារយើង និង សង្គមជាតិយើង៕

## កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនកូនភ្នំ សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ

http://cambodiapolice.com/policekh/ 3:50 pm 1 វិច្ឆិកា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមបទបញ្ជារបស់ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលរដ្ឋចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនកូនភ្នំ ដឹកនាំដោយលោកអនុសេនីយ៍ឯក ខៀវ-វ៉ាត់ (នាយប៉ុស្តិ៍)រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍ ដឹកនាំដោយលោកអនុសេនីយ៍ទោ សេង-វ៉ឺន(នាយផ្នែក)សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី១,វរសេនាតូចលេខ១ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឡៃ-លឿន (មេបញ្ជាការកងអនុសេនាតូច),កម្លាំង

យោធាកងអនុសេនាធំគាំទ្រ,វរសេនាតូច៥៣៣ ដឹកនាំដោយលោកអនុសេនីយ៍ត្រី គួង-វ៉ៃ(មេបញ្ជាការរងកងអនុសេនាធំ) បានទៅទទួលប្រជាពលរដ្ឋដែលវិលត្រឡប់មកពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចនៃភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ០២នាក់,ស្រី០១នាក់។ បន្ទាប់ពីសាកសួរ កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យទទួលយកទៅកាន់មណ្ឌលចត្តាទីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ ៕

## ប្រទេសថៃបាននិរទេសពលករចំណាកស្រុកខុសច្បាប់ជាង ៣ម៉ឺននាក់ក្នុងឆ្នាំនេះ ក្នុងនោះមានពលរដ្ឋខ្មែររាប់ពាន់នាក់

https://www.khmertimeskh.com/ Khmer Times November 2, 2021

ពលករចំណាកស្រុកខុសច្បាប់ត្រូវបានឃាត់ខ្លួននៅព្រំដែន។ ក្រសួងការពារជាតិព្រមានមន្ត្រីរដ្ឋណាដែលត្រូវបានរកឃើញថាពាក់ព័ន្ធនឹងការជួញដូរមនុស្សនឹងប្រឈមនឹងការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរ។ កងយុទ្ធពលភូមិន្ទថៃ ក្រសួងការពារជាតិបាននិយាយកាលពីថ្ងៃអាទិត្យថា ពលករចំណាកស្រុកខុសច្បាប់ជាង ៣០,០០០នាក់ ត្រូវបាននិរទេសចាប់តាំងពីដើមឆ្នាំ ដោយចំនួនកើនឡើងមុនពេលការបើកប្រទេសឡើងវិញនៅថ្ងៃចន្ទ។

អ្នកនាំពាក្យក្រសួងបាននិយាយថា ភាគច្រើននៃពលករចំណាកស្រុកខុសច្បាប់ចំនួន ៣០,៣៤៣ នាក់ដែលត្រូវបានចាប់និងឃុំខ្លួននៅតាមព្រំដែនខ្មែរ-ថៃ និងមីយ៉ាន់ម៉ា-ថៃ ជាពិសេសនៅខេត្តឈៀងម៉ៃ តាក កានចាន់បុរី និងខេត្តចាន់ថាបុរី។ លោកបានបន្តថា មន្ត្រីរដ្ឋត្រូវបានគេចោទថាមានជាប់ពាក់ព័ន្ធនឹងសកម្មភាពជួញដូរមនុស្សទាំងនេះ ហើយអាជ្ញាធរកំពុងស៊ើបការណ៍ពួកគេដើម្បីបង្កើតទំនាក់ទំនងជាមួយក្រុមជួញដូរមនុស្ស។ លោកឧត្តមសេនីយ៍ Kongcheep Tantravanich បាននិយាយថា អាជ្ញាធរសន្តិសុខកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងនៅតាមព្រំដែន ដើម្បីទប់ស្កាត់ការលួចចូលខុសច្បាប់ និងសកម្មភាពឆ្លងដែនខុសច្បាប់ផ្សេងទៀត រួមទាំងការជួញដូរគ្រឿងញៀនផងដែរ។ លោកបន្តថា យោធាកំពុងសហការជាមួយប៉ូលិស និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្ក្រាបសកម្មភាពទាំងនេះ។ លោកបានមានប្រសាសន៍ថា ថៅកែក៏ត្រូវបានលើកទឹកចិត្តឱ្យសហការគ្នា ដោយមិនជួលកម្មករចំណាកស្រុកខុសច្បាប់ ដែលប្រហែលជាមិនត្រូវបានធ្វើតេស្តរកមេរោគកូវីដ-១៩ ដែលជាហានិភ័យបង្កឱ្យមានការផ្ទុះរីករាលដាលបន្ថែមទៀត។

កាលពីប៉ុន្មានខែមុន អាជីវកម្មបានរកពលករតាមរយៈមេខ្យល់ ដែលខ្លះរត់ពន្ធពលករដែលមិនបានចុះបញ្ជីមកពីប្រទេសជិតខាង។ ប្រភពមួយបាននិយាយថា នៅក្នុងខេត្ត Tak កាលពីថ្ងៃអាទិត្យ ទាហានមកពីអង្គភាពប្រតិបត្តិការពិសេសនៃក្រុម Naresuan Task Force និងប៉ូលិសស្រុក Mae Sot បានឆ្មក់ចូលក្នុងរមណីយដ្ឋានមួយក្នុងក្រុង Tha Sai Luat នៃ Mae Sot និងបានចាប់ខ្លួនពលករចំណាកស្រុកមីយ៉ាន់ម៉ាខុសច្បាប់ចំនួន ៣១ នាក់។ ពលករខុសច្បាប់មីយ៉ាន់ម៉ាចំនួន ៤៥នាក់ផ្សេងទៀត ត្រូវបានឃាត់ខ្លួន រួមជាមួយនឹងអ្នករត់ពន្ធ ០៥នាក់ ក្នុងការបង្ក្រាបនៅតាមបណ្តោយផ្លូវលំក្បែរព្រំដែនថៃ-មីយ៉ាន់ម៉ា ក្នុងស្រុក Muang នៃខេត្ត Prachuap Khiri Khan។ បន្ទាប់មក ពលករចំណាកស្រុកទាំងនេះ ត្រូវបានបញ្ជូនទៅកាន់អង្គភាពប៉ូលិសព្រំដែនក្នុងស្រុក ដើម្បីធ្វើតេស្តរកមេរោគកូវីដ-១៩៕ ប្រភព: Bangkokpost

## ទាហានថៃឃាត់ខ្លួន ប្រជាពលរដ្ឋខ្មែរប្រុសស្រី ចំនួន៥៣នាក់ លួចឆ្លងដែនដោយខុសច្បាប់

http://nokorwatnews.com/ 02/11/2021

ក្រុងប៉ោយប៉ែត៖ ប្រជាពលរដ្ឋខ្មែរ ប្រុស ស្រី ចំនួន៥៣នាក់ បានលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ត្រូវបានទាហានថៃឃាត់ខ្លួន នៅវេលាម៉ោង០៥ ទាបភ្លឺ ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១ នៅក្នុងឃុំផានស៊ឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ប្រទេសថៃ ។

នគរបាលវរសេនាតូចការពារព្រំដែនបានឲ្យដឹងថា៖ ប្រជាពលរដ្ឋខ្មែរ ដែលលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃទាំង ៥៣នាក់នោះ មានស្រី ២៥នាក់ ត្រូវបានទាហាន(ព្រាន)ឈុតខ្មៅថៃវរសេនាធំលេខ១២ ឃាត់បាននៅក្នុងភូមិសាស្រ្ត ឃុំផានស៊ឹក ស្រុកអារញ្ញ។ ប្រភពដដែលបានបញ្ជាក់ថា៖ប្រជាពលរដ្ឋខ្មែរទាំងនោះ បន្ទាប់ពីឃាត់ខ្លួនទាហានឈុតខ្មៅថៃ បានបញ្ជូនទៅអធិការដ្ឋាននគរបាលក្លងណាំសៃ បន្ទាប់មកនគរបាលក្លងណាំសៃបានបញ្ជូនបន្តទៅឲ្យ នគរបាលអន្តោប្រវេសន៍ ស្រុកអារញ្ញ ដើម្បីរៀបចំបញ្ជូនមកកម្ពុជាវិញ ៕

## កុងស៊ុលកម្ពុជា សហការជាមួយអាជ្ញាធរថៃ បញ្ជូនពលរដ្ឋខ្មែរ ៣៣នាក់ មកស្រុកកំណើតវិញ

https://dap-news.com/ ByPH104 Posted on November 2, 2021

**ភ្នំពេញ ៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បានឲ្យដឹងថា នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានអន្តរាគមន៍សហការ ជាមួយអាជ្ញាធរថៃ ជួយបញ្ជូនពលរដ្ឋខ្មែរ ២៩នាក់ ត្រឡប់មកប្រទេសកំណើតវិញ ។ លោក កុយ គួង បញ្ជាក់ថា ស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានអន្តរាគមន៍សហការ ជាមួយអាជ្ញាធរថៃ ជួយបញ្ជូនពលរដ្ឋខ្មែរចំនួន ២២នាក់ (ប្រុស ៨នាក់) ដែលត្រូវបានមេខ្យល់ នាំចូលទៅប្រទេសថៃ ដោយខុសច្បាប់ ហើយត្រូវអាជ្ញាធរថៃឃាត់ខ្លួន អោយបានត្រឡប់មកកម្ពុជាវិញ នៅព្រឹកថ្ងៃដដែល។

លោក កុយ គួង បន្ថែមថា ដោយឡែក នៅថ្ងៃដដែលនេះ ក៏មានពលករខ្មែរចំនួន ៧នាក់ និង កូនក្មេង ៤ នាក់ (ស្រី ៦នាក់) ដែលបានធ្វើដំណើរ មកពីបណ្តាខេត្តនានា និងទីក្រុងបាងកក មកស្នើសុំស្ថានអគ្គកុងស៊ុលកម្ពុជា នៅខេត្តស្រះកែវ ដើម្បីឲ្យជួយបញ្ជូនពួកគាត់ ត្រឡប់មកវិញ ខណៈព្រំដែនថៃពុំទាន់បើកច្រក ហើយពួកគាត់ចង់វិលត្រឡប់ ទៅស្រុកកំណើតវិញ។ ស្ថានអគ្គកុងស៊ុលបានអន្តរាគមន៍ បញ្ជូនពលករខ្មែរខាងលើ ត្រឡប់ទៅកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត យកទៅប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការ តាមនីតិវិធីសុខាភិបាល ៕

## អាជ្ញាធរថៃចាប់ពលករខ្មែរជាច្រើននាក់បញ្ជូនទៅកម្ពុជាវិញ ក្នុងថ្ងៃបើកប្រទេសដំបូង

https://www.rfa.org/khmer/news/ ដោយ ទីន ហ្សាការីយ៉ា2021-11-02

អាជ្ញាធរថៃចាប់ពលករខ្មែរជាច្រើននាក់បញ្ជូនទៅកម្ពុជាវិញ តាមច្រករបៀងព្រំដែន ខេត្តបន្ទាយមានជ័យ នៅថ្ងៃដែលរដ្ឋាភិបាលថៃបើកប្រទេសជំបូងទទួលអ្នកទេសចរ។ មន្ត្រីសង្គមស៊ីវិល សង្កេតឃើញថា ពលករខ្មែរសម្រុកឆ្លងដែនទៅប្រទេសថៃក្នុងពេលនេះកាន់តែច្រើនដោយសារតែពួកគាត់អត់ការងារធ្វើនៅក្នុងស្រុក និងជំពាក់ប្រាក់ធនាគារ ប៉ុន្តែការលួចឆ្លងដែនខុសច្បាប់បែបនេះ ធ្វើឲ្យពួកគេ ប្រឈមនឹងគ្រោះថ្នាក់ច្រើន។ អាជ្ញាធរថៃបានចាប់ខ្លួនពលករខ្មែរជាង ២០នាក់ក្នុងពេលដែលពួកគេលួចឆ្លងដែនខុសច្បាប់នៅស្រុកអារញ្ញ (Aranyaprathet) ខេត្តស្រះកែវ (Sra Kao) ជាប់ព្រំដែនក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យនៅព្រឹកថ្ងៃទី១វិច្ឆិកា។ សារព័ត៌មានថៃ

ចុះផ្សាយនៅព្រឹកថ្ងៃដដែលថា ពលករទាំងនោះឆ្លងដែនបម្រុងទៅរកការងារធ្វើនៅទីក្រុងបាងកកនិងខេត្តក្បែរនោះ ដើម្បីរកប្រាក់ផ្គត់ផ្គង់ជីវភាពគ្រួសារនៅកម្ពុជា។

ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យលោក អ៊ុំ សុលផល ប្រាប់វិទ្យុអាស៊ីសេរីថា ពលករខ្មែរទាំងនោះ ត្រូវបានអាជ្ញាធរថៃបញ្ជូនមកដល់កម្ពុជាវិញហើយនៅថ្ងៃដដែល ក្រោយពេលមានការអន្តរាគមន៍ពីសំណាក់អាជ្ញាធរខ្មែរ។ លោកបន្តថា ក្រុមពលករបានលួចឆ្លងដែនតាមច្រករបៀងព្រំដែននៅតំបន់មានលិចទឹកជំនន់ដែលគ្មានសមត្ថកិច្ចខ្មែរប្រចាំការ។លោកបញ្ជាក់ថា ក្នុងថ្ងៃដំបូងដែលរដ្ឋាភិបាលថៃបើកប្រទេសទទួលភ្ញៀវទេសចរនេះ អាជ្ញាធរខ្មែរបន្តរឹតបន្តឹងតាមព្រំដែនថៃ ដើម្បីទប់ស្កាត់ពលករលួចឆ្លងដែនខុសច្បាប់៖ «ខ្លះទៅគាត់លួចទៅយើងចាប់នៅខ្មែរ ចេញទៅយើងដេញចាប់មិនទាន់គាត់រត់ឆ្លងទៅដល់ថៃ ហើយសមត្ថកិច្ចចាប់ប្រគល់ឱ្យវិញ។ គ្រាន់តែឥឡូវវាមានទឹកទៅយើងអត់បានដើរល្បាត វាចន្លោះកន្លែងហ្នឹងគាត់ឆ្លងតាមទឹកហ្នឹងទៅ»។ មេប៉ូលិសផ្គាយមួយរូបនេះ បន្តថា រយៈពេលមួយសប្ដាហ៍មកនេះយ៉ាងហោចណាស់មានពលករខ្មែរជាង ១០០នាក់ក្នុងមួយថ្ងៃ ត្រូវបានអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញតាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យ។ក្នុងនោះនៅថ្ងៃទី៣១ វិច្ឆិកា មានពលករខ្មែរជាង១២០នាក់ ត្រូវបានបញ្ជូនតាមរបៀងព្រំដែន បឹងត្រកួន អូរបីជាន់ និងច្រកទ្វារអន្តរជាតិប៉ោយប៉ែត។

ជុំវិញរឿងនេះមន្ត្រីផ្នែកការពារសិទ្ធពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន សង្កេតឃើញថា អំឡុងពេលនេះមានពលករខ្មែរឆ្លងដែនទៅប្រទេសថៃច្រើនជាងពេលមុនៗ ដោយសារពួកគាត់អត់ការងារធ្វើនៅក្នុងស្រុក និងជំពាក់ប្រាក់ធនាគារ។ លោកយល់ថា ពលករមិនគួរឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះនោះទេ ពីព្រោះប្រឈមនឹងអាជ្ញាធរចាប់ខ្លួន ឆ្លងជំងឺកូវីដ១៩ និងចំណាយអស់ប្រាក់ច្រើនជាងពេលមុនទ្វេដង។ លោកបញ្ជាក់ថា សព្វថ្ងៃពលករបង់ថ្លៃឱ្យមេខ្យល់នាំឆ្លងដែនទៅដល់កន្លែងធ្វើការក្នុងម្នាក់ចន្លោះពី៦ពាន់ទៅ៩បាត ឬប្រមាណពី ១៩០ដុល្លាទៅ ២៨៥ អាមេរិក៖ «ហើយវាមានកត្តាដទៃផ្សេងៗទៀត ដូចជានៅក្នុងប្រទេសថៃ មានការបើកឱ្យចុះបញ្ជីតាមប្រព័ន្ធអនឡាញ ដើម្បីស្នើសុំ។តែទៅផ្ទុយទៅគោលការណ៍នៃការបើកឱ្យចុះបញ្ជីដើម្បីស្នើសុំប័ណ្ណការងារឱ្យពលករបរទេសឱ្យត្រឹមត្រូវតាមច្បាប់ហ្នឹង គឺរដ្ឋាភិបាលថៃគេកំណត់យកតែពលករដែលនៅក្នុងប្រទេសថៃទេ មិនមែនមានន័យថាសម្រាប់ឱ្យពលករខ្មែរឱ្យចូលមកប្រទេសថៃទេ។តែផ្ទុយទៅវិញខ្ញុំឃើញអំឡុងពេលហ្នឹងគឺពលករហ្នឹងសម្រុកមកច្រើនយកតែមែនទែន ច្រើនលើសលុប»។

លោក លឹង សុផុន ឱ្យដឹងថា ចាប់តាំងពីខែមករាដល់កញ្ញាមានពលករបរទេស រួមមាន លាវ (Lao) ភូមា ឬមីយ៉ាន់ម៉ា (Myanmar) និងពលករខ្មែរសរុបជាង៣ម៉ឺននាក់ត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ។ក្នុងនោះនៅខែតុលាមានពលករខ្មែរជាង១ពាន់(១.០០០) ត្រូវបានអាជ្ញាធរថៃបានចាប់ខ្លួនក្នុងពេលពួកគេឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ហើយពលករភាគច្រើនបញ្ជូនត្រឡប់ទៅកម្ពុជាវិញ និងមួយចំនួនដាក់ពន្ធនាគារនៅប្រទេសថៃ។ មន្ត្រីសង្គមស៊ីវិលរូបនេះ អំពាវនាវដល់រដ្ឋាភិបាលកម្ពុជាទាក់ទងទៅភាគីថៃ បើកច្រកទ្វារព្រំដែនប្រទេសទាំងពីរ នៅចំណុចណាមួយ ដើម្បីសម្រួលដល់ពលករខ្មែរចូលទៅធ្វើការនៅប្រទេសថៃក្នុងគ្រាអាសន្ននេះ ដោយមិនមានការចាប់ខ្លួន និងកាត់បន្ថយការចំណាយរបស់ពលករ។លោកជឿជាក់ថា ប្រសិនបើរដ្ឋាភិបាលប្រទេសទាំងពីរមិនដោះស្រាយបញ្ហានេះទេនោះ ពលករខ្មែរប្រឈមនឹងចាញ់បោកមេខ្យល់នាំឆ្លងដែនទាំងប្រថុយប្រថានទៅប្រទេសថៃបន្តទៀតជាមិនខាន៕

## អគ្គកុងស៊ុលកម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ បន្តអន្តរាគមន៍បញ្ជូនពលករខ្មែរ ៧នាក់ មកមាតុភូមិវិញ

http://freshnewsasia.com/ 2021-11-02 12:15pm

**(ភ្នំពេញ)៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងថា ស្ថានអគ្គកុងស៊ុលកម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ បានបន្តអន្តរាគមន៍បញ្ជូន ពលករខ្មែរ ៧នាក់ ឱ្យបានមាតុភូមិនិវត្តន៍វិញ។ លោកបានបញ្ជាក់ថា៖ **«នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ មានពលករខ្មែរចំនួន ០៧នាក់ និងកូនក្មេង ០៤នាក់ (ស្រី០៦នាក់) ដែលបានធ្វើដំណើរមកពីបណ្តាខេត្តនានា និងទីក្រុងបាងកកនៃប្រទេសថៃ មកស្នើសុំស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ ដើម្បីឲ្យជួយបញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញ ដោយសារព្រំដែនថៃពុំទាន់បើកច្រក ហើយពួកគាត់ចង់វិលត្រឡប់ទៅស្រុកកំណើតវិញ»**។ ស្ថានអគ្គកុងស៊ុលបានអន្តរាគមន៍ បញ្ជូនពលករខ្មែរខាងលើត្រឡប់ទៅកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត យកទៅប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល។ នេះបើតាមលោក កុយ គួង៕

## ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១

## នគរបាលនិងយោធា ទប់ស្កាត់ ប្រជាពលរដ្ឋខ្មែរចំនួន២១នាក់ បម្រុងលួចឆ្លងដែន ទៅប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatNovember 2, 2021

ខេត្តបន្ទាយមានជ័យ ៖ នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ សហការជាមួយយោធាកងល្បាតទី១ ទប់ស្កាត់ ប្រជាពលរដ្ឋខ្មែរចំនួន២១នាក់ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ នគរបាលប៉ុស្តិ៍ការពារព្រំដែនភ្នំប្រាក់ នៃវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានសហការជាមួយកម្លាំងយោធាកងល្បាតទី១ នៃវរសេនាតូចការពារព្រំដែនគោកលេខ៥០៣ ទប់ស្កាត់ប្រជាពលរដ្ឋខ្មែរប្រុស ស្រី ចំនួន ២១ នាក់ បម្រុងលួចឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់ នៅចំណុចចន្លោះ បង្គោលសីម៉ា(៣៦-៣៧) ក្នុងភូមិសាស្រ្ត ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ នៅវេលាម៉ោង០៩យប់ថ្ងៃទី០១ខែវិច្ឆិកា ឆ្នាំ២០២១ ។

ប្រភពព័ត៌មានពីនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានឲ្យដឹងថា ៖ ការទប់ស្កាត់ ប្រជាពលរដ្ឋខ្មែរទាំង២១នាក់ មានស្រី១០នាក់នេះ ក្នុងខណៈពេលដែលកម្លាំងនគរបាលប៉ុស្តិ៍ការពារព្រំដែនភ្នំប្រាក់ នៃវរសេនាតូចការពារព្រំដែនគោកលេខ៨០៧ បានសហការជាមួយកម្លាំងយោធាកងល្បាតទី១ នៃវរសេនាតូចការពារព្រំដែនគោកលេខ៥០៣ ដើរល្បាតតាមបន្ទាត់ព្រំដែនចន្លោះ បង្គោលសីម៉ា(៣៦-៣៧) ក៏បានប្រទះឃើញពួកគាត់ បម្រុងនាំគ្នាលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ។ ប្រភពដដែលបានបញ្ជាក់ថា៖ក្រោយពីបានឃាត់ខ្លួន ប្រជាពលរដ្ឋខ្មែរទាំង២១នាក់ បានបញ្ជូនទៅនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ គោករមៀត នៃ អធិការដ្ឋាននគរបាលស្រុថ្មពួក ដើម្បីមានវិធានការបន្ត ៕ រក្សាសិទ្ធិដោយ ៖ កូលាប

# ពលរដ្ឋខ្មែរជិត២០នាក់ ត្រូវអាជ្ញាធរថៃចាប់ខ្លួនក្នុងខេត្តស្រះកែវ

https://kohsantepheapdaily.com.kh/ ០២ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ១៧:១៥

ថៃ ៖ ពលរដ្ឋខ្មែរចំនួន១៧នាក់ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ពីបទឆ្លងដែនខុសច្បាប់ ចូលក្នុងស្រុក Watthana Nakhon នៃខេត្ត Sa Kaeo កាលពីព្រឹកថ្ងៃអង្គារ ទី២ វិច្ឆិកា នេះ។ ពលរដ្ឋទាំងនោះចូលក្នុងទឹកដីថៃ ដើម្បីស្វែងរកការងារធ្វើ។ ការចុះផ្សាយរបស់ Bangkok Post បានឲ្យដឹងថា នៅម៉ោងប្រហែល៥ព្រឹកថ្ងៃអង្គារ ក្រុមប៉ូលីសថៃស្ទាក់ចាប់បានរថយន្តចំនួន ២គ្រឿងដែលធ្វើដំណើរកាត់ស្រុក Watthana Nakhon ពីព្រំដែនកម្ពុជា។

រថយន្តទី១ មានប្រជាជនខ្មែរចំនួន១២នាក់ ក្នុងនោះមានស្ត្រី ២នាក់ ចំណែកអ្នកបើកបរឡានជាជនជាតិថៃ។ ចំណែកឡានទី ២ដែលខាងអាជ្ញាធរថៃចាប់មានពលរដ្ឋខ្មែរ ៥នាក់ក្នុងនោះមានប្រុស ៤នាក់ និងអ្នកបើកបរជាជនជាតិថៃមកពីខេត្ត Si Sa Ket។ ពួកគាត់មិនមានឯកសារធ្វើដំណើរ ឬលិខិតអនុញ្ញាតការងារអ្វីឡើយ។ ប្រជាពលរដ្ឋខ្មែរទាំងនោះត្រូវបានចោទប្រកាន់ពីបទឆ្លងដែនខុសច្បាប់ និងល្មើសក្រឹត្យរបស់ថៃ និងត្រូវបានប្រគល់ខ្លួនទៅឲ្យអាជ្ញាធរស្រុក Watthana Nakhon ដើម្បីចាត់ការបន្តតាមផ្លូវច្បាប់៕ (យោងតាមប្រភព៖ Bangkok Post)

# ឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន៣១នាក់បម្រុងលួចឆ្លងដែនទៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃអង្គារ ២ វិច្ឆិកា ២០២១ដោយ Kang Tola

កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ ៨០៧ បានចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន ៣១ នាក់ (ស្រី១៦នាក់) នៅ ២គោលដៅផ្សេងគ្នាក្នុងថ្ងៃតែមួយក្នុងភូមិសាស្ត្រ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដែលបម្រុងឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ។

លោកអនុសេនីយ៍ត្រី ង៉ា ស្រស់ នាយរងប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀតបានឱ្យដឹងថា នៅវេលាម៉ោង ១០យប់ថ្ងៃទី១ខែវិច្ឆិកា ឆ្នាំ២០២១កម្លាំងនគរបាលការពារព្រំដែនវរសេនាតូច ការពារព្រំដែនគោកលេខ ៨០៧ បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន១០នាក់ (ស្រី៦នាក់)មកពីខេត្តពោធិ៍សាត់នៅចំណុចផ្សារបឹងត្រកួន ឃុំគោករមៀត ស្រុកថ្មពួកប្រគល់ឱ្យ នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំគោករមៀត។ ប្រជាពលរដ្ឋទាំងនោះបានប្រាប់ថា ពួកគាត់មានបំណងទៅធ្វើការនៅប្រទេសថៃនិងបានទាក់ទងមេខ្យល់ជនជាតិថៃ ដោយគេយកថ្លៃជូនផ្លូវតម្លៃក្នុងម្នាក់ ៦៥០០ បាតដល់កន្លែងធ្វើការទើបប្រគល់ប្រាក់ ។ លុះធ្វើដំណើរដល់ចំណុចខាងលើក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

ដោយឡែកនៅវេលាម៉ោង១១យប់ ថ្ងៃដដែលនោះ នគរបាលប៉ុស្តិ៍ការពារព្រំដែនភ្នំប្រាក់នៃវរសេនាតូចការពារព្រំដែនគោកលេខ៨០៧បានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរបម្រុងលួច ឆ្លងដែនដោយខុសច្បាប់ក្នុងភូមិសាស្ត្រឃុំគោករមៀតចំនួន ២១ នាក់ (ស្រី១០នាក់) ក្នុងនោះមកពីខេត្តបន្ទាយមានជ័យ១៣នាក់,បាត់ដំបង ម្នាក់,ខេត្តស្ទឹងត្រែង ២នាក់ និងខេត្តសៀមរាបចំនួន ៥នាក់។ ពលរដ្ឋទាំង២១នាក់បានឲ្យដឹងថា ពួកគាត់មានបំណងទៅធ្វើការងារនៅប្រទេសថៃដោយបានទាក់ទងមេខ្យល់ជនជាតិថៃតាមទូរសព្ទដោយគេយកថ្លៃជូនផ្លូវចំនួន ៦,០០០ បាតទៅ ៦,៥០០បាត ហើយពួកគាត់បានជិះតាក់ស៊ីនៅទីរួមខេត្តបន្ទាយមានជ័យទៅច្រក់បឹងត្រកួនក្នុងតម្លៃក្នុងម្នាក់យក ៧០០បាត ទៅ ២,០០០បាត។ នៅពេលទៅដល់បឹងត្រកួន ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន។

បច្ចុប្បន្នពលរដ្ឋទាំង ៣១ នាក់ត្រូវបានបញ្ជូនទៅក្រុមការងារចម្រុះប្រចាំការនៅច្រកអូរបីជាន់ស្រុកអូរជ្រៅ ដើម្បីអនុវត្តតាមនីតិវិធី៕ *ដោយ ៖ ណារី*

# ក្រឡាប់ឡាននៅថៃ ស្លា.ប់និងរបួសពលករខ្មែរជាច្រើន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ០៩:៥៥

ខេត្តបន្ទាយមានជ័យ ៖ គ្រោះថ្នាក់ចរាចរណ៍ដ៏រន្ធត់មួយបានកើតឡើងលើទឹកដីថៃ បង្កឲ្យពលករខ្មែរយ៉ាងតិចជាង១០នាក់ស្លាប់ និងរបួសរជូករណែល កាលពីម៉ោងជាង៨យប់ថ្ងៃទី២ វិច្ឆិកា ២០២១ ដែលហេតុការណ៍នេះកើតមាននៅចំណុចផ្លូវបំបែក( ខ្លងយ៉ាយអ៊ីន ) ក្នុងឃុំវ៉ាំងថង ស្រុកវ៉ាំងសំប៊ូន ខេត្តស្រះកែវ ។ នេះយោងតាមប្រភពព័ត៌មានពីគេហទំព័រ និងកាសែតថៃមួយ។ មនុស្សចំនួន៥នាក់ ស្រី៣នាក់ បានស្លាប់នៅ និងកន្លែងរួមទាំងអ្នកបើកបរជាជនជាតិថៃម្នាក់ផងដែរ ។ ក្រៅពីនេះ មនុស្ស៨នាក់ផ្សេងទៀតរងរបួសធ្ងន់ និងស្រាលដោយ៦នាក់ បញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យក្នុងស្រុកកើតហេតុនិង២នាក់ ដែលរងរបួសធ្ងន់ត្រូវអាជ្ញាធរថៃបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យសម្តេចយុផារាជ្យ ក្នុងខេត្តស្រះកែវ។

ប្រភពបញ្ជាក់ថា ក្នុងចំណោមអ្នកបាត់បង់ជីវិតម្នាក់ គេរកឃើញមានផ្ទុកជំងឺកូវីដ១៩ ហើយគ្រោងបូជាសពក្រោយរយៈពេល២៤ម៉ោងទៀតផង។ប្រភពបន្តថា រថយន្តកើតហេតុពាក់ស្លាកលេខថៃ៤៥៥១ តែមិនបញ្ជាក់ម៉ាកទេ ផ្ទុកមនុស្សសរុប១៣នាក់ រួមទាំងអ្នកបើកបរជាជនជាតិថៃម្នាក់ផង។ ប្រភពបន្តទៀតថា មុនកើតហេតុ រថយន្តគ្រោះថ្នាក់ពាក់ស្លាកលេខថៃមួយគ្រឿងខាងលើបានដឹកពលករពេញ និងបើកបរយ៉ាងលឿនមកពីខៅឡែមជាប់ខេត្តចាន់បុរី ។ លុះដល់ចំណុចផ្លូវបំបែកខាងលើ ក៏ក្រឡាប់ជាច្រើនត្រឡប់បន្ទាប់មកទៅបុកជាប់ និងបង្គោលភ្លើងបង្កឲ្យពលករស្លា.ប់ និងរបួសរជូករណែល ហើយរថយន្តក៏ខូចខ្ទេចផងដែរ ។

បុរសជនជាតិថៃម្នាក់ដែលឃើញហេតុការណ៍និយាយថា មុនកើតហេតុមានរថយន្តភិកអាប់មួយគ្រឿងបោះពួយលឿនបុកឆាកខឿនវង្វង់មូលចំណុចកើតហេតុហើយធ្លាក់ស្នាមភ្លោះ តែបើកឡើងមកវិញយ៉ាងលឿនដើម្បីបន្តដំណើរ ទើបធ្វើឲ្យរថយន្តដឹកពលករដែលកំពុងបោះពួយមកដល់ទីនោះបួងចង្កូតធ្លាក់ផ្លូវ និងក្រឡាប់ជាច្រើនត្រឡប់កើតមានគ្រោះថ្នាក់បែបនេះ។

យោងការសាកសួរពលករដែលអាចនិយាយបានប្រាប់អាជ្ញាធរថៃថា ពួកគេទើបចេញពីកម្ពុជាតាមច្រករបៀង ប្រុងទៅរកការងារធ្វើនៅតាមទីតាំងមួយចំនួនក្នុងស្រុកថៃ ដូចជានិគមឧស្សាហកម្ម៣០៤ខេត្តឆាក់ធឹនសៅ,ទីក្រុងបាងកក,ខេត្តឈុនបុរីនិងខេត្តរ៉ាក់យ៉ង។

តាមការបញ្ជាក់ពីមន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជាថៃ ប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត ប្រាប់តាមទូរស័ព្ទ នាព្រឹកថ្ងៃទី០៣ វិច្ឆិកា នេះថា ករណីស្លា.ប់និងរបួសពលករខ្មែរលើទឹកដីថៃ ដោយសាគ្រោះថ្នាក់ចរាចរកាលពីយប់មិញនៅខេត្តស្រះកែវ គឺពិតជាកើតមានមែន។ មន្ត្រីដដែលបន្តថា ពេលនេះមន្ត្រីកម្ពុជាប្រចាំប្រទេសថៃរួមមានមន្ត្រីស្ថានទូតនិងស្ថានកុងស៊ុលកំពុងធ្វើការហើយ ដើម្បីស្រាវជ្រាវរកសាច់ញាតិជនរងគ្រោះ ។

# ស្ត្រីខ្មែរចំនួន៨នាក់ ដែលចាញ់មេខ្យល់បោករៀបការនៅប្រទេសចិន ត្រូវបានជួយសង្គ្រោះ និងបញ្ជូនមកកម្ពុជាវិញ

https://www.kampucheathmey.com/ ថ្ងៃពុធ ៣ វិច្ឆិកា ២០២១ដោយ Kang Tola

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានបានឲ្យដឹងនៅថ្ងៃនេះថា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងឆុងឈីង ប្រទេសចិន បានជួយសម្របសម្រួលបញ្ជូនស្ត្រីខ្មែរចំនួន០៨នាក់ ដែលរស់នៅខុសច្បាប់នៅប្រទេសចិន មកប្រទេសកម្ពុជាវិញនៅថ្ងៃនេះ។ បើតាមលោក កុយ គួង ស្ត្រីខ្មែរចំនួន០៨នាក់នោះ នឹងមកដល់ម៉ោង១៥ និង៣៥ នាទីរសៀល ថ្ងៃទី០៣ ខែវិច្ឆិកា នេះ។ លោកថា ស្ត្រីខ្មែរទាំងនោះ ភាគច្រើន ជាស្ត្រីចាញ់បោកមេខ្យល់ថាទៅរកការងារល្អនៅប្រទេសចិន តែតាមពិតគេយកទៅរៀបការប្តីចិនទៅវិញ។ *ដោយ ៖ កោះកែវ*

## ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១

## ឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ អំពាវនាវពលករខ្មែរដែលវិលត្រឡប់ពីប្រទេសថៃមិនទាន់ចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ត្រូវប្រញាប់ទៅចាក់ឱ្យទាន់ពេលវេលា

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២១

អនុប្រធានទី១ អាជ្ញាធរមីន ឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ បានធ្វើការអំពាវនាវយ៉ាងទទូចដល់ពលករខ្មែរដែលទើបវិលត្រឡប់ពីប្រទេសថៃ ដែលនៅមិនទាន់ទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ សូមប្រញាប់ប្រូសរាន់មកទទួលយកនូវការចាក់វ៉ាក់សាំងនេះនៅ តាមមន្ទីរពេទ្យក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានទាន់ពេលវេលា ហើយត្រូវរៀនរស់ក្នុងបរិបទ កូវីដ១៩ ដោយត្រូវចូលរួមអនុវត្តន៍នូវវិធានការនានារបស់ក្រសួងសុខាភិបាល ក៏ដូចអនុសាសន៍សម្តេចតេជោ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាល ៣ការពារ និង៣កុំ ឱ្យបានខ្ជាប់ ខ្ជួននោះ។ ការអំពាវនាវយ៉ាងដូច្នេះក្នុងឱកាសឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ និងក្រុមការងារបាន អញ្ជើញចុះពិនិត្យមើលស្ថានភាពច្រកទ្វារព្រំដែនបឹងត្រកួន និងជួបសំណេះសំណាលជាមួយពលករខ្មែរដែលទើបវិលត្រឡប់មកពីប្រទេសថៃវិញ តាមច្រកបឹងត្រកួន ស្ថិតនៅឃុំគោក រមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីព្រឹកថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២១ នេះ។

ក្នុងឱកាសនោះឯកឧត្តមទេសរដ្ឋមន្ត្រី លី ធុជ ក៏បានក្រើនរម្លឹកដល់អាជ្ញាធរកងកម្លាំងប្រដាប់អាវុធនៅតាមព្រំដែន ដែលសម្របសម្រួលបងប្អូនពលករយើងវិលត្រឡប់ពីប្រទេសថៃនៅគ្រប់ទីតាំង សូមឱ្យបន្តយកចិត្តទុកដាក់បំពេញបេសកកម្មការងារនេះដោយជោគជ័យ ច្បាស់លាស់ហ្មត់ចត់។ ឯកឧត្តមបានបន្ថែមទៀតថា អ្វីដែលសំខាន់កម្លាំងសមត្ថកិច្ចត្រូវបង្កើនការទប់ស្កាត់ឱ្យបាន និងជួយផ្សព្វផ្សាយអប់រំបន្ថែមដល់ប្រជាពលរដ្ឋកុំឱ្យពួកគាត់លួចឆ្លងដែនចេញចូល ទៅក្នុងប្រទេសថៃដោយខុសច្បាប់តាមការបោកពីមេខ្យល់វាគ្រោះថ្នាក់ណាស់។ ជាមួយគ្នានេះឯកឧត្តមទេសរដ្ឋមន្ត្រីក៏បានអំពាវនាវដល់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានក្នុង និងក្រៅប្រទេសសូមចូលរួមអនុវត្តន៍តាមការផ្សព្វផ្សាយអប់រំណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលដែលបានចាក់ផ្សាយរាល់ថ្ងៃ ពីវិធានការទប់ស្កាត់ការរីករាលដាល ជំងឺកូវីដ១៩ និងចូលរួមថែរក្សាអនាម័យបរិស្ថាន ថែរក្សាសុខភាពដោយខ្លួនឯង បើមានបញ្ហាសុខភាពខុសពីប្រក្រតី សូមប្រញាប់ទៅមន្ទីរពេទ្យ ឬមណ្ឌលសុខភាពជាបន្ទាន់៕ ដោយឈុនសារ៉ាត

## អ្នកឃ្លាំមើលថា ប៉ូលិសថៃអនុវត្តល្មើសសេចក្តីណែនាំក្រសួងមហាផ្ទៃថៃ រឿងចាប់ខ្លួនពលករខ្មែរក្នុងវិបត្តិជំងឺកូវីដ១៩

https://www.rfa.org/ ដោយ មាន ឫទ្ធិ2021-11-03

អ្នកឃ្លាំមើលសិទ្ធិពលករខ្មែរក្នុងប្រទេសថៃអះអាងថា ប៉ូលិសថៃ បានអនុវត្តល្មើសសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃថៃ ដែលបានបង្គាប់ឲ្យផ្អាកការចាប់ពលករគ្មានឯកសារស្របច្បាប់ក្នុងស្ថានភាពជួបវិបត្តិជំងឺកូវីដ១៩ (Covid-19)។ ការលើកឡើងនេះ ក្រោយពេលដែលអាជ្ញាធរថៃសន្យាថា នឹងដោះលែងពលករខ្មែរទាំង ៧នាក់ ដែលបានចាប់ខ្លួនកាលពីថ្ងៃទី២៩ តុលា។ ប៉ូលិសអន្តោប្រវេសន៍ថៃ មិនទាន់ដោះលែងពលករខ្មែរទាំង ៧នាក់ពីមន្ទីរឃុំឃាំងនៃការិយាល័យអន្តោប្រវេសន៍ទីក្រុងបាងកកនៅឡើយទេ គិតត្រឹមរសៀលថ្ងៃទី២ វិច្ឆិកា។

សាច់ញាតិ និងជាអ្នកធ្វើការជាមួយពលករទាំង ៧នាក់ គឺ លោក ផៃ លឿង ឲ្យដឹងថា ពួកលោកបានរកខ្ចីលុយគ្នីគ្នាម្នាក់បន្តិចយកទៅបង់ឲ្យប៉ូលិសថៃអស់ហើយ ដើម្បីធ្វើប័ណ្ណការងារស្របច្បាប់ តាំងពីថ្ងៃទី១ វិច្ឆិកាមក។ លោកបន្តថា អាជ្ញាធរថៃ ក៏បានយល់ព្រមវាយត្រាចេញឯកសារបញ្ជាក់ឲ្យរួចរាល់ដែរ តែខាងប៉ូលិសអន្តោប្រវេសន៍បានដាក់លក្ខខណ្ឌបន្ថែមទៀតថា ទាល់តែថៅកែថៃទៅធានាយកមកវិញ ទើបខាងប៉ូលិសដោះលែង។ លោក ផៃ

លឿង បន្តថា នៅថ្ងៃទី២ វិច្ឆិកា ថៅកែជនជាតិថៃបានធានាពលករទាំង ៧នាក់នោះ តែខាងប៉ូលិសបន្តលើកពេលដោះលែងទៅថ្ងៃទី៣ វិច្ឆិកាបន្តទៀត ដោយមិនទាន់បញ្ជាក់ហេតុផលយ៉ាងណានោះទេ៖ «ម្នាក់ ៤.០០០បាត ដែលគេយកអស់ហើយណា។ និយាយទៅវានៅតែ១០.០០០បាតទេ។ ក្នុងមួយម៉ឺនបាតនេះគេ (ថៅកែ) ដើររឿងអ្វីរៀបរយអស់ហើយណា ព្រោះម្សិលមិញនេះ ខ្ញុំបានទៅជាមួយគាត់ (ថៅកែ) ហ្នឹង ខ្ញុំថតយកមកអស់ហើយគេហៅអាដែងបែប្រថាប៉ត្រា ត.ម៉។ ខ្ញុំថតយកមកដាក់ទូរស័ព្ទខ្ញុំទាំង៧នាក់ហ្នឹង»។

ទាក់ទងនឹងបញ្ហានេះប៉ូលិសថៃបានប្រាប់ថៅកែជនជាតិថៃថា ពួកគេនឹងដោះលែងពលករតែ ៤នាក់ទេ ក្នុងចំណោម ៧នាក់នោះ ព្រោះពលករ ៣នាក់ទៀត ត្រូវបានរកឃើញមានឆ្លងជំងឺកូវីដ១៩។ លោក ឆៃ លឿង ឲ្យដឹងទៀតថា ខាងប៉ូលិសនឹងបញ្ជូនពលករឆ្លងកូវីដ១៩ ទាំង ៣នាក់ទៅព្យាបាល តែមិនបានប្រាប់ទីតាំងថានៅកន្លែងណាទេ។ ប៉ូលិសថៃបានចុះឆ្មក់ចាប់ក្រុមពលករចំនួន ៧នាក់ កាលពីថ្ងៃទី២៣ តុលា ក្នុងពេលដែលតំណាងពលករប្រមាណ ៥០នាក់ ជួបជុំគ្នាដាក់ញត្តិស្នើសុំដំណោះស្រាយផ្នែកការងារនៅមុខក្រសួងការងារថៃ។ ប៉ូលិសថៃបានចោទថា ពលករសំណាង់ទាំង ៧នាក់ គ្មានឯកសារស្របច្បាប់ និងត្រូវចាប់បញ្ជូនភ្លាមៗ ទៅឃុំឃាំងនៅពន្ធនាគារនៃការិយាល័យអន្តោប្រវេសន៍ក្នុងទីក្រុងបាងកក (IDC Prison - immigration detention center)។ ការឆ្មក់ចាប់អ្នកគ្មានឯកសារស្របច្បាប់ក្នុងប្រទេសថៃ តែងតែកើតឡើងជារឿយៗលើពលករខ្មែរ ឡាវ និងភូមា ដែលកំពុងធ្វើការក្នុងប្រទេសថៃ។ ប៉ុន្តែអ្នកឃ្លាំមើលអះអាងថា ការចាប់ពលករក្នុងស្ថានភាពដែលថៃកំពុងជួបវិបត្តិជំងឺកូវីដ១៩នេះ គឺជាករណីល្មើសនឹងសេចក្ដីសម្រេចរបស់ក្រសួងមហាផ្ទៃថៃ ដែលរដ្ឋាភិបាលថៃធ្លាប់ប្រកាសលើកលែងឯកសារផ្លូវច្បាប់នានាឲ្យពលកររហូតដល់មានការធូរស្រាលនៃការឆ្លងជំងឺកូវីដ១៩ ឡើងវិញ។

ប្រធានមូលនិធិពលករខ្មែរប្រចាំប្រទេសថៃលោក សុន សីហា សង្កេតឃើញថា បើទោះជារដ្ឋាភិបាលដាក់ចេញបម្រាមនេះក៏ដោយ ក៏អាជ្ញាធរថៃតែងតែចុះចាប់ និងគំរាមពលករគ្មានឯកសារច្បាប់ជារឿយៗ ដែរ។ លោកថាភាគច្រើនប៉ូលិសថៃ ឆ្មក់ចាប់ពលករភ្លាមៗ ហើយគំរាមពលករមិនឲ្យផ្សព្វផ្សាយព័ត៌មានចេញក្រៅទេ ជាថ្នូរនឹងការតម្រូវឲ្យបង់លុយក្រៅផ្លូវការ ឬរត់ការចេញឯកសារស្របច្បាប់ និងដោះលែងវិញជាដើម។ លោកបន្តថា ពលករខ្មែរភាគច្រើនជាមនុស្សស្លូតត្រង់ មិនសូវមានចំណេះដឹង និងមិនចូលចិត្តជម្លោះ ម្ល៉ោះហើយពួកគាត់មិនសូវពឹងពាក់តំណាងស្ថានទូត អង្គការសិទ្ធិមនុស្សអ្វីទេ គឺសុខចិត្តរកខ្ចីលុយគេមកឲ្យប៉ូលិសថៃដើម្បីបញ្ចប់រឿងរ៉ាវតែម្ដង៖ «ស្ថានទូតមិនបានទទួលព័ត៌មានទេ នៅពេលចាប់ហ្នឹងពីព្រោះថាការចាប់ទារប្រាក់ពីពលករហ្នឹង គឺគេ (អាជ្ញាធរថៃ) មានផែនការរបស់គេ មិនឲ្យព័ត៌មានហ្នឹងលេចឮ។ អ៊ីចឹង! បើសិនជាស្ថានទូតគាត់អត់អាចទទួលបានព័ត៌មានហ្នឹងទាន់ពេលវេលា គាត់អត់ដឹងថា ជួយយ៉ាងម្ដេច? គាត់អត់អាចជួយបានទេ ទី១។ ទី២ ទៀត បើសិនជាប៉ះករណីពលករដែលគាត់អត់ឯកសារគ្រប់គ្រាន់ អ៊ីចឹង! ផ្លូវច្បាប់ ទោះបីស្ថានទូត ក៏ដោយក៏មិនអាចជួយរំដោះគាត់នៅពេលគេចាប់ខ្លួននោះទេ»។

ចាប់តាំងថៃជួបវិបត្តិជំងឺកូវីដ១៩ មក ពលករជាច្រើនបាត់បង់ការងារធ្វើ គ្មានប្រាក់ចំណូល ជាហេតុធ្វើឲ្យពួកគាត់គ្មានលទ្ធភាពធ្វើប័ណ្ណការងារស្របច្បាប់។ ការធ្វើប័ណ្ណការងារ ឬការបន្តប័ណ្ណការងារមានសុពលភាពម្ដងរយៈពេល ២ឆ្នាំ ត្រូវចំណាយលុយសរុបទាំងថ្លៃរត់ការ សេវារដ្ឋ និងការពិនិត្យសុខភាពជាដើម ប្រមាណ ១២.០០០បាត ឬប្រហែល ៤០០ដុល្លារ។

ជុំវិញករណីនេះវិទ្យុអាស៊ីសេរីមិនអាចសុំការបញ្ជាក់ពីអគ្គរាជទូតកម្ពុជាប្រចាំប្រទេសថៃលោកអ៊ុក សោភ័ណ និងអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិលោក កុយ គួង បានទេ នៅថ្ងៃទី២ វិច្ឆិកា។

របាយការណ៍របស់អង្គការសង់ត្រាល់ (CENTRAL) បង្ហាញថា មុនពេលប្រទេសថៃជួបវិបត្តិជំងឺកូវីដ១៩ មានពលករខ្មែរធ្វើការនៅក្នុងប្រទេសនេះ ជិតពីរលាន (២លាន)នាក់ គឺរាប់បញ្ចូលទាំងពលករមានប័ណ្ណការងារ

និងពលករគ្មានប័ណ្ណការងារ។ មន្ត្រីអង្គការសង់ត្រាល់ (CENTRAL) ប្រចាំប្រទេសថៃ លោក លឹង សុផុន បញ្ជាក់បន្ថែមថាគិតត្រឹមខែតុលា មានពលករខ្មែរជាង ១.០០០នាក់ ត្រូវបានអាជ្ញាធរថៃចាប់បានពេលឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់។ ភាគច្រើននៃពលករទាំងនោះ ត្រូវចាប់បញ្ជូនត្រឡប់ទៅកម្ពុជាវិញ និងមួយចំនួនដាក់ពន្ធនាគារនៅប្រទេសថៃ៕

## អាជ្ញាធរថៃចាប់ខ្លួនពលករកម្ពុជាចំនួន ១៧នាក់ពីបទឆ្លងដែនខុសច្បាប់ចូលក្នុងប្រទេសថៃ

https://khmernote.com.kh/ អន្តរជាតិ November 3, 2021 Pheakdey

ថៃ៖ យោងតាមការចុះផ្សាយនៅក្នុងបណ្តាញសារព័ត៌មាន បាងកកប៉ុស្ដិ៍ បានឲ្យដឹងថា កាលព្រឹកថៃអង្គារទី២ ខែវិច្ឆិកា ម្សិលមិញនេះ អាជ្ញាធរថៃបានចាប់ខ្លួនពលរដ្ឋកម្ពុជាចំនួន ១៧នាក់ ពីបទឆ្លងដែនខុសច្បាប់ចូលទៅកាន់ប្រទេសថៃ។ ការចាប់ខ្លួនពលរដ្ឋកម្ពុជាទាំង ១៧នាក់នេះត្រូវបានធ្វើឡើងនៅម៉ោង ៥ព្រឹក ក្នុងទឹកដីខេត្តសាកែវ ដែលជាខេត្តមានព្រំប្រទល់ជាប់ប្រទេសកម្ពុជា។ បើតាមអាជ្ញាធរថៃបានបញ្ជាក់ថា ពលរដ្ឋកម្ពុជាទាំង ១៧នាក់នោះគឺជាពលករចំណាក់ស្រុក ដែលមានគោលបំណងចង់ទៅរកការងារធ្វើនៅក្នុងទីក្រុងបាងកក ប្រទេសថៃ។

យ៉ាងណាក្តី ពលរដ្ឋកម្ពុជាទាំងអស់នោះពុំមានលិខិតអនុញ្ញាតឲ្យធ្វើដំណើរចូលទៅក្នុងប្រទេសថៃឡើយ ហើយពួកគេក៏ពុំមានលិខិតបញ្ជាក់ថា ត្រូវទៅបំពេញការងារនៅក្នុងប្រទេសដែរ ពោលគឺពួកគេព្យាយាមឆ្លងដែនដោយខុសច្បាប់ទាំងស្រុងតែម្តង។ ក្រៅតែពីបានចាប់ខ្លួនពលរដ្ឋកម្ពុជា អាជ្ញាធរថៃក៏បានចាប់ខ្លួនពលរដ្ឋចំនួន ២នាក់ផ្សេងទៀតផងដែរ ព្រោះពលរដ្ឋថៃទាំង ២នាក់នេះគឺជាមេខ្យល់នាំផ្លូវពលរដ្ឋកម្ពុជាចូលក្នុងទឹកដីថៃដោយខុសច្បាប់៕

## មន្ត្រីជាន់ខ្ពស់ថៃ៖ កម្ពុជា អាចផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ចាក់ជូនពលករនៅថៃបាន តែមន្ត្រីសុខាភិបាលថៃជាអ្នកចាក់

http://freshnewsasia.com/ 2021-11-04 01:36pm

**(បាងកក, ថៃ)៖** មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលថៃ បានឱ្យដឹងថា រាជរដ្ឋាភិបាលកម្ពុជា អាចផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ ដើម្បីចាក់ជូនប្រជាពលរដ្ឋខ្មែរកំពុងរស់នៅ និងធ្វើការនៅប្រទេសថៃ។ រីឯការចាក់ គឺត្រូវអនុវត្តដោយមន្ត្រីសុខាភិបាលថៃ។ ព័ត៌មាននេះត្រូវបានបញ្ជាក់ដោយឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលថៃ លោក វិស្ណុ គ្រឿងង៉ាម ក្នុងពេលជួបពិភាក្សាការងារជាមួយលោកបណ្ឌិត សុខ សុក្រឹត្យា ទីប្រឹក្សាផ្ទាល់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងជារដ្ឋលេខាធិការក្រសួងទេសចរណ៍នៅទីក្រុងបាងកក ប្រទេសថៃ នាពេលថ្មីៗនេះ។

លោកបណ្ឌិត សុខ សុក្រឹត្យា មន្ត្រីខ្មែរដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីរបស់ថៃ ហើយកំពុងបំពេញទស្សនកិច្ចនៅថៃនោះ បានប្រាប់អង្គភាពព័ត៌មាន Fresh News នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១នេះថា ក្នុងជំនួបនោះ រូបលោក និងលោកឧបនាយករដ្ឋមន្ត្រីថៃ បានជជែកគ្នាពីការផ្តល់វ៉ាក់សាំងជូនប្រជាពលរដ្ឋខ្មែរកំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ។ ក្នុងឱកាសនោះ លោក ក៏បានស្នើបន្ថែមទៅឧបនាយករដ្ឋមន្ត្រីជួយយកចិត្តទុកដាក់ផ្តល់វ៉ាក់សាំងដល់ពលរដ្ឋខ្មែរ ដើម្បីទប់ទល់ការរាលដាលជំងឺកូវីដ១៩។ លោក សុខ សុក្រឹត្យា បានបន្ថែមថា ក្នុងជំនួបនោះ លោក៏បានលើកពីបំណងរបស់សម្តេចតេជោ ហ៊ុន សែន រកកិច្ចសហប្រតិបត្តិការ ដើម្បីបានផ្តល់ជាវ៉ាក់សាំងចាក់ជូនប្រជាពលរដ្ឋនៅក្នុងប្រទេសថៃផងដែរ។

ឆ្លើយតបសំណើស្តីពីកិច្ចសហប្រតិបត្តិការដើម្បីផ្តល់វ៉ាក់សាំងជូនពលរដ្ឋខ្មែរនេះ លោកឧបនាយករដ្ឋមន្ត្រីថៃ វិស្ណុ គ្រឿងង៉ាម ក៏បានបញ្ជាក់ថា រដ្ឋាភិបាលថៃ បានជជែក ហើយក៏បានសម្រេចដែរថា កម្ពុជា អាចផ្តល់វ៉ាក់សាំងសម្រាប់ចាក់ជូនពលរដ្ឋរស់នៅ និងធ្វើការក្នុងប្រទេសថៃបាន។ ប៉ុន្តែមិនអាចទៅចាក់ដោយខ្លួនឯងបានឡើយ

ពេលគឺកម្ពុជា អាចផ្តល់វ៉ាក់សាំង ហើយមន្ត្រីសុខាភិបាលថៃជាអ្នកចាក់ជូន។ ដោយឡែកមន្ត្រីកម្ពុជា អាចចូលរួមសង្កេតការណ៍លើការងារចាក់នេះបាន។

លោកបណ្ឌិត សុខ សុក្រឹត្យា បានបញ្ជាក់ដូច្នេះ «លោក [វិស្ណុ គ្រឿងង៉ាម] ថា តាមផ្លូវច្បាប់ថៃហ្នឹង យើងមិនអាចយកវ៉ាក់សាំងមក ហើយយកមន្ត្រីសុខាភិបាលយើងមកចាក់បានទេ។ តែបើយើងយកវ៉ាក់សាំងមក ហើយឱ្យមន្ត្រីសុខាភិបាលថៃចាក់ ដោយមានយើងសង្កេតការណ៍ អាហ្នឹងអាចធ្វើទៅបាន»។

ក្នុងជំនួបនោះ លោក វិស្ណុ គ្រឿងង៉ាម ក៏បានបញ្ជាក់ដែរថា ទោះបីជាយ៉ាងណា រដ្ឋាភិបាលថៃ បានយកចិត្តទុកដាក់ដល់ពលរដ្ឋខ្មែរ ហើយក៏បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ១៩ជូនពួកគេផងដែរ ប៉ុន្តែមិនបានលឿននោះឡើយ។ លោក វិស្ណុ គ្រឿងង៉ាម បានលើកឡើងថា ប្រសិនបើកម្ពុជាអាចផ្តល់វ៉ាក់សាំងទៅ ការចាក់ជូនពលរដ្ឋខ្មែរអាចបានលឿន។ លោកឧបនាយករដ្ឋមន្ត្រីថៃ ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការយកចិត្តទុកដាក់របស់សម្តេចតេជោ ហ៊ុន សែន លើប្រជាពលរដ្ឋខ្មែរនៅក្នុងប្រទេសថៃ។

លោក សុខ សុក្រឹត្យា បានគូសបញ្ជាក់ថា ពេលនេះមន្ត្រីក្រសួងការបរទេសនៃប្រទេសទាំងពីរ កំពុងជជែកគ្នាលើការងារនេះ ដើម្បីរកយន្តការកិច្ចសហប្រតិបត្តិការឈានទៅការផ្តល់វ៉ាក់សាំងជូនពលរដ្ឋខ្មែរនៅថៃ។ សូមបញ្ជាក់ថា កាលពីថ្ងៃទី០១ ខែវិច្ឆិកា កន្លងទៅនេះ សម្តេចតេជោ ហ៊ុន សែន ក៏បានបង្ហើបនូវព័ត៌មាននៃគម្រោងផ្តល់វ៉ាក់សាំងទៅចាក់ជូនពលរដ្ឋខ្មែរនៅក្នុងប្រទេសថៃផងដែរ។ តាមព័ត៌មាននានា បានបញ្ជាក់ថា បច្ចុប្បន្នមានពលរដ្ឋខ្មែរប្រមាណជា ១លាននាក់កំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ ហើយរដ្ឋាភិបាលថៃ បានចាក់ជូនពលរដ្ឋខ្មែរបានប្រមាណ ២សែនដូសហើយ៕

# ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១

## សាច់ញាតិជនរងគ្រោះស្នើសុំអន្តរាគមន៍លើករណីជួញដូរមនុស្ស ខណៈស្នងការខេត្តព្រះសីហនុ នឹងពិនិត្យឬសគល់

https://thmeythmey.com/ 04, Nov 2021 , 9:59 pm ដោយ: ឡាយ សុភាវតី

ភ្នំពេញ៖ លោក ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុថា សមត្ថកិច្ចនឹងចុះស្រាវជ្រាវលើករណីជួញដូរមនុស្ស ក្រោយរកពុំឃើញមានករណីនេះ ស្របពេលសារព័ត៌មានចុះផ្សាយព្រោងព្រាត។ ការអះអាងនេះ ធ្វើឡើងក្រោយសាច់ញាតិជនរងគ្រោះ បានដាក់ពាក្យបណ្តឹងសុំការអន្តរាគមន៍ ទាក់ទងការលក់និងបង្ខាំងមនុស្សពីកន្លែងមួយទៅកន្លែងមួយ។

លោក ញឹប ភ្លាវ៉ា ដែលជាសាច់ញាតិជនរងគ្រោះ បានប្រាប់សារព័ត៌មានថ្មីៗតាមទូរស័ព្ទថា បងប្អូនរបស់លោក ចំនួន៣នាក់ បានដាក់ពាក្យធ្វើការនៅទីក្រុងភ្នំពេញ ហើយក៏ត្រូវក្រុមជនជាតិចិនទាំងនោះ បញ្ជូនទៅធ្វើការកាស៊ីណូអនឡាញមួយកន្លែង ដោយពុំមានឈ្មោះច្បាស់លាស់ ក្នុងខេត្តព្រះសីហនុ នៅអំឡុងខែសីហា ឆ្នាំ២០២១។ ប្អូនស្រីរបស់លោក ភ្លាវ៉ា បានប្រាប់លោកតាមទូរស័ព្ទថា ក្រុមជនជាតិចិននោះ បានសន្យាផ្តល់ប្រាក់ខែ១០០០ដុល្លារក្នុងមួយខែ ប៉ុន្តែខែដំបូងគឺទទួលបានតែ៥០០ដុល្លារប៉ុណ្ណោះ។ ក្រោយមិនទទួលបានប្រាក់ខែតាមការសន្យានេះ ប្អូនស្រីរបស់លោក ក៏បានសុំឈប់ពីការងារ តែថៅកែចិននោះ មិនព្រមឲ្យឈប់ ដោយផ្ទេរពួកគេទៅក្រុមហ៊ុនកាស៊ីណូមួយផ្សេងទៀត ដោយពុំមានឈ្មោះដូចគ្នា។ «ពួកខ្ញុំអត់ស្គាល់ឈ្មោះក្រុមហ៊ុនឬឈ្មោះកាស៊ីណូនោះទេ ព្រោះអគារកាស៊ីណូនោះពុំមានដាក់ឈ្មោះអ្វីឡើយ ស្គាល់តែទីតាំងដែលប្អូនរបស់ខ្ញុំកំពុងធ្វើការនិងស្នាក់នៅ គឺម្តុំវត្តក្រោម ភូមិទី១ សង្កាត់៣ ក្រុងព្រះសីហនុ»។ នេះបើតាមលោក ភ្លាវ៉ា ដោយបញ្ជាក់បន្ថែមថា ប្អូនខ្លួនក៏ស្នើសុំឈប់ទៀត នៅពេលទៅដល់ក្រុមហ៊ុនកាស៊ីណូថ្មី ប៉ុន្តែអ្នកគ្រប់គ្រងនៅទីនោះថា ពួកគេត្រូវបានកន្លែងកាស៊ីណូចាស់

លក់មកកាន់ទីតាំងកាស៊ីណូថ្មីនេះ ក្នុងតម្លៃ៣០០០ពាន់ដុល្លារ។ ដូច្នេះ បើចង់ឈប់លុះត្រាតែអ្នកទាំង៣រូបនោះបង់ប្រាក់នៃតម្លៃខ្លួនខាងលើនេះសិន។ លោក ភ្លារ៉ា បានឲ្យដឹងថាៈ «ស្ថានភាពរស់របស់ពួកគេ(បងប្អូនទាំង៣របស់លោក) គឺក្រុមហ៊ុនដាក់សន្តិសុខមិនឱ្យចេញក្រៅ។គំរាមធ្វើបាប មិនឲ្យរាយការណ៍ចេញក្រៅឬតាមហ្វេសប៊ុក និងរឹតត្បិតការប្រើប្រាស់ទូរស័ព្ទ»។

ចំណែកសាច់ញាតិម្នាក់ទៀត ឈ្មោះ យុត ហេង បានរៀបរាប់ប្រាប់សារព័ត៌មានថ្មីៗថា ក្រុមកាស៊ីណូទី២ពុំស្គាល់ឈ្មោះ ដែលបងប្អូនទាំង៣នាក់របស់លោកកំពុងធ្វើការនោះ បានបង្ខំពួកគេកិច្ចសន្យាការងាររយៈពេល១២ខែ ដោយមិនដឹងច្បាស់ពីខ្លឹមសារលម្អិត ព្រោះជាអក្សរវៀតណាម។ បន្ទាប់ពីទទួលបានព័ត៌មានពីប្អូនស្រីលោក នៅថ្ងៃទី២៧ តុលាហើយ លោក យុត ហេង ក៏បានដាក់ពាក្យបណ្ដឹងទៅស្នងការនគរបាលខេត្តព្រះសីហនុ នៅថ្ងៃទី៤ កញ្ញានេះ ។ បើតាមពាក្យបណ្ដឹងនោះ លោក យុត ហេង បានបណ្ដឹងជនជាតិចិនម្នាក់ មានឈ្មោះហៅក្រៅថា «អាឡុង» ដែលជាអ្នកនាំបងប្អូនរបស់លោក ទៅលក់ពីកន្លែងមួយទៅកន្លែងមួយ។ «ឥឡូវពួកខ្ញុំដែលជាសាច់ញាតិនៅខាងក្រៅបានត្រឹមរងចាំចំណាត់ការពីអាជ្ញាធរ ហើយកំពុងស្វែងរកឲ្យអង្គការពាក់ព័ន្ធផ្សេងទៀតជួយ ដើម្បីឲ្យបងប្អូនខ្ញុំមានសេរីភាពវិញ»។ នេះបើតាមការបញ្ជាក់របស់លោក យុត ហេង។

ជនរងគ្រោះឈ្មោះ កញ្ញា ហង្ស ទីទី បានផ្ដល់ព័ត៌មានថា យ៉ាងខ្លីមកកាន់សារព័ត៌មានថ្មីៗតាមបណ្ដាញសង្គមតេឡេក្រាមថា ខ្លួនពុំស្គាល់ឈ្មោះក្រុមហ៊ុនណាមួយឡើយ ដោយដឹងត្រឹមថា គេបញ្ជូនខ្លួនពីភ្នំពេញទៅកាន់ព្រះសីហនុ។ «មុនដំបូងគេថាធ្វើការនៅភ្នំពេញ តែដល់ភ្នំពេញគេថាភ្នំពេញកន្លែងពេញហើយ ហើយគេបញ្ជូនមកដល់កំពង់សោម។ ក្រុមហ៊ុនឈ្មោះអីញុមអត់ដឹងទេ! ដំណឹងការងារដឹងតាមរយៈបងស្រី»។ នេះបើតាមខ្លឹមសារជនរងគ្រោះ។

ជុំវិញករណីនេះ លោក ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុ បានអះអាងថា លោកនឹងពិនិត្យមើលពាក្យបណ្ដឹងហើយចុះស្រាវជ្រាវលើករណីនេះ ដោយសារកិច្ចការងារច្រើនពេក ទើបពុំបានដឹងថាមានសំណុំរឿងណាខ្លះនោះទេ។ លោកថា ការដាក់ពាក្យបណ្ដឹងផ្ទាល់ជុំវិញ ការជួញដូរមនុស្សពុំឃើញមានច្រើននោះទេ ប៉ុន្តែភាគច្រើនមានបណ្ដឹងតាម Hotline ពីការលក់ដូរនិងបង្ខាំងមនុស្សខុសច្បាប់។ បើតាមលោក ណារិន កន្លងមកសមត្ថកិច្ចបានចុះស្រាវជ្រាវតាមករណីនីមួយៗ ដោយឃើញមានតែបុគ្គលិកចូលធ្វើការហើយមិនពេញចិត្ត ក៏ចង់ប្ដូរទៅកន្លែងផ្សេង។ ដូច្នេះ ករណីនេះលោកចាត់ទុកថា មិនមែនជាករណីជួញដូរឡើយ។ យ៉ាងណាស្នងការរូបនេះបានសង្កត់ធ្ងន់ថាៈ «ខ្ញុំចង់ដឹងព័ត៌មានហ្នឹង(ការជួញដូរមនុស្ស) ហើយចង់ស្រាវជ្រាវឲ្យដល់ឫសគល់លើករណីនេះដែរ។ ឮព័ត៌មាននេះ តែពីខាងសារព័ត៌មាន តែខាងខ្ញុំទទួលព័ត៌មានអត់ដែលបានពិស្តារទេ។ ខ្ញុំនឹងឆែកមើលករណីនេះ»។ ទន្ទឹមនឹងនេះ លោកអះអាងថា ក្រុមការងារធ្វើការស្រាវជ្រាវកន្លងមក ពុំដែលឃើញមានករណីពាក់ព័ន្ធនឹងការជួញដូរមនុស្សឡើយ។

បើតាមលោក សេង រាជ មន្ត្រីផ្នែកច្បាប់របស់អង្គការសង់ត្រាល់ កំពុងសហការជាមួយសាច់ញាតិរបស់ជនរងគ្រោះទាំង៣រូបខាងលើ ដើម្បីប្រមូលព័ត៌មានបន្ថែមលើករណីនេះ។ លោកក៏ពុំដឹងថា ក្រុមហ៊ុនកាស៊ីណូនោះឈ្មោះអ្វីដែរ ដោយគ្រាន់តែដឹងត្រឹមរើបសាយ។

ចំណែក លោក យុន ថារ៉ូ អ្នកគ្រប់គ្រងកម្មវិធីការងារ នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្សរបស់អង្គការសង់ត្រាល់ សង្កេតឃើញថា មានករណីមិនប្រក្រតីច្រើន លើការរំលោភសិទ្ធិមនុស្សនិងសិទ្ធិការងារក្នុងខេត្តព្រះសីហនុ។ លោកទទួលបានព័ត៌មាន៤ករណី ដែលមានបុគ្គលិកប្រមាណ១០០០ពាន់នាក់ ជួបបញ្ហាបង្ខំនិងបង្ខាំងឲ្យធ្វើការក្នុងវិស័យសណ្ឋាគារនិងកាស៊ីណូ។ «យើងបារម្ភនៅកម្ពុជាយើងអាចវិវឌ្ឍនជាទីតាំងភូមិសាស្ត្រជួញដូរ មិនមែនតែពលរដ្ឋខ្មែរទេដែលជាជនរងគ្រោះ គឺមានពលករបរទេសដែលត្រូវជួញដូរនៅព្រះសីហនុ»។ នេះបើ

តាមការព្រួយបារម្ភរបស់អ្នកឃ្លាំមើលសិទ្ធិការងារ ដោយបន្ថែមថា ការបង្ខាំងមនុស្ស និងការដាក់កំហិតឬគំរាមលើបុគ្គលិក តាមរយៈមេការ និងកេងប្រវ័ញ្ចកម្លាំងបង្ខំឲ្យធ្វើការ គឺជាការជួញដូរមនុស្សនិងរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។ ភាពមិនប្រក្រតីទាំងនេះ អាជ្ញាធរ ពិសេសមន្ទីរការងារ មានតួនាទីក្នុងការចុះអធិការកិច្ច ពិនិត្យតាមក្រុមហ៊ុន ឬកន្លែងអាជីវកម្មផ្សេងៗ ដើម្បីធានាសុវត្ថិភាពដល់សាធារណជន។ ពាក់ព័ន្ធនឹង ករណីស្នើសុំអន្តរាគមន៍របស់ក្រុមសាច់ញាតិខាងលើនេះ ក្រុមការងាររបស់សង់ត្រាល់កំពុងស្រាវជ្រាវ និងរង់ចាំមើលចំណាត់ការរបស់អាជ្ញាធរ។ ទន្ទឹមនឹង លោកថាករណីបង្ខាំងមនុស្សនិងជួញដូរបែបនេះ អាចនឹងមានអ្នករងគ្រោះច្រើន ខណៈអ្នកជួបវិបត្តិហិរញ្ញវត្ថុ ភាគច្រើនកំពុងស្វែងរកការងារធ្វើក្នុងបរិបទកូវីដ-១៩។

ក្នុងឆ្នាំ២០២១នេះ ក្រុមការងារនៃមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចុះអធិការកិច្ចប្រមាណ ២០០ទីតាំង។ ជាមួយគ្នាដែរ ការដោះស្រាយវិវាទរវាងការងារមានជាង៧០ករណី គឺបានដោះស្រាយទាំងអស់ រួមទាំងការដោះស្រាយបញ្ហាមួយចំនួន ដេលបានរាយការណ៍តាមប្រព័ន្ធទូរស័ព្ទ។ នេះបើតាម លោក យ៉ូវ ខេមរា ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ ដោយអះអាងថា មន្ត្រីចុះបំពេញការងារខាងលើនេះ ពុំឃើញមានករណីជួញដូរមនុស្សឡើយ។ ប៉ុន្តែ លោក បានកត់សម្គាល់ឃើញថា ក្រុមសារព័ត៌មានមួយចំនួន ដែលមាននិន្នាការប្រឆាំងនឹងរដ្ឋាភិបាល តែងតែចុះផ្សាយព័ត៌មានខុសទម្រង់ ពោលគឺបកស្រាយខុសការពិត ទៅជាការជួញដូរមនុស្ស ខណៈអាជ្ញាធរ និងកន្លែងការងារអនុវត្តវិធានការផ្ទៃក្នុង។ លោកថ្លែងប្រាប់សារព័ត៌មានថ្មីៗតាមទូរស័ព្ទយ៉ាងដូច្នេះថា៖ «រូបភាពវាមាន(បែបជួញដូរមនុស្ស) ប៉ុន្តែអ្នកសារព័ត៌មានខ្លួនឯងដែលមាននិន្នាការមិនគាំទ្ររដ្ឋាភិបាល ច្រើនបកស្រាយទៅទម្រង់ផ្សេង ដូចជាការអនុវត្តវិធានការផ្ទៃក្នុង»។ ប្រធានមន្ទីររូបនេះ បានពន្យល់បន្ថែមថា មានករណីបុគ្គលិកធ្វើចត្តាឡីស័ក មិនជួបភ្ញៀវ ឬបំពេញការងារជាដើម ត្រូវបានបុគ្គលិកនិងក្រុមអ្នកប្រឆាំងរដ្ឋាភិបាល ចាត់ទុកជារូបភាពបង្ខាំងមនុស្ស។ ជាក់ស្តែងអាជ្ញាធរបានកំពុងបង្កើតក្រុមការងារចុះតាមដានរកករណីបង្ខាំងនិងជួញដូរមនុស្ស នៅកាស៊ីណូ ជឺសេនជូរី ខេត្តព្រះសីហនុ ។ ប៉ុន្តែ ព័ត៌មានបឋមរកពុំឃើញមានករណីសង្ស័យណាមួយឡើយ ពីការជួញដូរមនុស្ស។ នេះបើតាមការលើកឡើងរបស់ប្រធានមន្ទីរការងារ។

សូមជម្រាបថា កាលពីដើមខែតុលា បុគ្គលិកជាច្រើននាក់ នៅកាស៊ីណូ ជឺសេនជូរី ត្រូវបានរកឃើញឆ្លងកូវីដ-១៩ ប៉ុន្តែបុគ្គលិកខ្លះ មិនព្រមទៅសម្រាកព្យាបាលទៅមន្ទីរពេទ្យទេ។ មិនតែប៉ុណ្ណោះពួកគេ អះអាងថា ថៅកែកាស៊ីណូ បង្ខាំងពួកគេ មិនឱ្យចេញក្រៅទៀតផង។ ហើយអាជ្ញាធរ ក៏បានចុះស៊ើបអង្កេតករណីបង្ខាំងមនុស្សនៅកាស៊ីណូ ជឺសេនជូរីម នេះ។ ករណីលេចឮព័ត៌មាន ជួញដូរមនុស្សក្នុងខេត្តព្រះសីហនុមានជាច្រើនដងហើយ ហើយអាជ្ញាធរក៏តែងតែបកស្រាយដែរថា ពុំមានករណីជួញដូរមនុស្សបន្ទាប់ចុះពិនិត្យ។ កាលពីខែកញ្ញា លោក ជួន ណារិន្ទ ស្នងការនគរបាលខេត្តព្រះសីហនុ បានបកស្រាយថា រឿងជនជាតិថៃមួយក្រុម ដែលបង្ហោះវីដេអូ សុំការអន្តរាគមន៍នោះ ពីការបង្ខាំងមនុស្ស មិនមែនជាករណីបង្ខាំងឡើយ គឺជាករណីធ្វើចត្តាឡីស័ក។

កាលពីចុងខែតុលានេះ សម្តេច ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានកត់សម្គាល់ឃើញថា រយៈពេល៩ខែ ឆ្នាំ២០២១ ស្ថានភាពសន្តិសុខ មានភាពល្អប្រសើរ ក្នុងនោះបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ បានថយចុះ៩ភាគរយ។ ប៉ុន្តែ ក្នុងបរិបទនៃជំងឺកូវីដ-១៩ ការរត់ពន្ធមនុស្សឆ្លងដែន និងបទល្មើសពាក់ព័ន្ធនឹងបច្ចេកវិទ្យា គឺមានការកើនឡើង៕

## ថៃបញ្ជូនពលករខ្មែរ ១២៦ នាក់ឲ្យត្រឡប់មកកម្ពុជាវិញតាមច្រកអូរអន្លក់ ស្រុកកំរៀង ខេត្តបាត់ដំបង

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៥ វិច្ឆិកា ២០២១ដោយ Kang Tola

ថៃបញ្ជូនពលករខ្មែរ ដែលលួចចូលទៅធ្វើការនៅក្នុងប្រទេសថៃ ដោយខុសច្បាប់ ចំនួន១២៦នាក់ ឲ្យត្រឡប់មកកម្ពុជាវិញតាមច្រកអូរអន្លក់ ស្រុកកំរៀង ខេត្តបាត់ដំបង នៅព្រឹកថ្ងៃទី ៥ ខែ វិច្ឆិកា ២០២១ ។ នេះបើយោងតាមប្រភពព័ត៌មានរបស់ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង។

ប្រភពព័ត៌មានពីលោកវរសេនីយ៍ឯក សួន ស៊ីវ៉ា នាយការិយាល័យផ្សព្វផ្សាយ និងអប់រំ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបងបានឲ្យដឹងថា នៅថ្ងៃទី៥ ខែវិច្ឆិកា នេះ អង្គភាពវរសេនាតូចលេខ ៨១៩ កងកម្លាំងប៉ុស្តិ៍អូរអន្លក់បានសហការជាមួយកងកម្លាំងឃោធភូមិភាគទី៥ និងកងរាជអាវុធហត្ថបានទទួលយកពលករខ្មែរដែលបានត្រូវបានភាគីថៃបញ្ជូនត្រឡប់មកក្នុងប្រទេសកម្ពុជាវិញតាមច្រកអូរអន្លក់ ស្រុកកំរៀង ខេត្តបាត់ដំបង ចំនួន១២៦នាក់ក្នុងនោះមានស្រីចំនួន៤៧នាក់ក្មេងចំនួន១១ នាក់ស្រី៧នាក់។ ប្រជាពលករខ្មែរទាំង ១២៦ នាក់នោះត្រូវបានកងកម្លាំងបានធ្វើការវាស់កំដៅនិងកត់ត្រារួចបន្ទាប់មកក្រុមគ្រូពេទ្យជំនាញដែលប្រចាំការនៅតាមតំបន់ព្រំដែនបានយកសំណាកដើម្បីធ្វើតេស្តរហ័សរួចរាល់ហើយផងដែរ។ ជាលទ្ធផលក្រោយពីធ្វើតេស្តរហ័សពលករទាំង១២៦នាក់នោះគឺអវិជ្ជមានជំងឺកូវីដ១៩ទាំងអស់។ ក្រុមការងារបានធ្វើការបញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័កបន្តនៅមណ្ឌលចត្តាឡីស័កអូរល្វាស្ថិតក្នុងស្រុកសំពៅលូនខេត្តបាត់ដំបង៕ *ដោយ ៖ ណារី*

## ទាហានថៃឃាត់ពលរដ្ឋខ្មែរប្រុស ស្រី៣៤នាក់ ឆ្លងដែនចូលទៅទឹកដីថៃខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ០៥ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ១៥:៤១

បន្ទាយមានជ័យ ៖ ប្រជាពលរដ្ឋខ្មែរ ប្រុសស្រីចំនួន៣៤នាក់ ក្នុងនោះមានក្មេងចំនួន០៣នាក់ បានលួចឆ្លងដែនចូលទៅទឹកដីថៃដោយខុសច្បាប់ត្រូវបានទាហានថៃឈុតខ្មៅលេខ(១៣.០២) ឃាត់បាននៅចំណុចភូមិថាប់ភិក ឃុំថាប់ភិក ស្រុកអារញ្ញ ខេត្តស្រះកែវ ។

លោកវរសេនីយ៍ត្រី ប៊ុន គុន នាយប៉ុស្តិ៍ការពារព្រំដែនចំបក់បានឲ្យដឹងថា៖ នៅវេលាម៉ោង០៤ ថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ខណៈពេលលោកដឹកនាំកម្លាំងល្បាតក្នុងភូមិសាស្រ្តព្រំដែនដែលទទួលខុសត្រូវ បានប្រទះឃើញប្រជាពលរដ្ឋខ្មែរលួចឆ្លងដែនទៅប្រទេសថៃខុសច្បាប់(ឆ្លងដល់មាត់អូរជីថៃ) ។ បន្ទាប់មកកម្លាំងយើងបានផ្តល់ព័ត៌មានដល់ទាហានឈុតខ្មៅថៃ(១៣.០២)ដែលឈរជើងទល់មុខឱ្យជួយសហការទប់ស្កាត់ ប្រជាពលរដ្ឋទាំងនោះ ។ លោកនាយប៉ុស្តិ៍បានសបញ្ជាក់ថា ៖ នៅវេលាម៉ោង០៦ព្រឹក ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ខាងទាហានឈុតខ្មៅថៃ (១៣.០២) បានផ្តល់ព័ត៌មានថា ប្រជាពលរដ្ឋខ្មែរដែលត្រូវបានឃាត់មានចំនួន៣៤នាក់ ស្រី១៧នាក់ កុមារ០៣នាក់ ។ ការឃាត់ខ្លួននេះធ្វើឡើង នៅចំណុចនៅចំណុចភូមិថាប់ភិក ឃុំថាប់ភិក ស្រុកអារញ្ញ ។ បច្ចុប្បន្នប្រជាពលរដ្ឋទាំងនោះ បានបញ្ជូនទៅអធិការដ្ឋាននរបាលក្លងណាំសៃ ដើម្បីមានវិធានការបន្ត ៕

## អ្នកនាំពាក្យការបរទេសកម្ពុជា ៖ ២ថ្ងៃ អាជ្ញាធរថៃឃាត់ពលករខ្មែរ លួចឆ្លងដែនខុសច្បាប់ ជាង៧០នាក់

https://cen.com.kh/ Posted ByPen Srey NeatNovember 5, 2021

ភ្នំពេញ ៖ អ្នកនាំពាក្យ ក្រសួង ការបរទេសកម្ពុជា លោកកុយ គួង បានឲ្យដឹងនៅមុននេះបន្តិចថា កាលពីរសៀលថ្ងៃទី ០៤ និងព្រឹកថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០២១ អាជ្ញាធរមានសមត្ថកិច្ចថៃបានឃាត់ខ្លួនពលករខ្មែរ លួចឆ្លងដែនដោយខុសច្បាប់ (ពុំមានលិខិតស្នាម) ចំនួន៧២នាក់ (ប្រុស៣៦ នាក់)នៅពីរចំណុចផ្សេងៗគ្នា។ បន្ទាប់ពីទទួលបានព័ត៌មានភ្លាម ស្ថានអគ្គកុងស៊ុលកម្ពុជាបានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើមកមាតុប្រទេសវិញ នៅរសៀលថ្ងៃទី៥ ខែវិច្ឆិកានេះ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕ រក្សាសិទ្ធិដោយ ៖ ចេស្តារ

## មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ ដាក់ចេញបទបញ្ជាត្រូវយកចិត្តទុកដាក់ចេញល្បាត ត្រួតពិនិត្យ គ្រប់ចំណុចគោលដៅ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ៥ វិច្ឆិកា ២០២១ដោយ Kang Tola

ឧត្តរមានជ័យ ៖ ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ឧត្តមសេនីយ៍ទោ តន់ ញាន មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងឧត្តរមានជ័យ បានដាក់ចេញនូវបទបញ្ជាយ៉ាងម៉ឺងម៉ាត់ ដល់កងកម្លាំងតាមបណ្តាកងឯកភាពចំណុះទាំងអស់ ត្រូវយកចិត្តទុកដាក់សហការជាមួយកងកម្លាំងចម្រុះក្នុងការរឹតបណ្តឹង ល្បាត នៅតាមខ្សែបន្ទាត់ព្រំដែនការពារឲ្យបានការលួចឆ្លងដែន និងបទល្មើសគ្រប់ប្រភេទ ក្នុងភូមិសាស្ត្រ និងតាមគោលដៅត្រួតពិនិត្យរបស់ខ្លួន។ ជាមួយនឹងការពង្រឹងការអនុវត្តបទបញ្ជានេះ កម្លាំងរបស់តំបន់ប្រតិបត្តិការសឹករងឧត្តមរមានជ័យ បានសហការជាមួយក្រុមការងារទំនាក់ទំនងព្រំដែនកម្ពុជា ប្រចាំច្រក អូរស្មាច់ ច្រកថ្មដូន និងច្រជប់គគី និងសហការជាមួយ កងពលតូចដឹកជញ្ជូនលេខ៩៩ កងកម្លាំងចម្រុះ មន្ត្រីជំនាញ និងអាជ្ញាធរមូលដ្ឋាន ក្នុងការទប់ស្កាត់ ប្រមូល និងដឹកជញ្ជូនប្រជាពលករ ដែលត្រឡប់មកពីប្រទេសថៃតាមច្រកអន្តរជាតិអូរស្មាច់ទៅដាក់នៅក្នុងមណ្ឌលចត្តាឡីស័ក ជាមួយគ្នានោះកម្លាំងមួយផ្នែកបាននៅប្រចាំការ ការពារ នៅតាមទីតាំងមណ្ឌលចត្តាឡីស័ក ទូទាំងក្នុងខេត្តឧត្តរមានជ័យ។

សូមជម្រាបជូនថា នៅថ្ងៃ០៤ ខែវិច្ឆិកា ឆ្នាំ២០២១ ម្សិលមិញនេះ មានបងប្អូនប្រជាពលរដ្ឋឆ្លងដែនពីប្រទេសថៃ មកដល់ទឹកដីកម្ពុជា តាមច្រកអន្តរជាតិអូស្មាច់សរុបចំនួន ៩៩នាក់ ស្រី ៣៨នាក់ បានយកទៅធ្វើចត្តាឡីស័កនៅតាមមណ្ឌលទាំង ០៩ ក្នុងខេត្តឧត្តរមានជ័យ៕ *ដោយ ៖ ចាន់ ជី*

## លម្អិតពីការស្លាប់ និងរបួសពលករខ្មែរ ១៣ នាក់ ក្នុងគ្រោះថ្នាក់ចរាចរណ៍ នៅប្រទេសថៃ

https://www.kampucheathmey.com/ ថ្ងៃសៅរ៍ ៦ វិច្ឆិកា ២០២១ដោយ Dy Bunnara

សមត្ថកិច្ចថៃ បាននាំខ្លួនពលករខ្មែរដែលរួចផុតពីសេចក្តីស្លាប់នៅក្នុងឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរ នៅខេត្តស្រះកែវឲ្យទៅចង្អុលបង្ហាញច្រកដែលពួកគេឆ្លងចូលមកក្នុងប្រទេសថៃ។ ករណីគ្រោះថ្នាក់ចរាចរបណ្តាលឲ្យមនុស្សស្លាប់ចំនួន ៥ នាក់ ក្នុងចំណោមជនរងគ្រោះសរុប ១៣ នាក់ បានកើតឡើងនៅក្នុងខេត្តស្រះកែវ ប្រទេសថៃ ដោយសាររថយន្តក្រឡាប់ គឺនៅវេលាម៉ោង ៩ និង ១០ នាទីយប់ ខាងមុខសាលារៀន ខ្លងយ៉ាយឥន្ទ្រ ក្នុងភូមិសាស្ត្រឃុំវ៉ាំងថង ស្រុកវ៉ាំងសុំប៊ូន ខេត្តស្រះកែវ។ ដោយពេលនោះមានរថយន្តមួយគ្រឿងដែលដឹកពលករខ្មែរសរុបទាំង

អស់ចំនួន ១៣ នាក់ បានបើកបរក្នុងល្បឿនលឿន ហើយបានរេចង្កូតទៅបុកនឹងសសរបង្គោលភ្លើង និងធ្វើអោយរថយន្តក្រឡាប់ជាច្រើនត្រឡប់ ធ្វើអោយពលករខ្មែរស្លាប់ និងរបួសធ្ងន់ជាច្រើននាក់។ ក្រោយពីកម្លាំងតម្រួតថៃចុះពិនិត្យជាក់ស្តែងគឺសង្កេតឃើញថា មានមនុស្សស្លាប់នៅនឹងកន្លែងចំនួន ៥ នាក់ ក្នុងនោះស្រី៣ ប្រុស២ និងអ្នកបើកបររថយន្តដែលជាជនជាតិថៃម្នាក់។ ដោយឡែកពលករខ្មែរដែលរបួសធ្ងន់ចំនួន ៤ នាក់ កំពុងបញ្ជូនទៅមន្ទីរពេទ្យដើម្បីសង្គ្រោះ និង៤នាក់ដែលរបួសស្រាល ត្រូវបាននាំយកទៅកាន់ស្ថានីយ៍តម្រួតដើម្បីសាកសួរ។

បើតាមការរៀបរាប់ពីជនរងគ្រោះខ្មែរម្នាក់បានបញ្ជាក់ថា ពួកគេទាំងអស់មានចំនួន៣០នាក់ ដោយមានមេខ្យល់ខ្មែរឈ្មោះ ទា នាំឆ្លងអូរក្បែរច្រកអន្តរជាតិដូង ក្នុងស្រុកកំរៀង ខេត្តបាត់ដំបង (ច្រកបានឡែម ក្នុងខេត្តច័ន្ទបុរី) ដោយយកលុយម្នាក់ ៧.០០០ បាត ដោយមានរថយន្តមកចាំដឹកយកទៅសំងំក្នុងផ្ទះមួយកន្លែងក្នុងខេត្តស្រះកែវ។ លុះនៅយប់ថ្ងៃកើតហេតុគឺមានរថយន្តចំនួន៣គ្រឿងមកដឹកពួកគេ ដោយរថយន្តដែលជួបគ្រោះថ្នាក់គឺចេញក្រោយគេក្នុងទិសដៅទៅធ្វើការក្នុងរោងចក្រកែច្នៃសាច់មាន់នៅក្នុងក្រុមហ៊ុនល្បីឈ្មោះមួយ ក្នុងស្រុកកាប៊ីនបុរី ខេត្តប្រាជីនបុរី។ ប៉ុន្តែពេលចេញដំណើរបានប្រហែលកន្លះម៉ោង ក៏ជួបនឹងគ្រោះថ្នាក់តែម្តង។ សមត្ថកិច្ចថៃបានបង្ហាញអត្តសញ្ញាណជនរងគ្រោះទាំងអស់គឺ អ្នកបើកបរឈ្មោះ ប្រាវិត ច័ន្ទស្វាង អាយុ ៣៩ ឆ្នាំ អ្នករស់នៅខេត្តថៃភូមិ (ស្លាប់)។ ចំណែកជនរងគ្រោះខ្មែរដែលភាគច្រើនចេញពីខេត្តបាត់ដំបង ដែលរបួសស្រាល ៤ នាក់គឺ ១.ឈ្មោះ យ៉យ កាកែ ភេទប្រុស អាយុ ២២ ឆ្នាំ ២.ឈ្មោះ វេត រាត្រី ភេទប្រុស អាយុ ១៩ ឆ្នាំ ៣.ឈ្មោះ ហៀប សឿន ភេទប្រុស អាយុ ១៨ ឆ្នាំ និង៤.ឈ្មោះ យ៉ង ឡាយ ភេទប្រុស អាយុ ២៤ ឆ្នាំ ចំណែកអ្នករបួសធ្ងន់ ៤ នាក់គឺ ១.ឈ្មោះ ង៉ែត កុសល ភេទប្រុស ២.ឈ្មោះ សុខ នី ភេទប្រុស ៣.ឈ្មោះ ហេង ឈាងហ៊ួ ភេទប្រុស និង៤.អត់ទាន់ស្គាល់អត្តសញ្ញាណដោយសាររបួសធ្ងន់ពេក ដោយឡែកចំពោះអ្នកស្លាប់ចំនួន ៤ នាក់ គឺស្គាល់តែម្នាក់ប៉ុណ្ណោះ គឺឈ្មោះ អ៊ុំ កញ្ញា ភេទស្រី រីឯ៣នាក់ទៀតគឺប្រុស១ ស្រី២ មិនទាន់ស្គាល់ឈ្មោះឡើយ ដោយក្នុងនោះសពមនុស្សស្រីម្នាក់ មានផ្ទុកកូវីដ-១៩ ។

បច្ចុប្បន្នក្រុមការងារសហព័ន្ធ សហជីព កម្មករថៃ កំពុងស្រាវជ្រាវរកក្រុមគ្រួសារ សាច់ញាតិ ដើម្បីប្រគល់ប្រាក់ឧបត្ថម្ភ ដោយសព ១ នាក់ ទទួលបានប្រាក់ ៥០០.០០០ បាត ដោយឡែកអ្នករបួសទទួលបាន មិនលើសពី ៨០.០០០ បាត៕ អត្ថបទ៖ សោ និយមរ័ត្ន

## អាជ្ញាធរស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋ៣នាក់ ដែលវិលត្រឡប់ពីប្រទេសថៃ និងប្រគល់ទៅឲ្យក្រុមគ្រូពេទ្យដែលប្រចាំការ នៅចំណុចច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣

https://gdlf-kh.com/ 05/11/2021 Seng Chanmonirith ខេត្តបាត់ដំបង

ខេត្តបាត់ដំបង៖ នៅវេលាម៉ោង១១:១០នាទី នាថ្ងៃសុក្រ ១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបងជាប់ជាប្រចាំ ស្តីពីការ ការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ និងត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករ ចេញ ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា_ថៃ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់កម្លាំងប៉ុស្តិ៍ព្រំដែនកូនភ្នំ ចំនួន០៤នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ ឌឹម-ធុល (នាយរងប៉ុស្តិ៍) រួមជាមួយកម្លាំងផ្នែកស៊ើបការណ៍ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ទោ សេង-អ៊ីន (នាយផ្នែក) សហការជាមួយកម្លាំងយោធាកងអនុសេនាធំទី១, វរសេនាតូចលេខ១ ចំនួន០៣នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឡៃ-លឿន (មេបញ្ជាការកងអនុសេនាតូច) រួមជាមួយកម្លាំងកងអន្តរាគមន៍វរសេនាតូចលេខ១ ចំនួន០២នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី អ៊ុក-វ៉ដួល (ជំនួយការហ្វឹកហ្វឺន), កម្លាំងយោធាកងអនុសេនាធំគាំទ្រវរៈ៥៣៣ ចំនួន០៤

នាក់ ដឹកនាំដោយលោកអនុសេនីយ៍ត្រី ឈឹម-សុភាព (មេបញ្ជាការកងអនុសេនាតូច) បានទទួលប្រជាពលរដ្ឋដែលវិលត្រឡប់ចូលមកប្រទេសកម្ពុជាវិញត្រង់ចំណុចភូមិសាស្រ្ត ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន០៣នាក់ ស្រី០១នាក់ ក្មេងស្រី០១នាក់។ បន្ទាប់ពីសាកសួរ, កត់ឈ្មោះ និងអប់រំណែនាំរួច កម្លាំងយើងបានប្រគល់បងប្អូនឲ្យទៅក្រុមគ្រូពេទ្យដែលប្រចាំការនៅច្រកទ្វារព្រំដែនអន្តរជាតិគីឡូ១៣។

## ចាប់ពលករចំណាកស្រុកខ្មែរ ៤៦នាក់ឆ្លងដែនខុសច្បាប់

https://www.khmertimeskh.com/ November 6, 2021

ពលករចំណាកស្រុកខុសច្បាប់កាន់តែច្រើនពីប្រទេសកម្ពុជាត្រូវបានឃាត់ខ្លួន ខណៈឆ្លងដែនចូលប្រទេសថៃ បន្ទាប់ពីនាយករដ្ឋមន្ត្រីបញ្ជាឱ្យស៊ើបអង្កេតរកមេខ្លោងជួញដូរមនុស្សនៅពីក្រោយការឆ្លងដែនខុសច្បាប់ទាំងនេះ។ ប្រភពមួយបានឲ្យដឹងថា នៅខេត្តស្រះកែវ ពលករចំណាកស្រុកខ្មែរ ៤៦នាក់ត្រូវបានឃុំខ្លួនកាលពីម្សិលមិញក្នុងហេតុការណ៍ ពីរផ្សេងគ្នានៃការឆ្លងដែនខុសច្បាប់។ លោកវរៈសេនីយ៍ឯក រុន ណារ៉ុង សេងមី ប្រធានអង្គភាពអនុរក្សយោធាបានឲ្យដឹងថា ហេតុការណ៍ទី១ គឺមានជនជាតិខ្មែរចំនួន៣៥នាក់ បុរស១៦នាក់ និងស្ត្រី១៩នាក់ ត្រូវបានឃាត់ខ្លួននៅឃុំបានថាព្រិច ស្រុកអារញ្ញប្រាថេត ដោយកម្លាំងចម្រុះនៃកងនគរបាល និងអនុរក្ស ច្រកព្រំដែន។ លោកវីរៈសេនីយ៍ រុនណារ៉ុង បាននិយាយថា កម្មករដែលត្រូវបានឃាត់ខ្លួនបាននិយាយថា ពួកគេបានបង់ប្រាក់ឱ្យឈ្មួញកណ្តាល ចន្លោះពី ៦,០០០ បាតទៅ ៩,០០០ បាតដើម្បីរត់ពន្ធពួកគេអោយឆ្លងកាត់ព្រំដែន។ គាត់បាននិយាយថា ពួកគេមានបំណងធ្វើការនៅក្នុងរោងចក្រផលិតនំប៉័ង ការដ្ឋានសំណង់ ហាងសាច់អាំង និងក្រុមហ៊ុននៅ Rayong, Bangkok, Chon Buri និង Pathum Thani ។ ប្រភពព័ត៌មានមួយបាននិយាយថា អត្រាដែលពួកគេបានបង់គឺខ្ពស់ជាងការចោទប្រកាន់ចំពោះជនចំណាកស្រុកខុសច្បាប់ដែលត្រូវបានឃុំខ្លួនកាលពីមុន។

លោកវីរៈសេនីយ៍ Wirachai Phongkaeo ប្រធានកងពលថ្មើរជើងពិសេសទី៤ នៃកងពលថ្មើរជើងពិសេសទី៤ បាននិយាយថា៖ បន្ថែមពីលើនេះ ជនចំណាកស្រុកមីយ៉ាន់ម៉ា ២៣នាក់ ក្នុងនោះបុរស ១១នាក់ ស្ត្រី ៥នាក់ និងកុមារ ៧នាក់ ត្រូវបានឃុំខ្លួនកាលពីម្សិលមិញ ខណៈកំពុងធ្វើដំណើរដោយថ្មើរជើងនៅភូមិព្រំដែនមួយក្នុងស្រុក Fang នៃខេត្តឈៀងម៉ៃ។ លោកវីរៈសេនីយ៍ Wirachai បាននិយាយថា ក្រុមល្បាតព្រំដែនបានរកឃើញពួកគេនៅពេលដែលពួកគេកំពុងល្បាតជាផ្នែកមួយនៃប្រតិបត្តិការជាទៀងទាត់មួយក្នុងគោលបំណងទប់ស្កាត់លំហូរនៃគ្រឿងញៀនរត់ពន្ធ និងពលករចំណាកស្រុកខុសច្បាប់។ ជនចំណាកស្រុកបានប្រាប់អាជ្ញាធរថា ពួកគេមានបំណងស្វែងរកការងារធ្វើនៅឈៀងម៉ៃ។

## មេខ្យល់ម្នាក់ដែលបម្រុងនាំពលករ ១២ នាក់ ឆ្លងដែនទៅប្រទេសថៃ ត្រូវបានសមត្ថកិច្ចខេត្តបាត់ដំបងឃាត់ខ្លួន

https://www.postkhmer.com/national/ រី សុចាន់ | Publication date 06 November 2021 | 09:47 ICT

**បាត់ដំបង:** មេខ្យល់ម្នាក់ដែលបម្រុងនាំពលករ ១២ នាក់ ឆ្លងដែនទៅប្រទេសថៃខុសច្បាប់ ត្រូវបានសមត្ថកិច្ចខេត្តបាត់ដំបងឃាត់ខ្លួននៅចំណុចក្រុមទី៧ ភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន នៅថ្ងៃទី៥ វិច្ឆិកា។ គេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិបានឱ្យដឹងនៅថ្ងៃទី ៥ ខែវិច្ឆិកាថា៖ «ក្នុងកិច្ចប្រតិបត្តិការនេះ សមត្ថកិច្ចបានធ្វើការទប់ស្កាត់ពលករបម្រុងឆ្លងដែនទៅប្រទេសថៃ ខុសច្បាប់ចំនួន ១២ នាក់ (ស្រីចំនួន ៥នាក់ អនីតិជនចំនួន ២ នាក់) និងឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ម្នាក់»។ បុរសជាមេខ្យល់មានអាយុ ៣៨ ឆ្នាំ មានទីលំនៅនៅភូមិសាលាឆេះ ឃុំហោល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ ជននេះ បានសារភាពប្រាប់សមត្ថកិច្ចថា ការនាំមនុស្សចេញទៅប្រទេសថៃនេះ ខ្លួនបានយកប្រាក់ថ្លៃធ្វើដំណើរពីពលករក្នុងម្នាក់ពី ៦៥០០បាត (១៩៥ ដុល្លារ)

ទៅ ១១៥០០ បាត (៣៨៥ ដុល្លារ)។ សមត្ថកិច្ចនគរបាលស្រុក សំពៅលូន បានកសាងសំណុំរឿងបញ្ជូនមេខ្យល់រូបនេះទៅកាន់ការិយាល័យជំនាញ ដើម្បីអនុវត្តតាមច្បាប់ រីឯប្រជាពលរដ្ឋត្រូវបានអប់រំណែនាំឱ្យវិលទៅលំនៅឋានវិញ៕

## ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១

### ពលករខ្មែរកាន់តែច្រើនបន្តសម្រុកឆ្លងដែនទៅធ្វើការនៅប្រទេសថៃ

https://www.rfa.org/khmer/news/ ដោយ ជីវិតា2021-11-07

ពលករខ្មែរជាច្រើននាក់បន្តសម្រុកឆ្លងដែនទៅធ្វើការងារនៅប្រទេសថៃ តាមច្រករបៀងព្រំដែនខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបងជារៀងរាល់ថ្ងៃ។ មន្ត្រីសង្គមស៊ីវិល យល់ថា ការឆ្លងដែននេះកើតឡើងដោយសារអាជ្ញាធរព្រំដែនអនុវត្តច្បាប់ធូររលុង និងបណ្ដោយឲ្យក្រុមមេខ្យល់នាំពលករឆ្លងដែនតាមអំពើចិត្ត។ មន្ត្រីសង្គមស៊ីវិលសង្កេតឃើញថា ពលករឆ្លងដែនក្នុងពេលនេះ ដោយសារពួកគាត់អត់ការងារធ្វើនៅក្នុងស្រុក និងជំពាក់បំណុលធនាគារ ប៉ុន្តែប្រឈមនឹងគ្រោះថ្នាក់ជាច្រើន ដែលអាជ្ញាធរពាក់ព័ន្ធមិនគួរបណ្ដោយឱ្យពួកគេឆ្លងដែនទាំងប្រថុយប្រថានបែបនេះឡើយ។

មន្ត្រីផ្នែកការពារសិទ្ធពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី៧ វិច្ឆិកា ថា ពលករខ្មែរកាន់តែច្រើនបានចាញ់បោកមេខ្យល់នាំឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ជាច្រើនរាល់ថ្ងៃ។ លោកមើលឃើញថា ការដែលពលករឆ្លងដែននៅពេលនេះកើតឡើងដោយសារតែអាជ្ញាធរព្រំដែនកម្ពុជា និងថៃអនុវត្តច្បាប់ធូររលុង ដែលធ្វើឱ្យមេខ្យល់មិនខ្លាចច្បាប់ ហើយនាំពលករឆ្លងដែនទៅប្រទេសថៃជាបន្តបន្ទាប់។ មន្ត្រីសង្គមស៊ីវិលរូបនេះ ជឿជាក់ថា ប្រសិនបើអាជ្ញាធរព្រំដែនប្រទេសទាំងពីរ អនុវត្តច្បាប់តឹងរ៉ឹង ដោយស្រាវជ្រាវចាប់មេខ្យល់នៅតំបន់ព្រំដែនឱ្យអស់ នោះពលរដ្ឋខ្មែរមិនអាចឆ្លងដែនបានឡើយ។ លោកបញ្ជាក់ទៀតថា សព្វថ្ងៃពលករបង់ថ្លៃធ្វើដំណើរឱ្យមេខ្យល់នាំឆ្លងដែនទៅដល់កន្លែងធ្វើការក្នុងម្នាក់ចន្លោះពី ៦ពាន់ទៅ ៩បាត ឬប្រមាណពី១៩០ដុល្លារទៅ ២៨៥ដុល្លារអាមេរិក៖ «ណាមួយទៀតថ្មីៗនេះឃើញព័ត៌មាននេះគេនឹងបើកប្រព័ន្ធអឹមអូយូ (MOU) តែគ្រាន់តែការបើកហ្នឹងជាការមិនទាន់ជាក់លាក់នៅឡើយទេ។ អ៊ីចឹងហើយកុំអាលជឿទៅតាមមេខ្យល់ឬក៏ជឿតាមក្រុមហ៊ុនណាដែលមិនមានព័ត៌មានអីច្បាស់អីចឹង។ ចាំមើលខាងរដ្ឋាភិបាលខ្មែរនិងរដ្ឋាភិបាលថៃគេហ្នឹងប្រកាសបើកឱ្យបានត្រឹមត្រូវចាំមក។ បើសិនជាមកក៏យើងគួរតែទាក់ទងតាមក្រុមហ៊ុនណាដែលគេមានធានាខុសត្រូវដល់ឯកសារ យើងអាយុជីវិតយើង ហើយហ្នឹងការងាររបស់យើង»។ លោក លឹង សុផុន បន្តថា ពលករឆ្លងដែនបែបនេះ គឺប្រឈមនឹងគ្រោះថ្នាក់នឹងអាជ្ញាធរថៃចាប់ខ្លួន ឆ្លងជំងឺកូវីដ១៩ និងប្រឈមគ្រោះថ្នាក់ចរាចរក្នុងពេលធ្វើដំណើរនៅប្រទេសថៃ ដោយសារតែមេខ្យល់បើកឡានក្នុងល្បឿនលឿនដើម្បីគេចប៉ូលិសថៃ។ ជាក់ស្ដែងកាលពីថ្ងៃទី២ វិច្ឆិកា មានពលករខ្មែរចំនួន៤នាក់បានក្រឡាប់ឡានឆេះភ្លើងស្លាប់ និង៨នាក់ទៀតរងរបួសធ្ងន់ ក្នុងពេលធ្វើដំណើរនៅខេត្តស្រះកែវ ជាប់ព្រំដែនខេត្តបន្ទាយមានជ័យ ។ បច្ចុប្បន្នជនរងគ្រោះដែលស្លាប់ទាំង៤នាក់ ត្រូវបានអាជ្ញាធរថៃបញ្ជូនទៅដល់កម្ពុជាហើយ ចំណែកអ្នករងរបួសទាំងនោះកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យក្នុងខេត្តស្រះកែវនៅឡើយ។ លោកថា ពលករភាគច្រើនឆ្លងដែនទៅប្រទេសថៃតាមច្រករបៀងព្រំដែនខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

ទាក់ទងនឹងបញ្ហានេះស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា នៅព្រំដែនខេត្តបន្ទាយមានជ័យពុំសូវមានពលករឆ្លងដែនទៅប្រទេសថៃនោះទេ។ លោកបញ្ជាក់ទៀតថា សមត្ថកិច្ចខ្មែរបានដាក់ពង្រាយកងកម្លាំងជាច្រើននាក់នៅតាមព្រំដែន ដើម្បីទប់ស្កាត់ពលករឆ្លងដែនជារៀងថ្ងៃដែរ ប៉ុន្តែលោកថា ការដែលមានពលករឆ្លងដែននេះភាគច្រើនកើតឡើងដោយសារពួកគេលួចធ្មក់នៅ

ពេលដែលពុំសមត្ថកិច្ចប្រចាំការប៉ុណ្ណោះ «មិនមែនមកពីខេត្តបន្ទាយមានជ័យទេ គឺគាត់ចេញពីច្រកឡែមនៅខេត្តបាត់ដំបងទេ។ ខ្ញុំបានសួរប៉ូលិសថៃអស់ហើយ មិនមែនចេញពីច្រកក្នុងខេត្តបន្ទាយមានជ័យទេ។ វាសំខាន់គឺគាត់ចាញ់បោកមេខ្យល់ ទី២គាត់នៅប្រទេសថៃគាត់ខ្វះកម្មករទៅគាត់ចេះតែទូរស័ព្ទទាក់ទងមកខ្មែរកម្មករចាស់ៗដែលគាត់ត្រឡប់មកកម្ពុជាពេលមុនអឺចឹងខាងថៃគេហៅទៅវិញ»។ មេប៉ូលិសផ្កាយ១រូបនេះបន្តថា នៅថ្ងៃដដែលនេះ អាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរចំនួន៣៥នាក់ ត្រឡប់មកកម្ពុជាវិញតាមច្រករបៀងព្រំដែន ក្នុងខេត្តបន្ទាយមានជ័យ។

របាយការណ៍អាជ្ញាធរថៃឱ្យដឹងថា រយៈពេល១សប្តាហ៍កន្លងមកនេះ មានពលករខ្មែរបានជិត១ពាន់នាក់ (៩៩៦) ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនក្នុងពេលពួកគេឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។ អាជ្ញាធរថៃបានបង្កើតការរឹតបន្តឹងនៅតំបន់ព្រំដែនជាប់កម្ពុជា ដើម្បីទប់ស្កាត់ពលករខ្មែរឆ្លងដែនដោយខុសច្បាប់។

គេហទំព័រហ្វេសប៊ុក (Facebook) មន្ត្រីស្ថានទូតខ្មែរ ទទួលបន្ទុកពលករប្រចាំនៅប្រទេសថៃ ចុះផ្សាយកាលពីថ្ងៃទី៤ វិច្ឆិកាថា ប្រសិនបើប្រជាពលរដ្ឋនិងជនបរទេសណាប្រទះឃើញអាជ្ញាធរថៃមានជាប់ពាក់ព័ន្ធនឹងការនាំពលករបរទេសចូលប្រទេសថៃដោយខុសច្បាប់អំឡុងពេលនេះ ពួកគេត្រូវប្រញាប់ជូនដំណឹងដល់អាជ្ញាធរថៃដើម្បីចាត់វិធានការជាបន្ទាន់។

មន្ត្រីការពារសិទ្ធិពលករលោក លឹង សុផុន ឱ្យដឹងថា ចាប់តាំងពីខែមករា ដល់ខែកញ្ញាមានពលករបរទេសរួមមាន លាវ (Lao) ភូមា ឬមីយ៉ាន់ម៉ា (Myanmar) និងពលករខ្មែរសរុបជាង៣ម៉ឺននាក់ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ។ ក្នុងនោះនៅខែតុលាមានពលករខ្មែរជាង ១ពាន់ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួនក្នុងពេលពួកគេឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ហើយពលករភាគច្រើនបញ្ជូនត្រឡប់ទៅកម្ពុជាវិញ និងមួយចំនួនដាក់ពន្ធនាគារនៅប្រទេសថៃ។ លោកជឿជាក់ថា ប្រសិនបើអាជ្ញាធរប្រទេសទាំងពីរមិនបង្កើតការពារនៅតំបន់ព្រំដែនឱ្យបានតឹងរ៉ឹងទេនោះ ពលករខ្មែរជាច្រើននាក់នឹងបន្តចាញ់បោកមេខ្យល់នាំឆ្លងដែនទៅប្រទេសថៃដែលប្រឈមនឹងគ្រោះថ្នាក់ទៀតជាមិនខាន៕

## សង្គមស៊ីវិលជាតិ និងអន្តរជាតិជាង១០០ស្ថាប័នទាមទារឲ្យអាជ្ញាធរថៃ ដោះលែងពលករខ្មែរ ៧នាក់

https://www.rfa.org/khmer/news/ ដោយ ខែ សុណង 2021-11-06

សង្គមស៊ីវិលជាតិ និងអន្តរជាតិជាង១០០ ស្ថាប័នចាត់ទុកការបន្តឃុំខ្លួនពលករខ្មែរ ៧នាក់ ពីសំណាក់អាជ្ញាធរក្រុងបាងកក ប្រទេសថៃ (Thailand) ថា ជាការរំលោភបំពានសិទ្ធិមនុស្ស។ ក្រុមអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិទាំងនោះមានដូចជា អង្គការសង់ត្រាល់ (Central) លីកាដូ (Licadho) បណ្តាញពលករតំបន់មេគង្គ (MMN) មូលនិធិធនធានអាស៊ី (ARF) មូលនិធិសម្រាប់សិទ្ធិជំនួយប្រចាំប្រទេសថៃ (HRDF) និងមជ្ឈមណ្ឌលជំនួយការសម្រាប់កម្មករប្រចាំប្រទេសហ្វីលីពីន (WAC) ជាដើម បានរួមគ្នាចេញសេចក្តីថ្លែងការណ៍មួយ កាលពីថ្ងៃទី១ ខែវិច្ឆិកា។ ពួកគេអំពាវនាវដល់រដ្ឋាភិបាលក្រុងបាងកក ដោះលែងពលករខ្មែរ ៧នាក់ជាបន្ទាន់ ដោយចាត់ទុកការចាប់ខ្លួននេះ ថា ជាការរំលោភបំពានសិទ្ធិមនុស្ស បន្ទាប់ពីការសម្រេចរបស់រដ្ឋាភិបាលក្រុងបាងកក ផ្តល់ការលើកលែងចំពោះពលករអន្តោប្រវេសន៍ដែលគ្មានឯកសារគ្រប់គ្រាន់។ កាលពីថ្ងៃទី២៩ ខែតុលា អាជ្ញាធរថៃបានចាប់ខ្លួន អ្នកទាំងនោះ ខណៈពួកគាត់ទៅដាក់ញត្តិនៅក្រសួងការងារថៃ ទាមទារឱ្យមានភាពប្រសើរឡើងនូវកិច្ចគាំពារសុខុមាលភាព និងសិទ្ធិពលករអន្តោប្រវេសន៍ដែលកំពុងធ្វើការនៅប្រទេសនេះ អំឡុងវិបត្តិជំងឺកូវីដ-១៩៕

## ក្រសួងការងារ នឹងដាក់ក្រុមហ៊ុនឬបុគ្គលណា ជ្រើសរើសពលករទៅធ្វើការនៅអូស្ត្រាលី ចូលក្នុងបញ្ជីខ្មៅ

https://www.kampucheathmey.com/ ថ្ងៃចន្ទ ៨ វិច្ឆិកា ២០២១ដោយ Sorn Phanith

អ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការព្រមានដាក់ក្រុមហ៊ុនឬបុគ្គលទាំងឡាយណា ដែលផ្សព្វផ្សាយជ្រើសរើសពលករកម្ពុជាទៅធ្វើការផ្នែកកសិកម្មនៅអូស្ត្រាលីចូលក្នុងបញ្ជីខ្មៅមិនឱ្យធ្វើសេវាកម្មបាន ពេលគម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលីបើកដំណើរការ។ ការព្រមានរបស់អ្នកនាំពាក្យនេះ បានធ្វើឡើងបន្ទាប់ពីមានក្រុមហ៊ុនមួយចំនួននៅបន្តផ្សព្វផ្សាយពីការជ្រើសរើសពលករខ្មែរ ទៅធ្វើការផ្នែកកសិកម្មនៅប្រទេសអូស្ត្រាលី ខណៈកន្លងមកក្រសួងការងារ និងស្ថានទូតអូស្ត្រាលីបានប្រកាសបដិសេធរួចហើយពាក់ព័ន្ធនឹងបញ្ហានេះ ដើម្បីកុំឱ្យប្រជាពលរដ្ឋមានការភ័ន្តច្រឡំនិងចាញ់បោកបញ្ឆោតជនខិលខូច។

តាមរយៈទំព័រហ្វេប៊ុក លោក ហេង សួរ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានមានប្រសាសន៍ថា « សូមសាធារណជនជ្រាប និងសហការផ្តល់ព័ត៌មានដល់ក្រសួង ដើម្បីក្រសួងចាត់វិធានការ និងផ្តល់ព័ត៌មានដល់ភាគីអូស្ត្រាលី ដើម្បីដាក់ក្រុមហ៊ុន ឬបុគ្គលទាំងនោះចូលក្នុងបញ្ជីខ្មៅ មិនឲ្យធ្វើសេវាកម្មនេះ នៅពេលដែលឱកាសការងារនេះកើតមាន និងដាក់ឲ្យដំណើរការពិតប្រាកដ»។ លោកបាន ហេង សួរ ថា ទោះបីយ៉ាងណាក៏ដោយ មកដល់ម៉ោងនេះ និងយ៉ាងហោចណាស់ដល់ដំណាច់ឆ្នាំ២០២១នេះ គឺក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងរដ្ឋាភិបាលអូស្ត្រាលី មិនទាន់អនុញ្ញាតឲ្យមានការជ្រើសរើស និងបញ្ជូនពលរដ្ឋកម្ពុជាទៅធ្វើការនៅប្រទេសអូស្ត្រាលីនៅឡើយ។

លោក ហេង សួរ បានបញ្ជាក់បន្ថែមថា បច្ចុប្បន្ននេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកំពុងពិភាក្សាអំពីយន្តការ និងនីតិវិធីនៃការជ្រើសរើស, ប្រាក់បៀវត្ស និងអត្ថប្រយោជន៍សម្រាប់អ្នកស្វែងរកការងារធ្វើ, លក្ខខណ្ឌ ដែលនិយោជក និងរដ្ឋាភិបាលអូស្ត្រាលីតម្រូវលើអ្នកស្វែងរកការងារធ្វើ, និងលក្ខខណ្ឌ ដែលអ្នកស្វែងរកការងារធ្វើត្រូវសន្យា និងធានាថាខ្លួននឹងមិនរត់គេចធ្វើអន្តោប្រវេសន៍ខុសច្បាប់ ពេលទៅដល់ប្រទេសអូស្ត្រាលី។ លោក ហេងសួរ បានបន្តទៀតថា«កម្ពុជាបានជូនដំណឹងដល់រដ្ឋាភិបាលអូស្ត្រាលី អំពីការទទួលយកឱកាសការងារនៅអូស្ត្រាលីនេះ តាមរយៈឯកឧត្តមឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា Pablo Kang ក្នុងឱកាសដែលឯកឧត្តមបានជួបពិភាក្សាការងារ ជាមួយឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង កាលពីខែកញ្ញាកន្លងទៅនេះ។ ស្ថានទូតកម្ពុជាប្រចាំប្រទេសអូស្ត្រាលី ក៏កំពុងសហការស្វះស្វែងជួបពិភាក្សាការងារនេះជាមួយភាគីពាក់ព័ន្ធយ៉ាងសកម្មផងដែរ»។

សូមបញ្ជាក់ថា គម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលី (Australian AgricultureVisa) ត្រូវបានប្រកាសកាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២១ ក្នុងនោះអូស្ត្រាលីត្រូវការជ្រើសរើសពលករផ្នែកកសិកម្ម នេសាទនិងជលផលនិងឧស្សាហកម្មធនធានដើម។ គម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលីនេះ ស្រដៀងគ្នានឹងគម្រោងការងារប៉ាស៊ីហ្វិក (Pacific Labour Scheme) ដោយពលករក្រោមគម្រោងទិដ្ឋាការកសិកម្មអូស្ត្រាលីអាចធ្វើការបានរហូតដល់រយៈពេល ១ឆ្នាំ ដល់ ៣ឆ្នាំក្រោមការទទួលបន្ទុកដោយក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី។ **អត្ថបទ៖ សំអឿន**

## ឃាត់ខ្លួនមេខ្យល់២នាក់ប្រុងនាំពលករឆ្លងដែនទៅថៃ

https://www.khmertimeskh.com/ ខ្មែរថាមស៍ November 8, 2021

នគរបាល បានឃាត់ខ្លួនមុខសញ្ញា នាំពលករខ្មែរឆ្លងដែនល្មើសច្បាប់ចំនួន ២ នាក់ នៅក្នុងភូមិសាស្ត្រ ខេត្តបាត់ដំបង។ នគរបាលជំនាញ បានបញ្ជាក់ថា អនុវត្តតាមការណែនាំ របស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាល ខេត្តបាត់ដំបង ស្តីពីការការពារសន្តិសុខ តាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ នៅថ្ងៃទី ៧ ខែវិច្ឆិកា

ឆ្នាំ២០២១ នេះ កម្លាំងអង្គភាពចម្រុះ បានចុះបង្ក្រាប និងឃាត់ខ្លួន មេខ្យល់ចំនួន ២នាក់ដែលបម្រុងនាំពលករឆ្លងដែនល្មើសច្បាប់ ១ករណីនៅទីតាំងភូមិសាស្ត្រ ភូមិដំណាក់អំពិល ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

ជនសង្ស័យដែលនាំមនុស្សឆ្លងដែនខាងលើជាមេខ្យល់អ្នកនាំផ្លូវផង និងជាអ្នករត់ម៉ូតូឌុបផង ដែលទាំង ២ នាក់ មានឈ្មោះ នី ង៉ែត ភេទប្រុស អាយុ ៥៨ឆ្នាំ និងម្នាក់ទៀត ឈ្មោះ ញ៉ឹក ណយ ភេទប្រុស អាយុ ៥១ឆ្នាំ មានទីលំនៅ ភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខណៈប្រុងឆ្លងដែននាំពលករ ចំនួន ៣នាក់ ចូលទៅក្នុងទឹកដីថៃ ហើយក៏បានត្រូវសមត្ថកិច្ច ស្រាវជ្រាវចុះឃាត់ខ្លួនតែម្តង។ ពលករទាំង ៣ នាក់នោះ រស់នៅខេត្តបន្ទាយមានជ័យ និងខេត្តកំពត។ ក្រោយបង្ក្រាបទប់ស្កាត់បាន កម្លាំងការពារគោលដៅតំបន់ព្រំដែន បានសាកសួរ ដើម្បីស្រាវជ្រាវបន្ថែម ព្រមទាំងធ្វើកិច្ចសន្យា អប់រំណែនាំ ហើយបន្តនីតិវិធី ប្រគល់មុខសញ្ញាមេខ្យល់ ទាំងអស់ទៅឲ្យផ្នែកជំនាញនៃអធិការដ្ឋាននគរបាលស្រុកភ្នំព្រឹកដើម្បីចាត់ការតាមផ្លូវច្បាប់៕

## នគរបាលស្រុកសំពៅលូន ឃាត់ខ្លួនជនសង្ស័យជាមេខ្យល់បម្រុងនាំពលករឆ្លងដែនចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់ម្នាក់ និងពលករចំនួន ១២នាក់ទៀត

https://khmernote.com.kh/ November 8, 2021 srey nuch

ខេត្តបាត់ដំបង៖ យោងតាមការចុះផ្សាយរបស់ អធិការដ្ឋាននគរបាលស្រុកសំពៅលូន បានឲ្យដឹងថា ដោយអនុវត្តតាមមតិដឹកនាំរបស់ ឯកឧត្តម ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នឹងក្រោមការដឹកនាំបញ្ជាផ្ទាល់យ៉ាងយកចិត្តទុកដាក់របស់លោកវរសេនីយ៍ទោ ទឹម រិទ្ធ័យ អធិការនគរបាលស្រុកសំពៅលូន ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង ០០ និង ៥៥ នាទី នៅចំណុច ក្រុមទី០៧ ភូមិត្រពាំងព្រលិត ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន សហការជាមួយ កម្លាំងផ្នែកសឹករងស្រុកសំពៅលូន បង្ក្រាបករណី ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (បម្រុងចូលទៅក្នុងប្រទេសថៃ) ០១ ករណី បានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន ០១នាក់៖

១- ឈ្មោះ សុខ សំណាង ហៅ កូនង៉ា ភេទប្រុស អាយុ ៣៨ ឆ្នាំ មានទីលំនៅភូមិសាលាឆេះ ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ (ឃាត់ខ្លួនបាន)។

២-ឈ្មោះ ប៊ុនថេន ភេទប្រុស អាយុ ៣៨ ឆ្នាំ ស្នាក់ធ្វើការនៅប្រទេសថៃ (ឃាត់ខ្លួនមិនបាន)

៣- មិនស្គាល់អត្តសញ្ញាណ ភេទប្រុស អាយុប្រហែល ៣០ ឆ្នាំជាង មានទីលំនៅចំណុចបារាំងធ្លាក់ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ប្រើប្រាស់លេខទូរស័ព្ទ ០៩០ ៤៦៥ ៥១២ (ឃាត់ខ្លួនមិនបាន) បានធ្វើសកម្មភាព ទាក់ទងគ្នា លួចនាំពលករចំនួន ១២ នាក់ ស្រី ០៥ នាក់ រួមមាន៖

១.ឈ្មោះ ហ៊ុយ ធារី ភេទស្រី អាយុ ២៩ ឆ្នាំ

២. ឈ្មោះ ជឿន ផល្លី ភេទស្រី អាយុ ២២ ឆ្នាំ

៣. ឈ្មោះ ទិច សារិន ភេទស្រី អាយុ ៣០ ឆ្នាំ

៤. ឈ្មោះ លៀប ធួរ ភេទប្រុស អាយុ ៣៤ ឆ្នាំ នាក់ទាំងបួននាក់ មានទីលំនៅភូមិពពេល ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៥.ឈ្មោះ ឡា គីមឡាយ ភេទស្រីអាយុ ២១ ឆ្នាំ មានទីលំនៅភូមិអញ្ចាញ ឃុំសំរោង ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

៦.ឈ្មោះ សាមុត ប៊ុនឈឿត ភេទប្រុស អាយុ ៤៨ ឆ្នាំ មានទីលំនៅភូមិរហាល ឃុំរហាល ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៧.ឈ្មោះ ចិន្តា សៅណាក់ ភេទប្រុស អាយុ ១៨ ឆ្នាំ

៨.ឈ្មោះ ចិន្តា សៅឃីត ភេទប្រុស អាយុ ២១ ឆ្នាំ អ្នកទាំងពីរ មានទីលំនៅភូមិអ្នកតាឈរ ឃុំសំរោងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ

៩.ឈ្មោះ ចំរើន ទីហុង ភេទប្រុស អាយុ ៣៣ ឆ្នាំ ភូមិកោកោង ឃុំកោកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល

១០.ឈ្មោះ អ៊ុក សុម៉ាឡា ភេទប្រុស អាយុ ៣១ ឆ្នាំ មានទីលំនៅភូមិចុងខ្សាច់ សង្កាត់ ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

១១.ឈ្មោះ ភាព មករា ភេទប្រុស អាយុ ១៧ ឆ្នាំ

១២.ឈ្មោះ សុំា ស្រីពុំ ភេទស្រី អាយុ ១៦ ឆ្នាំ អ្នកទាំងពីរ មានទីលំនៅភូមិថ្មល់ទទឹង ឃុំមុខដា ស្រុករមាសហែក ខេត្តស្វាយរៀង ដោយយកប្រាក់ថ្លៃធ្វើដំណើរពីពលករ ក្នុងម្នាក់ ៦.៥០០ បាត ទៅ ១១.៥០០ បាត ។

បច្ចុប្បន្ន ករណីខាងលើ កម្លាំងជំនាញបានធ្វើការឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន ០១ នាក់ កសាងសំណុំរឿង ដើម្បីបញ្ជូនទៅការិយាល័យជំនាញខេត្តចាត់ការបន្តតាមនីតិវិធី។ ដោយឡែកពលករទាំង ១២ នាក់ សមត្ថកិច្ចយើងបាន ធ្វើការអប់រំណែនាំ និងឱ្យវិលត្រឡប់ទៅមូលដ្ឋានវិញ ៕

## ជនជាតិចិនម្នាក់ អះអាងថា ត្រូវគេឆបោកពីប្រទេសចិន ឱ្យមកធ្វើការនៅកម្ពុជា ដោយមានការគំរាមកំហែង និងបិទសិទ្ធិសេរីភាព ត្រូវកម្លាំងនគរបាលខេត្តពោធិ៍សាត់ ជួយសង្គ្រោះ

https://cen.com.kh/ Posted ByPen Srey NeatNovember 9, 2021

ពោធិ៍សាត់ ៖ ជនជាតិចិនម្នាក់បានអះអាងថា ត្រូវបានជនជាតិចិនដូចគ្នា ឆបោកពីប្រទេសចិន ឱ្យមកបម្រើការងារដោយខុសច្បាប់នៅក្រុមហ៊ុន Internet Investment Park នៅខេត្តពោធិ៍សាត់ ដែលនៅទីនោះមានការគំរាមកំហែង និងបិទសិទ្ធិសេរីភាពទៀតផង ហើយបុរសជនជាតិចិនរូបនេះ បានផ្ញើសារចូលក្នុងគេហទំព័រ facebook ផ្លូវការរបស់សម្តេចតេជោ ហ៊ុន សែន ដើម្បីស្នើសុំជួយអន្តរាគមន៍។

ក្រុមការងារប្រតិកម្មរហ័ស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានពិនិត្យឃើញមានជនជាតិចិនម្នាក់ដែលបានអះអាងថា ត្រូវបានជនជាតិចិនដូចគ្នា ឆបោកពីប្រទេសចិន ឱ្យមកបម្រើការងារដោយខុសច្បាប់នៅក្រុមហ៊ុន Internet Investment Park នៅខេត្តពោធិ៍សាត់ ដែលនៅទីនោះមានការគំរាមកំហែង និងបិទសិទ្ធិសេរីភាពទៀតផង ហើយបុរសជនជាតិចិនរូបនេះ បានផ្ញើសារចូលក្នុងគេហទំព័រ facebook ផ្លូវការរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយមានខ្លឹមសារដូចខាងក្រោម ÷ (បកប្រែក្រៅផ្លូវការ) សួស្តីសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ខ្ញុំគឺជាជនជាតិចិនម្នាក់ ត្រូវបានគេឆបោកពីប្រទេសចិន ឲ្យមកធ្វើការនៅក្រុមហ៊ុនវិនិយោគផ្នែកអ៊ីនធឺណិត (Internet Investment Park) នៅខេត្តពោធិ៍សាត់។ នៅទីនេះ មានគេឱ្យខ្ញុំកុហកអ្នកដទៃ ប៉ុន្តែខ្ញុំខ្លាចមិនហ៊ាននិយាយនោះទេ។ ខ្ញុំបានព្យាយាមស្វែងរកការសង្គ្រោះដោយសម្ងាត់ អស់រយៈពេលជាង ២ខែមកហើយ ប៉ុន្តែពុំទាន់មានដំណឹងនោះឡើយ។ បច្ចុប្បន្ន ខ្ញុំមានជំងឺធ្ងន់ធ្ងរ និងពុំអាចទៅធ្វើការបាននោះទេ ខ្ញុំបាត់បង់តម្លៃសម្រាប់ពួកគេហើយ ។ មនុស្សម្នាក់អ្នកដែលធ្លាប់បានកុហកខ្ញុំនោះ និយាយថានឹងលក់ខ្ញុំឱ្យទៅអ្នកដទៃ ...ខ្ញុំខ្លាចខ្លាំងណាស់ និងគ្មានជំនួយទេ។ ខ្ញុំសង្ឃឹមថាសម្តេច អាចជួយសង្គ្រោះខ្ញុំបាន។ បន្ទាប់ពីបានទទួលព័ត៌មាននេះ ក្រុមការងារប្រតិកម្មរហ័ស នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើចំណាត់ការករណីនេះ ជូនក្រុមការងារប្រតិកម្មរហ័សនៃស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ ដើម្បីជាសមត្ថកិច្ចក្នុងការអនុវត្តជំនាញ។

យោងតាមរបាយការណ៍បឋម ពីក្រុមការងារប្រតិកម្មរហ័ស នៃស្នងការដ្ឋាននគរបាលខេត្តពោធិ៍សាត់ បានបញ្ជាក់ថា អនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ ស ថេង ស្នងការនគរបាលខេត្តពោធិ៍សាត់ កាលពីព្រឹកថ្ងៃចន្ទ ទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្ត បានចុះទៅពិនិត្យផ្ទាល់ និងធ្វើការបំពេញនីតិវិធីជំនាញពាក់ព័ន្ធ ព្រមទាំងធ្វើការប្រគល់-ទទួល យកជនរងគ្រោះ ជាជនជាតិចិនម្នាក់ឈ្មោះ Xiong Liqiang អាយុ ២៣ឆ្នាំ នៅចំណុចក្នុងតំបន់សេដ្ឋកិច្ចពិសេសថ្មដា ស្ថិតនៅឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ ក្នុងកិច្ចប្រតិបត្តិការខាងលើ មានការសម្របសម្រួល និងចូលរួមដោយលោកព្រះរាជអាជ្ញាអមសាលាដំបូងខេត្តពោធិ៍សាត់ និងបុគ្គលតំណាងក្រុមហ៊ុនតំបន់សេដ្ឋកិច្ចពិសេសផងដែរ ។ ជនរងគ្រោះខាងលើ ត្រូវបានប្រគល់ជូនជំនាញផែនការងារអន្តោប្រវេសន៍ ដើម្បីអនុវត្តវិធានការជំនាញស្របតាមនីតិវិធី៕ រក្សាសិទ្ធិដោយ ៖ កូលាប

## ឃាត់ខ្លួនមេខ្យល់២នាក់ ជាប់ពាក់ព័ន្ធការរត់ពន្ធមនុស្ស ឆ្លងដែនខុសច្បាប់ទៅធ្វើការនៅប្រទេសថៃ !

https://cen.com.kh/ Posted ByPen Srey NeatNovember 9, 2021

ខេត្តបាត់ដំបង ៖ កម្លាំងសមត្ថកិច្ចគរបាលការពារព្រំដែនស្រុកសំពៅលូន សហការជាមួយទាហានការពារព្រំដែនកាលពីថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០២១ ឃាត់ខ្លួន ជនសង្ស័យចំនួន ២នាក់ ដែលជាមុខសញ្ញាមេខ្យល់ នាំមនុស្សឆ្លងដែនខុសច្បាប់ ចូលទៅប្រទេសថៃ និងឃាត់ខ្លួនពលករចំណាកស្រុកចំនួន៧នាក់ នៅចំណុចក្នុងភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ សមត្ថកិច្ចខេត្តបាត់ដំបង បានឲ្យដឹងថា មេខ្យល់២នាក់នេះ មាន៖ ទី១-ឈ្មោះ ហាច ផល ភេទប្រុស អាយុ៥៦ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។ និង ទី២-ឈ្មោះ ឈន រី ភេទប្រុស អាយុ៥៧ឆ្នាំ មានទីលំនៅភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។

ចំណែកឯ ពលករចំណាកស្រុកទាំង៧នាក់នោះ មានឈ្មោះ មាន ៖ ១- ឈ្មោះ ខៀវ ចន្ទ ភេទស្រី អាយុ ២៩ឆ្នាំ ឈ្មោះ រឹម និត ភេទប្រុស អាយុ២២ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ ២-ឈ្មោះ ថៃ គីមឡាង ភេទស្រី អាយុ២០ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ ៣-ឈ្មោះ ថៃ សុខឡាយ ភេទប្រុស អាយុ១៧ឆ្នាំ ។មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ ៤-ឈ្មោះ រស់ ប្រុស ភេទប្រុស អាយុ២១ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។ ៦-ឈ្មោះ យិន គង្គ ភេទប្រុស អាយុ១៨ឆ្នាំ មានទីលំនៅភូមិត្រពាំង ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង ។ និង ៧-ឈ្មោះគង់ សារ៉េន ភេទប្រុស អាយុ៣៣ឆ្នាំ មានទីលំនៅភូមិត្រពាំង ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង ។ បច្ចុប្បន្ននេះ ជនសង្ស័យទាំង២នាក់ ត្រូវបានបញ្ជូនទៅ អធិការដ្ឋាននគរបាលស្រុកសំពៅលូន ដើម្បីចាត់ការតាមនីតិវិធីនីតីច្បាប់។ ចំណែកឯ ពលករទាំង៧នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅឯមណ្ឌលសុខភាព។ ចន្ទា ភា

## ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១

## បញ្ជូនខ្លួនមេខ្យល់២នាក់ ទៅតុលាការ ជាប់ពាក់ព័ន្ធការរត់ពន្ធ មនុស្សឆ្លងដែន ខុសច្បាប់ ទៅធ្វើការ នៅប្រទេសថៃ

https://dap-news.com/national/ ByPH104 Posted on November 9, 2021

ភ្នំពេញ៖ សមត្ថកិច្ចនគរបាលស្រុកសំពៅលូន កាលពីថ្ងៃទី៩ ខែ វិច្ឆិកា ឆ្នាំ ២០២១នេះ បានចាប់ និង បញ្ជូនខ្លួន ជនសង្ស័យចំនួន២នាក់ ដែលជាមុខសញ្ញាមេខ្យល់ នាំមនុស្សឆ្លងដែនខុសច្បាប់ ចូលទៅប្រទេសថៃ ទៅកាន់សាលាដំបូងខេត្តបាត់ដំបង ដើម្បីធ្វើការសាកសួរ និង ចោទប្រកាន់ ជាប់ពាក់ព័ន្ធនឹងការរត់ពន្ធ ពលករចំណាកស្រុកចំនួន៧នាក់ ដោយខុសច្បាប់ ទៅធ្វើនៅ ក្នុងប្រទេសថៃ។ សមត្ថកិច្ចខេត្តបាត់ដំបង បានឲ្យដឹងថា មេខ្យល់ ២ នាក់នេះ មាន៖ ទី១-ឈ្មោះ ហាច ផល ភេទប្រុស អាយុ៥៦ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ។ និង ទី២-ឈ្មោះ ឈន រី ភេទប្រុស អាយុ៥៧ឆ្នាំ មានទីលំនៅភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ពួកគេត្រូវបានចាប់ខ្លួន កាលពីថ្ងៃទី៧ ខែ វិច្ឆិកា ២០២១ នៅចំណុចក្នុងភូមិសាស្ត្រ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។

ក្រោយឃាត់ខ្លួនពួកគេ, កម្លាំងសមត្ថកិច្ច ក៏បានឃាត់ ពលករចំណាកស្រុក ចំនួន៧នាក់ផងដែរ ក្នុងនោះ មានប្រុស ៥នាក់ និង ស្រី២នាក់។ ពលករចំណាកស្រុកទាំង៧នាក់ មានឈ្មោះ ៖

១- ឈ្មោះ ខៀវ ចន្ទ ភេទស្រី អាយុ២៩ឆ្នាំ ឈ្មោះ រឹម និត ភេទប្រុស អាយុ២២ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

២-ឈ្មោះ ថៃ គីមឡាង ភេទស្រី អាយុ២០ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

៣-ឈ្មោះ ថៃ សុខឡាយ ភេទប្រុស អាយុ១៧ឆ្នាំ មានទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

៤-ឈ្មោះ រស់ ប្រុស ភេទប្រុស អាយុ២១ឆ្នាំ ទីលំនៅភូមិទួលខ្ពស់ ឃុំភ្នំព្រឹក ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

៦- ឈ្មោះ យិន គង្គ ភេទប្រុស អាយុ១៨ឆ្នាំ មានទីលំនៅភូមិត្រពាំង ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង ។

និង ៧-ឈ្មោះគង់ សារ៉េន ភេទប្រុស អាយុ៣៣ឆ្នាំ មានទីលំនៅភូមិត្រពាំង ឃុំដូង ស្រុករមាសហែក ខេត្តស្វាយរៀង ។

បច្ចុប្បន្ននេះ ពលករទាំង៧នាក់ ត្រូវបានបញ្ជូនទៅធ្វើចត្តាឡីស័ក នៅឯមណ្ឌលសុខភាពស្រុកសំពៅលូន៕ ដោយ រស្មី អាកាស

## ថៃ មើលឃើញរលកនៃជនអន្តោប្រវេសន៍ខុសច្បាប់ ក្រោយបើកដំណើរការឡើងវិញ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១

(ថៃ)៖ ចាប់តាំងពីប្រទេសថៃបើកដំណើរការឡើងវិញ សម្រាប់ភ្ញៀវទេសចរបរទេស នៅថ្ងៃទី ១ ខែវិច្ឆិកា ជនអន្តោប្រវេសន៍ជាង ៣០០០ នាក់ត្រូវបានចាប់ខ្លួន ពីបទចូលប្រទេសដោយខុសច្បាប់ ដែលភាគច្រើនបានធ្វើដំណើរទៅរាជធានីបាងកក និងខេត្តជុំវិញ ដើម្បីស្វែងរកការងារធ្វើ។នេះបើយោងតាមការចុះ ផ្សាយរបស់សារព័ត៌មានCNAនៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០២១។ មន្ត្រីសន្តិសុខបាននិយាយថា អ្នកឆ្លងដែនខុសច្បាប់ភាគច្រើន

មកពីប្រទេសមីយ៉ាន់ម៉ា និងកម្ពុជា ហើយពួកគេត្រូវបានចាប់បានចូលតាមព្រំដែនភាគខាងជើង និងភាគឦសាន ដោយគ្មានឯកសារចូលត្រឹមត្រូវ ឬការពិនិត្យជំងឺកូវីដ-១៩ ត្រឹមត្រូវ។

អាជ្ញាធរនិយាយថា ជនអន្តោប្រវេសន៍បានបង់ប្រាក់ឱ្យអ្នកជួញដូរម្នាក់ ដើម្បីជួយពួកគេចូលក្នុងប្រទេសថៃ ហើយពួកគេកំពុងស្វែងរកការងារធ្វើនៅក្នុងរោងចក្រក្បែរទីក្រុងបាងកក។ មន្ត្រីសន្តិសុខបារម្ភថា ការចូលដោយគ្មានការធ្វើចត្តាឡីស័ក អាចបង្កឱ្យមានការរីករាលដាលនៃការឆ្លង នៅក្នុងប្រទេស ហើយអាជ្ញាធរកំពុងបង្កើនប៉ុស្តិ៍ត្រួតពិនិត្យ និងល្បាតតាមព្រំដែន៕ អត្ថបទ៖ សាន លីម៉ា

## ស្ថានអគ្គកុងស៊ុលកម្ពុជាចុះអន្តរាគមន៍ និង សង្គ្រោះ ពលករចំណាកស្រុកខ្មែរ ៣៤នាក់ នៅប្រទេសថៃ

https://cen.com.kh/ Posted ByPen Srey NeatNovember 9, 2021

ភ្នំពេញ ៖ មន្ត្រីស្ថានអគ្គកុងស៊ុល ប្រចាំនៅប្រទេសទេសថៃ បានឱ្យដឹងថា កាលពីថ្ងៃទី ៨ ខែវិច្ឆិកា ឆ្នាំ ២០២១ កន្លងទៅនេះ អាជ្ញាធរមានសមត្ថកិច្ចថៃ បានឃាត់ខ្លួនពលករខ្មែរ លួចឆ្លងដែនដោយខុសច្បាប់ ចំនួន៣៤ ទៀត ក្នុងនោះ មានប្រុស២០នាក់។ បន្ទាប់ពីទទួលបានព័ត៌មានភ្លាម, ស្ថានអគ្គកុងស៊ុលកម្ពុជា ក៏បានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើ មកមាតុប្រទេសវិញ កាលពីរសៀលថ្ងៃទី៩ ខែវិច្ឆិកា ២០២១ នេះ តាមច្រកទ្វារព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ បច្ចុប្បន្ននេះ , ពលករចំណាកស្រុកទាំងនោះ ត្រូវបានប្រគល់ជូនអាជ្ញាធរកម្ពុជា ពាក់ព័ន្ធ ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## រយៈពេល ២ ថ្ងៃ ទាហានថៃឃាត់ខ្លួនពលរដ្ឋខ្មែរ លួចឆ្លងដែនសរុប ៥៥ នាក់

https://www.gntimes.com/ ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១

បន្ទាយមានជ័យ៖ ពលរដ្ឋខ្មែរលួចឆ្លងដែនចូលទៅប្រទេសថៃ ត្រូវបានទាហានឈុតខ្មៅថៃ កងអនុសេនាធំ ១៣.០២ ឃាត់ខ្លួនជាបន្តបន្ទាប់សរុប ៥៥នាក់ (ស្រី១៩នាក់ ) នៅចំណុចភូមិ ថាប់ភិកណយ ឃុំថាប់ភិក និងភូមិខៅណយ ឃុំក្លងណាំសៃ ស្រុកអរញ្ញ ខេត្តស្រះកែវ ។

បើតាមប្រភពព័ត៌មានពីនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ ៨១៥ បានឲ្យដឹងថា៖ នៅវេលាម៉ោង០៤រសៀល ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ ទាហានឈុតខ្មៅថៃ កងអនុសេនាធំ ១៣.០២ ដែលឈរជើងទល់មុខប៉ុស្តិ៍ការពារព្រំដែនចំបក់ ក្នុងភូមិសាស្រ្ត ស្រុកម៉ាឡៃ បានផ្តល់ព័ត៌មានមកថា មានប្រជាពលរដ្ឋខ្មែរចំនួន ៣៤ នាក់ (ស្រី១៦នាក់) បានលួចឆ្លងដែនចូលទៅទឹកដីថៃ ហើយត្រូវបានឃាត់ខ្លួន។ ប្រជាពលរដ្ឋខ្មែរទាំង៣៤នាក់នេះ តាមការសួរនាំ គឺដើរចេញមកពីចំណុចភូមិគីឡូ៩ ស្រុកសំពៅលូន ខេត្តបាត់ដំបង ឆ្លងអូរចូលទឹកដីថៃ ។ ប្រភពដដែលបានបញ្ជាក់ថា៖ បន្ទាប់ពីបានឃាត់ខ្លួន ទាហានឈុតខ្មៅថៃអនុសេនាធំ ១៣.០២ បានបញ្ជូនប្រជាពលរដ្ឋទាំង ៣៤នាក់ ទៅអធិការដ្ឋាននគរបាលក្លងណាំសៃ ដើម្បីមានវិធានការបន្ត ។

នគរបាលវរសេនាតូចការពារព្រំដែនគោកលេខ ៨១៥ បានឲ្យដឹងទៀតថា៖ នៅវេលាម៉ោង០៣ និង៣០ នាទីទាបភ្លឺ ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ ទាហាន(ព្រាន)ឈុតខ្មៅថៃ កងអនុសេនាធំ ១២.០៣ ដែលឈរជើងទល់មុខប៉ុស្តិ៍ខ្លាងាប់ បានផ្តល់ព័ត៌មានពីការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរដែលលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួន១១នាក់(ស្រី០៣នាក់) ត្រូវបានឃាត់ខ្លួននៅចំណុចមាត់អូរព្រំដែន ក្នុងភូមិសាស្រ្តភូមិ ខៅណយ ឃុំក្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ។ បន្ទាប់ពីឃាត់ខ្លួនប្រជាពលរដ្ឋទាំង១១នាក់នោះ បានបញ្ជូនទៅអធិការដ្ឋាននគរបាលក្លងណាំសៃផងដែរ ដើម្បីមានវិធានការបន្ត៕ ដោយ៖ ចន្ទ្រា

## ថៃ គ្រោងបើកព្រំដែនទទួលពលករខ្មែរវិញ ដោយសារខ្វះកម្លាំងពលកម្ម

https://www.kampucheathmey.com/ ថ្ងៃពុធ ១០ វិច្ឆិកា ២០២១ដោយ Sok Sovann

ប្រទេសថៃ គ្រោងនឹងបើកព្រំដែនរបស់ខ្លួនឡើងវិញចំពោះកម្មករមកពីប្រទេសជិតខាងដូចជាកម្ពុជា មីយ៉ាន់ម៉ា និងឡាវ ក្នុងគោលបំណងបន្ធូរបន្ថយកង្វះខាតកម្លាំងពលកម្ម ដែលកំពុងប៉ះពាល់ដល់ការនាំចេញ និងសេដ្ឋកិច្ចដែលពឹងផ្អែកលើវិស័យទេសចរណ៍។

លោក Pairote Chotikasathien មកពីក្រសួងការងារបាននិយាយថា វិធានទាក់ទងនឹងស្ថានភាពរាំកសាំងសម្រាប់ពលករចំណាកស្រុក នីតិវិធីធ្វើចត្តាឡីស័ក និងការធ្វើតេស្តរកជំងឺកូវីដ-១៩ នឹងត្រូវសម្រេចនៅថ្ងៃពុធនេះ។ ឧស្សាហកម្មនាំចេញធំៗរបស់ប្រទេសថៃ ដូចជាអាហារ និងផលិតកម្មកៅស៊ូ គឺពឹងផ្អែកយ៉ាងខ្លាំងទៅលើពលករចំណាកស្រុក។ ប៉ុន្តែការត្រួតពិនិត្យព្រំដែនដ៏តឹងរ៉ឹង និងច្បាប់ធ្វើចត្តាឡីស័ក បានបញ្ឈប់ការធ្វើចំណាកស្រុកស្ទើរតែទាំងស្រុង។ លោក Pairote បានប៉ាន់ប្រមាណថា នៅពេលនេះ ប្រទេសថៃត្រូវការពលករបរទេសចំនួន ៤២០,០០០នាក់ ដែលភាគច្រើននៅក្នុងឧស្សាហកម្មសំណង់ ផលិតកម្ម និងអាហារសមុទ្រ។ ពលករជាច្រើនបានចាកចេញពីប្រទេសថៃ ខណៈខ្លួនប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ដ៏អាក្រក់បំផុត កាលពីដើមឆ្នាំនេះ ហើយពួកគេទាំងនោះមិនបានត្រឡប់មកវិញទេ។

គួរបញ្ជាក់ថា ប្រទេសថៃមានការឆ្លងជិត២លានករណី និងស្លាប់ចំនួន១៩,៧៦៤ នាក់ ដែលភាគច្រើនកើតឡើងក្រោយខែមេសា នៅពេលការឆ្លងវីរុសបំប្លែងខ្លួនត្រូវបានរកឃើញក្នុងជំរំពលករចំណាកស្រុក៕ *Vann Vann*

## ថៃបញ្ជូនពលរដ្ឋខ្មែរខុសច្បាប់ចំនួន ១៥នាក់

https://www.khmertimeskh.com/ Khmer Times November 10, 2021

អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជា លោក កុយ គួង មានប្រសាសន៍ថា អាជ្ញាធរថៃបានចាប់ខ្លួនពលករខ្មែរខុសច្បាប់ចំនួន១៥នាក់ ក្នុងនោះមានស្ត្រី៣នាក់កាលពីថ្ងៃទី០៨ ខែវិច្ឆិកា។ ក្រោយទទួលបានព័ត៌មានភ្លាមស្ថានអគ្គកុងស៊ុលកម្ពុជា បានអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរខាងលើ នៅយប់ថ្ងៃដដែល នៅច្រកព្រំដែនខេត្តបន្ទាយមានជ័យ ប្រគល់ឱ្យអាជ្ញាធរកម្ពុជា ចាត់ការតាមនិតិវិធី។

ក្រសួងការពារជាតិបាននិយាយថា ជនចំណាកស្រុកខុសច្បាប់ជាង ៣០,០០០ នាក់ត្រូវបាននិរទេសចាប់តាំងពីដើមឆ្នាំជាមួយនឹងចំនួនកើនឡើងមុនពេលការបើកប្រទេសឡើងវិញនៅថ្ងៃទី១ ខែវិច្ឆិកា។ ក្នុងចំណោម៣ម៉ឺននាក់នេះ មានពលករខ្មែរខុសច្បាប់រាប់ពាន់នាក់ដែលត្រូវបាននិរទេសចេញពីប្រទេសថៃ។ បញ្ហានេះបានកើតឡើងពេលដែលសេដ្ឋកិច្ចរបស់ប្រទេសថៃបើកចំហរ និងមានតម្រូវការពលករចំណាកស្រុក ដើម្បីបំពេញការងារដែលខ្វះកំលាំងពលកម្មជាច្រើននៅប្រទេសថៃ។ ពលករចំណាកស្រុកខ្មែរភាគច្រើនទៅធ្វើការក្នុងចំការផ្លែឈើ សំណង់ ធ្វើការផ្ទះ នេសាទ រោងចក្រកែច្នៃចំណីអាហារ និងវិស័យដែលពឹងផ្អែកលើកម្លាំងពលកម្មផ្សេងទៀត។

លោកឧត្តមសេនីយ៍ឯក Kongcheep Tantravanich អ្នកនាំពាក្យក្រសួងបាននិយាយថា អាជ្ញាធរសន្តិសុខកំពុងបង្កើនកិច្ចខិតខំប្រឹងប្រែងនៅតាមព្រំដែន ដើម្បីទប់ស្កាត់ការចូលខុសច្បាប់ និងសកម្មភាពឆ្លងដែនខុសច្បាប់ផ្សេងទៀត រួមទាំងការជួញដូរគ្រឿងញៀនផងដែរ។ លោកបន្តថា យោធាកំពុងសហការជាមួយប៉ូលិស និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្ក្រាបសកម្មភាពទាំងនេះ។ លោកបានមានប្រសាសន៍ថា ថៅកែក៏ត្រូវបានលើកទឹកចិត្តឱ្យសហការគ្នា ដោយមិនអោយជួលកម្មករចំណាកស្រុកខុសច្បាប់ ដែលប្រហែលជាមិនត្រូវបានធ្វើតេស្តរកមេរោគកូវីដ-១៩ ហើយមានហានិភ័យក្នុងការបង្កឱ្យមានការឆ្លងរីករាលដាលបន្ថែមទៀត។ Swift News/Bangkok Post

## កម្លាំងចម្រុះឃាត់ខ្លួនប្រជាពលរដ្ឋបម្រុងលួចឆ្លងដែនចំនួន៣០នាក់

http://nokorwatnews.com/ 09/11/2021

**ក្រុងប៉ោយប៉ែត៖** ប្រជាពលរដ្ឋខ្មែរចំនួន៣០នាក់ បម្រុងលួចឆ្លងដែនទៅប្រទេសថៃ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកម៉ាឡៃ ទប់ស្កាត់មិនឲ្យឆ្លងដែនដោយខុសច្បាប់ នៅវេលាម៉ោង០៧ និង៣០នាទីព្រឹក ថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២១ ត្រង់ចំណុចភូមិអភិវឌ្ឍន៍ ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយ មានជ័យ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកម៉ាឡៃ នៅវេលាម៉ោង០៧និង៣០នាទីព្រឹកថ្ងៃទី០៩ខែវិច្ឆិកា ឆ្នាំ២០២១ បានដើរល្បាតតាម បន្ទាត់ព្រំដែន ប្រទះឃើញប្រជាពលរដ្ឋខ្មែរចំនួន៣០នាក់ ស្រី១៥នាក់ បម្រុងលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ត្រូវបានកម្លាំងសមត្ថកិច្ចយើងធ្វើការទប់ស្កាត់មិនឲ្យពួកគាត់ឆ្លងដែនដោយខុសច្បាប់ ។ហើយ បានធ្វើការសួរនាំ និងធ្វើកិច្ចសន្យាដល់ពួកគាត់រួច ប្រគល់ទៅអធិការដ្ឋាននគរបាល ស្រុកម៉ាឡៃ ចាត់ការបន្តតាមនីតិវិធី ។

លោកមេបញ្ជាការ បានបន្តថា៖ នៅវេលាម៉ោង០៨ និង៤៥នាទី ថ្ងៃដដែល កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងផ្នែកសឹករងស្រុកម៉ាឡៃ កងអនុសេនាតូចទី៣ បានល្បាតក្នុងភូមិសាស្ត្រ និងឃាត់ខ្លួនជនសង្ស័យចំនួន ០១នាក់ ក្នុងករណីនាំមនុស្សឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ រួមនិងសម្ភារៈមួយចំនួនមាន៖ ១/-ម៉ូតូ០១គ្រឿង ម៉ាកWave ពណ៌-ស គ្មានស្លាកលេខ, ២/- ទូរស័ព្ទដៃ ០១គ្រឿង, ៣/-កាំបិត ០១ដើម ។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ថា៖ យុវជនដែលត្រូវបានឃាត់ខ្លួនឈ្មោះ ហៀត ហាក់ អាយុ ២៩ឆ្នាំ ទីលំនៅក្នុងភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ។តាមការសួរនាំជននេះ បានសារភាពថាខ្លួនគេធ្លាប់បានដឹកមនុស្សឆ្លងទៅប្រទេសថៃចំនួន ០២លើក រួចមកហើយ ។ដោយផ្អែកលើចម្លើយសារភាព ជនសង្ស័យនិងវត្ថុតាង ត្រូវបានប្រល់ទៅអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីចាត់វិធានការបន្តតាមនីតិវិធី៕

## កម្លាំងការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ទប់ស្កាត់ពលរដ្ឋបំរុងលួចឆ្លងដែនខុសច្បាប់៣នាក់

http://cambodiapolice.com/policekh/ 2:14 pm 7 វិច្ឆិកា 2021

ខេត្តបាត់ដំបង ៖ ប្រជាពលរដ្ឋ៣នាក់បម្រុងលួចឆ្លងដែន តាមមេខ្យល់២នាក់ ត្រូវបានកម្លាំងការពារសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ឃាត់ខ្លួននៅវេលាម៉ោង០៧ និង៣០នាទី ថ្ងៃអាទិត្យ ៣កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២១ ។

ពលរដ្ឋបម្រុងលួចឆ្លងដែនតាមមេខ្យល់នោះរួមមាន ៖

1/-ឈ្មោះ គុណ-ចំរើន ភេទស្រី អាយុ២០ ឆ្នាំ ទីលំនៅភូមិបឹងរាំង ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

2/-ឈ្មោះ ប៊ី-ចន្ធូ ភេទ ប្រុសអាយុ២០ឆ្នាំ ទីលំនៅភូមិគោកសំរោង ឃុំសឿ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ។

3/-ឈ្មោះ អ៊ុក-រដ្ឋ ភេទប្រុសអាយុ៥១ឆ្នាំ ទីលំនៅភូមិគោក ឃុំម្រោម ស្រុកអង្គរជ័យ ខេត្តកំពត ។

មុខសញ្ញាសង្ស័យនាំមនុស្សឆ្លងដែន (ជាអ្នករត់ម៉ូតូឌុបចំនួន០២នាក់) មានឈ្មោះនិងទីលំនៅដូចខាងក្រោម ៖

1/-ឈ្មោះ នី -ង៉ែត ភេទ ប្រុស អាយុ៥៨ឆ្នាំ ។

2/-ឈ្មោះ ញ៉ឹក-ណយ ភេទប្រុស អាយុ៥១ឆ្នាំ អ្នកទាំង០២ មានទីលំនៅភូមិអូរ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។

បន្ទាប់ពីទប់ស្កាត់កម្លាំងបានសាកសួរ កត់ឈ្មោះ ធ្វើកំណត់ហេតុនិងកិច្ចសន្យាអប់រំណែនាំ រួចបានប្រគល់បងប្អូនទាំងអស់ឲ្យទៅកម្លាំងជំនាញនៃអធិការដ្ឋាននគរបាលស្រុកភ្នំព្រឹកចាត់ការបន្តតាមនីតិវិធី៕

## ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១

### ជប៉ុនចាប់ផ្តើមធ្វើតេស្តជំនាញពលករខ្មែរ ទៅធ្វើការនៅប្រទេសជប៉ុន

https://www.kampucheathmey.com/ ថ្ងៃពុធ ១០ វិច្ឆិកា ២០២១ដោយ Dy Bunnara

ភ្នំពេញ៖ ជប៉ុនបានចាប់ផ្តើមធ្វើតេស្តជំនាញ និងភាសាជប៉ុនសម្រាប់ពលករខ្មែរជំនាញផ្នែកកសិកម្ម និងសេវាកម្ម ដើម្បីបញ្ជូនទៅធ្វើការនៅប្រទេសជប៉ុននាពេលខាងមុខនេះ។

លោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានឲ្យដឹងថា អង្គភាពទទួលបន្ទុកការធ្វើតេស្តជំនាញ និងតេស្តភាសាជប៉ុន នឹងរៀបចំការធ្វើតេស្តជំនាញនិងភាសាជប៉ុន សម្រាប់ពលករខ្មែរជំនាញផ្នែកកសិកម្មនិងភោជនីដ្ឋាន ដើម្បីទៅធ្វើការនៅប្រទេសជប៉ុននាពេលខាងមុខ។ នៅក្នុងសេចក្តីជូនដំណឹងស្តីពីការធ្វើតេស្តជំនាញនិងភាសាជប៉ុន សម្រាប់ពលករជំនាញចុះថ្ងៃទី១០ វិច្ឆិកានេះ លោករដ្ឋមន្ត្រីបានបន្តថា ការធ្វើតេស្តជំនាញនិងភាសាជប៉ុន សម្រាប់ផ្នែកកសិកកម្មគឺធ្វើឡើងនៅសាកលវិទ្យាល័យអន្តរជាតិនៅថ្ងៃទី១២វិច្ឆិកា។ នៅមណ្ឌលសកលវិទ្យាល័យប៊ែលធីសាខាទួលស្លែងចាប់ពីថ្ងៃទី២៤ដល់២៧ វិច្ឆិកា និងចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៥ធ្នូ នៅមណ្ឌលវិទ្យាស្ថានអភិវឌ្ឍន៍វិស័យអប់រំ ដែលមានអាសយដ្ឋាននៅសង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

លោករដ្ឋមន្ត្រីបានបន្តទៀតថា ជំនាញភោជនីដ្ឋានវិញធ្វើតេស្តនៅសាកលវិទ្យាល័យអន្តរជាតិនៅថ្ងៃទី១២វិច្ឆិកានិងថ្ងៃទី ២៤ ដល់ថ្ងៃទី២៧វិច្ឆិកា និងថ្ងៃទី០១ដល់ថ្ងៃទី០៥ធ្នូ និងថ្ងៃទី០៩ដល់ថ្ងៃទី១១ធ្នូនៅមណ្ឌលសកលវិទ្យាល័យប៊ែលធីសាខាទួលស្លែង។ លោករដ្ឋមន្ត្រីបានបន្ថែមទៀតថា ចំពោះការចុះឈ្មោះធ្វើតេស្តជំនាញ និងភាសាជប៉ុនបេក្ខជនត្រូវបង់ប្រាក់តម្លៃ៣៣ដុល្លារអាមេរិក ដោយបេកជនមានអាយុចាប់ពិ១៧ឆ្នាំឡើងទៅ ដោយមិនគិតពីកម្រិតវប្បធម៌ឡើយ និងត្រូវភ្ជាប់មកជាមួយឯកសារមួយចំនួនដូចជាអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬប័ណ្ណបើកបរ។ លោករដ្ឋមន្ត្រីបានបញ្ជាក់ថា ការបរិច្ឆេទនៃការធ្វើតេស្តនេះ អាចនឹងផ្លាសប្តូរអាស្រ័យទៅលើស្ថានភាពជំងឺកូវីដ១៩៕ អត្ថបទ៖ សំអឿន

### ៩ខែឆ្នាំនេះ ពលករខ្មែរជាង៣៥00នាក់ត្រូវបានជួយសង្គ្រោះ បន្ទាប់ពីពួកគេលួចឆ្លងដែនខុសច្បាប់ទៅថៃ

https://www.vodkhmer.news/ លោក យុត សុគន្ធ| ០៩ វិច្ឆិកា ២០២១ម៉ោង ១៨:២៦

មន្ត្រីជាន់ខ្ពស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានឱ្យដឹងថា ក្នុងរយៈពេល៩ខែ នៃឆ្នាំ២០២១នេះ អាជ្ញាធរកម្ពុជាបានជួយសង្គ្រោះពលករខ្មែរបានជាង៣៥០០នាក់ បន្ទាប់ពីពួកគេបានលួចឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ។ អ្នកនាំពាក្យក្រសួងការបរទេស លោក កុយ គួង ប្រាប់ វីអូឌី នៅថ្ងៃអង្គារនេះថា ពលរដ្ឋខ្មែរដែលលួចឆ្លងដែនដោយខុសច្បាប់ជាង៣៥០០នាក់ ដែលត្រូវសមត្ថកិច្ចថៃចាប់និងជួយ

សង្គ្រោះមកកម្ពុជាវិញនោះ ភាគច្រើនជាពលករដដែលៗ។ អ្នកនាំពាក្យរូបនេះបន្តថា អាជ្ញាធរកម្ពុជាតែងតែណែនាំ និងជួយពន្យល់ដល់ពលករទាំងនោះអំពីផ្លូវច្បាប់ និងបញ្ហាប្រឈមនានាពេលដែលពួកគេលួចឆ្លងដែនខុសច្បាប់ ប៉ុន្តែពួកគេមិនបានស្តាប់ ហើយនៅតែបន្តលួចឆ្លងដែនទៅប្រទេសថៃម្តងហើយម្តងទៀត។ លោកបន្ថែមថា៖ «**ពេលដែលជួយសង្គ្រោះបាន អគ្គកុងស៊ុលយើងតែងតែនិយាយពន្យល់ពួកគាត់ និងបានជួយសង្គ្រោះដោយបញ្ជូនគាត់ត្រលប់មកវិញ។ ពេលខ្លះឃើញគាត់ត្រលប់ទៅវិញទៀត គេឃាត់ខ្លួនទៀតទៅ។ ពេលខ្លះ ច្រើនជាពលករដដែលទេ**»។ បើតាមលោក កុយ គួង កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១នេះ អាជ្ញាធរថៃបានឃាត់ខ្លួនពលករខ្មែរចំនួន ៤៩នាក់ដែលលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ហើយស្ថានអគ្គកុងស៊ុលកម្ពុជាបានចុះទៅជួយអន្តរាគមន៍និងបញ្ជូនពួកគេមកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអូរបីជាន់ និងច្រកទ្វារព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីយប់ថ្ងៃដដែល និងនៅរសៀលថ្ងៃទី៩ ខែវិច្ឆិកានេះ។

មន្ត្រីគម្រោងនៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (សង់ត្រាល់) ប្រចាំប្រទេសថៃ លោក លឹង សុផុន មានប្រសាសន៍ថា កត្តាដែលជំរុញពលករខ្មែរបន្តប្រថុយប្រថានឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃទាំងខុសច្បាប់ គឺដោយសារជីវភាពរបស់ពួកគេក្រីក្រ កង្វះការងារនៅក្នុងស្រុក ប្រាក់ឈ្នួលការងារនៅក្នុងស្រុកតិចពេក និងការអូសទាញពីមេខ្យល់ ជាដើម។ លោកផ្តល់ជាយោបល់ថា៖ «**ខ្ញុំយល់ឃើញថា ដើម្បីកុំឱ្យបងប្អូនប្រថុយប្រថានគ្រោះថ្នាក់ដូចពេលនេះ គឺរដ្ឋាភិបាលនៃប្រទេសទាំងពីរគួរមានវិធានការណាមួយ ដើម្បីសម្របសម្រួលដល់បងប្អូនពលករខ្មែរយើងដែលចំណាកស្រុកមករកការងារធ្វើនៅប្រទេសថៃហ្នឹង ឱ្យពួកគាត់មានសុវត្ថិភាព កុំឱ្យពួកគាត់មានបញ្ហា ដូចជាគេចាប់ដូចបច្ចុប្បន្ននេះ។ មួយវិញទៀត គួរតែធ្វើច្បាប់ណាមួយឱ្យពួកគាត់បានចូលមកដោយស្របច្បាប់។ យើងឃើញហើយ រហូតមកដល់ពេលនេះ មិនទាន់មានវិធានការណាមួយ ដើម្បីជួយឱ្យពួកគាត់ចូលមកដោយស្របច្បាប់នៅឡើយទេ នៅអំឡុងពេលជំងឺកូវីដ-១៩នេះ**»។

សង្គមស៊ីវិលដែលធ្វើការផ្តោតលើសិទ្ធិពលករចំណាកស្រុក ក៏ធ្លាប់បានលើកឡើងកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១ដែរថា កង្វះខាតការងារក្នុងស្រុក និងតម្រូវការកម្លាំងពលកម្មនៅក្នុងប្រទេសថៃ ស្របពេលរដ្ឋាភិបាលថៃផ្តល់ភាពស្របច្បាប់ដល់ពលករអន្តោប្រវេសន៍ជាថ្មីផងនោះ កំពុងជំរុញកំណើនពលករខ្មែរឱ្យប្រថុយប្រថានឆ្លងដែនទៅរកការងារធ្វើក្នុងប្រទេសថៃ។ បើតាមប្រភពពីក្រសួងការបរទេសកម្ពុជាវិញ ឱ្យដឹងកន្លងមកថា មានពលរដ្ឋខ្មែរប្រមាណ១លាននាក់ កំពុងរស់នៅនិងធ្វើការក្នុងប្រទេសថៃ។ តួលេខនេះ គឺតិចជាងការប៉ាន់ប្រមាណរបស់អង្គការសង់ត្រាល់ ដែលថា ពលរដ្ឋខ្មែរប្រមាណជិត២លាននាក់កំពុងរស់នៅនិងធ្វើការក្នុងប្រទេសក្បែរខាងកម្ពុជាមួយនេះ ទាំងស្របច្បាប់ និងមិនស្របច្បាប់៕

## ពលករខ្មែរ៣៧នាក់អស់លុយហើយ មេខ្យល់យកទៅប្លុងចោលក្នុងព្រៃត្រូវទាហានឈុតខ្មៅថៃ ឃាត់ខ្លួន

https://www.kampucheathmey.com/ ថ្ងៃពុធ ១០ វិច្ឆិកា ២០២១ ដោយ Kang Tola

បន្ទាយមានជ័យ ៖ ពលករខ្មែរ៣៧នាក់អត់បាយអត់ទឹកនៅពេញព្រៃក្នុងទឹកដីថៃ ក្នុងនោះអស់លុយហើយ ថៃមទាំងចាញ់បោកមេខ្យល់យកទៅប្លុងចោលក្នុងព្រៃត្រូវទាហានឈុតខ្មៅនៃកងអនុសេនាធំលេខ១២.០៦របស់ថៃ ឃាត់ខ្លួនបាននៅវេលាម៉ោង៨និង៣០នាទីយប់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១ ត្រង់ចំណុចសយស៊ី (សយ៤) ក្នុងភូមិសាស្ត្របានណូន ឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ទល់មុខភូមិសាស្ត្រ ភូមិបន្ទាយទី២ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ ៨១៥ បានឲ្យដឹងថា នៅវេលាម៉ោង៨ព្រឹក ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ ទាហានព្រានឈុតខ្មៅថៃកងអនុសេនាធំលេខ១២.០៦ បានផ្តល់ព័ត៌មានមកថា ក្រុមរបស់ខ្លួនបានឃាត់ខ្លួនប្រជាពលរដ្ឋខ្មែរចំនួន៣៧នាក់ក្នុងនោះមាន ស្រី១៩នាក់ បានលួចឆ្លងដែនទៅរកការងារនៅប្រទេសថៃដោយខុសច្បាប់ក្នុងភូមិសាស្ត្របានណួន ឃុំផានសឹក ស្រុកអារញ្ញ។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា ក្រោយពីឃាត់ខ្លួនប្រជាពលរដ្ឋទាំងនោះ ត្រូវបានទាហានឈុតខ្មៅថៃកងអនុសេនាធំលេខ១២.០៦ បានបញ្ជូនទៅអធិការដ្ឋាននគរបាលក្លងណាំសៃដើម្បីមានវិធានការបន្ត។ លោកវរសេនីយ៍ឯក សួង សៅ បានបញ្ជាក់ឲ្យដឹងបន្តទៀតថា ពលករទាំង៣៧នាក់នោះ បាននិយាយថា ក្រុមខ្លួនបានចាញ់បោកមេខ្យល់ថា និងជូនក្រុមខ្លួនទៅប្រទេសថៃដើម្បីរកការងារធ្វើក្នុងការជូននោះបង់ឲ្យមេខ្យល់ជូនក្នុងម្នាក់ ១.០០០បាត ក្រោយពីជូនដល់ចំណុចក្នុងទឹកដីថៃព្រំដែន កម្ពុជាថៃ ដោយឃើញមានទាហានឈុតខ្មៅនៃកងអនុសេនាធំលេខ១២.០៦របស់ថៃកំពុងល្បាតតាមព្រំដែនមេខ្យល់ក៏គេចខ្លួនបាត់។ លោកបានធ្វើការអំពាវនាវដល់បងប្អូនពលករទាំងអស់ គួរឲ្យគិតនិងពិចារណាឲ្យបានដិតដល់មុននិងឲ្យមេខ្យល់ជូនទៅថៃ ព្រោះមេខ្យល់ជូនឆ្លងដែន ខុសច្បាប់ ទាំងប្រថុយប្រថានផងដែរ៕ *ដោយ ៖ រ៉ន ណាង*

## អត្ថាធិប្បាយ៖ ហេតុអ្វីពលរដ្ឋខ្មែរ នៅបន្តឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ?

https://kohsantepheapdaily.com.kh/ ភ្នំពេញ ១០ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ២២:២៥

ខេត្តបន្ទាយមានជ័យ៖ ទោះបីជាក្នុងពេលឆ្លងរាលដាលកូវីដ១៩ ហើយរហូតដល់ពេលនេះ កូវីដមិនទាន់បាត់ឆ្លង ទាំងនៅកម្ពុជា និងទាំងនៅប្រទេសថៃ ក៏ប៉ុន្តែប្រជាពលរដ្ឋខ្មែរយើងច្រើននាក់ នៅតែបន្តលួចឆ្លងដែនខុសច្បាប់។ ការប្រថុយនឹងគ្រោះថ្នាក់ ទាំងផ្លូវច្បាប់ និងទាំងការឆ្លងជំងឺកូវីដ១៩ តាមរយៈការលួចឆ្លងដែនខុសច្បាប់នេះ គឺមានបំណង ដើម្បីទៅរកការងារធ្វើ ក្នុងទឹកដីថៃ។

កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រជាពលរដ្ឋខ្មែរចំនួន ៣០នាក់ ដែលបម្រុងលួចឆ្លងដែន ទៅប្រទេសថៃ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាផ្នែកសឹករងស្រុកម៉ាឡៃ ទប់ស្កាត់មិនឲ្យឆ្លងដែនដោយខុសច្បាប់នោះទេ។ អ្នកទាំងនោះ ត្រូវបានឃាត់ខ្លួន នៅវេលាម៉ោង ៧ និង ៣០នាទី ព្រឹកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១ នៅភូមិអភិវឌ្ឍន៍ ឃុំទួលពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ក្រោយមកបន្តិច កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ ក៏សហការជាមួយកម្លាំងផ្នែកសឹករងស្រុកម៉ាឡៃ កងអនុសេនាតូចទី៣ បានល្បាតក្នុងភូមិសាស្ត្រ និងឃាត់ខ្លួនជនសង្ស័យ ម្នាក់ទៀត ជាមេខ្យល់ ក្នុងករណីនាំមនុស្សឆ្លងដែនខុសច្បាប់ ទៅប្រទេសថៃ។ មេខ្យល់រូបនេះ បានសារភាពថា ខ្លួនគេធ្លាប់បានដឹកមនុស្សឆ្លងដែន ទៅប្រទេសថៃ ចំនួន ២លើករួចមកហើយ។

ដោយឡែក នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រជាពលរដ្ឋខ្មែរ ដែលបានលួចឆ្លងដែន ចូលទៅប្រទេសថៃដោយខុសច្បាប់ ត្រូវបានទាហានឈុតខ្មៅថៃ ឃាត់ខ្លួនជាបន្តបន្ទាប់ សរុបចំនួន ៥៥នាក់ (ស្រី ១៩នាក់)។ ពលរដ្ឋខ្មែរទាំងនោះ ត្រូវបានថៃ ចាប់ខ្លួន នៅភូមិថាប់ភិកណយ ឃុំថាប់ភិក និងភូមិខៅណយ ឃុំក្លងណាំសៃ ស្រុកអរញ្ញ ខេត្តស្រះកែវ ជាប់ព្រំដែនកម្ពុជា ក្នុងខេត្តបន្ទាយមានជ័យ និងក្នុងខេត្តបាត់ដំបង។ ដំណឹងនៃការចាប់ឃាត់ខ្លួនពលរដ្ឋខ្មែរ លួចឆ្លងដែនខុសច្បាប់ចេញចូលទឹកដីថៃ ដើម្បីស្វែងរកការងារធ្វើនេះ បានកើតឡើងយូរមកហើយ ពិសេសទោះជាក្នុងពេលកូវីដ ឆ្លងរាតត្បាតខ្លាំង ទាំងនៅកម្ពុជាយើង និងទាំងនៅប្រទេសថៃ ក៏ដោយ។ នៅពេលនេះទៀត កូវីដមិនទាន់បាត់ឆ្លងផង ក៏មានពលរដ្ឋខ្មែរយើងទាំងក្រុមៗ បន្តលួចឆ្លងដែន ចូលប្រទេសថៃ ហើយទោះជាមានអ្នកឆ្លងប៉ារាស់រួចពីទឹកដីកម្ពុជាយើង តែក៏នៅត្រូវអាជ្ញាធរសមត្ថកិច្ចថៃ ស្ទាក់ចាប់បានច្រើននាក់។

ការបន្តផ្សងព្រេង ប្រថុយនឹងគ្រោះថ្នាក់ ទាំងឆ្លងកូវីដ និងទាំងគ្រោះថ្នាក់ផ្លូវកាយ ដល់អាយុជីវិតផងនេះ ក៏ដើម្បីតែរកការងារធ្វើ បានប្រាក់ចិញ្ចឹមគ្រួសារ។ ការងារនៅប្រទេសថៃ ទទួលកម្រៃច្រើនជាងនៅស្រុកយើង ហើយនៅថៃ ក៏សំបូរការងារធ្វើ ខណៈដែលអ្នកឆ្លងដែនទាំងនោះ រកការងារមិនបានធ្វើ ឬក៏មិនធ្វើការងារក្នុងស្រុក ដែលទទួលកម្រៃតិចជាង នៅប្រទេសថៃ ជាដើម។ ពេលនេះ ទោះជាត្រូវប្រឈមនឹងការឆ្លងកូវីដ តែក្រុមអ្នកឆ្លងដែនសុខចិត្តប្រថុយ ជាជាងស្លាប់ ដោយសារតែមិនមានចំណូល និងមិនមានការងារធ្វើ បើបន្តដេកនៅស្រុកកំណើត។ ម្យ៉ាងការលួចឆ្លងដែននេះ ម្នាក់ៗ ត្រូវចំណាយលុយឲ្យមេខ្យល់ ដែលជាអ្នកនាំផ្លូវប្រមាណ ៥០០០បាត ស្មើប្រមាណ ១៥០ដុល្លារ ក្នុងម្នាក់ៗ ថែមទៀត។

ដូច្នេះដើម្បីដោះស្រាយករណីពលរដ្ឋខ្មែរលួចឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃនេះ ទាមទារឲ្យអាជ្ញាធរសមត្ថកិច្ច ពិសេសរាជរដ្ឋាភិបាល ដាក់ចេញនូវផែនការច្បាស់លាស់ ដោះស្រាយ និងបង្កើតការងារធ្វើនៅតាមស្រុកភូមិ ឲ្យកាន់តែច្រើនជាងសព្វថ្ងៃ។ រីឯការងារ និងមុខរបរមួយចំនួន ពិសេសការងារប្រើកម្លាំង ដូចជាការងារសំណង់ ធ្វើស្រែចំការ ការងារក្នុងវិស័យកសិកម្ម និងឧស្សាហកម្ម ដែលមិនត្រូវការជំនាញ ជាដើម ត្រូវចេញច្បាប់ហាមឃាត់ មិនឲ្យជនបរទេស ធ្វើឡើយ។ ទុកការងារទាំងនេះ សម្រាប់ប្រជាពលរដ្ឋខ្មែរ។ ប្រាក់ឈ្នួល ក៏ត្រូវទទួលបានសមរម្យ ដោយមិនចាំបាច់ដល់ថ្នាក់ដូចការងារក្នុងប្រទេសថៃទេ តែក្រោមបន្តិចបន្តួច ក៏បានដែរ។

មួយវិញទៀត អាជ្ញាធរសមត្ថកិច្ចយើង បើថា មិនអាចបង្កើតការងារឲ្យច្រើននៅតាមស្រុកភូមិទេ ក៏ត្រូវតែរៀបចំធ្វើយ៉ាងណា ឲ្យពលរដ្ឋខ្មែរយើង ដែលឆ្លងដែនទៅធ្វើការនៅក្រៅប្រទេស ពិសេសនៅប្រទេសថៃ ត្រូវចេញចូលដោយស្របច្បាប់។ ពោលគឺចុះស្រង់តាមស្រុកភូមិ តាមខ្នងផ្ទះតែម្តង ចំពោះអ្នកចង់ទៅធ្វើការនៅក្រៅប្រទេស ត្រូវរៀបចំឲ្យមានលិខិតឆ្លងដែន និងប័ណ្ណអនុញ្ញាតឲ្យធ្វើការតែម្តង ដោយសហការជាមួយភាគីថៃ។ ធ្វើដូច្នេះ យើងអាចគ្រប់គ្រងអ្នកឆ្លងដែន ហើយក្នុងពេលកូវីដនេះ ក៏យើងអាចការពារ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺបាន តាមរយៈការចេញចូលតាមច្រកព្រំដែនផ្លូវការ និងឆ្លងកាត់ការត្រួតពិនិត្យ និងការធ្វើចត្តាឡីស័កត្រឹមត្រូវ។

កន្លងមក ដោយសារតែបែបបទនៃការធ្វើលិខិតឆ្លងដែន និងប័ណ្ណការងារ លំបាក ហើយចំណាយលុយច្រើន គួបផ្សំនឹងពលរដ្ឋមួយចំនួន មិនយល់ដឹងផង ក៏កើតជាការលួចលាក់ឆ្លងដែន ដែលប្រឈមនឹងគ្រោះថ្នាក់ផ្លូវកាយ សន្តិសុខផង និងពិសេសប្រឈមនឹងការឆ្លងកូវីដថែមទៀត។ រីឯការគ្រប់គ្រងអ្នកចំណាកស្រុកទាំងនោះ ក៏លំបាក និងមិនអាចទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ១៩ បានឡើង បើមានអ្នកលួចឆ្លងដែនដូច្នេះ។ ដោយឡែកពលរដ្ឋខ្មែរ អ្នកឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ក៏ត្រូវតែបញ្ឈប់ការលួចលាក់ ឆ្លងដែនខុសច្បាប់ ឬទៅតាមគ្នា តាមមេខ្យល់។ រកវិធីចូលធ្វើការដោយស្របច្បាប់ តាមរយៈទីភ្នាក់ងារក្រុមហ៊ុន ឬក៏អាជ្ញាធរសមត្ថកិច្ច នៅតាមខេត្តជាប់ព្រំដែន ដោយត្រូវមានលិខិតឆ្លងដែន និងបណ្ណធ្វើការងារត្រឹមត្រូវ។ បើបន្តទៅលួចលាក់ខុសច្បាប់ទៀត មិនត្រឹមតែប្រឈមគ្រោះថ្នាក់ទេ តែអស់ទាំងលុយ ហើយបើត្រូវអាជ្ញាធរសមត្ថកិច្ចព្រំដែនទាំងខាងខ្មែរយើង និងទាំងនៅខាងប្រទេសថៃ ស្ទាក់ចាប់បាន ដូចព័ត៌មានចុះផ្សាយជាហូរហែ គឺទៅមិនដល់កន្លែងធ្វើការ តែត្រូវអស់លុយដែលបានបង់ឲ្យមេខ្យល់។ ម្យ៉ាងទៀត ក៏គួរតែរកការងារធ្វើក្នុងស្រុក ដែលសព្វថ្ងៃ មិនថា ក្នុងវិស័យសំណង់ ឬក៏វិស័យកសិកម្មនោះទេ គឺយើងកំពុងខ្វះខាតកម្លាំងពលកម្ម ហើយតម្លៃឈ្នួល ទោះជាស្រុកយើង មិនបានថ្លៃដូចនៅប្រទេសថៃ ក៏គួរតែធ្វើការនៅក្នុងស្រុក ប្រសើរជាងលួចឆ្លងដែនទៅថៃ ដូចពាក្យចាស់លោកថា ជួញជិត ជាជាងជួញឆ្ងាយ៕

## ប្រទេសថៃផ្តល់ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដល់ពលករចំណាកស្រុកកម្ពុជា

https://www.khmertimeskh.com/ Khmer Times November 11, 2021

រដ្ឋមន្ត្រីរដ្ឋាភិបាលបាននិយាយកាលពីថ្ងៃពុធថា អាជ្ញាធរនឹងត្រៀមវ៉ាក់សាំងបង្ការកូវីដ-១៩ ដល់ទៅ ៥០០,០០០ ដូស សម្រាប់ពលករបរទេស ខណៈដែលខ្លួនរៀបចំស្វាគមន៍ពួកគេត្រឡប់ចូលប្រទេសថៃវិញ ដើម្បីជួយសម្រាលការខ្វះខាតកម្លាំងពលកម្ម។ រដ្ឋាភិបាលគ្រោងអនុញ្ញាតឲ្យកម្មករមកពីប្រទេសជិតខាងមានដូចជា កម្ពុជា មីយ៉ាន់ម៉ា និងឡាវ ចូលប្រទេសវិញនៅដើមខែក្រោយ ហើយបំពេញការខ្វះខាតកំលាំងពលកម្មក្នុងឧស្សាហកម្មនាំចេញធំៗ ដូចជាចំណីអាហារ និងផលិតកម្មកៅស៊ូ។

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បាននិយាយថា កម្មករនឹងត្រូវធ្វើចត្តាឡីស័ករយៈពេលពីរសប្តាហ៍ ហើយក្នុងអំឡុងពេលនោះ វ៉ាក់សាំងនឹងត្រូវបានរៀបចំចាក់ជូនពួកគាត់។ ពួកគាត់ក៏នឹងត្រូវធ្វើតេស្តរកជំងឺកូវីដ-១៩ផងដែរ។ លោកបានថ្លែងថា៖ «យើងបានត្រៀមវ៉ាក់សាំងពី ៤០០, ០០០ ទៅ ៥០០,០០០ ដូសដើម្បីចាក់ដល់ពលករចំណាកស្រុក។ ក្រសួងការងារប៉ាន់ប្រមាណថាមានតម្រូវការបន្ទាន់សម្រាប់ពលករចំណាកស្រុកចំនួន៤២០,០០០ នាក់ ។ រដ្ឋាភិបាលបាននិយាយថា ការបន្ធូរបន្ថយការគ្រប់គ្រងក៏នឹងជួយបញ្ឈប់ការរត់ពន្ធកម្មករផងដែរ។ មនុស្សជិត១១,០០០ នាក់ត្រូវបានចាប់ខ្លួននៅក្នុងករណីដែលពាក់ព័ន្ធនឹងការរត់ពន្ធកាលពីខែមុន ធៀបនឹងការចាប់ខ្លួនចំនួន ១,៤៥៦ ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ប្រភព: Bangkokpost

## រឿង៣យ៉ាង ពលករខ្មែរត្រូវដឹង ពេលត្រឡប់ទៅធ្វើការនៅ ថៃ វិញ

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១១ វិច្ឆិកា ២០២១ដោយ Sok Sovann

អាជ្ញាធរថៃ នឹងត្រៀមវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដល់ទៅ ៥០០,០០០ដូស សម្រាប់ពលករបរទេស ខណៈខ្លួនរៀបចំស្វាគមន៍ពួកគេត្រឡប់មកប្រទេសវិញ ដើម្បីជួយសម្រាលការខ្វះខាតកម្លាំងពលកម្ម។ រដ្ឋាភិបាលថៃ គ្រោងនឹងអនុញ្ញាតឲ្យពលករមកពីប្រទេសជិតខាង កម្ពុជា មីយ៉ាន់ម៉ានិងឡាវ ចូលប្រទេសវិញនៅដើមខែក្រោយ ហើយបំពេញការខ្វះខាតក្នុងឧស្សាហកម្មនាំចេញធំៗ ដូចជាអាហារ និងផលិតកម្មកៅស៊ូ ជាដើម។ រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin បាននិយាយថា នៅពេលពលករត្រឡប់មកវិញ ពួកគេត្រូវជួបរឿង៣យ៉ាងដែលក្នុងនោះមានដូចជា ១.ពួកគេនឹងត្រូវដាក់ឲ្យធ្វើចត្តាឡីស័ករយៈពេល២សប្តាហ៍ ២.ក្នុងអំឡុងពេលធ្វើចត្តាឡីស័កនោះ ពួកគេនឹងត្រូវចាក់វ៉ាក់សាំង ហើយទី៣. ពួកគេក៏នឹងត្រូវធ្វើតេស្តរកជំងឺកូវីដ-១៩ផងដែរ។ រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin លោកថ្លែងថា "យើងបានត្រៀមវ៉ាក់សាំងពី ៤០ម៉ឺន ទៅ ៥០ ម៉ឺនដូស ដើម្បីចាក់ដល់ពលករចំណាកស្រុក"។ ទន្ទឹមនោះ ក្រសួងការងារបានប៉ាន់ប្រមាណថា មានតម្រូវការបន្ទាន់សម្រាប់ពលករចំណាកស្រុកចំនួន៤២០,០០០នាក់៕ *ប្រែសម្រួល៖ Vann Vann ប្រភព៖* Bangkok Post

## ប្រទេសថៃស្វែងរកជីកាចាប់ខ្លួនអ្នករត់ពន្ធពលករឆ្លងដែនខុសច្បាប់ ដែលមានពលរដ្ឋខ្មែរជាច្រើននាក់ជាជនរងគ្រោះ

https://www.khmertimeskh.com/ Khmer Times November 11, 2021

កំពុងស្វែងរកជីកាចាប់ខ្លួន អ្នករត់ពន្ធពលករចំណាកស្រុកខុសច្បាប់ ហើយទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវរឹបអូស ខណៈដែលការបង្ក្រាបនៅតែបន្តលើជនដែលចូលប្រទេសដោយខុសច្បាប់ដើម្បីស្វែងរកការងារធ្វើបន្ទាប់ពីបើកដំណើរការប្រទេសឡើងវិញនៅថ្ងៃទី១ ខែវិច្ឆិកា។ ក្រសួងការពារជាតិបាននិយាយថា ជនចំណាកស្រុកខុសច្បាប់ជាង ៣០.០០០នាក់ត្រូវបានបញ្ជូនមកវិញចាប់តាំងពីដើមឆ្នាំ ដោយមានចំនួនកើនឡើងមុនពេលប្រទេស

បើកដំណើរការឡើងវិញនៅថ្ងៃទី១ខែវិច្ឆិកា។ ក្នុងចំណោម ៣០.០០០នាក់នេះ មានពលករខ្មែររាប់ពាន់នាក់ខុសច្បាប់នៅប្រទេសត្រូវបានបញ្ជូនមកវិញ។

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បាននិយាយថា ក្រសួងបានស្នើសុំជំនួយអគ្គស្នងការនគរបាលជាតិ ឧត្តមសេនីយ៍ទោ Surachet Hakparn ដើម្បីស្វែងរកដីកាសម្រាប់ចាប់ខ្លួនអ្នករត់ពន្ធខណៈដែលការិយាល័យប្រឆាំងការលាងលុយកខ្វក់ត្រូវបានស្នើសុំឱ្យរឹបអូសទ្រព្យសម្បត្តិរបស់ពួកគេ។ លោក Suchart បាននិយាយកាលពីថ្ងៃអង្គារថា "ពលករចំណាកស្រុកមិនគួរត្រូវរង់ចាំយូរជាងបីសប្តាហ៍មុនពេលពួកគេអាចចូលប្រទេសដោយស្របច្បាប់ក្រោមអនុស្សរណៈនៃការយោគយល់គ្នាថ្មី"។ ការនាំចូលកម្លាំងពលកម្មផ្អែកលើអនុស្សារណៈជាមួយប្រទេសជិតខាងត្រូវបានផ្អាកតាំងពីខែមីនាឆ្នាំមុន នៅពេលដែលជំងឺកូវីដ-១៩ បានវាយលុកលើប្រទេស។ លោក Suchart បាននិយាយថា ចាប់តាំងពីពេលនោះមក អាជីវកម្ម និងឧស្សាហកម្មបានប្រឈមនឹងការខ្វះខាតកំលាំងពលករ ដែលជំរុញឱ្យអ្នកខ្លះជួលជនចំណាកស្រុកខុសច្បាប់។

ចំណាត់ការរបស់ក្រសួងការងារបានធ្វើឡើងបន្ទាប់ពីនាយករដ្ឋមន្ត្រី Prayut Chan-o-cha ពីមុនបានណែនាំខ្លួនឱ្យពន្លឿនកិច្ចខិតខំប្រឹងប្រែងដើម្បីដោះស្រាយបញ្ហាកង្វះកម្មករ និងការកើនឡើងនៃចំនួនជនចំណាកស្រុកខុសច្បាប់ដែលប៉ុនប៉ងលួចចូលប្រទេសថៃ ដោយបន្ទាប់មកមានការផ្ទុះជំងឺកូវីដ-១៩ ដែលមានការពាក់ព័ន្ធនឹងពួកគេ។ អនុវត្តតាមបទបញ្ជារបស់នាយករដ្ឋមន្ត្រី ក្រសួងកាលពីថ្ងៃចន្ទបានពិភាក្សាលើសំណើដែលដាក់ដោយប្រតិបត្តិករអាជីវកម្ម និងអង្គការក្រៅរដ្ឋាភិបាលលើបញ្ហានេះ។ ភាគីទាំងអស់ត្រូវបានក្រើនរំលឹកឱ្យអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការត្រួតពិនិត្យជំងឺកូវីដ-១៩ របស់រដ្ឋាភិបាល និងយោងទៅលើគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងពលករចំណាកស្រុកដែលចេញស្របតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីកាលពីថ្ងៃទី ២៨ ខែកញ្ញា។

លោកបាននិយាយថា នាយកដ្ឋានការងារនឹងជួបជាមួយទីភ្នាក់ងាររដ្ឋផ្សេងទៀត និងប៉ូលីសថៃនៅថ្ងៃស្អែកដើម្បីពិភាក្សាលើអនុស្សារណៈដោយលោកបន្ថែមថា ក្រសួងការងារកំពុងពិចារណានាំយកពលករបរទេសបន្ថែមទៀត។ លោក Suchart បាននិយាយថា ពលករណាដែលនាំយកមកក្រោមអនុស្សារណៈ ត្រូវមានការយល់ព្រមពីមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រងស្ថានភាពជំងឺកូវីដ-១៩ (CCSA) និងការយល់ព្រមចុងក្រោយពីគណៈរដ្ឋមន្ត្រី។ លោកបានបន្ថែមថា ប្រធានសភាពាណិជ្ជកម្មថៃ ប្រធានសហព័ន្ធឧស្សាហកម្មថៃ និងប្រតិបត្តិករអាជីវកម្មក៏នឹងត្រូវបានអញ្ជើញឱ្យពិភាក្សាអំពីបញ្ហានេះនៅក្នុងកិច្ចប្រជុំនៅថ្ងៃស្អែកផងដែរ។

លោក Suchart បាននិយាយថា "សូមប្រាកដថា បញ្ហានឹងត្រូវបានដោះស្រាយក្នុងពេលឆាប់ៗនេះ" ដោយបន្ថែមថា ក្រសួងបានសម្រេចចិត្តនាំយកពលករចំណាកស្រុកមកក្រោមអនុស្សារណៈដោយសារមានវ៉ាក់សាំងគ្រប់គ្រាន់។ លោក Suchart បាននិយាយថា ពួកគេនឹងត្រូវដាក់ឱ្យនៅដាច់ពីគេរយៈពេល ១៤ ថ្ងៃ ហើយនឹងត្រូវបានចាក់វ៉ាក់សាំងក្នុងរយៈពេលខ្លីមុនពេលបញ្ចប់ការដាក់ឱ្យនៅដាច់ដោយឡែកពីគេ។ លោកបានកត់សម្គាល់ថា ពលករចំណាកស្រុកចន្លោះពី ៥០.០០០-៨០.០០០ ត្រូវបានរំពឹងថានឹងមកដល់ក្រោមកិច្ចព្រមព្រៀងដំបូងនេះ។ កាលពីថ្ងៃចន្ទ លោក Suchart បានបង្ហាញថា មានតម្រូវការកម្មករកើនឡើងដោយមានឧស្សាហកម្មមួយចំនួនដូចជាសំណង់ និងឧស្សាហកម្មអាហារក្លាសេ ដែលត្រូវការកម្លាំងពលកម្មបរទេសប្រមាណ ២០០.០០០នាក់។ ម្នាក់ៗត្រូវបង់ប្រាក់ ២៥.០០០-២៦.០០០ បាតដល់ឈ្មួញការងារកណ្តាល៕ ប្រភព: Bangkokpost

## អ្នកនាំពាក្យក្រសួងការបរទេស៖ ពលករខ្មែរខុសច្បាប់៧០នាក់ទៀត ដែលអាជ្ញាធរថៃឃាត់ខ្លួន ត្រូវបានអន្តរាគមន៍ឱ្យធ្វើមាតុភូមិនិវត្តន៍វិញ

http://freshnewsasia.com/ 2021-11-11 01:16pm

**(ភ្នំពេញ)៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានឱ្យដឹងនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២១នេះថា មានពលករខ្មែរខុសច្បាប់ចំនួន ៧០នាក់ទៀត ដែលអាជ្ញាធរថៃឃាត់ ត្រូវបានអន្តរាគមន៍ និងសម្រួលឱ្យធ្វើមាតុភូមិនិវត្តន៍វិញ។ លោក កុយ គួង បានបញ្ជាក់ថា **«ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១ អាជ្ញាធរមានសមត្ថកិច្ចថៃបានឃាត់ខ្លួនពលករខ្មែរលួចឆ្លងដែនដោយខុសច្បាប់ (ពុំមានលិខិតស្នាម) ចំនួន ៧០នាក់ (ប្រុស៣៦ នាក់) នៅពីរចំណុចផ្សេងៗគ្នា»**។ បន្ទាប់ពីទទួលបានព័ត៌មានភ្លាម ស្ថានអគ្គកុងស៊ុលកម្ពុជា បានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើ មកមាតុប្រទេសវិញ នៅរសៀលថ្ងៃដដែល តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល។ សូមជម្រាបថា កាលពីរសៀលថ្ងៃទី០៤ និងព្រឹកថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ អាជ្ញាធរមានសមត្ថកិច្ចថៃ ក៏បានឃាត់ខ្លួនពលករខ្មែរ លួចឆ្លងដែនដោយខុសច្បាប់ (ពុំមានលិខិតស្នាម) ចំនួន ៧២នាក់ (ប្រុស៣៦ នាក់) នៅពីរចំណុចផ្សេងៗគ្នា និងត្រូវបានអន្តរាគមន៍ និងសម្រួលឱ្យធ្វើមាតុភូមិនិវត្តន៍វិញផងដែរ៕

## មេខ្យល់បម្រុងនាំពលករទៅថៃ ត្រូវកម្លាំងនគរបាលព្រំដែនឃាត់ខ្លួនក្នុងរថយន្ត២គ្រឿង និងពលករខ្មែរ១៤នាក់

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១១ វិច្ឆិកា ២០២១ដោយ Kang Tola

បន្ទាយមានជ័យ ៖ ម្តងនេះមេខ្យល់អស់លក្ខណ៍ម្នាក់ ដែលមានគំនិតនាំពលករ១៤នាក់ បម្រុងឆ្លងដែនទៅរកការងារធ្វើដឹកតាមរថយន្ត២គ្រឿង ត្រូវកម្លាំងនគរបាលព្រំដែនឃាត់រថយន្តទាំង២នេះបានក្នុងរថយន្តមានពលករខ្មែរចំនួន១៤នាក់ ក្នុងនោះមានមេខ្យល់ម្នាក់ទៀតចុះគេចបាត់នៅវេលាម៉ោង ១១ យប់ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០២១ ចេញភូមិ គីឡូម៉ែត្រ ៤ សង្កាត់ ផ្សារកណ្តាល ក្រុង ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

លោកឧត្តមសេនីយ៍ត្រី អ៊ុ សុផល ស្នងការរងទទួលផែនការងារព្រំដែន នៃស្នងការនគរបាល ខេត្តបន្ទាយមានជ័យបានប្រាប់អ្នកយកព័ត៌មានឲ្យដឹងថា អនុវត្តតាមបទបញ្ជារបស់ លោកឧត្តម សេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការ នគរបាល ខេត្តបន្ទាយមានជ័យលោកបានដឹកនាំកម្លាំងចុះស្រាវជ្រាវឈានដល់ឃាត់រថយន្តបាន២គ្រឿង។ លោកឧត្តមសេនីយ៍ត្រី អ៊ុ សុផល បានបញ្ជាក់ឲ្យដឹងបន្តថា រថយន្តទាំង២គ្រឿងនោះមាន ម៉ាកសាំ យ៉ុង ពណ៌ស ផ្លាកលេខ 2V.2810 ភ្នំពេញ និង ១គ្រឿងទៀតរថយន្តមានម៉ាកកា ម៉ា រី សេរី ៩៥ ពណ៌ស ផ្លាកលេខ 2A.2155 បាត់ដំបង។ រថយន្តទាំង២គ្រឿងនោះក្រោយពីដឹកពលករចេញពីភូមិ គីឡូម៉ែត្រ ៤ឆ្ពោះមកកាន់ស្រុកម៉ាឡៃបើកមកដល់ ចំណុច ផ្លូវកែង ខ្លា ងាប់ ស្រុក ម៉ាឡៃ ខេត្តបន្ទាយមានជ័យ រថយន្ត ទាំង ២ នេះដោយឃើញសមត្ថកិច្ចធ្វើការត្រួតពិនិត្យនោះអ្នកបើករថយន្តម៉ាកសាំ យ៉ុង ពណ៌ សចុះគេចខ្លួនបាត់ក្នុងនោះសមត្ថកិច្ច បាន ឃាត់ រថយន្ត ម៉ាក កាម៉ារី ១ គ្រឿង ដែលជាអ្នកនាំមនុស្សឆ្លងដែនខុសច្បាប់អ្នកបើកឈ្មោះ ឈុំ សា ផុន ភេទ ប្រុស អាយុ ២៨ ឆ្នាំ រួម និងពលករ ចំនួន ១៤ នាក់។ ពលករទាំង១៤នាក់បានបញ្ជូនមកកាន់ ប៉ុស្តិ៍រដ្ឋបាលឃុំទួលពង្រ ដើម្បីសាកសួរ។

តាមចម្លើយសារភាពរបស់ឈ្មោះ ឈុំ សា ផុនបានប្រាប់សមត្ថកិច្ចថា ខ្លួនជាអ្នកដឹកមនុស្សពីស្រុកខ្មែរ ឆ្លងដែនយកទៅឲ្យមេខ្យល់ នៅប្រទេសថៃក្នុងម្នាក់ជូនយកទៅឲ្យមេខ្យល់នៅថៃ១.០០០បាទនេះជាឈ្នួលជូនទៅ។ លោកបានបញ្ជាក់ឲ្យដឹងបន្តថា រថយន្ត ដឹក ពលករ ទាំង២គ្រឿងនិង អ្នកបើករថយន្តរួម និង ពលករ ទាំងអស់បានជញ្ជូនទៅកាន់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃចាត់ការបន្តហើយ៕ *ដោយ ៖ វ៉ាន់ ណាង*

## ត្រឹម២ថ្ងៃ ពលករខ្មែរជិត១០០នាក់ត្រូវទាហានថៃចាប់បានពេលលួចឆ្លងដែន

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១២ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ០៨:៤៣

ខេត្តបន្ទាយមានជ័យ ៖ ពលករខ្មែរដែលលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ បានត្រូវទាហានថៃឃាត់ខ្លួនរយៈពេល២ថ្ងៃមានជិត១០០នាក់ នៅក្នុងខេត្តស្រះកែវ ប្រទេសថៃ ឈមនឹងខេត្តបន្ទាយមានជ័យ ។ មន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ បានឲ្យដឹងថា កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ កន្លងទៅ នៅតាមបន្ទាត់ព្រំដែនស្ថិតក្នុងភូមិខៅណយ ឃុំក្លងណាំសៃ ស្រុកអារញ្ញ ខេត្តស្រះកែវដែលឈមនឹងឃុំម៉ាឡៃ ស្រុកម៉ាឡៃ កម្លាំងយោធាថៃបានឃាត់ខ្លួនពលករខ្មែរចំនួន៥៥នាក់ (ស្រី១៩នាក់) ដែលលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃដោយខុសច្បាប់ ។ ដោយឡែក កាលពីយប់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០២១ នៅតាមបន្ទាត់ព្រំដែស្ថិតក្នុងភូមិបានណូន ឃុំផានសឹក ស្រុកអារញ្ញ ខេត្តស្រះកែវ ដែលឈមនឹងភូមិបន្ទាយទី១ ឃុំអូរសំព័រ ស្រុកម៉ាឡៃ ទាហានថៃបានឃាត់ខ្លួនពលករខ្មែរចំនួន៣៧នាក់ ។ មន្ត្រីទំនាក់ទំនងព្រំដែនកម្ពុជា-ថៃបញ្ជាក់ថា ពលករខ្មែរដែលត្រូវទាហានថៃឃាត់ខ្លួននៅតាមបន្ទាត់ព្រំដែន គឺជាពលករខ្មែរដែលឆ្លងដែនតាមរយៈមេខ្យល់ខ្មែរនិងថៃ ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ ដែលក្នុងម្នាក់ត្រូវបានមេខ្យល់យក៨.០០០បាត ។ លុះនៅពេលមេខ្យល់ខ្មែរនាំឆ្លងដែនចេញពីដីខ្មែរហើយចូលទៅទឹកដីថៃ ត្រូវបានមេខ្យល់ថៃចាំទទួលនាំយកទៅរកការងារធ្វើនៅប្រទេសថៃជាបន្តទៀត។ ចំពោះពលករខ្មែរដែលត្រូវបានទាហានថៃឃាត់ខ្លួននៅតាមបន្ទាត់ព្រំដែននេះ ត្រូវបានបញ្ជូនត្រឡប់កម្ពុជាវិញតាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២១៕

## ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

## សមាគមមួយស្នើសុំលើកលែងការបង់ថ្លៃសេវាធ្វើតេស្តកូវីដ និងចេញវិញ្ញាបនបត្រដល់ពលករក្រៅប្រទេស

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១២ វិច្ឆិកា ២០២១ដោយ Sokhom Khon

ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា នឹងស្នើសុំទៅក្រសួងសុខាភិបាលលើកលែងការបង់ថ្លៃសេវាការធ្វើតេស្តជំងឺកូវីដ១៩ និងចេញវិញ្ញាបនបត្របញ្ជាក់ថា គ្មានជំងឺកូវីដ១៩ដល់ពលករ ខណៈតម្លៃសេវាមានតម្លៃថ្លៃរហូតដល់១៣០ដុល្លារអាមេរិក។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានឲ្យដឹងនៅព្រឹកថ្ងៃទី១២ ខែវិច្ឆិកានេះថា «យើងនឹងស្នើសុំទៅក្រសួងសុខាភិបាលលើកលែងការបង់ថ្លៃសេវាការធ្វើតេស្តរកជំងឺកូវីដ១៩ និងចេញវិញ្ញាបនបត្របញ្ជាក់ថាគ្មានជំងឺកូវីដ១៩ សម្រាប់ពលករក្រៅប្រទេសដែលជាការអំណោយផលដល់ពួកគាត់ទៅធ្វើការដោយស្របច្បាប់បើមិនដូច្នេះទេ ពួកគាត់ត្រូវទៅខ្ចីលុយពីធនាគារឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដើម្បីទៅធ្វើតេស្ត»។ លោកបានបន្តថា បច្ចុប្បន្ននេះពលករទៅធ្វើការនៅជប៉ុនត្រូវបង់ប្រាក់ចំនួន១៣០ដុល្លារអាមេរិក ក្នុងនោះ១០០ដុល្លារសម្រាប់ចំណាយទៅលើការធ្វើតេស្តតាមម៉ាស៊ីន PCR និង៣០ដុល្លារទៀតសម្រាប់ចំណាយទៅលើការចេញវិញ្ញាបនបត្របញ្ជាក់ថា គ្មានជំងឺកូវីដ១៩ ដែលមានតម្លៃថ្លៃដែលពួកគាត់មិនមានលទ្ធភាពក្នុងការចំណាយទៅលើសេវាទាំងនេះឡើយ។ លោកបានបន្ថែមទៀតថា «ប្រសិនបើមានការលើកលែងសេវាទាំងនេះនោះ ប្រៀបដូចជាការធ្វើបុណ្យជាមួយពលករយើងអីចឹងដែរ ពិសេសពលករធ្វើការនៅប្រទេសថៃ ដើម្បីអាចឱ្យពួកគាត់អាចទៅស្វែងរកការងារធ្វើនៅប្រទេសថៃដោយស្របច្បាប់ និងកាត់បន្ថយការលួចឆ្លងដែនដោយខុសច្បាប់»។

លោកបានឱ្យដឹងទៀតថា នៅពេលដែលពលករទៅធ្វើការដោយខុសច្បាប់ នឹងធ្វើឱ្យមានបញ្ហាច្រើនហើយចុងក្រោយធ្លាក់បន្ទុកមកលើរដ្ឋាភិបាលវិញដដែល ព្រោះថា ពេលចូលឆ្លងដែនខុសច្បាប់តម្រួតថៃត្រូវបញ្ជូនត្រឡប់

មកវិញហើយត្រូវយកគាត់មកធ្វើចត្តាឡីស័ក ធ្វើតេស្តរកកូវីដហើយពេលរកឃើញត្រូវព្យាបាល ត្រូវចំណាយយ៉ាងច្រើនថ្លៃអាហារ និងព្យាបាលនិងស្នាក់នៅដែលត្រូវចំណាយយ៉ាងច្រើនលើសការធ្វើតេស្តទៅទៀត។ លោកបានបន្តទៀតថា សម្រាប់ពលករម្នាក់ចេញទៅធ្វើការនៅក្រៅប្រទេសត្រូវចំណាយថវិកាជាង២០០ដុល្លារអាមេរិក ដើម្បីរៀបចំលិខិតឆ្លងដែន និងរៀបចំឯកសារផ្ទាល់ខ្លួន។ ចំពោះប័ណ្ណធ្វើការងារ និងវីសាគឺជាបន្ទុករបស់និយោជក។ លោកបានបញ្ជាក់ថា នាពេលខាងមុខនេះរដ្ឋាភិបាលថៃនឹងបើកប្រទេសឡើងវិញ ដើម្បីទទួលពលករបរទេសពិសេសប្រទេសជិតខាងថៃរួមមានកម្ពុជា ឡាវ មីយ៉ាន់ម៉ា ដោយសារថៃមានតម្រូវការពលករច្រើន។ លោក អន ប៊ុនហាក់ បានបន្ថែមថា ពលករដែលអាចទៅធ្វើការនៅប្រទេសថៃត្រូវមានលក្ខខណ្ឌមួយចំនួនដូចជា ត្រូវមានកាតចាក់វ៉ាក់សាំងដែលបញ្ហានេះពលករយើងមិនមានបញ្ហានោះទេព្រោះថាពលករបានចាក់វ៉ាក់សាំងរួចហើយ និងការធ្វើតេស្តរកជំងឺកូវីដ១៩រយៈពេល៧២ម៉ោងតាមម៉ាស៊ីន PCRដើម្បីបញ្ជាក់វិញ្ញាបនបត្រថា មិនមានឆ្លងជំងឺកូវីដ១៩ដែលពលករត្រូវចេញថ្លៃតេស្តខ្លួនឯង។

លោក អនប៊ុនហាក់ បានបន្ថែមទៀតថា ប៉ុន្តែពេលចូលទៅដល់ប្រទេសថៃមិនតម្រូវឱ្យពលករបង់ទេជាកាតព្វកិច្ចរបស់និយោជកថៃត្រូវបង់ជំនួសទាំងការធ្វើតេស្តនិងចេញថ្លៃព្យាបាលប្រសិនបើពលករនោះមានវិជ្ជមានកូវីដ១៩។ យ៉ាងណាក៏ដោយលោកបានមានប្រសាសន៍ថា យើងនៅមិនទាន់ទទួលបាននីតិវិធីជាផ្លូវការពីភាគីថៃនៅឡើយទេ។ ប៉ុន្តែយើងបានត្រៀមពលករមានវីសាប្រមាណ៩ពាន់នាក់រួចហើយ។ លោកប្រធានសមាគមបានបន្តទៀតថា នៅសល់៩ពាន់នាក់នេះ ដោយសារតែការរង់ចាំយូរកន្លងមកមានពលករមួយចំនួនដែលបានចុះឈ្មោះទៅធ្វើការនៅប្រទេសថៃ៣០ទៅ៥០ភាគរយបានលួចចូលទៅក្នុងប្រទេសថៃ ហើយមានខ្លះចូលបាន និងខ្លះទៀតត្រូវតម្រួតថៃចាប់បញ្ជូនត្រឡប់មកវិញ៕ អត្ថបទ៖ សំអឿន

## តុលាការឧទ្ធរណ៍ ជម្រះបណ្តឹង ជនជាប់ចោទម្នាក់ ជាប់ពាក់ព័ន្ធនឹងការបើកកន្លែងម៉ាស្សា តែបង្កប់សេវាវ៉ៃសិច !!!!

https://cen.com.kh/ Posted ByPen Srey NeatNovember 12, 2021

ភ្នំពេញ ៖ សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០២១ បានបើកសវនាការជំនុំជំម្រះ លើបណ្តឹងឧទ្ធរណ៍ របស់ជនជាប់ចោទម្នាក់ ដែលត្រូវបានសាលាដំបូងខេត្តកណ្តាល កាត់ទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ និងបង្គាប់ឱ្យសងជំងឺចិត្ត ៥ ម៉ឺនដុល្លារ ដល់ជនរងគ្រោះ ជាប់ពាក់ព័ន្ធនឹងបទល្មើសសញ្ជារកម្មមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តកាលពីអំឡុងឆ្នាំ ២០២០ នៅខេត្តកណ្តាល។

លោក យន់ ណារ៉ុង ប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ សាលាឧទ្ធរណ៍ រាជធានីភ្នំពេញ បានឲ្យដឹងថា ជនជាប់ចោទខាងលើ មានឈ្មោះ ថៃ ម៉េងហួត ភេទ ប្រុស អាយុ ៣៨ ឆ្នាំ ។ ជនជាប់ចោទ សមត្ថកិច្ចឃាត់ខ្លួនកាលពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០ នៅត្រង់ក្នុងចំណុចហាងម៉ាស្សារបស់ជនជាប់ចោទ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៧៣ នៅឃុំ វិហារសួគ៌ ស្រុកវិហារសួគ៌ ខេត្តកណ្តាល ។ ជនជាប់ចោទ ត្រូវបានតុលាការដំបូងខេត្តកណ្តាលកាលពីខែ កក្កដា ឆ្នាំ ២០២០ កាត់ទោសដាក់ពន្ធនាគា កំណត់ ៥ ឆ្នាំ តែពួកគេបានប្តឹងមកកាន់សាលាឧទ្ធរណ៍ភ្នំពេញ ។

នាពេលសវនាការ ជនជាប់ចោទ ថៃ ម៉េងហួត បានឆ្លើយសារភាពថា គាត់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន (បើកកន្លែងម៉ាស្សា លួចបង្កប់សេវាវ៉ៃសិច) ។ ថៃ ម៉េងហួត បានសុំអោយតុលាការឧទ្ធរណ៍ មេត្តាបន្ធូបន្ថយទោសដល់គាត់ផង ដើម្បីឆាប់បាន វិលត្រឡប់ជួបជុំគ្រួសារគាត់វិញ។ សំណុំរឿងក្តីនេះ សាលាឧទ្ធរណ៍នឹងប្រកាសសាលដីកា នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២១ វេលាម៉ោង ៨ ព្រឹក៕រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## បង្ក្រាបមុខសញ្ញា នាំពលករចេញ ដោយមិនស្របច្បាប់ ដើម្បីឆ្លងដែនចូលក្នុងទឹកដីថៃ ចំនួន ២៥នាក់

https://cen.com.kh/ Posted ByPen Srey Neat November 13, 2021

បាត់ដំបង ៖ កងកម្លាំងវរសេនាតូចលេខ ៨១៩ បង្ក្រាបមុខសញ្ញានាំពលករចេញដោយមិនស្របច្បាប់ដើម្បីឆ្លងដែនចូលក្នុងទឹកដីថៃ ចំនួន២៥នាក់ ដែលស្ថិតនៅក្នុងភូមិកណ្ដាល ឃុំត្រាង ស្រុកកំរៀង ខេត្តបាត់ដំបង គោលដៅដើមពុទ្រា ហើយកម្លាំងជំនាញបានអប់រំ និងធ្វើកំណត់ហេតុ រួចបញ្ជូនទៅឲ្យអធិការដ្ឋាននគរបាលស្រុកកំរៀង។

លោកវរសេនីយ៍ឯក ម៉ង់ ស៊ី មេបញ្ជាការ វរសេនាតូចលេខ ៨១៩ បានឲ្យដឹងថា នៅព្រឹកថ្ងៃសៅរ៍ ទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ ដោយតាមបទបញ្ជា និងមានការអនុវត្តន៍ដឹកនាំជាប់ជាប្រចាំ កងកម្លាំងវរសេនាតូចលេខ ៨១៩ កងកម្លាំងប៉ុស្ដិ៍តាសែន សហការជាមួយកងកម្លាំងកងពលលេខ៥៣ និងកងកម្លាំងសឹករងស្រុក បានធ្វើការឃាត់ខ្លួនពលករដែលបម្រុងឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ចំនួនសរុប ២៥នាក់ ស្រី ១១នាក់ ក្មេង ០២ នាក់ ដែលស្ថិតនៅក្នុងភូមិកណ្ដាល ឃុំត្រាង ស្រុកកំរៀង ខេត្តបាត់ដំបង គោលដៅដើមពុទ្រា បច្ចុប្បន្នកម្លាំងជំនាញបានអប់រំ និងធ្វើកំណត់ហេតុ រួចបញ្ជូនទៅឲ្យអធិការដ្ឋាននគរបាលស្រុកកំរៀង អនុវត្តទៅតាមនីតិវិធីច្បាប់បន្ត៕ កូលាប

## ប្រតិបត្តិករអាជីវកម្មថៃ ត្រូវការពលករខ្មែរចំនួន ១៣០,១៣៨ នាក់

https://www.khmertimeskh.com/ November 14, 2021

យោងតាមការសិក្សាដោយនាយកដ្ឋានការងាររបស់ប្រទេសថៃនៅក្នុងខែឧសភា បានរកឃើញថា ប្រតិបត្តិករអាជីវកម្មថៃ ត្រូវការពលករកម្ពុជាចំនួន ១៣០,១៣៨ នាក់, ពលករមីយ៉ាន់ម៉ា ចំនួន២៥៦,០២៩ នាក់ និងពលករឡាវចំនួន ៣៨,៥៣៦ នាក់ សម្រាប់អាជីវកម្មរបស់ពួកគេ។ ការងារភាគច្រើនគឺនៅក្នុងវិស័យកសិកម្ម ចិញ្ចឹមសត្វ សំណង់ សេវាកម្មបដិសណ្ឋារកិច្ច និងវិស័យកាត់ដេរ។

សហព័ន្ធឧស្សាហកម្មថៃ (FTI) បាននិយាយថា ខ្លួនរំពឹងថានឹងត្រូវការពលករពី ៣០០,០០០ ទៅ ៥០០,០០០នាក់ បន្ទាប់ពីរដ្ឋាភិបាលបានអនុវត្តវិធានការបិទប្រទេស ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគ។ សហព័ន្ធឧស្សាហកម្មថៃ (FTI) មានការព្រួយបារម្ភថា ពលករចំណាកស្រុកដែលចូលប្រទេសថៃដោយលួចលាក់និងមិនបានធ្វើតេស្តរកមេរោគកូវីដ-១៩ អាចបង្ករឱ្យមានការឆ្លងថ្មីជាចង្កោម ។ វិស័យឯកជនកំពុងអំពាវនាវឱ្យរដ្ឋាភិបាលពន្លឿនការអនុញ្ញាតឱ្យពលករចំណាកស្រុកដែលចាក់វ៉ាក់សាំងបង្ការរួចចូលធ្វើការវិញ ក្រោមអនុស្សរណៈយោគយល់គ្នា (MoU) ដែលត្រូវបានចុះហត្ថលេខាជាមួយប្រទេសជិតខាង។

លោក Tanit Sorat អនុប្រធានសហភាពនិយោជកនៃពាណិជ្ជកម្ម និងឧស្សាហកម្មថៃបាននិយាយថា រដ្ឋាភិបាលគួរតែអនុញ្ញាតឱ្យពលករដែលចាក់វ៉ាក់សាំងរួចមកពីប្រទេសមីយ៉ាន់ម៉ា ឡាវ និងកម្ពុជា ក្រោមអនុស្សរណៈយោគយល់គ្នា MoU ចូលប្រទេសថៃក្នុងខែនេះជំនួសឱ្យខែធ្នូ។ លោកបានបន្តថា៖ «តម្រូវការកម្លាំងពលកម្មបរទេសកំពុងកើនឡើងនៅពេលនេះ បន្ទាប់ពីប្រទេសថៃបានបើកដំណើរការឡើងវិញនៅថ្ងៃទី១ ខែវិច្ឆិកា»។ «កំណើននៃការនាំចេញ និងការនាំចូលក៏បណ្ដាលអោយខ្វះខាតយ៉ាងខ្លាំងនៃពលករគ្មានជំនាញ»។ លោក Tanit បាននិយាយថា កិច្ចប្រជុំរួមគ្នារវាងក្រសួងការងារ និងទីភ្នាក់ងារពាក់ព័ន្ធនាពេលថ្មីៗនេះ បានយល់ព្រមពន្យារពេលអនុវត្ត MoU សម្រាប់ពលករបរទេសដែលចាក់វ៉ាក់សាំងរួចមកពីប្រទេសជិតខាងទាំងបីប្រទេសរហូតដល់ខែធ្នូ។

លោកបានមានប្រសាសន៍ថា "MOU គួរតែត្រូវបានចុះហត្ថលេខា និងអនុវត្តនៅក្នុងខែនេះ ដោយសារតែនីតិវិធីពិនិត្យពិនិត្យពលករដែលចាក់វ៉ាក់សាំងរួចចំណាយពេលយូរ"។ យោងតាមលោក Tanit សហព័ន្ធនិយោជកបានស្នើឱ្យនិយោជកទទួលបន្ទុកក្នុងការផ្តល់វ៉ាក់សាំងសម្រាប់ពលករបរទេស និងឧបត្ថម្ភធនលើការចំណាយ

សម្រាប់វិធានការចត្តាឡីស័ករយៈពេល១៤ ថ្ងៃមុនពេលពួកគេចាប់ផ្តើមធ្វើការ។ លោកក៏បានស្នើឲ្យរដ្ឋាភិបាលកែប្រែបទប្បញ្ញត្តិដែលអនុញ្ញាតឲ្យបុគ្គលិកផ្លាស់ប្តូរការងារបន្ទាប់ពីធ្វើការបានតែមួយខែប៉ុណ្ណោះ។ លោក Tanit បាននិយាយថា ពលករចំណាកស្រុកដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ច ដោយនិយាយថា ប្រជាជនថៃមានការស្ទាក់ស្ទើរក្នុងការងារក្នុងវិស័យឧស្សាហកម្មមួយចំនួន។ លោកបន្តថា តម្រូវការពលករបរទេសទំនងជាមានចំនួនលើសពីការព្យាកររបស់ក្រសួងការងារដែលរំពឹងថាប្រទេសថៃត្រូវការពលករបរទេសចំនួន ៤២០,០០០ នាក់។ លោកបានព្យាករណ៍ថា តម្រូវការនឹងកើនឡើងបន្ថែមទៀតនៅឆ្នាំក្រោយ។

## មជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូវីដ-១៩ (CCSA) របស់ប្រទេសថៃយល់ស្របអំពីវិធីនាំពលករចំណាកស្រុកដោយសុវត្ថិភាព រួមទាំងប្រជាជនកម្ពុជាផងដែរ

https://www.khmertimeskh.com/ Khmer November 14, 2021

មជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូវីដ-១៩ (CCSA) បានអនុម័តដំណើរការនាំពលករចំណាកស្រុកចូលប្រទេស ដើម្បីដោះស្រាយបញ្ហាកង្វះកម្លាំងពលកម្មដែលកំពុងបន្តបំពេញដោយច្បាប់ ដើម្បីធានាថាពួកគេមិនមានជំងឺឆ្លង។

លោកវេជ្ជបណ្ឌិត Taweesilp Visanuyothin អ្នកនាំពាក្យមជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូវីដ-១៩ បាននិយាយថា ក្រសួងការងារបានស្នើរអោយមានដំណាក់កាលចំនួន ៨ ដើម្បីធានាថា ប្រជាជនមកពីប្រទេសផ្សេងៗអាចត្រូវបានគេជួលដោយសុវត្ថិភាព ដោយមិននាំចូលករណីឆ្លងថ្មីនៃជំងឺកូវីដ-១៩ ហើយ CCSA បានផ្តល់ការឯកភាពជាផ្លូវការ។ ការយល់ព្រម។ វិធានការថ្មីនឹងចូលជាធរមាននៅខែក្រោយ។ ដំណឹងនេះអាចជាការធូរស្រាលដល់ម្ចាស់អាជីវកម្ម ដោយសារឧស្សាហកម្មជាច្រើនកំពុងប្រឈមនឹងការខ្វះខាតកម្លាំងពលកម្ម ទីបំផុតការបិទខ្ទប់ដោយកូវីដ ត្រូវបានដកចេញខណៈដែលមានការបង្ក្រាបលើពលករខុសច្បាប់។ លោកវេជ្ជបណ្ឌិត Taweesilp បាននិយាយថា និយោជកត្រូវបំពេញពាក្យទៅការិយាល័យការងារ ប្រសិនបើពួកគេត្រូវការជួលពលករចំណាកស្រុកពីក្រៅប្រទេស ហើយដាក់ពាក្យស្នើសុំនោះទៅអាជ្ញាធរពាក់ព័ន្ធ។
ប្រទេសផ្សេងទៀតត្រូវតែចងក្រងបញ្ជីឈ្មោះកម្មករសម្រាប់ពេលអនាគត ហើយបញ្ជូនវាទៅក្រសួងការងារថៃ និងទៅនិយោជក មុនពេលនិយោជកអាចចេញប័ណ្ណការងារអោយ។ ក្រសួងក៏នឹងទាមទារភស្តុតាងដែលបញ្ជាក់ថាពលករបានចាក់វ៉ាក់សាំងរួច និងមានការធានារ៉ាប់រងសុខភាព ដើម្បីឲ្យពួកគេអាចចុះឈ្មោះក្នុងប្រព័ន្ធបេឡាជាតិសន្តិសុខសង្គម។

លោកវេជ្ជបណ្ឌិត Taweesilp បាននិយាយថា នាយកដ្ឋានការងារនឹងទំនាក់ទំនងជាមួយស្ថានទូតថៃនៅក្រៅប្រទេស ដើម្បីជួយសម្រួលដល់ការចូលប្រទេសថៃដោយស្របច្បាប់របស់ពលករចំណាកស្រុក។ លោកបានបន្ថែមថា ពលករត្រូវដាក់តាមខ្លួននូវលិខិតអនុញ្ញាត្ត, ក៏ដូចជាលទ្ធផលតេស្តកូវីដ-១៩, ឯកសារចាក់វ៉ាក់សាំង, ទិដ្ឋាការ និងព័ត៌មានដែលបង្ហាញពីកន្លែងដែលពួកគេនឹងត្រូវធ្វើចត្តាឡីស័ក និងពួកគាត់ត្រូវធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនមួយណា។ ពលករចំណាកស្រុកដែលទទួលការចាក់វ៉ាក់សាំងបង្ការពេញលេញ តម្រូវអោយធ្វើចត្តាឡីស័ក យ៉ាងហោចណាស់ប្រាំពីរថ្ងៃ និងធ្វើតេស្តពីរដង រីឯអ្នកដែលមិនបានចាក់វ៉ាក់សាំង ត្រូវចំណាយពេលពីរសប្តាហ៍ដើម្បីធ្វើចត្តាឡីស័ក និងអនុវត្តការធ្វើតេស្តចំនួនពីរដងដូចគ្នា។ និយោជករបស់ពួកគេនឹងទទួលខុសត្រូវចំពោះថ្លៃព្យាបាលទាំងអស់។ បន្ទាប់ពីការធ្វើចត្តាឡីស័ក និយោជករបស់ពួកគេត្រូវតែមកទទួលយកពួកគេដូច្នេះពួកគេអាចទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងទទួលបានប័ណ្ណការងាររបស់ពួកគេ។

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បាននិយាយថា និយោជកអាចនាំពលករចំណាកស្រុកដោយខ្លួនឯង ឬតាមរយៈក្រុមហ៊ុនជ្រើសរើសពលករ។ ខេត្តចំនួនប្រាំគឺ Ranong, Tak (ស្រុក Mae Sot), Sa Ka eo, Nong Khai និង Mukdahan នឹងត្រូវយកធ្វើជាទីតាំងចត្តាឡីស័កសម្រាប់ពលករដែលមកពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងឡាវ។ សណ្ឋាគារជាក់លាក់នឹងត្រូវបានកំណត់ឱ្យទទួលពួកគេ។ ទន្ទឹមនឹងនេះ ជនចំណាកស្រុកខុសច្បាប់អាចចុះឈ្មោះជាមួយក្រសួងដោយមិនគិតថ្លៃរហូតដល់ថ្ងៃទី ៣០ ខែវិច្ឆិកា។

## នគរបាលខេត្តឧត្តរមានជ័យ ឃាត់ខ្លួនពលករខ្មែរ១០នាក់ បម្រុងលួចឆ្លងដែនទៅថៃ ហើយអប់រំណែនាំ និងឲ្យត្រឡប់ទៅផ្ទះវិញ

https://cen.com.kh/ Posted ByPen Srey NeatNovember 14, 2021

ឧត្តរមានជ័យ ៖ ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ បានឲ្យដឹងថា ប្រជាពលរដ្ឋចំនួន១០នាក់ លួចឆ្លងដែនតាមច្រករបៀងទៅប្រទេសថៃ ក្នុងភូមិសាស្ត្រ ភូមិរួតចំប៉ី សង្កាត់អូរស្មាច់ ក្រុងសំរោង ក្នុងខេត្តឧត្តរមានជ័យ ត្រូវបានកម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៧០២ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលអូរស្មាច់ និងកម្លាំងជំនាញនៃអធិការដ្ឋាននគរបាលក្រុងសំរោង ធ្វើការឃាត់ខ្លួន ដើម្បីយកមកសាកសួរ និងធ្វើកិច្ចសន្យាអប់រំនៅស្នងការរដ្ឋាននគររបាលខេត្តឧត្តរមានជ័យ ។ ស្នងការនគរបាលខេត្តឧត្តរមានជ័យ បានបញ្ជាក់ថា ពលករខ្មែរចំនួន១០នាក់ ដែលមានបំណងចង់លួចឆ្លងដែន ចូលក្នុងប្រទេសថៃដោយខុសច្បាប់ ហើយត្រូវសមត្ថកិច្ចឃាត់ខ្លួនបាននោះ ត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញហើយ នៅព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១នេះ ។

នៅព្រឹកថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១នេះ លោក ឧត្តមសេនីយ៍ទោ ហួត សុធី ស្នងការនគរបាលខេត្ត បានធ្វើការអប់រំណែនាំ ពលរដ្ឋខ្មែរ ចំនួន ១០ នាក់ ស្រី០៤ នាក់ មកពីបណ្តាខេត្តផ្សេងៗ ដែលលួចឆ្លងដែនតាមច្រករបៀងទៅប្រទេសថៃ មានបំណង បម្រុងលួចឆ្លង ដោយខុសច្បាប់ ដើម្បីទៅរកការងារធ្វើនៅប្រទេសថៃ។ ក្រោយកម្លាំងចម្រុះដែលប្រចាំការគោលដៅអូរស្មាច់ ល្បាតពួនស្ទាក់ ឃាត់បាននៅវេលាម៉ោង ២០និង៣៧ នាទី ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០២១ នៅចំណុចខាងកើតអូរទី២ ភូមិសាស្ត្រប៉ុស្តិ៍អណ្តែតមុត UA(៥៦៥០០-៩៤៨៣៦) ស្ថិតក្នុងភូមិរួតចំប៉ី សង្កាត់អូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យ ។ លោកឧត្តមសេនីយ៍ទោស្នងការ បានថ្លែងថា ពលរដ្ឋខាងលើមានទីលំនៅស្រុកអង្គរជុំខេត្តសៀមរាប និងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ក្រោយពីបានធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យារួចហើយ លោកក៏បានអនុញ្ញាតឱ្យវិលត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួន។ លោកឧត្តមសេនីយ៍ទោ ហួត សុធី ក៏បានថ្លែងណែនាំបន្ថែម ដល់កងកម្លាំងនគរបាលដែលឈរជើងតាមខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់អនុវត្តតួនាទីភារកិច្ច ដោយការទទួលខុសត្រូវខ្ពស់ និងប្រកបដោយប្រសិទ្ធិភាព ស្របតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ និងគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តឧត្តរមានជ័យ៕ រក្សាសិទ្ធិដោយ ៖ កូលាប

## ពលករខ្មែរ២២នាក់ត្រូវអាជ្ញាធរថៃឃាត់ខ្លួន, អគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវជួយអន្តរាគមន៍បញ្ជូនមកមាតុភូមិវិញ

http://freshnewsasia.com/ 2021-11-14 01:32pm

**(ភ្នំពេញ)៖** អាជ្ញាធរមានសមត្ថកិច្ចថៃ នាថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១នេះ បានឃាត់ខ្លួនពលករខ្មែរចំនួន២២នាក់ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតនាំឆ្លងដែនចូលទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់។ នេះបើតាមលោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ លោកបានបន្តថា បន្ទាប់ពីទទួលបានព័ត៌មានភ្លាម ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវបានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បី

បញ្ជូនពលរដ្ឋខ្មែរខាងលើមកមាតុប្រទេសវិញ នៅរសៀលថ្ងៃទី១៣ ខែវិច្ឆិកាដដែល តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕

## ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១

## ឃាត់ខ្លួនជនសង្ស័យជាមេខ្យល់បម្រុងនាំពលករឆ្លងដែនចូលទៅក្នុងប្រទេសថៃដោយខុសច្បាប់ម្នាក់ និងពលករចំនួន ០៦ នាក់

https://khmernote.com.kh/ November 15, 2021 srey nuch

ខេត្តបាត់ដំបង៖ យោងតាមការចុះផ្សាយរបស់ អធិការដ្ឋាននគរបាលស្រុកសំពៅលូន បានឲ្យដឹងថា ដោយអនុវត្តតាមមតិដឹកនាំរបស់ ឯកឧត្តម ឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការ នៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង នឹងក្រោមការដឹកនាំបញ្ជាផ្ទាល់យ៉ាងយកចិត្តទុកដាក់របស់លោកវរសេនីយ៍ទោ ទឹម រិទ្ធ័យ អធិការនគរបាលស្រុកសំពៅលូន។ នៅថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០២១ វេលាម៉ោង ០២ និង ៣០ នាទី នៅចំណុច ជាប់មាត់អូរព្រំដែនកម្ពុជា-ថៃ ក្រុមទី ០៧ ភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង កម្លាំងអធិការដ្ឋាននគរបាលស្រុកសំពៅលូន សហការជាមួយ កម្លាំង វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ កម្លាំងវរលេខ១ និងកម្លាំងវរៈសេនាតូច៥៣៣ បង្ក្រាបករណី ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន (បម្រុងចូលទៅក្នុងប្រទេសថៃ ) ០១ ករណី បានឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន ០១ នាក់៖

ឈ្មោះ ញឹក ចាន់ ភេទប្រុស អាយុ ១៨ ឆ្នាំ មានទីលំនៅ ភូមិអូរស្វាត់ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង និងជនសង្ស័យជាមេខ្យល់ម្នាក់ទៀតឈ្មោះ ភេទ ភេទប្រុស អាយុប្រហែល ២៤ ឆ្នាំ មានទីលំនៅ ចំណុចចក្រី ស្រុក ភ្នំព្រឹក ខេត្តបាត់ដំបង (ឃាត់ខ្លួនមិនបាន) បានធ្វើសកម្មភាព ទាក់ទងគ្នា លួចនាំពលករចំនួន ០៦ នាក់រួមមាន៖

១. ឈ្មោះ សុខ បូរិន ភេទស្រី អាយុ ២៧ ឆ្នាំ

២. ឈ្មោះ សុខ លីដា ភេទប្រុស អាយុ ២៤ ឆ្នាំ

៣. ឈ្មោះ សុក ចាន់លី ភេទស្រី អាយុ ៣៩ ឆ្នាំ អ្នកទាំងបីនាក់ មានទីលំនៅ ភូមិកស្វាយ ឃុំហោត់ទឹក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។

៤. ឈ្មោះ ជោង ចាត់ ភេទប្រុស អាយុ ២៥ ឆ្នាំ

៥. ឈ្មោះ ជី ប៊ុនថន ភេទស្រី អាយុ ២៥ ឆ្នាំ

៦. ឈ្មោះ ឡឹម យីង ភេទប្រុស អាយុ ៣០ ឆ្នាំ អ្នកទាំងបីនាក់ មានទីលំនៅ ភូមិអូរប្រាសាទ ឃុំអូរប្រាសាទ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ បម្រុងនាំឆ្លងដែនទៅធ្វើការនៅប្រទេសថៃ ដោយយកប្រាក់ថ្លៃធ្វើដំណើរពីពលករក្នុងម្នាក់ ៥,៥០០ បាត ។

បច្ចុប្បន្ន ករណីខាងលើ កម្លាំងជំនាញបានធ្វើការឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន ០១ នាក់ កសាងសំណុំរឿង បញ្ជូនទៅការិយាល័យជំនាញខេត្តចាត់ការបន្តតាមនីតិវិធី។ ដោយឡែកពលករទាំង ០៦ នាក់ សមត្ថកិច្ចយើងបាន ធ្វើការអប់រំណែនាំ និងឱ្យវិលត្រឡប់ទៅមូលដ្ឋានវិញ ៕

# មន្ត្រីជាន់ខ្ពស់សង្គមកិច្ច៖ រាជរដ្ឋាភិបាលកម្ពុជា កំពុងចូលរួមចំណែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សយ៉ាងខ្លាំងក្លា គ្រប់រូបភាពរួមជាមួយដៃគូសហការ និងប្រជាពលរដ្ឋ

http://freshnewsasia.com/ 2021-11-15 12:32pm

**(ភ្នំពេញ)៖** លោក ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងលោក វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានលើកឡើងថា អំពើជួញដូរមនុស្ស គឺជាបញ្ហាសង្គម និងជាអំពើរំលោភសិទ្ធិមនុស្ស យ៉ាងធ្ងន់ធ្ងរ ដែលបាន និងកំពុងកើតមានស្ទើរតែគ្រប់ប្រទេសនៅលើសាកលលោកទាំងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍។ វាជាបទឧក្រិដ្ឋដែលមនុស្សជាតិស្អប់ខ្ពើម និងមិនអាចអត់អោនឲ្យបានឡើយ ហើយបណ្តាប្រទេសលើសាកលលោក បាននឹងកំពុងតែប្រយុទ្ធប្រឆាំងយ៉ាងខ្លាំងក្លា។ លោកបន្តថា រាជរដ្ឋាភិបាលកម្ពុជា កំពុងចូលរួមចំណែកប្រយុទ្ធប្រឆាំងយ៉ាងខ្លាំងក្លា គ្រប់រូបភាព រួមជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងប្រជាពលរដ្ឋ។

ការលើកឡើងរបស់ លោក ញ៉ឹក វណ្ណារ៉ា បានធ្វើឡើងនៅក្នុងពិធីបើកកិច្ចប្រជុំពិនិត្យ ពិភាក្សាលើទម្រង់ និងឧបសម្ព័ន្ធ ស្តីពីដំណើរការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស នាថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច បានបន្ថែមថា ក្រសួងសង្គមកិច្ចជាក្រសួងជំនាញបច្ចេកទេស ដែលមានការចូលរួមពីកិច្ចសហការដៃគូសហការជាមួយដៃគូអភិវឌ្ឍន៍ និងមានការសម្របសម្រួលពី អង្គការទេសន្តរប្រវេសន៍អន្តរជាតិ បានរៀបចំកិច្ចប្រជុំពិនិត្យ ពិភាក្សាលើទម្រង់ និងឧបសម្ព័ន្ធ ស្តីពី ដំណើរការគ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រៀមកិច្ចប្រជុំជាមួយភាគីថៃនាពេលខាងមុខនេះ។ កិច្ចប្រជុំនេះ គឺផ្អែកតាមការចង្អុលបង្ហាញនៅក្នុងដំណើរការគ្រប់គ្រងករណី នៃការនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សនេះ បង្ហាញពីឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលទាំង២ ក្នុងការរៀបចំឲ្យមានឯកសារនេះ ឡើងក្នុងគោលបំណងជួយដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស។ ផ្តើមចេញពីបទពិសោធន៍នៃការផ្តល់សេវា សង្គ្រោះ ស្តារនីតិសម្បទា គ្រប់គ្រងករណីនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជាច្រើនឆ្នាំកន្លងមក។ ប្រទេសកម្ពុជា ជាប្រទេសដែលបានបញ្ជូនប្រទេសគោលដៅ និងជាប្រទេសឆ្លងកាត់នៃអំពោះជួញដូរមនុស្ស មានកុមារ និងស្ត្រីជាច្រើន ជាពិសេសនៅខេត្តបន្ទាយមានជ័យ បាត់ដំបង សៀមរាប និងខេត្តផ្សេងទៀតដែលជាប់ព្រំដែនជាមួយថៃ។

លោក ញ៉ឹក វណ្ណារ៉ា ជឿជាក់ថា ការចូលរួមកិច្ចប្រជុំនាថ្ងៃនេះ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ការចូលរួម និងពិភាក្សាក្នុងកម្រិតបច្ចេកទេសសម្រាប់ទៅពិភាក្សាជាមួយថៃ ក្នុងនាមក្រសួងជំនាញតំណាងឲ្យរាជរដ្ឋាភិបាល និងត្រូវខិតខំធ្វើយ៉ាងណាឲ្យសម្រេចបាននូវឯកសារជាផ្លូវការដើម្បីគ្រប់គ្រងករណី នៃការនៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស ប្រកបដោយសុវត្ថិភាព និងមានប្រសិទ្ធភាពទៅក្នុងក្រុមគ្រួសារ និងសហគមន៍ ដើម្បីទទួលបានសេវាសមស្រប និងទទួលបានសេចក្តីថ្លៃថ្នូរ សុខុមាលភាព និងសិទ្ធរបស់ពួកគាត់៕

## ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ ប្រាប់ពលករខ្មែរត្រឡប់ពីថៃ ដែលបានចាក់វ៉ាក់សាំងការពារកូវីដ១៩ ពេញលេញ មិនតម្រូវឲ្យធ្វើចត្តាឡីស័កនោះឡើយ តែត្រូវធ្វើតេស្តរហ័ស

http://freshnewsasia.com/ 2021-11-15 05:53pm

**(បន្ទាយមានជ័យ)៖** លោកវេជ្ជៈបណ្ឌិត ឡេ ចាន់សង្វាត ប្រធានមន្ទីរសុខាភិបាលខេត្តបន្ទាយមានជ័យ នៅថ្ងៃ១៥ ខែវិច្ឆិកា ឆ្នាំ២០២១នេះ បានប្រាប់ពលករខ្មែរត្រឡប់ពីប្រទេថៃចូលមកកម្ពុជាវិញ ដែលបានចាក់វ៉ាក់សាំងការពារកូវីដ១៩ ពេញលេញមិនចាំបាច់ធ្វើចត្តាឡីស័កនោះឡើយ តែត្រូវធ្វើតេស្តរហ័ស។ ចំពោះពលករណា ដែលទទួលបានលទ្ធផលអវិជ្ជមាន រថយន្តក្រសួងការពារជាតិនឹងដឹកជញ្ជូនដល់លំនៅដ្ឋានរបស់ពួកគេតែម្តង។ ការលើកឡើងបែបនេះបន្ទាប់ពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្រ្តីនៃកម្ពុជា បានសម្រេចអនុញ្ញាតឲ្យអ្នកដំណើរទាំងជនជាតិខ្មែរ និងជនជាតិបរទេសទាំងអស់ ធ្វើដំណើរចូលកម្ពុជា ហើយបានចាក់វ៉ាក់សាំងពេញលេញ (២ដូស) គឺមិនតម្រូវឲ្យធ្វើចត្តាឡីស័កទៀតទេ។ លោកប្រធានមន្ទីសុខាភិបាល បានបញ្ជាក់ថា អ្នកដែលមិនទាន់បានចាក់វ៉ាក់សាំងការពារជំងឺកូវីដ១៩ទេ តម្រូវឲ្យធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃ ហើយពលករខ្មែរដែលរកឃើញវិជ្ជមានកូវីដ១៩ ដោយតេស្តរហ័សត្រូវបានបញ្ជូន ទៅព្យាបាលនៅមណ្ឌលកងវ៉ាក្រុងសិរីសោភ័ណ។

នាឱកាសនេះ លោកវរសេនីយ៍ទោ ម៉ាន់ ធី អធិការរងនគរបាលស្រុកអូរជ្រៅ បានប្រាប់ឲ្យដឹងថា ពលករខ្មែរដែលត្រឡប់ពីប្រទេសថៃ ចូលមកកម្ពុជា តាមច្រកអូរបីជាន់ ស្រុកអូរជ្រៅ និងច្រកតំបន់ព្រំដែនបឹងត្រកួនស្រុកថ្មពួក រយៈពេល២ថ្ងៃចាប់ពីថ្ងៃទី១៣-១៤ ខែវិច្ឆិកា ឆ្នាំ២០២១ បានទទួលពលករខ្មែរចំនួន៣០១នាក់ ស្រី១៤៦នាក់ កុមារ៣៨នាក់ស្រី២២នាក់ និងរកឃើញអ្នកវិជ្ជមានកូវីដមានចំនួន១១នាក់៕

## ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១

### ទោះបានជាប់ទៅធ្វើការនៅជប៉ុន តែពលករខ្មែរ ត្រូវអនុវត្តតាមប៉ុន្មានចំណុចនេះសិន!

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

(ភ្នំពេញ)៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅថ្ងៃទី១៥ ខែវិច្ឆិកានេះ បានចេញសេចក្តីជូនដំណឹងស្តីពីនីតិវិធីសម្រាប់កម្មសិក្សាការី-ពលករជំនាញកម្ពុជា ទៅធ្វើការនៅប្រទេសជប៉ុន ស្របតាមវិធានការព្រំដែនថ្មីរបស់រដ្ឋាភិបាលជប៉ុន។ ក្នុងសេចក្តីជូនដំណឹង ក្រសួងការងារបានជម្រាបទៅដល់សាធារណជន ទីភ្នាក់ងារជ្រើសរើសឯកជន និងកម្មសិក្សាការី-ពលករជំនាញ ដែលត្រៀមចេញដំណើរទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុនទាំងអស់ ឱ្យបានជ្រាបថា រដ្ឋាភិបាលនៃប្រទេសជប៉ុន បានសម្រេចអនុញ្ញាតឱ្យជនបរទេស រួមទាំងកម្មសិក្សាការី-ពលករជំនាញកម្ពុជា ចូលប្រទេសជប៉ុនឡើងវិញ ចាប់ពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១នេះតទៅ ដោយត្រូវអនុវត្តទៅតាមនីតិវិធីដូចខាងក្រោម៖

សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវ៖ ១. សហការជាមួយក្រុមហ៊ុនទទួល ឬសមាគមនៅប្រទេសជប៉ុន ដើម្បីស្នើសុំលិខិតអនុញ្ញាតសម្រាប់កម្មសិក្សាការី-ពលករជំនាញចូលប្រទេសជប៉ុន ដែលចេញដោយក្រសួង ឬភ្នាក់ងារមានសមត្ថកិច្ចនៃប្រទេសជប៉ុន និង២. ត្រូវភ្ជាប់បន្ថែមនូវលិខិតអនុញ្ញាតសម្រាប់កម្មសិក្សាការី-ពលករជំនាញចូលប្រទេសជប៉ុន នៅពេលស្នើសុំទិដ្ឋាការជូនកម្មសិក្សាការី-ពលករជំនាញ នៅស្ថានទូតជប៉ុនប្រចាំកម្ពុជា។ ដោយឡែក កម្មសិក្សាការី-ពលករជំនាញត្រូវ៖ ១. មានវិញ្ញាបនបត្របញ្ជាក់លទ្ធផលតេស្តកូវីដ១៩ អវិជ្ជមាន ក្នុងរយៈពេល ៧២ម៉ោង មុនពេលចាកចេញទៅប្រទេសជប៉ុន។ ២. បំពេញកិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័ក ដែលតម្រូវដោយរដ្ឋាភិបាលនៃប្រទេសជប៉ុនមុនពេលចាកចេញទៅប្រទេសជប៉ុន។ ៣. ទាញយក និងចុះឈ្មោះក្នុងកម្ម

វិធី Covid-19 Contact-Confirming Application ក្នុងទូរស័ព្ទដៃមុនពេលចាកចេញទៅប្រទេសជប៉ុន។ ៤. ផ្ដល់កិច្ចសន្យាអនុវត្តវិធានការចត្តាឡីស័ក ជូនការិយាល័យទទួលបន្ទុកអនុវត្តចត្តាឡីស័កនៅអាកាសយានដ្ឋានប្រទេសជប៉ុន និង៥. អនុវត្តការធ្វើចត្តាឡីស័ក ទៅតាមវិធានការរបស់រដ្ឋាភិបាល នៃប្រទេសជប៉ុន នៅពេលទៅដល់ប្រទេសជប៉ុន។ ក្រសួងការងារបានគូសបញ្ជាក់ថា ក្នុងករណីដែលកម្មសិក្សាការី-ពលករជំនាញ មិនអនុវត្តតាមគោលការណ៍ណែនាំនៅប្រទេសជប៉ុន អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសជប៉ុន នឹងចាត់វិធានការតាមផ្លូវច្បាប់៕

## ជនជាតិថៃជាង៦០នាក់ដែលក្រុមជួញដូរបង្ខាំង ត្រូវបានរំដោះនិងប្រគល់ឲ្យសមត្ថកិច្ចថៃវិញ

http://nokorwatnews.com/ 15/11/2021

ក្រុងប៉ោយប៉ែត៖ កម្លាំងសមត្ថកិច្ចកម្ពុជាបានចូលទៅរំដោះបុគ្គលិកជនជាតិថៃជាង៦០នាក់ ដែលត្រូវថៅកែល្បែងតាមអនឡាញជនជាតិចិនក្នុងក្រុងប៉ោយប៉ែត ជាក្រុមជួញដូរមនុស្សបង្ខំឲ្យធ្វើការខុសច្បាប់ រួមទាំងធ្វើទុក្ខបុកម្នេញ និងលក់បន្តទៅឲ្យថៅកែអនឡាញជនជាតិចិនផ្សេង បើមិនអាចធ្វើការបាន។លើសពីនេះទៀត បើចង់ត្រឡប់ទៅប្រទេសថៃវិញត្រូវយកលុយមកលស់ក្នុងម្នាក់ៗចាប់ពី៣០,០០០-៥០,០០០បាត។

ប្រភពពីសមត្ថកិច្ចកម្ពុជាបានឲ្យដឹងថា ក្រោយពីកម្លាំងសមត្ថកិច្ចកម្ពុជារំដោះជនជាតិថៃជាង៦០នាក់បានហើយ ក៏បានប្រគល់ពួកគេទាំងប្រុស-ស្រីជាង៦០នាក់ ទៅឲ្យភាគីថៃនៅលើស្ពានមិត្តភាពកម្ពុជា-ថៃកាលពីវេលាម៉ោង១០ព្រឹក ថ្ងៃទី១៥ វិច្ឆិកា២០២១នេះ។ ប្រភពច្បាស់ការប្រាប់ថា បញ្ហាខាងលើនេះជនរងគ្រោះជាជនជាតិថៃបានប្ដឹងទៅស្ថានទូតថៃនៅព្រះរាជាណាចក្រថៃទើបកម្លាំងជម្នាញថៃផ្ដល់ព័ត៌មានទៅស្ថានទូតថៃប្រចាំព្រះរាជាណាចក្រកម្ពុជាដើម្បីសុំកម្លាំងសហការនិងជួយសង្គ្រោះជនជាតិថៃដែលត្រូវក្រុមជួញដូរមនុស្សធ្វើទុក្ខបុកម្នេញ។ ប្រភពដដែលបន្តថា ក្រោយពីទទួលកិច្ចអន្តរាគមន៍ពីស្ថានទូតថៃប្រចាំកម្ពុជា ទើបកម្លាំងជំនាញរបស់ក្រសួងមហាផ្ទៃសុំកិច្ចសហការជាមួយកម្លាំងសមត្ថកិច្ចខេត្តបន្ទាយមានជ័យដើម្បីស្រាវជ្រាវ។

បន្ទាប់ពីស្រាវជ្រាវយ៉ាងយូរកម្លាំងសមត្ថកិច្ចជំនាញបានរំដោះជនជាតិថៃទាំងនោះចេញពីកន្លែងធ្វើការកាលពីថ្ងៃទី១៤ខែឆ្នាំដដែល ហើយយកជនជាតិថៃប្រុស ស្រីទាំងអស់ទៅរក្សានៅកន្លែងកម្លាំងនគរបាលវរការពារព្រំដែនគោក៩១១។ លុះនៅព្រឹកថ្ងៃទី១៥ ខែវិច្ឆការ ឆ្នាំ២០២១នេះ ជនជាតិថៃទាំងអស់នោះត្រូវបានកម្លាំងជំនាញកម្ពុជាប្រគល់ជូនកម្លាំងសមត្ថកិច្ចថៃនៅលើស្ពានច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត។

ប្រភពដាច់ដោយឡែកមួយទៀតថា ក្នុងករណីនេះតើកម្លាំងសន្តិសុខផ្ទៃក្នុងរបស់ក្រសួងមហាផ្ទៃដែលឈរជើងនៅក្រុងប៉ោយប៉ែតរាប់សិបនាក់ មានតួនាទីធ្វើអ្វីបានជាមិនដឹងរឿង? លុះជនរងគ្រោះជនជាតិថៃប្ដឹងទៅស្ថានទូតរបស់គេថាមានថៅកែអនឡាញចិនបង្ខំឲ្យជនជាតិថៃជាង៦០នាក់ ដើម្បីធ្វើការងារឲ្យគេទៅវិញ ហើយនៅពេលកម្លាំងក្រសួងមហាផ្ទៃចុះមកជួយសង្គ្រោះទើបដឹង។ ម្យ៉ាងទៀតល្បែងនៅទីក្រុងប៉ោយប៉ែតមិនត្រូវបានបិទនោះទេ មានដំណើការបើករហូតតាំងពីដំណាក់កាលcovid-19ដំបូងរហូតទល់បច្ចុប្បន្ន។

បញ្ហាខាងលើនេះ អ្នកយកព័ត៌មាននគរវត្តសុំការបំភ្លឺពីសមត្ថកិច្ចជំនាញតាមតេលេក្រាម តែមិនមានការឆ្លើយតប៕

## ចាប់ខ្លួនពលរដ្ឋខ្មែរប្រុសស្រីមកពី៥ខេត្ត ចំនួន២១នាក់ បម្រុងលួចឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ០៩:២១

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលប៉ុស្តិ៍ការពារព្រំដែនក្បាលទំនប់ នៃវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាប្រតិបត្តិការសិករងស្រុកម៉ាឡៃ នៅវេលាម៉ោង០៦និង៥០នាទីយប់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរប្រុសស្រីចំនួន២១នាក់ ដែលបម្រុងលួចឆ្លងដែន

ដោយខុសច្បាប់ទៅប្រទេសថៃ នៅចំណុចគោលដៅដើមធ្នង់ ស្ថិតក្នុងភូមិសាស្រ្ត ភូមិក្បាលទំនប់ ឃុំអូរសំពរ ស្រុកម៉ា ឡៃ ខេត្តបន្ទាយមានជ័យ ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថាៈ ប្រជាពលរដ្ឋខ្មែរចំនួន២១នាក់ ក្នុងនោះស្រីចំនួន០៧នាក់ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ហើយក៏ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ការពារព្រំដែនក្បាលទំនប់ សហការជាមួយកម្លាំងយោធាប្រតិបត្តិការសិករង ស្រុកម៉ាឡៃ ធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរទាំងនោះមកពី០៥ខេត្ត ក្នុងនោះ ១-បន្ទាយមានជ័យ ចំនួន០៣នាក់, ២-កំពង់ធំ ចំនួន០៧នាក់, ៣-បាត់ដំបង ចំនួន០៣នាក់, ៤-ត្បូងឃ្មុំ ចំនួន០៧នាក់ និង៥-កំពត ចំនួន០១នាក់ ។ លោកមេបញ្ជាការបានបញ្ជាក់ថាៈ ក្រោយពីទប់ស្កាត់ សមត្ថកិច្ចក៏បាននាំប្រជាពលរដ្ឋទាំងនោះមកសួរនាំ និងធ្វើកិច្ចសន្យា រួចក៏បានប្រគល់ពួកគាត់ជូនទៅផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីមានវិធានការបន្តតាមនីតិវិធី ៕

## ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

### ពលករខ្មែរ២១នាក់ត្រូវបាននគរបាលឃាត់ខ្លួនសួរនាំ ខណៈបម្រុងឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 16/11/2021

ខេត្តបន្ទាយមានជ័យ ៖ ពលករប្រុសស្រីចំនួន២១ នាក់ ត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ក្បាលទំនប់ នៃបញ្ជាការវរៈការពារព្រំដែនគោក លេខ៨១៥ សហការជាមួយកម្លាំងយោធាប្រតិបត្តិការសឹករងស្រុកម៉ាឡៃ ស្ទាក់ឃាត់ខ្លួនសួរនាំ ខណៈព្យាយាមឆ្លងដែនខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃ។ ការឃាត់សួរនាំនោះធ្វើឡើងកាលពីវេលាម៉ោង៧យប់ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅចំនុចគោលដៅដើមធ្នង់ ក្នុងភូមិសាស្រ្ត ភូមិក្បាលទំនប់ ឃុំអូរសំពរ ស្រុកម៉ា ឡៃ ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ បានឲ្យដឹងថា ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ក្នុងការទប់ស្កាត់រាល់បទល្មើសតាមព្រំដែន ពិសេសបទល្មើសពលករឆ្លងដែនខុសច្បាប់នោះ កម្លាំងនគរបាលការពារព្រំដែនតែងតែល្បាតទ្រាលសភាពការណ៍ ហើយនៅល្ងាចថ្ងៃចន្ទម្សិលមិញនេះ ក៏បានស្ទាក់ឃាត់ពលរដ្ឋខ្មែរបាន២១នាក់ យកមកសួរនាំខណៈដែលពួកគាត់បម្រុងឆ្លងដែនខុសច្បាប់ចូលទឹកដីថៃ។ លោកមេបញ្ជាការបានបន្តថា ប្រជាពលរដ្ឋខ្មែរ ចំនួន២១នាក់ ស្រីចំនួន០៧នាក់ បម្រុងលួចឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ ហើយត្រូវបានកម្លាំងនគរបាលប៉ុស្តិ៍ការពារព្រំដែនក្បាលទំនប់ សហការជាមួយកម្លាំងយោធាប្រតិបត្តិការសិករងស្រុកម៉ាឡៃ ទប់ស្កាត់នោះ មកពី០៥ខេត្ត ក្នុងនោះ ១-បន្ទាយមានជ័យ ០៣នាក់, ២-កំពង់ធំ ០៧នាក់, ៣-បាត់ដំបង ០៣នាក់, ៤-ត្បូងឃ្មុំ ០៧នាក់, ៥-កំពត ០១នាក់ ។ បច្ចុប្បន្នពលករទាំងនោះ ត្រូវបានប្រគល់ជូនផ្នែកជំនាញរបស់អធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ចាត់ការបន្តតាមនីតិវិធី៕

### មន្ត្រីក្រសួងមហាផ្ទៃអំពាវនាវដល់ពលរដ្ឋកុំឆ្លងដែនទៅរកការងារនៅថៃតាំងប្រថុយប្រថាន

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 17/11/2021 - 07:17

ខណៈពលរដ្ឋខ្មែរជាក្រុមៗបាននាំគ្នាចេញទៅរកការងារធ្វើនៅប្រទេសថៃ រាប់ចាប់តាំងពីចុងខែតុលាមកដល់ឥលូវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅថ្ងៃទី១៧ វិច្ឆិកានេះបានអំពាវនាវឲ្យពួកគេរងចាំបន្តិចសិន កុំឆ្លងដែន

ទាំងប្រថុយប្រថានក្នុងដំណាក់កាលមិនច្បាស់លាស់នៃវិបត្តិកូវីដ១៩។ បើតាមមន្ត្រី ដដែលក្រសួងពាក់ព័ន្ធកំពុងរកដំណោះស្រាយលៃលកធ្វើយ៉ាងណាឲ្យពលករទទួលបានភាពសមធម៌ រវាងប្រទេសបញ្ជូន និងប្រទេសទទួលក្នុងដំណាក់កាលថ្មី។ ពលករខ្មែរដែលនាំគ្នាចេញទៅរកការងារធ្វើនៅប្រទេសថៃតាមច្រកព្រំដែន មិនក្រោម២០នាក់ឡើយនៅរៀងរាល់ថ្ងៃ ត្រូវបានអាជ្ញាធរខ្មែរប្រចាំការនៅព្រំដែនចាប់បញ្ជូនត្រឡប់មកវិញ ដែលគិតជាសរុបប្រមាណជា១ពាន់នាក់បានកត់ត្រាក្នុងបញ្ជីនៃការបញ្ជូនត្រឡប់មកវិញ រាប់ចាប់តាំងពីចុងខែតុលាមកដល់ឥលូវ។ តែក៏នៅមានអ្នកដែលរបូតទៅដល់ដីថៃបានសម្រេចដែរ ប៉ុន្តែមិនមានចំនួនច្រើនទេ។ ថ្លែងប្រាប់វិទ្យុបារាំងអន្តរជាតិនៅថ្ងៃពុធទី១៧វិច្ឆិកានេះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានគូសបញ្ជាក់ថាទោះជាពលករខ្មែរមួយចំនួនទៅដល់ដីថៃ ក៏គង់តែអាជ្ញាធរថៃចាប់បញ្ជូនត្រឡបមកវិញដដែលទេ។ លោកស្រីបន្ថែមថា ដំណាក់កាលនេះមិនមែនជាពេលវេលា ដែលពលរដ្ឋត្រូវសម្រុកចេញទៅធ្វើការនៅថៃដោយខុសច្បាប់ និងប្រថុយប្រថានអ៊ីចឹងទេ! ព្រោះត្រូវចំណាយលុយក្រៅផ្លូវការកាន់ច្រើនពេលទៅដល់ប្រទេសថៃ។ នៅពេលដែលពលករខំប្រឹងជម្នះទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ពួកគេនឹងជួបបទពិសោធន៍ចាស់ដដែលដោយបន្តធ្វើជាកម្មករថៃរហូតតដល់កូន ដើម្បីទូទាត់ថ្លៃបំណុលរបស់ឳពុក-ម្ដាយ ដែលបានជំពាក់តាមរយៈការចំណាយលុយក្រៅផ្លូវការជាថ្នូរនឹងការបានការងារនៅស្រុកគេ។ នេះជាកង្វល់របស់លោកស្រី ជូរ ប៊ុនអេង ។

ដូចគ្នាដែរ លោក លឹង សុផុន មន្ត្រីសិទ្ធិការងារទទួលបន្ទុកផ្នែកពលករចំណាកស្រុករបស់អង្គការសង់ត្រាល់ ប្រចាំប្រទេសថៃ បានថ្លែងថា ការបន្តវិលចូលប្រទេសថៃ នៅគ្រានេះ មិនមែនជារឿងងាយស្រួលឡើយ ពីព្រោះពលករខ្មែរត្រូវចំណាយលុយក្រៅផ្លូវការកាន់ច្រើន។ ម្យ៉ាងទៀតលោកថានៅប្រទេសថៃគ្រានេះ ការរស់នៅ និងធ្វើការមិនមានសេរីភាពដូចមុនឡើយ។ ដូច្នេះហើយទើបលោកស្រីស្នើឲ្យពលករខ្មែររងចាំបន្តិចសិន ដើម្បីទទួលបានសិទ្ធិជាពលករស្របច្បាប់ព្រោះបើតាមលោកស្រី ថៃនិងកម្ពុជាកំពុងធ្វើការរួមគ្នាលើបញ្ហានេះ ក្នុងដំណាក់កាលថ្មីលៃលកធ្វើយ៉ាងណាឲ្យពលករទទួលបានភាពសមធម៌ រវាងប្រទេសបញ្ជូននិងប្រទេសទទួល។ អំឡុងពេលរងចាំ រដ្ឋាភិបាលកម្ពុជាក៏មិនបានឱបដៃឈរមើលភាពខ្វះខាតរបស់ពលករខ្មែរដែរតាមរយៈជំនួយសង្គមក្រោយពួកគេទៅដល់ភូមិកំណើត។ បើតាមមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃរូបនេះរាប់ចាប់តាំងពីដើមឆ្នាំ២០២០មកដល់ជិតដំណាច់ឆ្នាំ២០២១នេះមានពលករខ្មែរប្រមាណ២៦ម៉ឺននាក់បានបញ្ជូនមកដល់ដីកម្ពុជា។ ចាប់តាំងពីពេលនោះមកដល់ពេលបច្ចុប្បន្នក៏ព្រំដែនកម្ពុជាថៃនៅតាមបណ្ដាខេត្តមួយចំនួនបើកទ្វារអនុញ្ញាត្តឲ្យពលរដ្ឋចេញចូលរកការធ្វើដូចគ្រាមុនដែរ៕

**ពលករខ្មែរចំនួន ៣២ នាក់ ត្រូវបានបញ្ជូនមកមាតុប្រទេសវិញ**

https://www.kampucheathmey.com/ ថ្ងៃពុធ ១៧ វិច្ឆិកា ២០២១ដោយ KC Virak

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិតបត្តិការអន្តរជាតិកម្ពុជា បានឱ្យដឹងនារសៀលថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០២១ នេះថា កាលពីយប់ថ្ងៃទី ១៦ ខែវិច្ឆិកានេះ អាជ្ញាធរមានសមត្ថកិច្ចថៃបានឃាត់ខ្លួនពលករខ្មែរ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតយកឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ចំនួន ៣២ នាក់ (ប្រុស ១៩ នាក់)។ បើតាមលោក កុយ គួង បានឱ្យដឹងបន្ថែមថា បន្ទាប់ពីទទួលបានព័ត៌មាននេះភ្លាម ស្ថានអគ្គកុងស៊ុលកម្ពុជាបានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើមកមាតុប្រទេសវិញនៅរសៀលថ្ងៃទី ១៧ ខែវិច្ឆិកា នេះ តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល។

គួររំលឹកថា កាលពីទី ១៣ ខែវិច្ឆិកា ឆ្នាំ២០២១ អាជ្ញាធរមានសមត្ថកិច្ចថៃ ក៏បានឃាត់ខ្លួនពលករខ្មែរដែលត្រូវបានមេខ្យល់បោកបញ្ឆោតយកឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ចំនួន ២២ នាក់ (ប្រុស១៨ នាក់) ផងដែរ។ បន្ទាប់ពីទទួលបានព័ត៌មានភ្លាម ស្ថានអគ្គកុងស៊ុលកម្ពុជាបានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើមកមាតុប្រទេសវិញនៅរសៀលថ្ងៃដដែល តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕ អត្ថបទ៖ កោះកែវ

## ជនល្មើស បានប្រើប្រាស់កម្មវិធីបណ្តាញសង្គម លើប្រព័ន្ធអ៊ីនធឺណិត ជាមធ្យោបាយធ្វើការលួងលោមកុមារ ដើម្បីធ្វើការចែកចាយរូបភាព សម្ភារៈអាសអាភាសកុមារ

https://cen.com.kh/ Posted ByPen Srey NeatNovember 18, 2021

កែប ៖ ពាក់ព័ន្ធនឹងអំពីបទល្មើសពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញ ឧត្តមសេនីយ៍ឯក ជា ពៅ បានលើកឡើងថា ជនល្មើសដែលបានប្រើបាស់កម្មវិធីបណ្តាញសង្គម លើប្រព័ន្ធអ៊ីនធឺណិត ជាមធ្យោបាយធ្វើការលួងលោមកុមារ ដែលជាអនីតិជន ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាផ្សេងៗ ដើម្បីធ្វើការចែកចាយរូបភាព សម្ភារៈអាសអាភាសកុមារ។

ឯកឧត្តម ឧត្តមសេនីយ៍ឯក ជា ពៅ ប្រធាននាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បានថ្លែងបែបនេះ ក្នុងឱកាសចូលរួមជាវាគ្មិន ធ្វើបទអន្តរាគមន៍លើប្រធានបទ "ច្បាប់ និងបទល្មើសពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមអនឡាញ" ដែលបានប្រព្រឹត្តនាថ្ងៃទី ១៦-១៧ ខែវិច្ឆិកា ឆ្នាំ២០២១ នៅខេត្តកែប ។ ឧត្តមសេនីយ៍ឯក ជា ពៅ បានលើកឡើងថា វគ្គបណ្តុះបណ្តាលនេះត្រូវបានរៀបចំឡើងដោយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងគោលបំណងលើកកម្ពស់ ការយល់ដឹងពីការប្រើប្រាស់កម្មវិធីបណ្តាញសង្គមហ្វេសប៊ុក ប្រកបដោយសុវត្ថិភាព ដល់កុមារនិងយុវជន ក៏ដូចជាស្វែងយល់អំពីបទល្មើសពាក់ព័ន្ធនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ (OCSE) ការឆ្លើយតបខាងផ្លូវច្បាប់ និងបណ្តាញរាយការណ៍បន្ទាន់ (Internet Hotline) ។

ក្នុងនោះដែរ នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា បានធ្វើការចែករំលែកនូវបទពិសោធន៍ស្រាវជ្រាវ និងបង្ក្រាបជនល្មើសពាក់ព័ន្ធ នឹងការរំលោភបំពាន និងការកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ដោយសង្កត់ធ្ងន់ទៅលើសកម្មភាពជនល្មើស ដែលបានប្រើបាស់កម្មវិធីបណ្តាញសង្គម លើប្រព័ន្ធអ៊ីនធឺណិត ជាមធ្យោបាយធ្វើការលួងលោមកុមារ ដែលជាអនីតិជន ការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាផ្សេងៗ ដើម្បីធ្វើការចែកចាយរូបភាព សម្ភារៈអាសអាភាសកុមារ ការលេចឡើងនៃសញ្ញាណថ្មីៗ របស់ជនសង្ស័យ ជាជានជាតិខ្មែរ ប្រព្រឹត្តអំពើរំលោភបំពានផ្លូវភេទកុមារ តាមប្រព័ន្ធអនឡាញ ក៏ដូចជាបញ្ហាប្រឈមពាក់ព័ន្ធនឹងផ្លូវច្បាប់៕ រក្សាសិទ្ធិដោយ៖ កូលាប

## ម៉ាស៊ីនផ្លុំខ្យល់អុកស៊ីសែនរលត់ ធ្វើឲ្យពលករខ្មែរម្នាក់ ស្លាប់នៅបាតសមុទ្រ នាក្រុងផាត់តាយ៉ា

https://www.kampucheathmey.com/ ថ្ងៃព្រហស្បតិ៍ ១៨ វិច្ឆិកា ២០២១ដោយ sopheak khoun

ពលករខ្មែរម្នាក់ បានស្លាប់នៅក្រោមផ្ទៃទឹក ខណៈមុជរកគ្រុំនៅបាតសមុទ្រ ដែលមានជម្រៅជ្រៅ ស្រាប់តែម៉ាស៊ីនផ្លុំខ្យល់ អុកស៊ីសែន ដែលនៅលើទូករលត់ ធ្វើឲ្យជនរងគ្រោះស្លាប់ ដោយគ្មានខ្យល់ដកដង្ហើម។ ហេតុការណ៍នេះ កើតឡើងនៅវេលាម៉ោង ២រសៀល ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០២១ នៅចំណុចលើផ្ទៃទឹកសមុទ្រនាក្រុងផាត់តាយ៉ា ក្នុងឃុំណាក្លឿ ស្រុកបាងឡាក់មុង ខេត្តឈុនបុរី។

ជនរងគ្រោះមានឈ្មោះ ឡុង សារឿង ភេទប្រុស អាយុ ៤១ឆ្នាំ។ រីឯម្នាក់ទៀត ដែលជាអ្នកនាំសពយកមកប្រាំង មានឈ្មោះ ពេជ្រ កុមារ ភេទប្រុស អាយុ ៣៧ឆ្នាំ បានរៀបរាប់ថា កាលពីវេលាម៉ោង ១០ព្រឹក ថ្ងៃទី ១៧ ខែ

វិច្ឆិកា ឆ្នាំ ២០២១ ពួកគេទាំង ២នាក់ បានចេញទូកទៅកណ្តាលសមុទ្រ ដើម្បីរកគ្រុំ និងរបស់ផ្សេងៗ ទៀត នៅបាតសមុទ្រ ដែលនៅទីនោះមានជម្រៅប្រហែល ៧ម៉ែត្រ។ សាក្សីរូបនេះបានបន្តថា ពេលមុជទៅបាតសមុទ្រ គឺពួកគេបានប្រើប្រាស់ខ្សែទម្លាក់ចេញពីទូក និងបំពាក់ទុយោខ្យល់អុកស៊ីសែនរៀងៗខ្លួន ដែលបញ្ចូនខ្យល់តាមរយៈម៉ាស៊ីននៅលើទូក។ ខណៈដែលជនរងគ្រោះ មុជដល់បាតសមុទ្រ ស្រាប់តែម៉ាស៊ីននៅខាងលើទូករលត់ ធ្វើឲ្យលែងមានខ្យល់ដកដង្ហើម។ ចំពោះបុរសជាសាក្សី បានទាញខ្សែដែលចងជាប់ទូក ស្ទុះឡើងមកលើផ្ទៃទឹក រីឯជនរងគ្រោះដែលស្លាប់ គឺមិនបានទាញខ្សែឡើងទេ គឺគេជាក់ជីស្ទុះហែលឡើងតែមិនទាន់ពេល ក៏ដាច់ខ្យល់ស្លាប់នៅក្នុងទឹកតែម្តង។

បុរសឈ្មោះ ពេជ្រ កុមារ បានមុជទៅម្តងទៀត ដើម្បីទាញសពដាក់លើទូក នាំយក មកកាន់ច្រាំង ហើយក៏បានរាយការណ៍ទៅសមត្ថកិច្ចតែម្តង។ ក្រោយពេលកើតហេតុ សមត្ថកិច្ចថៃ បាននាំយកសពទៅពិនិត្យ និងធ្វើកោសល្យវិច័យ នៅឯមន្ទីរពេទ្យបន្ថែមទៀត។ បន្ទាប់មកពិនិត្យឃើញថា គ្មានស្លាកស្នាមណាមួយ ពាក់ព័ន្ធនឹងអំពើឃាតកម្មឡើយ៕ អត្ថបទ៖ សោ និយមរ័ត្ន

## ពលករខ្មែរពលករជាង ៣០ នាក់ត្រូវថៃបញ្ជូនមកកម្ពុជាវិញ

https://www.khmertimeskh.com/ November 18, 2021

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លោក កុយ គួង បានរាយការណ៍ថា កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសថៃបានបញ្ជូនពលរដ្ឋខ្មែរជាង៣០នាក់មកកម្ពុជាវិញ។ ពលករទាំងនោះ ត្រូវមេខ្យល់បោកប្រាស់ ដែលក្រុមនេះមានពលរដ្ឋខ្មែរចំនួន ៣២នាក់ ស្រី១៣នាក់។ លោកបាននិយាយថា៖«នៅយប់ថ្ងៃទី១៦ ខែវិច្ឆិកា អាជ្ញាធរថៃបានចាប់ខ្លួនពលករខ្មែរចំនួន ៣២ នាក់ដែលត្រូវមេខ្យល់បោក នាំចូលប្រទេសថៃដោយខុសច្បាប់»។ ភ្លាមៗ បន្ទាប់ពីទទួលបានដំណឹងនៃការចាប់ខ្លួនពលរដ្ឋខ្មែរទាំង៣២នាក់ ស្ថានអគ្គកុងស៊ុលកម្ពុជាបានអន្តរាគមន៍បញ្ជូនពលករមកកម្ពុជាវិញ។ ពលរដ្ឋខ្មែរទាំងនោះ បានត្រឡប់មកកម្ពុជាវិញនៅថ្ងៃទី១៧ ខែវិច្ឆិកាតាមច្រកទ្វារអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត បន្ទាប់មកពួកគេត្រូវបានប្រគល់ឱ្យអាជ្ញាធរកម្ពុជាដើម្បីចាត់ការតាមនីតិវិធី។ ដោយសារជំងឺកូវីដ-១៩ នៅតែបន្តប៉ះពាល់ដល់សេដ្ឋកិច្ច ប្រជាជនកម្ពុជាកាន់តែច្រើនឡើងៗ បន្តឆ្លងព្រំដែនចូលប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ។

ប្រទេសថៃបានរាយការណ៍ថា ជនចំណាកស្រុកខុសច្បាប់ជាង ៣០.០០០នាក់ ត្រូវបាននិរទេសចេញពីប្រទេសថៃ ក្នុងនោះ រួមមានជនជាតិខ្មែរ៕

## ក្នុងមួយថ្ងៃៗ មានពលករចំណាកស្រុកកម្ពុជា ឆ្លងដែនវិលត្រឡប់ពីប្រទេសថៃ ចំនួន ៤០០ នាក់ អំឡុងពេលនៃការរាតត្បាតកូវីដ ១៩

https://www.postkhmer.com/national/ រី សុចាន់ | Publication date 18 November 2021 | 13:51 ICT

**ភ្នំពេញ:** អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) បានឱ្យដឹងថា ក្នុងមួយថ្ងៃៗគិតជាមធ្យម មានពលករចំណាកស្រុកកម្ពុជា ដែលបានឆ្លងដែនវិលត្រឡប់ ពីប្រទេសថៃ មកកម្ពុជាវិញ មានចំនួន ៤០០ នាក់ ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ ១៩។ IOM បញ្ជាក់ក្នុងហ្វេសប៊ុកនៅថ្ងៃទី ១៨ ខែវិច្ឆិកា ថា តាមរយៈការគាំទ្ររបស់អង្គការ IOM ពលករដែលវិលត្រឡប់មកវិញនេះ ទទួលបានអាហារ ទឹក និងវិធានការការពារខ្លួនពីជំងឺកូវីដ ១៩ នៅតាមច្រកចូល។ IOM លើកឡើងថា៖ «ខណៈដែលប្រទេសជាច្រើនក្នុងតំបន់កំពុងត្រៀមរៀបចំត្រលប់ទៅរកការរស់នៅតាមបែបគន្លងថ្មី និងបើកព្រំដែនប្រទេសរបស់ខ្លួនឡើងវិញ ការយកចិត្តទុកដាក់ជាច្រើនត្រូវធ្វើឡើង ដើម្បី

សម្របសម្រួលឱ្យមាន ទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងទៀងទាត់ សំដៅការពារទាំងជនទេសន្តរប្រវេសន៍ និងសហគមន៍ពីជំងឺរីករាលដាលជាសកលផ្សេងៗ ដែលអាចកើតមាននាពេលអនាគត»៕

## កម្មករខ្មែរ២នាក់ រងរបួសស្ទើរបាត់បង់ជីវិត ដោយសារអគារបាក់ស្រុតសង្កត់ពេលចាក់ប្លង់សេ

https://www.kampucheathmey.com/ ថ្ងៃសុក្រ ១៩ វិច្ឆិកា ២០២១ដោយ deth leng

ពលករខ្មែរប្រុស ស្រី ចំនួន ២ នាក់ បានរងរបួសធ្ងន់ ខណៈដែលពួកគេកំពុងធ្វើការនៅលើអគារជាន់ទី៥ ស្រាប់តែជ្រុងមួយនៃជាន់ទី៦ បានបាក់ស្រុតមកសង្កត់តែម្តង ពេលកំពុងចាក់បេតុងប្លង់សេ។ ហេតុការណ៍នេះបានកើតឡើង នៅវេលាម៉ោង ៩ និង៤៥ នាទី ព្រឹកថ្ងៃទី ១៨ វិច្ឆិកា ឆ្នាំ២០២១ ត្រង់ចំណុចអគារកំពុងកសាងមួយកន្លែង នៅក្នុងបរិវេណ មហាវិទ្យាល័យ តិចណូឡូជី រាជមង្គលរតនៈកោសិន ក្នុងខេត្តណាក់ខនប៉ាថុំ ប្រទេសថៃ។ អគារដែលកំពុងកសាង មានកម្ពស់ ៦ ជាន់ ដោយនៅមុនពេលកើតហេតុ គឺមានការចាក់ប្លង់សេនៅលើជាន់ទី៦ ដែលទំនងជាដែកជើងទម្រ មិនអាចទ្រទម្ងន់បាន ទើបធ្វើអោយជ្រុងម្ខាងនៃអគារ បានបាក់ស្រុតមកតែម្តង ហើយក៏បានសង្កត់កៀបជាប់ពលករខ្មែរចំនួន ២ នាក់ ដែលមានឈ្មោះ តា កូ ភេទប្រុស អាយុ ២៩ ឆ្នាំ និងឈ្មោះ លី ធីន ភេទស្រី អាយុ ៣៧ ឆ្នាំ។

ភ្លាមៗនោះដែរ កម្លាំងសមត្ថកិច្ចថៃ បានចាត់កម្លាំងជំនាញឡើងទៅកាត់ដែកសរសៃដើម្បីទាញយកកម្មករទាំងពីរចេញពីគំនរដែក និងបេតុង ដើម្បីបញ្ជូនទៅសង្គ្រោះនៅមន្ទីរពេទ្យ ដោយជនទាំងពីររងរបួសពេញខ្លួនប្រាណ គឺសង្ឃឹមរស់តិចបំផុត។ បច្ចុប្បន្នក្រោយពេលកើតហេតុ សមត្ថកិច្ចបានហៅអ្នកម៉ៅការសាងសង់ និងអ្នកគ្រប់គ្រងយកទៅសាកសួរហើយ អំពីបច្ចេកទេសនៃការសាងសង់ដើម្បីរកមូលហេតុ៕ អត្ថបទ : សោ និយមរ័ត្ន

## យោធាថៃ ឃាត់ខ្លួនពលករខ្មែរប្រុសស្រី ឆ្លងដែនខុសច្បាប់ ២១នាក់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ១៩:០៦

បន្ទាយមានជ័យ៖ សេចក្តីរាយការណ៍ពីសមត្ថកិច្ច តាមបន្ទាត់ព្រំដែន បានឲ្យដឹងថា នៅថ្ងៃទី១៩ វិច្ឆិកា ឆ្នាំ ២០២១ កម្លាំងទាហានថៃ ដែលឈរជើងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ បានប្រទះឃើញក្រុមបុគ្គល ដែលគួរឲ្យសង្ស័យ ដើរមកតាមច្រករបៀង សំដៅចូលប្រទេសថៃ ត្រង់បរិវេណភូមិកូ ណាំឃ្លៀង ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ចំនួន ១១នាក់ ក្នុងនោះ មានប្រុស ៥នាក់ ស្រី៥ និងក្មេងម្នាក់ ទើបនាំខ្លួនយកទៅសួរនាំ។

ពេលសមត្ថកិច្ចថៃសាកសួរ ពលករខ្មែរខាងលើ បានប្រាប់ថា ពួកគេមានទីលំនៅក្នុងខេត្តសៀមរាប ចំនួន ២នាក់ បាត់ដំបងចំនួន ២នាក់ ព្រៃវែងចំនួន ៤នាក់ ក្រចេះម្នាក់ តាកែវ ២នាក់ ចង់ស៊ីឈ្នួលកាប់អំពៅ ក្នុងស្រុកគោកឃ្សូង ខេត្តស្រះកែវ ដែលមានថៅកែជាជនជាតិថៃ ឈ្មោះ ទុយ ដោយមានការទំនាក់ទំនងពីជនជាតិខ្មែរ ដែលស្នាក់នៅប្រទេសថៃ អោយពួកគេ ធ្វើដំណើរមកស៊ីឈ្នួលកាប់អំពៅជាមួយគ្នា ដោយពលករទាំងនោះ ត្រូវចំណាយលុយឲ្យមេខ្យល់នាំផ្លូវក្នុងម្នាក់ ១៥០០បាត អោយលុយមុនក្នុងម្នាក់ ៥០០បាត និងនៅពេលទៅដល់កន្លែងធ្វើការ ត្រូវចំណាយបន្ថែមក្នុងម្នាក់១០០០បាតទៀត។ ក្រោយសួរចម្លើយ សមត្ថកិច្ចថៃ ក៏បញ្ជូនទៅឲ្យជំនាញខ្លងលឹក ដើម្បីចាត់ការតាមច្បាប់បន្ត។

ក្នុងថ្ងៃដដែលនេះដែរ កម្លាំងទាហានថៃ ប្រចាំស្រុកតាប្រាយ៉ា ខេត្តស្រះកែវ បានប្រទះឃើញក្រុមបុគ្គលគួរឲ្យសង្ស័យផងដែរ ខណៈដើរមកតាមច្រករបៀង សំដៅចូលទឹកដីថៃ ត្រង់បរិវេណភូមិទព័សៀម ឃុំ/ស្រុកតាប្រាយ៉ា ខេត្តស្រះកែវចំនួន ៩នាក់ ក្នុងនោះ ស្រី ៤នាក់។ ក្រោយសមត្ថកិច្ចថៃសួរនាំជំហ៊ានដំបូង បានឲ្យដឹងថា ពលរដ្ឋខ្មែរ

ខាងលើ ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ ៨នាក់ និងបាត់ដំបងម្នាក់ ទៅធ្វើការសំណង់ នៅខេត្តមីនបុរី និងក្រុងបាងកក ដោយចំណាយលុយក្នុងម្នាក់ ចាប់ពី ៧០០០ទៅ ៩០០០បាត និងចំណាយលុយឲ្យអ្នកនាំផ្លូវខាងដីខ្មែរក្នុងម្នាក់ ចំនួន ១០០០បាត ទៅ ៣០០០បាត និងចំណាយបន្ថែម ៦០០០បាត នៅពេលទៅដល់គោលដៅ។ ក្រោយសួរនាំ សមត្ថកិច្ចថៃ ក៏បញ្ជូនទៅឲ្យជំនាញស្រុកតាប្រាយ៉ា ដើម្បីចាត់ការតាមច្បាប់បន្ត៕ ណុប រក្សា

# ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១

## ជំងឺកូវីដ-១៩ ជំរុញឱ្យមានការធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យពលករចំណាកស្រុកកម្ពុជា ក្នុងចំណោមវិធានការដ៏ទៃទៀត

https://www.khmertimeskh.com/ November 19, 2021 Khmer Times

សាលាក្រុងបានចាប់ផ្តើមធ្វើបច្ចុប្បន្នភាពមូលដ្ឋានទិន្នន័យ របស់ខ្លួនអំពីពលករចំណាកស្រុកមកពីប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ដែលបច្ចុប្បន្នកំពុងរស់នៅ និងធ្វើការនៅទីក្រុងបាងកក ដោយតម្រូវឱ្យទាំងកម្មករ និងនិយោជករបស់ពួកគេបញ្ជូនព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានការងាររបស់ពួកគេឡើងវិញ។

លោក Khachit Chatchawanit ស្មៀនសាលាក្រុងបាននិយាយថា នៅពេលដែលស្ថានការណ៍ជំងឺកូវីដ-១៩ បានថមថយ ការធ្វើបច្ចុប្បន្នភាពនៃមូលដ្ឋានទិន្នន័យពលករចំណាកស្រុកបានចាប់ផ្តើមកាលពីថ្ងៃច័ន្ទ ដើម្បីប្រមូលព័ត៌មានថ្មីៗអំពីពលករចំណាកស្រុក ដែលនេះមានសារៈសំខាន់សម្រាប់ការគ្រប់គ្រងការងាររបស់កម្មករទាំងនេះខណៈដែលនៅតែបន្តដោះស្រាយជាមួយនឹងជំងឺរាតត្បាត។លោកបានបន្តថាផ្នែកចុះឈ្មោះពលករចំណាកស្រុកនៅការិយាល័យស្រុកទាំង ៥០ ឥឡូវនេះកំពុងទទួលចុះឈ្មោះកម្មករយ៉ាងច្រើនបំផុត ៣០ នាក់ក្នុងមួយថ្ងៃ ចាប់ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ហើយច្រើនបំផុត ៥០ នាក់ជារៀងរាល់ថ្ងៃសៅរ៍។ លោកបាននិយាយទៀតថា អ្នកដែលមានបំណងមកកាន់ការិយាល័យខណ្ឌទាំងនេះ ដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់ខ្លួន គឺតម្រូវឱ្យណាត់ជាមុនដើម្បីធានាថាការិយាល័យមិនមានមនុស្សច្រើនពេក។ លោកបាននិយាយថា ថៅកែដែលជួលកម្មករកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ក៏តម្រូវឱ្យដាក់សំណើរបស់ពួកគេតាមអនឡាញដើម្បីធ្វើបច្ចុប្បន្នភាពព័ត៌មានការងារ និងសម្រាប់អត្តសញ្ញាណប័ណ្ណថ្មីសម្រាប់ពលករចំណាកស្រុករបស់ពួកគេ។

លោកបានបន្តថា ចាប់ពីថ្ងៃទី២២ ខែវិច្ឆិកា តទៅ ការដាក់ពាក្យនឹងត្រូវអនុញ្ញាតឲ្យធ្វើឡើងតាមគេហទំព័រ http://nonthaiidbkk.bangkok.go.th។ លោកបាននិយាយថា រដ្ឋបាលក្រុងបាងកកក៏មានគម្រោងប្រើប្រាស់កម្មវិធីទូរស័ព្ទដូចជា Thai Chana និង Mor Chana ដើម្បីតាមដានពលករចំណាកស្រុកសម្រាប់ជួយដល់ការគ្រប់គ្រងជំងឺកូវីដ-១៩ ។ លោកបាននិយាយទៀតថា កម្មវិធីទាំងនេះនឹងផ្តល់ភាពកាន់តែងាយស្រួលសម្រាប់កម្មករ និងថៅកែរបស់ពួកគេផងដែរ ដោយសារតែពួកគេមិនចាំបាច់ផ្តល់ឯកសារការធ្វើដំណើររបស់ពួកគេដោយផ្ទាល់ដៃដូចដែលពួកគេធ្លាប់ធ្វើពីមុនមក។ លោកបាននិយាយថា ទាំងថៅកែ និងកម្មករចំណាកស្រុករបស់ពួកគេនៅតែតម្រូវឱ្យអនុវត្តតាមវិធានការត្រួតពិនិត្យជំងឺកូវីដ-១៩ យ៉ាងតឹងរ៉ឹង រួមទាំងវិធានការកំណត់ជំងឺកូវីដ-១៩ ផងដែរ។ ប្រភព: Bangkokpost

# ឡោមព័ទ្ធភូមិគ្រឹះមួយនៅភ្នំពេញចាប់ចិនជាង៤០នាក់ និងរំដោះជនបរទេសជិត១០០នាក់

https://kohsantepheapdaily.com.kh/ ភ្នំពេញ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ១១:៣៥

រាជធានីភ្នំពេញ ៖ សមត្ថកិច្ចប៉ូលិស នៃក្រសួងមហាផ្ទៃ កាលពីថ្ងៃព្រហស្បត្តិ៍ បានធ្វើការឡោមព័ទ្ធភូមិគ្រឹះមួយកន្លែង នៅរាជធានីភ្នំពេញ រំដោះបានជនជាតិថៃជិត១០០នាក់ ដែលត្រូវបានគេឃុំខ្លួន និងបង្ខំឱ្យធ្វើការដោយខុសច្បាប់ ក្នុងរាជធានីភ្នំពេញ ដែលអ្នកទាំងនោះត្រូវបានឃុំខ្លួនក្នុងអគារមួយគ្រប់គ្រងដោយក្រុមជើងកាងជាតិចិន ។ នេះបើយោងតាមចុះផ្សាយរបស់កាសែតបាងកកប៉ុស្តិ៍របស់ថៃ ។

យ៉ាងណាមិញ បើយោងតាមការចុះផ្សាយរបស់កាសែតបាងកកប៉ុស្តិ៍របស់ថៃ បានរាយការណ៍នៅថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០២១ នេះថា ប្រតិបត្តិការជួយសង្គ្រោះនេះ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដែលធ្វើឡើងដោយអាជ្ញាធរកម្ពុជា ប៉ូលីសថៃ និងមន្ត្រីស្ថានទូតថៃ។ នៅដើមប្រតិបត្តិការនៃការជួយសង្គ្រោះពលករថៃ នៅរាជធានីភ្នំពេញ គឺមន្ត្រីបានឡោមព័ទ្ធអគារដែលត្រូវបានយាមកាមដោយជនជាតិចិនជិត៥០នាក់។ សមត្ថកិច្ចខ្មែរ ចាប់បានជនជាតិចិនជិត៤០នាក់ ហើយជួយសង្គ្រោះជនជាតិថៃទាំងអស់ចេញពីអគារនៅម៉ោង៥ល្ងាច។ ពលករថៃដែលត្រូវបានសមត្ថកិច្ចខ្មែរជួយសង្គ្រោះទាំងអស់ ត្រូវបញ្ជូនត្រឡប់ទៅប្រទេសថៃ តាមច្រកទ្វារព្រំដែន Klong Luek ក្នុងខេត្តស្រះកែវ។ ពួកគេនឹងត្រូវបានដាក់ឱ្យនៅដាច់ដោយឡែករយៈពេល១៤ថ្ងៃ មុនពេលត្រូវបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះរបស់ពួកគេ។ ប្រភពដដែលបានរាយការណ៍បន្តថា ការធ្លាក់ចូលនេះ បានកើតឡើងបន្ទាប់ពីប៉ូលិសភូមិន្ទថៃ មជ្ឈមណ្ឌលប្រឆាំងការជួញដូរមនុស្ស និងក្រុមការពារស្ត្រី និងគ្រួសារកុមារ បានបញ្ជូនអ្នកស៊ើបអង្កេតដែលដឹកនាំដោយលោក ប៉ុល ខេមរិន្ទ ពិសាម៉ៃ (Khemarin Pissamai) ដើម្បីរកទីតាំងអគារដែលប្រើសម្រាប់ឃុំខ្លួនកម្មករ។ ប្រភពមួយបានឲ្យដឹងថា ជនរងគ្រោះភាគច្រើនត្រូវបានបោកប្រាស់ដោយជនជាតិថៃផ្សេងទៀតដែលជ្រើសរើសបុគ្គលិកសម្រាប់មុខតំណែងដែលមានប្រាក់ខែសមរម្យ ដូចជាការផ្សព្វផ្សាយល្បែងអនឡាញ និងទីផ្សារអនឡាញក្នុងប្រទេសកម្ពុជា។

ជនរងគ្រោះម្នាក់ត្រូវបានដកស្រង់សម្តីប្រាប់ប៉ូលិសថា ពួកគេបានដឹងពីការងារតាមរយៈហ្វេសប៊ុក។ ក្រុមជើងកាងជួញដូរមនុស្សមួយក្រុមត្រូវបានចោទប្រកាន់ថា បាននាំជនរងគ្រោះឆ្លងដែនពីស្រុកខុកស៊ូង ខេត្តស្រះកែវដោយខុសច្បាប់ រួចដឹកមកភ្នំពេញតាមរថយន្ត។ លុះពេលមកដល់អគារត្រូវគេឃុំទុកក្នុងអគារបិទទ្វារជិត និងបង្ខំឲ្យចុះកិច្ចសន្យា។

តាមការស៊ើបអង្កេត ជនរងគ្រោះត្រូវបានឃុំខ្លួននៅក្នុងអគារដែលយាមដោយក្រុមជនជាតិចិន។ ជនរងគ្រោះជាពលករថៃ គឺទទួលបានប្រាក់ខែត្រឹមខែដំបូងប៉ុណ្ណោះ។ ជនដែលមិនព្រមធ្វើការត្រូវបានគេវាយដំដាក់ខ្នោះ ឬទុកឱ្យអត់អាហារអស់រយៈពេលពីរថ្ងៃ។ ពួកគេទាំងអស់ ត្រូវបានគេរាយការណ៍ថា ត្រូវបានបង្ខំឱ្យទាក់ទាញជនរួមជាតិផ្សេងទៀតឱ្យធ្វើការសម្រាប់ប្រតិបត្តិការដូចគ្នា ឬវិនិយោគជាមួយពួកគេ។ ជនរងគ្រោះម្នាក់ៗត្រូវបានគេរំពឹងថា នឹងរកប្រាក់ចំណូលបានខ្ពស់ជាមួយនឹងគោលដៅប្រចាំខែពី 1-2 លានបាត (ប្រមាណពី 30670 ដុល្លារទៅ 61341 ដុល្លារ) ។ អ្នកដែលមិនបានសម្រេចគោលដៅត្រូវបានគេវាយដំ ឬវាយដំ។ ខ្លះទៀតក៏ត្រូវបានគេចាប់ពង្រត់ ឬសូម្បីតែលក់ទៅឲ្យក្រុមជើងកាងទំនើងផ្សេងទៀត។ រហូតមកដល់ពេលនេះ ប៉ូលិសកំពុងពង្រីកការស៊ើបអង្កេតរបស់ពួកគេ ដើម្បីសង្ឃឹមថា នឹងជួយសង្គ្រោះជនរងគ្រោះផ្សេងទៀត។ ប៉ូលិសជឿថា អាចមានរាប់រយទៀត។ ប៉ូលិសបានព្រមានបន្ថែមទៀតថា ចំពោះជនជាតិថៃដែលចង់ដាក់ពាក្យរកការងារដែលមានប្រាក់ខែល្អនៅបរទេស ត្រូវពិនិត្យជាមួយក្រសួងការងារ និងអនុវត្តតាមបទប្បញ្ញត្តិចាំបាច់ ដើម្បីចៀសវាងក្លាយជាជនរងគ្រោះនៃការជួញដូរមនុស្ស។

ឯកឧត្តម ខៀវ កាញារីទ្ធិ រដ្ឋមន្ត្រីក្រសួងព័ត៌មាននៅព្រឹកថ្ងៃសុក្រ ទី ១៩ ខែវិច្ឆិកា នេះ ក៏បានបង្ហោះរូបភាពនៃការជួយសង្គ្រោះជនជាតិថៃ ដោយសមត្ថកិច្ចខ្មែរ អមនឹងសំណេរថា «អ្នកនៅស្រុកខ្មែរមានមេខ្យល់បបួលទៅធ្វើការនៅថៃ ឯនៅថៃមានមេខ្យល់បបួលមកធ្វើការនៅខ្មែរ ! ក្នុងរូប គឺកងនគរបាលខ្មែរចូលរំដោះជនជាតិថៃចំនួន ៩៩ នាក់ ដែលគេយកមកធ្វើការនៅស្រុកខ្មែរដោយខុសច្បាប់ហើយឃុំឃាំងពួកគេនៅក្នុងអគារមួយកន្លែងក្នុងក្រុងភ្នំពេញ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ២០២១ ។

## មន្ត្រីអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ អន្តរាគមន៍បញ្ជូនពលករខ្មែរ ៩ នាក់ និងកុមារ ៣ នាក់មកកម្ពុជាវិញ

https://www.postkhmer.com/ រី សុចាន់ | Publication date 19 November 2021 | 12:24 ICT

**បន្ទាយមានជ័យៈ** មន្ត្រីស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ ប្រទេសថៃបានអន្តរាគមន៍បញ្ជូនពលករខ្មែរ ៩ នាក់ និងកុមារ ៣ នាក់ត្រឡប់មកកម្ពុជាវិញ នៅថ្ងៃទី ១៩ ខែវិច្ឆិកា បន្ទាប់ពីពួកគេស្នើសុំជំនួយពីអាជ្ញាធរកម្ពុជានៅនោះ ក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ ១៩។

លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសបានឱ្យដឹងនៅថ្ងៃទី ១៩ ខែវិច្ឆិកាថា៖ ពលករខ្មែរចំនួន ៩ នាក់ និងកូនក្មេង ៣ នាក់ ដែលបានធ្វើដំណើរមកពីបណ្ដាខេត្តនានា និងទីក្រុងបាងកកនៃប្រទេសថៃមកស្នើសុំស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ ដើម្បីជួយបញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញ»។ លោក បន្តថា ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវបានអន្តរាគមន៍ និងបញ្ជូនពលរដ្ឋខ្មែរទាំងអស់នេះត្រឡប់មកកម្ពុជាវិញតាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត នៃខេត្តបន្ទាយមានជ័យយកទៅប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាលសម្រាប់ទប់ស្កាត់ជំងឺកូវីដ ១៩៕

## ឃាត់ខ្លួនមេខ្យល់ ២នាក់ ដែលនាំពលករខ្មែរ បម្រុងលួចឆ្លងដែន ទៅប្រទេសថៃ

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ១៨:២១

បន្ទាយមានជ័យ៖ ប៉ូលិសបានឃាត់ខ្លួនមេខ្យល់ ២នាក់ ដែលនាំពលករខ្មែរ ៧នាក់ បម្រុងលួចឆ្លងដែន ទៅប្រទេសថៃ ដោយខុសច្បាប់។ មេខ្យល់ទាំង ២នាក់នោះ ត្រូវបានបញ្ជូនទៅតុលាការ សាលាដំបូងខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១។

មន្ត្រីអធិការដ្ឋាននគរបាលស្រុកថ្មពួក បានប្រាប់ថា ជនសង្ស័យជាមេខ្យល់ ២នាក់ រួមមាន៖ ១.ឈ្មោះ ឈៀតា ភ័ស្ស ភេទប្រុស អាយុ ១៩ឆ្នាំ និង២.ឈ្មោះ ឃឹម សំណាង ភេទប្រុស អាយុ ៤៨ឆ្នាំ ជនសង្ស័យ ២នាក់ រស់នៅភូមិសាមគ្គី ឃុំគោករមៀត ស្រុកថ្មពួក។ មន្ត្រីនគរបាលរូបនោះបានបញ្ជាក់ថា នៅពេលឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ គឺកម្លាំងអធិការដ្ឋាននគរបាលស្រុកថ្មពួក បានសហការជាមួយកម្លាំងនគរបាលការពារព្រំដែន ក៏បានឃាត់ពលករខ្មែរ ចំនួន ៧នាក់ ស្រី ៣នាក់ នៅវេលាម៉ោង ៧យប់ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ នៅក្បែរព្រំដែនក្នុងភូមិសាស្ត្រ ឃុំគោករមៀត ស្រុកថ្មពួក។ មន្ត្រីនគរបាល បានបញ្ជាក់ថា ក្រោយឃាត់ពលករខ្មែរ ហើយនាំយកទៅសាកសួរនៅអធិការនគរបាលស្រុកថ្មពួក ពលករ បានឆ្លើយថា ពួកគេ មានបំណងឆ្លងដែន ទៅរកការងារធ្វើ នៅប្រទេសថៃ តាមរយៈមេខ្យល់ ដោយម្នាក់ ត្រូវបង់ ៩.០០០ បាត។ យោងតាមចម្លើយនេះ កងកម្លាំងសមត្ថកិច្ច ក៏បានស្រាវជ្រាវចាប់ខ្លួនមេខ្យល់ ២នាក់ភ្លាមៗ នាំយកទៅសាកសួរ ហើយកសាងសំណុំរឿង បញ្ជូនទៅសាលាដំបូងខេត្ត ចាត់ការតាមច្បាប់។ ចំណែកពលករ ត្រូវបានបញ្ជូនទៅមណ្ឌលធ្វើចត្តាឡីស័ក៕ ប៊ុន ធឿន

# ពលករខ្មែរមួយចំនួនរៀបរាប់ពីការលំបាកពេលជាប់គុកដោយសារឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ

https://www.rfa.org/ ដោយ សុជីវី 2021-11-19

ពលករខ្មែរមួយចំនួនរៀបរាប់ពីការលំបាកវេទនាក្នុងពេលដែលពួកគេឆ្លងដែនខុសច្បាប់ ហើយត្រូវបានប៉ូលិសថៃចាប់ដាក់គុករយៈពេល៣ថ្ងៃ នៅតំបន់ព្រំដែនជាប់ខេត្តបន្ទាយមានជ័យ។ ពួកគេត្រូវបានប៉ូលិសបង្ខំឱ្យបង់ប្រាក់ម្នាក់ប្រមាណ ២០០ដុល្លារ ដើម្បីជាថ្នូរបានដោះលែងពួកគេបញ្ជូនត្រឡប់ទៅកម្ពុជាវិញ។ មន្ត្រីសង្គមស៊ីវិលសង្កេតឃើញថា ពលករឆ្លងដែនទៅប្រទេសថៃអំឡុងពេលនេះប្រឈមនឹងគ្រោះថ្នាក់ជាច្រើន ដែលរដ្ឋាភិបាលខ្មែរគួរតែទប់ស្កាត់ និងជួយរកការងារឱ្យពួកគេនៅក្នុងស្រុក។

ប៉ូលិសថៃបានចាប់បញ្ជូនពលករខ្មែរចំនួន១៥នាក់ យកទៅទម្លាក់ចោលនៅច្រករៀងព្រំដែនជាប់ស្រុកអូរជ្រៅខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ក្រោយពេលពីបានចាប់ពួកគេដាក់គុកអស់រយៈពេល៣ថ្ងៃ នៅស្រុកគោកស៊ូង (Khok Soung) ខេត្តស្រះកែវ (Sra Kao)។ បញ្ហានេះធ្វើឱ្យពលករខ្លះរាងចាលលែងចង់ទៅធ្វើការនៅប្រទេសថៃ និងខ្លះទៀតបានខ្ចីប្រាក់ពីអ្នកភូមិជាមួយគ្នា ដើម្បីផ្សងព្រេងរកការងារនៅប្រទេសថៃជាថ្មីរកប្រាក់ដោះស្រាយជីវភាពគ្រួសារ និងសងបំណុលធនាគារដែលបានខ្ចីគេជំពុះខាតអស់ដើមទុនកាលពីឆ្នាំកន្លងទៅ។

ពលកររស់នៅឃុំនិមិត្ត ស្រុកអូរជ្រៅ លោក ស៊ូ ពិសិទ្ធ រៀបរាប់ប្រាប់វិទ្យុអាស៊ីសេរីក្រោយពីលោកត្រឡប់ទៅដល់កម្ពុជាថា ការឆ្លងដែនអំឡុងពេលនេះលំបាកវេទនាជាងពេលមុនៗទ្វេដង ដូចជាបង់ប្រាក់ឱ្យមេខ្យល់ប្រមាណពី៧ពាន់ទៅ១ម៉ឺនបាត(១០.០០០)ឬប្រមាណពី២២០ទៅ៣០០ដុល្លារក្នុងម្នាក់។ លោកបន្តថា ពួកលោកមានគ្នាចំនួន១៩នាក់ត្រូវបានមេខ្យល់ជនជាតិថៃនាំដើរកាត់ព្រៃ កាត់ភក់ កាត់ចំការដំឡូងមី និងដេកក្នុងព្រៃអស់រយៈពេល៣យប់ ដើម្បីគេចពីសមត្ថកិច្ចថៃ។ លោកប្រាប់ថា ពលករខ្មែរចំនួន១៥នាក់រួមទាំងលោកផងត្រូវបានប៉ូលិសថៃចាប់ដាក់គុកនៅស្រុកគោកស៊ូង រយៈពេលថ្ងៃ៣ថ្ងៃ។ ចំណែកពលករ៤នាក់ផ្សេងទៀតបានត្រូវបានមេខ្យល់ដឹកតាមរថយន្តទៅដល់កន្លែងធ្វើការងារនៅទីក្រុងបាងកកដោយសុវត្ថិភាព។ ពលករវ័យ៣៧ឆ្នាំរូបនេះ បញ្ជាក់ទៀតថា អំឡុងពេលជាប់គុករយៈពេល៣ថ្ងៃនោះ ដោយ២ថ្ងៃប៉ូលិសថៃមិនបានចែកបាយ និងទឹកដល់ពួកលោកហូបនោះទេ គឺពលករត្រូវចំណាយប្រាក់ទិញបាយហូបដោយខ្លួនឯង៖ «គ្រាន់តែជាប់គុក៣ថ្ងៃប្រហែលមួយឆ្នាំហើយ វេទនាជាងអីទៀត បើមូសខាំដេកក៏ពិបាកចង្អៀតគ្នា ប្រហែលយើងអ្នកទោសសម្លាប់មនុស្ស អ្នកទោសគ្រឿងញៀន អ្នកវាយគេវាយឯងហើយ។ ខ្ញុំទៅខ្ញុំដឹងហើយដើរកាត់ទឹកកាត់ភក់កាត់ព្រៃកាត់ស្រែ ហើយក្រាបលូនសុទ្ធតែភក់ដល់ក្បាល មានអ្នកខ្លះដួលកប់ភក់ក៏មាន។ ខ្ញុំហើយទៅជួយស្រីៗ ជួយស្ពាយគេជួយអីមើល មើលទៅស្រណោះអាណិត ខ្លះចាស់ហើយពរកូនពរចៅដើរដួល យូរៗមើលទៅចង់លើសសម័យ ប៉ុល ពត ទៅទៀត»។

លោកបន្ថែមថា ប៉ូលិសថៃបង្ខំពួកលោកឱ្យប្រាក់បង់ប្រាក់ម្នាក់ ៦ពាន់ ៥០០បាត ឬស្មើប្រមាណ១៦០ដុល្លារ ដើម្បីជាថ្នូរបានដោះលែង បើមិនដូច្នេះទេ ប៉ូលិសថៃនឹងបញ្ជូនពួកលោកទៅតុលាការ។ លោកនិយាយថា ប៉ូលិសថៃបានគំរាមថា ប្រសិនបើពួកគាត់មិនបង់ប្រាក់ទេនោះ នឹងបញ្ជូនពួកលោកទៅតុលាការ ហើយអាចនឹងដាក់គុករយៈពេល៣ខែ។ ពួកលោកព្រួយបារម្ភខ្លាចជាប់គុកយូរកាន់តែប៉ះពាល់ដល់ជីវភាពគ្រួសារក៏សម្រេចចិត្តបង់ប្រាក់ឱ្យប៉ូលិសថៃ។ ក្រោយមកប៉ូលិសថៃបានបញ្ជូនពលករខ្មែរទាំង១៥នាក់ត្រឡប់ទៅទម្លាក់ចោលនៅព្រំដែនច្រករបៀងអូរបីជាន់ ស្រុកអូរជ្រៅ។ លោក ស៊ូ ពិសិទ្ធ ឱ្យដឹងទៀតថា ពួកលោកឈឺចាប់ម្ដងនៅប៉ូលិសថៃយកប្រាក់ហើយ នៅពេលមកកម្ពុជាត្រូវបានអាជ្ញាធរខ្មែរប្រចាំការនៅតំបន់ព្រំដែនអូរបីជាន់ យកប្រាក់ពីពលករថ្លៃដឹកជញ្ជូនទៅដល់ផ្ទះម្នាក់ពី៤០០ទៅ ១ពាន់បាត ឬស្មើប្រមាណពីជាង ១០ទៅ៣០ដុល្លារទៀត ទៅតាមអ្នកនៅជិតឬឆ្ងាយ៖ «ដូចអត់គិតពីយើងសោះគិតតែពីលុយ ដល់ផ្ទះហើយម្នាក់ៗ ខ្លះរាងហើយ ខ្លះសួរប្រវត្តិទៅថា ជាប់៣ដងហើយ

ម្នាក់ៗខ្ចីលុយគេទៅជាប់គុកទាំង ៣ដង អស់ម្នាក់សុទ្ធតែ២ពាន់ដុល្លារ។ខ្លះទៅអស់ជំនឿទៅ ខ្លះទៅមិនដឹងទៅធ្វើអី អង្គុយគិតច្រើន មិនដឹងថាខ្ចីលុយអ្នកណាបានទៅទៀត»។

ស្រដៀងគ្នានេះដែរ ពលរដ្ឋរស់នៅខេត្តបន្ទាយមានជ័យម្នាក់ទៀត លោកស្រី ឡេន លីសៀង ថ្លែងថា ទាហានខ្មែរប្រចាំការនៅតំបន់ព្រំដែនឃុំអូរបីជាន់បានយករថយន្តដឹកជញ្ជូនពួកលោកស្រី ៤នាក់ដល់ឃុំអូរប្រាសាទ ស្រុកមង្គលបូរី គឺយកប្រាក់ ២ពាន់ ៥០០បាត ឬប្រមាណ៨០ដុល្លារ ។ភ្លាមៗក្រោយពេលទៅដល់ផ្ទះ ស្ត្រីវ័យ២៥ ឆ្នាំរូបនេះបានទុកកូនអាយុក្រោម៤ឆ្នាំ ២នាក់ឱ្យម្ដាយមើល ហើយទៅខ្ចីប្រាក់ពីអ្នកភូមិក្បែរខាងគ្នាយកទៅបង់ឱ្យមេខ្យល់ ដើម្បីនាំលោកស្រី និងប្ដីត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញ។ លោកស្រីបន្តថា មូលហេតុដែលប្រញាប់ទៅ ប្រទេសថៃដោយសារគ្រួសារគាត់ជីវភាពក្រីក្រ ហើយអត់ការងារនៅក្នុងស្រុក ស្របពេលដែលលោកស្រីជំពាក់ប្រាក់ ធនាគារប្រមាណ ៥ពាន់ដុល្លារ (៥.០០០) ដែលបានខ្ចីគេធ្វើស្រែ និងដាំដំណាំខាតដើមទុនកាលពីឆ្នាំ២០២០។ បច្ចុប្បន្នគ្រួសារលោកស្រីបានទៅដល់ទីក្រុងបាងកកហើយ ដោយបង់ប្រាក់ឱ្យមេខ្យល់ម្នាក់ជាង៦ពាន់បាត ឬស្មើ ប្រមាណ២០០ដុល្លារ ប៉ុន្តែមិនទាន់មានការងារធ្វើនៅឡើយទេ៖ «ពេលថ្ងៃគេយកទៅដាក់ក្នុងដុបយប់ឡើងឆ្លងទៅ គេឱ្យដេកផ្ទះមេខ្យល់ខាងថៃ។ ចងការអ្នកស្រុក បើមិនអីចឹងទេមិនមានអីសងធនាគារមិនមានអីឱ្យកូនបៅ កូនខ្ញុំ ទើបតែ៦ខែឱ្យម៉ែមើលឱ្យ។ ខ្ញុំអាណិតកូនដែរ តែមិនដឹងធ្វើម៉េច បើមិនមកមិនមានលុយណា សងធនាគារ មាន លុយណាឱ្យកូនបៅដោះ។ ខ្ញុំទាល់តែសងគេអស់បានត្រឡប់ទៅផ្ទះវិញ បើមិនអីចឹងទៅផ្ទះមិនកើតទេ បើឆ្លងដែន មកថៃលំបាកបែបនេះ»។ ក្រុមពលករទាំងនេះឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែររាប់រយនាក់បានឆ្លងដែនទៅ ប្រទេសថៃតាមច្រករបៀងក្នុងឃុំអូរបីជាន់ ហើយភាគច្រើនត្រូវបានអាជ្ញាធរថៃចាប់ដាក់គុក និងបញ្ជូនត្រឡប់ទៅ កម្ពុជាវិញ។

ទាក់ទងនឹងបញ្ហានេះស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា នៅតំបន់ព្រំដែនខេត្តបន្ទាយមានជ័យមិនសូវមានពលករឆ្លងដែនច្រើននោះទេ។ លោកបន្តថា ពលករដែលថៃចាប់បាននៅតំបន់ព្រំដែន ភាគច្រើនត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ដោយមិនមាន ការដាក់គុកឡើយ៖ «វាអត់មានបងអត់មានឆ្លងដែនទេ ។កុងស៊ុលគាត់នៅហ្នឹងឯងកុងស៊ុលនៅប្រចាំស្រះកែវមាន តើបង ចាំអន្តោគមន៍។មកខាងខ្ញុំក៏បាន ទៅខាងកុងស៊ុលក៏បាន តាមតែគាត់ទាក់ទងមកបង ។បាទ គេចាប់ភ្លាមគេ រុញមកខាងយើងភ្លាមគេអត់ទុកទេ»។

វិទ្យុអាស៊ីសេរីមិនអាចទក់ទងមន្ត្រីអង្គកុងស៊ុលខ្មែរប្រចាំខេត្តស្រះកែវ ដើម្បីសុំអត្ថាធិប្បាយបន្ថែមជុំវិញពី បញ្ហាប៉ូលិសថៃចាប់ពលករខ្មែរដាក់គុកហើយបង្ខំបង់ប្រាក់នេះបានទេនៅថ្ងៃទី១៨ វិច្ឆិកា។

មន្ត្រីសម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក(Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា សង្កេតឃើញថា សព្វថ្ងៃមានពលករជាច្រើននាក់នាំគ្នាឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។ លោកបន្តថា ការ ឆ្លងដែនអំឡុងពេលនេះគឺពលករប្រឈមនឹងគ្រោះថ្នាក់ច្រើន ដូចជា ប្រឈមនឹងឆ្លងជំងឺកូវីដ១៩ ត្រូវអាជ្ញាធរចាប់ ដាក់គុក ទាហានថៃបាញ់ស្លាប់ ពស់ចឹក និងជាន់មីនជាដើម។ លោកបញ្ជាក់ថា មូលហេតុដែលពលករឆ្លងដែននៅ ពេលនេះ ដោយសារពួកគាត់មានជីវភាពក្រីក្រ ហើយអត់ការងារធ្វើនៅក្នុងស្រុក និងជំពាក់បំណុលធនាគារ៖ «បើ ជាប្រទេសខ្លាំងជាប្រទេសដែលមានអំណាចខ្លាំង ប្រទេសជិតខាងគេអត់ហានបំពារបំពានទៅលើប្រជាពលរដ្ឋរបស់ ខ្លួនទេ។ ប៉ុន្តែបើសិនជាប្រទេសយើងទន់ខ្សោយអីចឹងប្រទេសជិតខាងតែងតែធ្វើអ្វីបំពារបំពានទៅលើប្រជាពលរដ្ឋ របស់ខ្លួន។ អ៊ីចឹងរដ្ឋាភិបាលដែលមានទូតមានអង្គកុងស៊ុលមានអីហ្នឹងដែលនៅជាប់ព្រំដែនហ្នឹងគួរតែមីម្នាដោះ ស្រាយអំពីបញ្ហាហ្នឹង»។

របាយការណ៍អាផ្ទាធរថៃឱ្យដឹងថា រយៈពេល ១សប្តាហ៍នៅដើមខែវិច្ឆិកា មានពលករខ្មែរជិត ១ពាន់នាក់ (៩៩៦) ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនក្នុងពេលពួកគេឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។ ក្នុងនោះពលករភាគច្រើនឆ្លងដែនតាមច្រករបៀងព្រំដែនក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

សម្របសម្រួលសមាគមការពារសិទ្ធិមនុស្សអាដហុក (Adhoc) ខេត្តបន្ទាយមានជ័យ លោក ស៊ុំ ច័ន្ទគា អំពាវនាវដល់រដ្ឋាភិបាលកម្ពុជាទាក់ទងទៅភាគីថៃ បើកច្រកទ្វារព្រំដែនប្រទេសទាំងពីរ នៅចំណុចណាមួយ ដើម្បីសម្រួលដល់ពលករខ្មែរចូលទៅធ្វើការនៅប្រទេសថៃក្នុងគ្រាអាសន្ននេះ ដោយមិនមានការចាប់ខ្លួន និងកាត់បន្ថយការចំណាយរបស់ពលករ។ លោកជឿជាក់ថា ប្រសិនបើរដ្ឋាភិបាលប្រទេសទាំងពីរមិនដោះស្រាយបញ្ហានេះទេនោះ ពលករខ្មែរជាច្រើននាក់ប្រឈមនឹងចាញ់បោកមេខ្យល់នាំឆ្លងដែនទាំងប្រថុយប្រថានទៅប្រទេសថៃបន្តទៀតជាមិនខាន៕

## សមត្ថកិច្ចថៃ ឃាត់ខ្លួនពលករខ្មែរប្រុស-ស្រី លបលួចឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់សរុបចំនួន ២០នាក់ នៅខេត្តស្រះកែវ

https://khmernote.com.kh/ November 19, 2021 srey nuch

ខេត្តបន្ទាយមានជ័យៈ យោងតាមការចុះផ្សាយរបស់ នាយកដ្ឋានផ្សព្វផ្សាយអប់រំ បានឲ្យដឹងថា សេចក្តីរាយការពីសមត្ថកិច្ចតាមបន្ទាត់ព្រំដែន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២១ កម្លាំងទាហានថៃ ដែលឈរជើងតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ បានប្រទះឃើញក្រុមបុគ្គលដែលគួរឲ្យសង្ស័យ ដើរមកតាមច្រករបៀងសំដៅចូលប្រទេសថៃ ត្រង់បរិវេណភូមិកូណាំឃ្លៀង ឃុំប៉ារ៉ៃ ស្រុកអារញ្ញ ខេត្តស្រះកែវ ចំនួន១១នាក់ ក្នុងនោះប្រុស៥ ស្រី៥ និងក្មេងម្នាក់ ទើបនាំខ្លួនយកទៅសួរនាំ។

ពេលសមត្ថកិច្ចថៃសាកសួរ ពលករខ្មែរខាងលើបានប្រាប់ថា ពួកគេមានទីលំនៅក្នុងខេត្តសៀមរាប ចំនួន២នាក់,បាត់ដំបងចំនួន២នាក់, ព្រៃវែង ចំនួន៤នាក់, ក្រចេះ១នាក់, តាកែវ២នាក់ ចង់ស៊ីឈ្នួលកាប់អំពៅក្នុងស្រុកគោកឃ្សូង ខេត្តស្រះកែវ ដែលមានថៅកែជាជនជាតិថៃឈ្មោះ ទុយ ដោយមានការទំនាក់ទំនងពីជនជាតិខ្មែរដែលស្នាក់នៅប្រទេសថៃ អោយពួកគេធ្វើដំណើរមកស៊ីឈ្នួលកាប់អំពៅជាមួយគ្នា ដោយពលករទាំងនោះត្រូវចំណាយលុយឲ្យមេខ្យល់នាំផ្លូវក្នុងម្នាក់១,៥០០បាត អោយលុយមុនក្នុងម្នាក់៥០០បាត និងនៅពេលទៅដល់កន្លែងធ្វើការត្រូវចំណាយបន្ថែមក្នុងម្នាក់១,០០០បាតទៀត។ ក្រោយសួរចម្លើយ សមត្ថកិច្ចថៃក៏បញ្ជូនទៅឲ្យជំនាញខ្លួងលឹកដើម្បីចាត់ការតាមច្បាប់បន្ត។

ក្នុងថ្ងៃដដែលនេះដែរ កម្លាំងទាហានថៃប្រចាំស្រុកតាប្រាយ៉ា ខេត្តស្រះកែវ បានប្រទះឃើញក្រុមបុគ្គលគួរឲ្យសង្ស័យផងដែរ ខណៈដើរមកតាមច្រករបៀង សំដៅចូលទឹកដីថៃ ត្រង់បរិវេណភូមិទព័សៀម ឃុំ/ស្រុកតាប្រាយ៉ា ខេត្តស្រះកែវចំនួន៩នាក់ ក្នុងនោះ ស្រី៤នាក់ ក្រោយសមត្ថកិច្ចថៃសួរនាំដំហ៊ានដំបូងបានឲ្យដឹងថា ពលរដ្ឋខ្មែរខាងលើ ធ្វើដំណើរមកពីខេត្តបន្ទាយមានជ័យ ៨នាក់ និងបាត់ដំបង១នាក់ ទៅធ្វើការសំណង់នៅខេត្តមីនបុរី និងក្រុងបាងកក ដោយចំណាយលុយក្នុងម្នាក់ចាប់ពី៧,០០០ទៅ៩,០០០បាត និងចំណាយលុយឲ្យអ្នកនាំផ្លូវខាងដីខ្មែរក្នុងម្នាក់ចំនួន១,០០០ទៅ៣,០០០បាតនិងចំណាយបន្ថែម៦,០០០បាតនៅពេលទៅដល់គោលដៅ។ ក្រោយសួរនាំ សមត្ថកិច្ចថៃ ក៏បញ្ជូនទៅឲ្យជំនាញស្រុកតាប្រាយ៉ា ដើម្បីចាត់ការតាមច្បាប់បន្ត ៕

# លទ្ធផល នៃការផ្តន្ទាទោសជនល្មើស សម្រាប់ខែសីហា និងខែកញ្ញា ឆ្នាំ២០២១ ករណីរំលោភសេពសន្ថវៈទៅលើកុមារ

https://cen.com.kh/ Posted ByPen Srey NeatNovember 20, 2021

ភ្នំពេញ ៖ អង្គភាពការពារកុមារ ( CPU) នៅថ្ងៃទី២០ ខែវិច្ឆិកានេះ បានចេញលទ្ធផលនៃការផ្តន្ទាទោសសម្រាប់ខែសីហា និងខែកញ្ញា ឆ្នាំ២០២១។ រយៈពេលសម្រាប់បណ្តឹងឧទ្ធរណ៍ត្រូវបានបញ្ចប់។ នេះគឺជាការងារដ៏ល្អអំពីមន្ត្រីស៊ើបអង្កេត និងក្រុមការងារគាំពារកុមារទាំងអស់គ្នា។ អង្គភាពការពារកុមារ បានបន្តថា ខែសីហា ៖

១. លេខសំណុំរឿង CPU ០៦៥/២០២១, បទប៉ុនប៉ងរំលោភទៅលើកុមារអាយុ ១៣ឆ្នាំ នៅខេត្តរតនគិរី។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៣ឆ្នាំ។

២. លេខសំណុំរឿង CPU ០៣៩/២០២០, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ៤ឆ្នាំ នៅខេត្តកណ្តាល។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៧ឆ្នាំ។

៣. លេខសំណុំរឿង CPU ១៦០/២០២០, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ១៤ឆ្នាំ នៅខេត្តកណ្តាល។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៦ឆ្នាំ។

ខែកញ្ញា ៖

១. លេខសំណុំរឿង CPU ២៦៤/២០១៩, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ១០ឆ្នាំ នៅខេត្តកណ្តាល។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៧ឆ្នាំ។

២. លេខសំណុំរឿង CPU ២៣២/២០២០, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ១៣ឆ្នាំ នៅខេត្តកំពង់ឆ្នាំង។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៨ឆ្នាំ។

៣. លេខសំណុំរឿង CPU ២៨៨/២០២០, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ៩ឆ្នាំ នៅខេត្តកំពត។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៧ឆ្នាំ។

៤. លេខសំណុំរឿង CPU ៣១៣/២០២០, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ១៣ឆ្នាំ នៅខេត្តកំពត។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៧ឆ្នាំ។

៥. លេខសំណុំរឿង CPU ២១៦/២០២០, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ៥ឆ្នាំ នៅខេត្តកំពង់ឆ្នាំង។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៥ឆ្នាំ។

៦. លេខសំណុំរឿង CPU ០០៣, ០០៤, ០០៥/២០២១, បទប៉ុន.ប៉ងស.ម្លាប់ទៅលើកុមារអាយុ ៨ឆ្នាំ, ១៣ឆ្នាំ, និង៣២ឆ្នាំ នៅខេត្តកណ្តាល។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ១៥ឆ្នាំ។

៧. លេខសំណុំរឿង CPU ០១១/២០២១, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ១៤ឆ្នាំ នៅខេត្តកណ្តាល។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ៥ឆ្នាំ។

៨. លេខសំណុំរឿង CPU ០៥២/២០២១, បទរំលោភសេព.សន្ថវៈទៅលើកុមារអាយុ ៥ឆ្នាំ នៅខេត្តកំពង់ឆ្នាំង។ ផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេល ២ឆ្នាំ។

ប្រធានអង្គភាពការពារកុមារ (CPU) បានថ្លែងថា "ខ្ញុំសូមថ្លែងអំណរគុណទៅដល់តុលាការ និងមេធាវីរបស់អង្គភាពការពារកុមារ (CPU) ដែលតំណាងឲ្យជនរងគ្រោះ ចំពោះការខឹតខំប្រឹងប្រែង របស់ពួកគេដើម្បីបង្ហាញថា ប្រសិនបើមានជនណាម្នាក់ ដែលប្រព្រឹត្តបទល្មើសទៅលើកុមារ នៅក្នុងប្រទេសកម្ពុជា ជននោះនឹងត្រូវទទួលទោសជាប់ពន្ធនាគារ"៕ រក្សាសិទ្ធិដោយ ៖ កូលាប

## ពលករខ្មែរម្នាក់ចំណាយប្រាក់ឱ្យមេខ្យល់ពី៧០០០ទៅ៨០០០បាតសម្រាប់ឆ្លងដែនខុសច្បាប់ត្រូវយោធាថៃឃាត់ខ្លួន

http://nokorwatnews.com/ 21/11/2021

ប្រទេសថៃ៖ តាមសេចក្ដីរាយការណ៍ពីសមត្ថកិច្ចតាមបន្ទាត់ព្រំដែនបានឱ្យដឹងថា កាលពីវេលាម៉ោង១២និង ២០នាទី ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២១ កម្លាំងទាហានប្រាណទី១២ ប្រចាំស្រុកតាព្រះយ៉ា កងកម្លាំងបូផា បានចុះល្បាត និងត្រួតពិនិត្យក្នុងតំបន់ដែលខ្លួនទទួលខុសត្រូវ បានប្រទះឃើញក្រុមបុគ្គលគួរឱ្យសង្ស័យដើរមកតាមច្រករបៀង សំដៅមកប្រទេសថៃត្រង់បរិវេណបង្គោលគីឡូម៉ែត្រលេខ២៧-២៨ ភូមិទ័ពសៀម ឃុំ/ស្រុកតាព្រះយ៉ា ខេត្តស្រះកែវ ចំនួន៥៧នាក់ ក្នុងនោះមានប្រុស៣០នាក់ ស្រី២០នាក់ និងក្មេង៧នាក់។ ក្រោយពីសមត្ថកិច្ចថៃអនុវត្តតាមវិធានសុខាភិបាល ពួកគេមិនមានឯកសារធ្វើដំណើរនោះឡើយ។

សូមជម្រាបថា នៅពេលសមត្ថកិច្ចថៃសួរនាំជំហានដំបូងបានឱ្យដឹងថា ពលរដ្ឋខ្មែរខាងលើធ្វើដំណើរមកពីខេត្តបាត់ដំបង៦នាក់,បន្ទាយមានជ័យ៣០នាក់, ខេត្តឧត្តរមានជ័យ១០នាក់, សៀមរាប២នាក់ និងខេត្តកំពង់ធំ៩នាក់ ដោយពួកគេចង់ធ្វើដំណើរទៅធ្វើការខាងសំណង់នៅទីក្រុងបាងកក, ឈុនបុរី , ខេត្តចះឆឹងសៅ, សមុទ្រប្រាកាន, ខេត្តនន់បុរី និងខេត្តប៉ះធំថានី។ តាមការសាកសួររបស់សមត្ថកិច្ចថៃ សម្រាប់ពលករខ្មែរខាងលើ ពួកគេបានឆ្លើយថាបានចំណាយប្រាក់ធ្វើដំណើរទៅខេត្តផ្សេងៗរបស់ថៃ ក្នុងម្នាក់ៗចាប់ពី៧,០០០ដល់៨,០០០បាត ដោយចំណាយឱ្យមេខ្យល់មុន១,០០០បាតក្នុងម្នាក់ នៅពេលទៅដល់គោលដៅទើបឱ្យគ្រប់ចំនួន។ ក្រោយសួរនាំរួចសមត្ថកិច្ចថៃបាននាំខ្លួនពលករខ្មែរទាំង៥៧នាក់ មកសួរនាំបន្ថែមនៅទីបញ្ជាការកងអនុសេនាធំទី1203 និងបញ្ជូនទៅឱ្យជំនាញ ដើម្បីចាត់ការតាមច្បាប់បន្ត៕

## ជនជាតិថៃ២១៤នាក់ដែលបង្ខំឱ្យធ្វើការនៅភ្នំពេញត្រូវប៉ូលិសថៃជួយសង្គ្រោះ

https://www.facebook.com/CHNChannelNews/ CHN Channel News *ថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២១*

ភ្នំពេញ៖ កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្សរបស់ប្រទេសថៃ សហការជាមួយអាជ្ញាធរកម្ពុជា និងស្ថានទូតថៃប្រចាំទីក្រុងភ្នំពេញ ជួយសង្គ្រោះជនជាតិថៃមួយក្រុមដែលត្រូវបានបង្ខំឱ្យធ្វើការដូចទាសករនៅក្នុងទីក្រុងភ្នំពេញ និងចាប់ខ្លួនជាច្រើននាក់ទៀត ពាក់ព័ន្ធនឹងការចោទប្រកាន់ពីបទជួញដូរមនុស្ស។ នេះបើយោងតាមការចុះផ្សាយរបស់សារព័ត៌មានថៃ nation thailand។

នាយឧត្តមសេនីយ៍ Surachet Hakphan ជំនួយការអគ្គស្នងការនគរបាលជាតិ បាននិយាយកាលពីថ្ងៃសុក្រថា ប៉ូលីសបានទទួលព័ត៌មានថា មានជនជាតិថៃប្រមាណជាង ៣០០ នាក់ ដែលធ្វើការនៅក្នុងអគារមួយក្នុងរាជធានីភ្នំពេញ។ មន្ត្រីបានឆ្មក់ចូលអគារនោះ ហើយចាប់ខ្លួនជនជាតិថៃ ៩ នាក់ ដែលចោទថា បាននាំជនរងគ្រោះទៅធ្វើការនៅទីនោះ និងជនជាតិចិន ២០ នាក់ ដែលចោទប្រកាន់ថាបានបើកប្រតិបត្តិការ។ ជនរងគ្រោះទាំងអស់នោះ ត្រូវបានបង្ខំឱ្យធ្វើការជិត២០ម៉ោងជារៀងរាល់ថ្ងៃ ហើយមនុស្សទាំងនេះត្រូវបានបង្ខំឱ្យរស់នៅក្នុងអគារ មិនត្រូវបានអនុញ្ញាតឱ្យប្រើទូរស័ព្ទ ឬហៅទូរស័ព្ទទៅកាន់គ្រួសាររបស់ពួកគេ ហើយត្រូវបានគេធ្វើបាបរាងកាយ។ លោក Surachet បាននិយាយថា "ជនរងគ្រោះជាច្រើនមានសញ្ញានៃការរំលោភលើរាងកាយរបស់ពួកគេ"។

ស៊ីស៊ីថាមស៍មិនអាចសុំការបញ្ជាក់បន្ថែមពីខាងអាជ្ញាធរកម្ពុជាបាននៅឡើយទេនៅថ្ងៃនេះ។ ចំណែកពលករ ២១៤ នាក់បានត្រឡប់ទៅប្រទេសថៃវិញ និង ៩៩ នាក់ផ្សេងទៀតកំពុងរង់ចាំដំណើរការឯកសារ។ ចំពោះជនជាតិថៃ និងចិនទាំងអស់ដែលត្រូវបានឃុំខ្លួននឹងត្រូវនាំទៅប្រទេសថៃ ដើម្បីកាត់ទោស។នេះបើតាមនគរបាលបាលថៃ៕

# ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១

## សមត្ថកិច្ចថៃ ចាប់បានប្រជាពលរដ្ឋខ្មែរ ១៣នាក់ទៀត លួចឆ្លងដែនខុសច្បាប់ តាមច្រកធម្មជាតិ

https://cen.com.kh/ Posted ByPen Srey NeatNovember 22, 2021

ខេត្តស្រះកែវ – ថៃ ៖ នៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ១និង៤០នាទី ទាហានថៃចាប់បានប្រជាពលរដ្ឋខ្មែរចំនួន១៣នាក់ ដែលលួចឆ្លងដែនខុសច្បាប់ តាមច្រកធម្មជាតិ ។ ពលរដ្ឋទាំងអស់ ត្រូវបានចាប់បាននៅភូមិថ្លាម ភូមិ១០ ឃុំតាប្រាយ៉ា ស្រុកតាប្រា ខេត្តស្រះកែវ។ ពួកគេទាំងអស់ ធ្វើដំណើរមកពីខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ចង់ធ្វើការក្នុងនៅទីក្រុងបាងកក និង ខេត្តឆាក់ឈើងសាវ ហើយមន្ត្រីបានឃាត់ខ្លួនពួកគេដើម្បីចាត់ការបន្តតាមផ្លូវច្បាប់៕ រក្សាសិទ្ធិដោយ ៖ កូលាប

## សមត្ថកិច្ចថៃ ឃាត់ខ្លួនពលករខ្មែរប្រុស-ស្រី ៥៧នាក់ ឆ្លងដែនខុសច្បាប់

https://khmernote.com.kh/ November 22, 2021 srey nuch

ខេត្តបន្ទាយមានជ័យ៖ យោងតាមការចុះផ្សាយរបស់ នាយកដ្ឋានផ្សព្វផ្សាយអប់រំ នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ បានឲ្យដឹងថា តាមសេចក្តីរាយការណ៍ពីសមត្ថកិច្ចតាមបន្ទាត់ព្រំដែន កាលពីវេលាម៉ោង ១២និង២០នាទី ថ្ងៃត្រង់ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២១នេះ កម្លាំងទាហានប្រាណទី១២ ប្រចាំស្រុកតាប្រាយ៉ានិង កងកម្លាំងបូរផា បានចុះល្បាត និងត្រួតពិនិត្យក្នុងតំបន់ដែលខ្លួនទទួលខុសត្រូវ បានប្រទះឃើញក្រុមបុគ្គលគួរឲ្យសង្ស័យដើរតាមច្រករបៀង សំដៅមកប្រទេសថៃ ត្រង់បរិវេណបង្គោលគីឡូម៉ែត្រ២៧-២៨ ភូមិទព័សៀម ឃុំ/ស្រុកតាប្រាយ៉ា ខេត្តស្រះកែវ ចំនួន៥៧នាក់ ក្នុងនោះប្រុស៣០ ស្រី២០ និងក្មេង០៧នាក់ ហើយក៏ធ្វើការឃាត់ខ្លួន។

បន្ទាប់មកសមត្ថកិច្ចថៃអនុវត្តបានត្រួតពិនិត្យតាមវិធានសុខាភិបាល នឹងត្រួតពិនិត្យរកឯកសារ ប្រជាពលរដ្ឋទាំងនោះមិនមានឯកសារធ្វើដំណើរនោះឡើយ។ ពេលសមត្ថកិច្ចថៃសួរនាំមានពលរដ្ឋខ្មែរមកពីខេត្តបាត់ដំបង៦នាក់,បន្ទាយមានជ័យ ៣០នាក់, ឧត្តមានជ័យ១០នាក់, សៀមរាប២នាក់ និងកំពង់ធំ៩នាក់ ដោយពួកគាត់មានបំណង ចង់ធ្វើដំណើរទៅធ្វើការខាងសំណង់នៅក្រុងបាងកក,ឈុនបុរី ,ខេត្តចះធឹងសៅ ,សមុទ្រប្រាកាន ,ខេត្តនន់បុរី និងខេត្តប៉ះធំថានី ។

សមត្ថកិច្ចថៃបញ្ជាក់ថា៖ សម្រាប់ពលករខ្មែរខាងលើ ពួកគាត់បានឆ្លើយថាចំណាយប្រាក់ធ្វើដំណើរទៅខេត្តផ្សេងៗរបស់ថៃ ក្នុងម្នាក់ៗចាប់ពី៧,០០០ដល់៨,០០០បាត ដោយចំណាយឲ្យមេខ្យល់មុន១,០០០បាតក្នុងម្នាក់ នៅពេលដល់គោលដៅទើបឲ្យគ្រប់ចំនួន ក្រោយសួរនាំ សមត្ថកិច្ចថៃបាននាំខ្លួនពលករខ្មែរទាំង៥៧នាក់ មកសួរនាំបន្ថែមនៅទីបញ្ជាការកងអនុសេនាធំទី១២០៣ និងបញ្ជូនទៅឲ្យជំនាញ ដើម្បីចាត់ការតាមនិតិវិធីបន្ត៕

## ក្នុងខែតុលាសមត្ថកិច្ចថៃ ចាប់បញ្ជូនពលករខ្មែរជាង១ពាន់នាក់មកវិញ តាមច្រកខេត្តបាត់ដំបង

https://news.btv.com.kh/ 11/22/2021 01:11 PM

បាត់ដំបង៖ រយៈពេលពេញមួយខែតុលា ឆ្នាំ២០២១ ពលករខ្មែរជាង១ពាន់នាក់ ដែលបានលួចឆ្លងដែនខុសច្បាប់ទៅដល់ទឹកដីថៃត្រូវបានសមត្ថកិច្ចថៃចាប់បញ្ជូនមកឲ្យអាជ្ញាធរកម្ពុជាវិញតាមច្រកព្រំដែនខេត្តបាត់ដំបង។ ទោះបីជាអាជ្ញាធរ និងកងកម្លាំងការពារព្រំដែនចុះល្បាតទប់ស្កាត់ និងបង្ក្រាបទាំងយប់ទាំងថ្ងៃ ប៉ុន្តែសកម្មភាព

បណ្តាញមេខ្យល់នាំមនុស្សឆ្លងដែនចេញចូលខុសច្បាប់ និងប្រជាពលរដ្ឋលបលួចឆ្លងដែនខុសច្បាប់ ចូលប្រទេសថៃ នៅតែបន្តកើតមានឡើងឥតឈប់ឈរ។

យោងតាមរបាយការណ៍របស់រដ្ឋបាលខេត្តបាត់ដំបង បានបញ្ជាក់ថា ក្នុងខែតុលា អាជ្ញាធរ និងកងកម្លាំងចម្រុះការពារព្រំដែន បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋ ដែលបម្រុងឆ្លងដែនខុសច្បាប់ចំនួន ១៦លើក ដែលមានមនុស្ស២៣៩នាក់ និងសមត្ថកិច្ចថៃ បានចាប់បញ្ជូនមកវិញចំនួន៥០លើក ចំនួនមនុស្ស១១៨២នាក់ ។ ជាមួយគ្នានោះ កម្លាំងសមត្ថកិច្ចចម្រុះការពារព្រំដែនក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការ បង្ក្រាបករណីនាំចេញមនុស្សឆ្លងដែនខុសច្បាប់ ចូលប្រទេសថៃ ចំនួន១៧ករណី ឃាត់ខ្លួន២៦នាក់ អប់រំពលករ ១២៨នាក់ និងបានជួបប្រជុំជាមួយភាគីថៃ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការល្អ និងផ្លាស់ប្តូរព័ត៌មាន ចំនួន៥លើក។ ក្នុងខែតុលាកន្លងទៅនេះ ក៏មានអ្នកដំណើរឆ្លងកាត់ច្រកព្រំដែនអន្តរជាតិដូង ច្រកព្រំដែនអន្តរ ជាតិភ្នំដី និងច្រកទ្វារតំបន់ទាំងបី (មាន ច្រកអូរអន្លក់ (សួនស៊ុ) អូរជ្រៃ និងច្រក៤០០) ទាំងចេញ និងចូលសរុបចំនួនជាង៦២០០នាក់។

អាជ្ញាធរខេត្តបាត់ដំបង បានដាក់ទិសដៅបង្កើនសកម្មភាពល្បាតត្រួតពិនិត្យតាមបន្ទាត់ព្រំដែន ដោយរក្សាឲ្យខាងតែបាននូវបូរណភាពទឹកដី និងជំរុញសកម្មភាពប្រយុទ្ធប្រឆាំងការជួញដូរមនុស្សឲ្យខ្លាំងក្លាបន្ថែមទៀត ដោយយកចិត្តទុកដាក់ទប់ស្កាត់ និងបង្ក្រាបឲ្យមានប្រសិទ្ធភាពក្នុងសកម្មភាពជួញដូរ ពលករឆ្លងដែន និងចំណាកស្រុកខុសច្បាប់។ ដើម្បីចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩នៅកម្ពុជា កងកម្លាំងចម្រុះការពារព្រំដែន ក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បានធ្វើការទំនាក់ទំនង និងសហការយ៉ាងជិតស្និទជាមួយភាគីថៃ ដើម្បីទប់ស្កាត់មិនឲ្យប្រជាពលរដ្ឋខ្មែរលបលួចឆ្លងដែនចូលទៅក្នុងទឹកដីថៃដោយមិនស្របច្បាប់៕ អត្ថបទ៖ នឿត សុកគ្រ្គ

## ពលរដ្ឋខ្មែរជាង ២០នាក់ឆ្លងដែនខុសច្បាប់ត្រូវថៃចាប់ខ្លួន

https://www.khmertimeskh.com/ ខ្មែរថាមស៍ November 23, 2021

អាជ្ញាធរថៃបានចាប់ខ្លួនពលរដ្ឋខ្មែរជាង ២០នាក់ជាថ្មីម្តងទៀត ក្នុងរយៈពេលពីរថ្ងៃ ដែលចូលប្រទេសថៃដោយខុសច្បាប់។ ពលរដ្ឋមួយក្រុមនេះត្រូវបានចាប់ខ្លួននៅថ្ងៃទី ២១ ខែវិច្ឆិកានិង ថ្ងៃទី ២២ ខែវិច្ឆិកា។ អាជ្ញាធរថៃបានចាប់ខ្លួនមនុស្ស ៩ នាក់នៅថ្ងៃទី ២១ ខែវិច្ឆិកានិង ១៣ នាក់នៅថ្ងៃទី ២២ ខែវិច្ឆិកា។ បើតាមព័ត៌មានក្នុងស្រុកបានឲ្យដឹងថា បន្ទាប់ពីមានការចាប់ខ្លួនជនជាតិខ្មែរ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានជួយអន្តរាគមន៍ និងសម្របសម្រួលឱ្យពលរដ្ឋខ្មែរត្រឡប់ទៅប្រទេសវិញ។ ពួកគេត្រូវបានបញ្ជូនមកកម្ពុជាវិញនៅថ្ងៃទី២២ វិច្ឆិកា ហើយត្រូវប្រគល់ឱ្យអាជ្ញាធរកម្ពុជានៅច្រកទ្វារអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត សម្រាប់នីតិវិធីសុខភាពចាំបាច់ មុននឹងពួកគេអាចត្រឡប់ទៅផ្ទះវិញបាន។

អត្ថបទមុនរបស់ខ្មែរថាមស៍ បានសរសេរថា ពលករចំណាកស្រុករាប់សិបនាក់ បាននិងកំពុងព្យាយាមឆ្លងដែនចូលប្រទេសថៃជារៀងរាល់ថ្ងៃ ដើម្បីស្វែងរកការងារធ្វើ។ ខេត្តនានានៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ បន្តឃើញការប៉ុនប៉ងឆ្លងដែនខុសច្បាប់ ខណៈពលរដ្ឋខ្មែរព្យាយាមរកការងារធ្វើនៅប្រទេសថៃ។ តាមការបញ្ជាក់របស់មន្ត្រីនគរបាលច្រកទ្វារព្រំដែនអូរបីជាន់ ខេត្តបន្ទាយមានជ័យ លោក អ៊ាម ស៊ីគឿន អត្រាពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ក្នុងមួយថ្ងៃមានជាង ៤០នាក់ ហើយអាជ្ញាធរថៃបានបង្កើនវិធានការទប់ស្កាត់ការឆ្លងដែនខុសច្បាប់ផងដែរ៕

## ពលរដ្ឋខ្មែរ ២២នាក់ ដែលសមត្ថកិច្ចថៃឃាត់ខ្លួនករណីលួចឆ្លងដែនខុសច្បាប់ ត្រូវបាន បញ្ជូនមកកម្ពុជាវិញ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១

(បន្ទាយមានជ័យ)៖ អាជ្ញាធរមានសមត្ថកិច្ចថៃបានឃាត់ខ្លួនពលករខ្មែរ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតយកឆ្លងដែនចូលប្រទេសថៃដោយខុសច្បាប់ ចំនួន ៩នាក់ កាលពីថ្ងៃទី២១ និង ១៣នាក់ទៀត នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១នេះ។ តាមព័ត៌មានដែល Swift News ទទួលបាន ស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវ ប្រទេសថៃ បានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើមកមាតុប្រទេសវិញ នៅថ្ងៃដែលពួកគាត់ត្រូវបានឃាត់ខ្លួន តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល៕

## អាជ្ញាធរខេត្តជាប់ព្រំដែនត្រៀមពិភាក្សាជាមួយថៃ ដើម្បីបើកច្រកអន្តរជាតិឡើងវិញ

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 23 November 2021 | 09:15 ICT

**ភ្នំពេញ:** ថ្នាក់ដឹកនាំខេត្តជាប់ព្រំដែនកម្ពុជា-ថៃ កំពុងត្រៀមជួបប្រជុំពិភាក្សាគ្នាលើការបើកដំណើរការច្រកព្រំដែនអន្តរជាតិនានាឡើងវិញ ដើម្បីសម្រួលដល់ការចេញ-ចូលរបស់ប្រជាពលរដ្ឋ និងបើកអាជីវកម្ម ក៏ដូចជាការដឹកទំនិញ និងប្រកបរបរឆ្លងកាត់ព្រំដែននៃប្រជាជនប្រទេសទាំង ២។

លោក លី សារី អភិបាលរងខេត្តបន្ទាយមានជ័យថ្លែងនៅថ្ងៃទី ២២ វិច្ឆិកាថា រដ្ឋបាលខេត្តបន្ទាយមានជ័យនៅថ្ងៃទី ២៥ ខែវិច្ឆិកាខាងមុខនេះនឹងបើកកិច្ចប្រជុំជាមួយភាគីថៃ ស្ដីពីការបើកច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត និងច្រកមួយចំនួនទៀត ដើម្បីសម្រួលដល់ការចេញចូលរបស់ប្រជាពលរដ្ឋដូចធម្មតាឡើងវិញ។ លោកបានថ្លែងថា៖ «តាមផែនការនៃកិច្ចប្រជុំនេះ គឺយើងត្រៀមពិភាក្សាគ្នាក្នុងការបើកច្រកចេញ-ចូលព្រំដែនជាប្រក្រតីឡើងវិញ។ បើកច្រកបណ្ដោះអាសន្នតាមច្រកអន្តរជាតិថ្មីគឺច្រកស្ទឹងបត់ រួមនឹងពិភាក្សាគ្នាលើការការពារការរត់ពន្ធគ្រឿងញៀន និងជួញដូរមនុស្សជាដើម»។ លោក សារី បានឱ្យដឹងថា កិច្ចប្រជុំនេះភាគីថៃ បានស្នើសុំកម្ពុជាទៅចូលរួមធ្វើនៅលើទឹកដីប្រទេសថៃស្ថិតក្នុងខេត្តស្រះកែវ ដោយផ្ដោតសំខាន់លើការបើកច្រកចេញចូលព្រំដែនជាប្រក្រតីឡើងវិញ និងការស្នើរបស់ភាគីថៃក្នុងការចុះមកពិនិត្យវឌ្ឍនភាព នៃការសាងសង់ច្រកអន្តរជាតិថ្មីស្ទឹងបត់ដែលកំពុងសាងសង់។ លោកបានឱ្យដឹងថា ការប្រជុំរៀបចំបើកច្រកព្រំដែនកម្ពុជា-ថៃឡើងវិញនេះ ក្រោយពីស្ថានភាពនៃការឆ្លងរីករាលដាលជំងឺកូវីដ ១៩ មានការធូរស្រាល និងប្រជាពលរដ្ឋនៅតាមខេត្តជាប់ព្រំដែនភាគច្រើនបានចាក់វ៉ាក់សាំងការពារជំងឺកូវីដ ១៩ បាន ២-៣ ដូសរួចហើយ។ លោកបានបន្ថែមថា បញ្ហាប្រឈមនៅតាមព្រំដែនកម្ពុជា-ថៃ គឺប្រជាពលរដ្ឋកម្ពុជាមួយចំនួននៅបន្តចាញ់បោកមេខ្យល់លួចឆ្លងដែនខុសច្បាប់តាមច្រករបៀង ដែលអាចប្រឈមនឹងគ្រោះថ្នាក់គ្រប់ពេល។

លោក សឿម ប៊ុនរិទ្ធិ អភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបងក៏បានឱ្យដឹងដែរថា ទាក់ទងនឹងការបើកច្រកព្រំដែនកម្ពុជា-ថៃឡើងវិញនេះ ភាគីទាំង ២ គឺមានបំណងបើកដូចគ្នា ប៉ុន្តែដោយសារបញ្ហាជំងឺកូវីដ ១៩ នៅប្រទេសថៃ មានសភាពធ្ងន់ធ្ងរជាងកម្ពុជា ដូច្នេះការបើកជាប្រក្រតីឡើងវិញត្រូវរង់ចាំការឯកភាពគ្នាជាមុនសិន។ លោកបញ្ជាក់ថា៖ «ចាប់តាំងពីខែមិថុនា ខេត្តនៅជាប់ព្រំដែនកម្ពុជា-ថៃបានបើកឱ្យចរាចរទំនិញចេញ-ចូលជាធម្មតា ប៉ុន្តែចំពោះការបើកដំណើរការចេញ-ចូលរបស់ប្រជាពលរដ្ឋជាធម្មតាឡើងវិញគឺមិនទាន់អនុញ្ញាតនៅឡើយទេ គឺរង់ចាំការឯកភាពពីរដ្ឋាភិបាលថៃសិន»។ លោកបានបន្តថា៖ «ការបើកជាធម្មតាឡើងវិញខាងយើងបានឯកភាពហើយ ដោយទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាលក្នុងការបើកឡើងវិញ ប៉ុន្តែភាគីថៃនៅមិនទាន់មានគោលការណ៍នៅឡើយ។ ដូច្នេះជាធម្មតាប្រទេសជិតខាងគ្នាទាល់តែមានការឯកភាពគ្នាទាំងសងខាង»។ លោក សឿម

ប៊ុនរិទ្ធិ បញ្ជាក់ថា បច្ចុប្បន្នរដ្ឋបាលខេត្តក៏កំពុងរង់ចាំការស្នើសុំប្រជុំពីភាគីថៃ សម្រាប់ការបើកដំណើរការច្រកព្រំដែននានារវាងខេត្តទាំង ២ ជាប្រក្រតីឡើងវិញដែរ។

ដោយឡែកលោក សំឃិត វៀន អភិបាលរងនៃគណៈអភិបាលខេត្តកោះកុងបានឱ្យដឹងដែរថា ច្រកព្រំដែនអន្តរជាតិកម្ពុជា-ថៃក្នុងភូមិសាស្ត្រខេត្តកោះកុងបានបើកដំណើរការចរាចរណ៍ទំនិញជាធម្មតា ប៉ុន្តែការបើកច្រកជាប្រក្រតីឡើងវិញ ភាគីទាំង ២ នៅមិនទាន់បានពិភាក្សាគ្នាទេ។ លោកថ្លែងថា៖ «មកទល់ពេលនេះ យើងមិនទាន់បានទទួលព័ត៌មានពីភាគីថៃចំពោះការស្នើសុំបើកច្រកព្រំដែនឡើងវិញជាប្រក្រតីនៅឡើយទេ។ ខាងយើងមិនមានបញ្ហាអ្វីទេ យើងរង់ចាំតែបើកឡើងវិញទេ ប៉ុន្តែកិច្ចការងារនេះ គឺត្រូវរង់ចាំការឯកភាពពីភាគីថៃដែរ»៕

## ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១

## នគរបាលបាត់ដំបងបង្កើនល្បាតព្រំដែនទប់ស្កាត់ការឆ្លងដែនខុសច្បាប់

https://www.khmertimeskh.com/ ខ្មែរថាមស៍ November 24, 2021

កម្លាំងនគរបាលខេត្តបាត់ដំបង បានបង្កើនការល្បាតតាមព្រំដែន ក្នុងកិច្ចប្រឹងប្រែងទប់ស្កាត់ការកើនឡើងនៃការឆ្លងដែនខុសច្បាប់ចូលទៅក្នុងប្រទេសថៃ។ ការល្បាតត្រូវបានធ្វើឡើង ចំពេលមានសេចក្តីរាយការណ៍ថា ពលករចំណាកស្រុកបានលួចឆ្លងព្រំដែន។ ការចុះល្បាតនេះត្រូវបានបញ្ជាដោយលោកឧត្តមសេនីយ៍ទោ សាត គឹមស៊ាន ស្នងការនគរបាលខេត្ត។ សមត្ថកិច្ចបានចាត់កម្លាំងចុះល្បាតតាមគោលដៅចំនួន៥០ តាមបណ្តោយព្រំដែនក្នុងខេត្តបាត់ដំបង ដើម្បីស្ទាក់ចាប់មេខ្យល់ឲ្យបាន៕

## ថៃ ឃាត់ខ្លួន និងបញ្ជូនពលរដ្ឋខ្មែរ ២០នាក់ ត្រឡប់មកកម្ពុជាវិញ

https://dap-news.com/national/ ByKD102 Posted on November 24, 2021

**ភ្នំពេញ៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសខ្មែរ បានឲ្យដឹងថា កាលពីព្រឹកថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ អាជ្ញាធរមានសមត្ថកិច្ចថៃ បានឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន ២០នាក់ (ស្រី ៩នាក់) ដែលត្រូវបានមេខ្យល់បោកបញ្ឆោត យកឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់។ ភ្លាមៗស្ថានអគ្គកុងស៊ុលកម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ បានចុះទៅអន្តរាគមន៍ ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើ មកមាតុប្រទេសវិញ នៅរសៀលថ្ងៃដដែល តាមច្រកទ្វារព្រំដែន អន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការ តាមនីតិវិធីសុខាភិបាល ៕

## គណៈរដ្ឋមន្ត្រីថៃសម្រេចឲ្យបើកច្រកព្រំដែនអន្តរជាតិបានឡែម ខេត្តចន្ទបុរី ត្រូវនឹងច្រកព្រំដែនអន្តរជាតិភូមិដូង ខេត្តបាត់ដំ

https://www.facebook.com/Khmer.Channel.kh/ **ទឹកចិត្ត ពលករ ឆ្លងដែន** *ថ្ងៃទី 24 វិច្ឆិកា 2021!*

ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១ គណៈរដ្ឋមន្ត្រីថៃសម្រេចឲ្យបើកច្រកព្រំដែនអន្តរជាតិបានឡែម ខេត្តចន្ទបុរី ត្រូវនឹងច្រកព្រំដែនអន្តរជាតិភូមិដូង ខេត្តបាត់ដំបង ដើម្បីនាំពលករកម្ពុជាចូលមកធ្វើការតាមផ្លូវកាលដោះស្រាយបញ្ហាកង្វះខាតកំលាំងពលកម្ម ចាប់ផ្តើមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១។

លោក ប៊ុនធប សុទ្ធម៉ៈណាត់វង្ស នាយកខុទ្ទកាល័យក្រសួងការងារ អញ្ជើញជាប្រធានដឹកនាំកិច្ចប្រជុំដើម្បីត្រៀមលក្ខណៈក្នុងការនាំពលករបរទេសចូលមកធ្វើការក្នុងស្ថានការណ៍ការរីករាតត្បាតជំងឺកូវីដ១៩ តាមប្រព័ន្ធអនឡាញ ដោយមានការអញ្ជើញចូលរួមពីលោកអភិបាលរងខេត្តចន្ទថៈបុរីព្រមទាំងគណៈប្រតិភូ មន្ទីរការងារ សមាគម

ន៍ពាណិជ្ជកម្ម-ទេសចរណ៍ព្រំដែនកម្ពុជា-ថៃខេត្តចន្ទបុរី ការិយាល័យអន្តោប្រវេសន៍ និងអង្គភាពផ្នែកសន្តិសុខជាតិ។ កិច្ចប្រជុំបានសម្រេចគោលនយោបាយនាំពលករកម្ពុជាចូលមកធ្វើការតាមរដូវកាលនៅក្នុងភូមិសាស្ត្រខេត្តចន្ទបុរី។ ដោយឲ្យខេត្តចន្ទបុរីនាំពលករពីប្រទេសកម្ពុជាចូលមកដោះស្រាយបញ្ហាកង្វះខាតកំលាំងពលកម្មបេះផ្លែមៀន ចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ នៅច្រកព្រំដែនអន្តរជាតិបានទ្បែម ខេត្តចន្ទបុរី ត្រូវនឹងច្រកព្រំដែនអន្តរជាតិភូមិដូង ខេត្តបាត់ដំបង។

ពលករដែលធ្វើដំណើរចូល ត្រូវអនុវត្តតាមវិធានការដែលក្រសួងការងារស្នើទៅមជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍ជំងឺកូវីដ១៩ មានដូចជា មានលិខិតបញ្ជាក់ការចាក់វ៉ាក់សាំងកូវីដ១៩គ្រប់២ដូស ឬមួយដូសក្នុងករណីចាក់វ៉ាក់សាំងកូវីដ១៩ម៉ាកចនសាន់អែនចនសាន់ និងត្រូវឆ្លងកាត់ការត្រួតពិនិត្យ RT-PCR នៅច្រកព្រំដែនមុនចូលធ្វើចត្តាឡីស័ករយៈពេល ៧ថ្ងៃ ដោយថ្លៃចំណាយផ្សេងៗនិយោជកជាអ្នកទទួលបន្ទុក។ ខេត្តចន្ទបុរីបានត្រៀមលក្ខណៈរួចរាល់ហើយ ៩០% ដំណាក់កាលបន្តរង់ចាំការទំនាក់ទំនងផ្នែកឯកសារទៅកាន់ភាគីកម្ពុជា សន្និដ្ឋានថាថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២១ នេះ នឹងអាចដំណើរការបានយ៉ាងពិតប្រាកដ។ ប្រភព: NBT News

## ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១

### កម្ពុជា-ថៃ ពិភាក្សាគ្នាទប់ស្កាត់ការជួញដូរមនុស្សឆ្លងដែនខុសច្បាប់ កុំឱ្យចូលក្នុងទឹកដីថៃ

https://swiftnewsdaily.com/ SWIFT NEWS ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១

(បាត់ដំបង)៖ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានចាត់កម្លាំងនគរបាលចំណុះវរសេនាតូច នគរបាលការពារព្រំដែនគោកលេខ ៨១៧ ដឹកនាំដោយលោកវរសេនីយ៍ទោ ហ៊ុន ខែត មេបញ្ជាការរងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានជួបពិភាក្សាជាមួយភាគីតម្រួតល្បាតព្រំដែនថៃកងអនុសេនាធំលេខ១២៧ ដែលទើបផ្លាស់មកប្រចាំការទល់មុខD៨១៧ ចំនួន១៧នាក់ ,អាវុធខ្លីចំនួន០២ដើម ដឹកនាំដោយលោកវរសេនីយ៍ទោ ខាត់នីត-ភីវ៉ាខាវ មេបញ្ជាការកងអនុសេនាធំលេខ១២៧។

កិច្ចពិភាក្សាទ្វេភាគី បានពិភាក្សាលើ សហការទប់ស្កាត់ការនាំអាវុធចេញទៅប្រទេសថៃខុសច្បាប់ , សហកាទប់ស្កាត់ការជួញដូរមនុស្សឆ្លងដែនខុសច្បាប់ចូលក្នុងទឹកដីថៃ , បង្កើនកិច្ចសហការបន្ថែមទៀតក្នុងការផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក បើសិនជាមានបទល្មើសកើតឡើង។ កិច្ចពិភាក្សានេះភាគីតម្រួតល្បាតព្រំដែនថៃបានសំណូមពរមកភាគីកម្ពុជា ទំនាក់ទំនងគ្នាល្អ, ជួយទប់ស្កាត់ពលករខ្មែរដែលចូលទៅប្រទេសថៃដោយខុសច្បាប់,សុំឲ្យមានការជួបពិភាក្សារួមគ្នាក្នុងមួយខែម្តង តាមកងអនុសេនាធំនីមួយៗ,ស្នើឲ្យភាគីកម្ពុជាជួយទប់បស្កាត់ ការលួចដឹករ៉ែមាសត្រង់ចំណុច១១៣៕

### នារីខ្មែរអាយុ១៨ឆ្នាំនិង២៣ឆ្នាំត្រូវគេបោកទៅចិនត្រូវអគ្គកុងស៊ុលខ្មែរជួយ និងនាំមកស្រុកវិញ

https://www.facebook.com/CHNChannelNews/ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ ម៉ោង ១២:៤៥:៥៥

ភ្នំពេញ៖ បន្ទាប់ពីការអំពាវនាវរបស់ស្ត្រីខ្មែរដែលចាញ់បោកមេខ្យល់នាំទៅធ្វើការនៅប្រទេសចិន ឱ្យស្ថានអគ្គកុងស៊ុលកម្ពុជា ប្រចាំនៅចិនជួយនាំត្រឡប់មកស្រុកកំណើតវិញកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ មកទល់ពេលនេះស្ថានអគ្គកុងស៊ុលសហការជាមួយអាជ្ញាធរចិន បានជួយសម្របសម្រួលបញ្ជូនស្ត្រីខ្មែរចំនួន ២រូប ដែលរស់នៅខុសច្បាប់ក្នុងប្រទេសចិន ឲ្យវិលត្រឡប់ទៅកម្ពុជាវិញនៅថ្ងៃនេះ។

លោក យស សុខេមរៈ អគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅទីក្រុងធុងឈីង បានប្រាប់ស៊ីស៊ីថាមស៍ថា នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១នេះ ស្ថានអគ្គកុងស៊ុល សហការជាមួយអាជ្ញាធរចិន បានជួយសម្របសម្រួលបញ្ជូនស្ត្រីខ្មែរចំនួន ២រូប ដែលរស់នៅខុសច្បាប់ក្នុងប្រទេសចិន ឲ្យវិលត្រឡប់ទៅកម្ពុជាវិញ ដែលនឹងទៅដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញនៅវេលាម៉ោង ១៥:៣៥ រសៀលនេះ។ លោកបញ្ជាក់ថា ស្ត្រី២រូបដែលនឹងវិលត្រឡប់មកកម្ពុជានៅថ្ងៃនេះវិញមានឈ្មោះ សឿន បុប្ផា អាយុ២៣ឆ្នាំ មានស្រុកកំណើតនៅខេត្តស្ទឹងត្រែង និង មួយរូបទៀតឈ្មោះ ឈៀន ធុង អាយុ ១៨ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពង់ធំ។

គួរបញ្ជាក់ថា នារីរងគ្រោះឈ្មោះ សឿន បុប្ផា ដោយសារគ្រួសារមានជីវភាពខ្វះខាត បណ្តាលឱ្យនារីរងគ្រោះរូបនេះបានចាញ់បោកពាក្យលួងលោមជាច្រើនលើកច្រើនសារពីមេខ្យល់ ហើយកាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ រូបនាងបានរៀបរាប់តាមរយៈប្រអប់សារមកកាន់ស៊ីស៊ីថាមស៍ថា រូបនាងត្រូវបានចាញ់បោកមេខ្យល់ឱ្យមកធ្វើការនៅចិនអស់រយៈពេលជាងកន្លះឆ្នាំហើយបើគិតមកដល់បច្ចុប្បន្ននេះ ចាប់ពីខែធ្នូ ឆ្នាំ២០២០ ដល់ខែកក្កដា ឆ្នាំ២០២១៕ ប្រភព៖ ស៊ីស៊ីថាមស៍

## កម្ពុជា-ថៃ ប្រជុំពិភាក្សាគ្រោងបើកច្រកទ្វារអន្តរជាតិ និងច្រកតំបន់តាមបណ្តោយព្រំដែន ក្នុងខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង

http://freshnewsasia.com/ 2021-11-25 05:12pm

**(បន្ទាយមានជ័យ)៖** អភិបាលខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង បានជួបប្រជុំពិភាក្សាជាមួយអភិបាលខេត្តស្រះកែវ ប្រទេសថៃ នៅរសៀលថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅទីស្នាក់ការអន្តរជាតិក្លងលឹក ស្រុកអារ៉ញ្ញ ខេត្តស្រះកែវ ដើម្បីឈានដល់ការបើកច្រកព្រំដែនអន្តរជាតិ និងច្រកតំបន់តាមបណ្តោយព្រំដែនរវាងខេត្ត នៃប្រទេសទាំង២ឡើងវិញ។ ប្រតិភូកម្ពុជាដឹកនាំដោយលោក អ៊ុំ រាត្រី អភិបាលខេត្តបន្ទាយមានជ័យ និងលោក សុខ លូ អភិបាលខេត្តបាត់ដំបង ដោយឡែកភាគីថៃដឹកនាំដោយលោក បរិនបញ្ញា ភោធិសាធ អភិបាលខេត្តស្រះកែវ ព្រមទាំងមានការចូលរួមពីមន្ត្រីពាក់ព័ន្ធ និងកងកម្លាំងប្រដាប់អាវុធជាច្រើនរូបទៀត។

តាមសេចក្តីរាយការណ៍ពីភ្នាក់ងារព័ត៌មាន Fresh News ប្រចាំខេត្តបន្ទាយមានជ័យ បានឲ្យដឹងថា ភាគីទាំង២ បានពិភាក្សា ដើម្បីឈានដល់ការបើកច្រកជាប់ព្រំដែនខេត្តបន្ទាយមានជ័យរួមមាន៖ ច្រកទ្វារអន្តរជាតិប៉ោយប៉ែត ច្រកម៉ាឡៃ ច្រកបឹងត្រកួន រីឯខេត្តបាត់ដំបង គ្រោងបើកច្រកទ្វារអន្តរជាតិគីឡូ១៣ ស្រុកសំពៅលូន ឈមភាគីច្រកខៅឌិន ស្រុកក្លងហាត ខេត្តស្រះកែវ។ នៅក្នុងកិច្ចប្រជុំនោះ ភាគីកម្ពុជាបានស្នើសុំឲ្យចេញចូល១ថ្ងៃត្រឹម ៣.០០០នាក់ ពេលចេញចូលម៉ោង៦ព្រឹក ដល់ម៉ោង១០យប់ អ្នកអូសរទេះ១ថ្ងៃ អនុញ្ញាតត្រឹម៣០០ជើងក្នុង១រទេះ តែត្រូវអនុវត្តតាមការណែនាំរបស់ ក្រសួងសុខាភិបាលជានិច្ច។ សម្រាប់ពលករដែលមានបណ្ណឆ្លងព្រំដែនត្រូវអនុញ្ញាតរយៈពេល៣ខែ សម្រាប់ធ្វើកសិកម្មតាមបន្ទាត់ព្រំដែន។ ក្នុងប្រជុំពិភាក្សាភាគីថៃ បានទទួលយកសំណើពីភាគីកម្ពុជា ដើម្បីស្នើសុំបន្តទៅថ្នាក់ដឹកនាំរដ្ឋាភិបាលថៃរបស់ពួកគេ ដើម្បីសម្រេចពេលក្រោយ៕

## អាជ្ញាធរថៃ ចាប់ឃាត់ខ្លួនជនចំណាកស្រុកជិត២០០នាក់ ឆ្លងដែនចូលក្នុងប្រទេសរបស់ខ្លួន

https://kbn.news/ November 25, 2021

រាជធានីបាងកក៖ ប្រជាពលរដ្ឋភូមា បានឆ្លងដែនដោយខុសច្បាប់ ចូលមកទឹកដីថៃ ក៏ត្រូវអាជ្ញាធរ នៃប្រទេសនេះចាប់ឃាត់ខ្លួន ជិត២០០នាក់ នៅក្នុងព្រៃ ស្ថិតក្នុងឃុំ Tambon Chong Khaeb ស្រុក Phop Phra នាខេត្តភាគខាងជើង កាលពីព្រឹក ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២១។ សារព័ត៌មាន Bangkok Post បានចេញផ្សាយ នៅថ្ងៃព្រហស្បតិ៍ (ទី២៥ ខែវិច្ឆិកា) ថា អ្នកឆ្លងដែនខុសច្បាប់ ចំនួន ១៨៤នាក់ បានចេញ មកពី

ប្រទេសភូមា ហើយត្រូវបានចាប់ខ្លួន នៅក្នុងចំណុចខាងលើ។ ការចាប់ខ្លួនជនចំណាកស្រុក ឆ្លងដែនដោយខុសច្បាប់នេះ បានធ្វើឡើង ខណៈប៉ូលិស ទាហាន និងអាជ្ញាធរថៃ កំពុងតែដើរល្បាត។

មន្ត្រីប៉ូលិស បានបញ្ជាក់ថា ជនចំណាកស្រុក ទាំង១៨៤នាក់នោះ មានបុរស១១១នាក់ និងស្ត្រី៧២នាក់។ ពួកគេទាំងអស់ជាជនជាតិមីយ៉ាន់ម៉ា (ឬភូមា) ហើយក៏មានឯកសារពាក់ព័ន្ធការឆ្លងដែននេះ។ ប៉ុន្តែក្រោយការពិនិត្យសុខ ស្វែងរកជំងឺកូវីដ-១៩ ប៉ូលិសបានបញ្ជូនទៅកាន់អធិការដ្ឋានប៉ូលិសស្រុក Phop Phra ដើម្បីសាកសួរ និងចាត់ការតាមច្បាប់៕

## ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១

## សម្តេច ស ខេង ស្នើបារាំង រួមគ្នាជាមួយកម្ពុជា ប្រយុទ្ធប្រឆាំង បទល្មើសបច្ចេកវិទ្យា និង ឧក្រិដ្ឋកម្មឆ្លងដែន

https://dap-news.com/national/ ByPH104 Posted on November 26, 2021

**ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានស្នើពិនិត្យលទ្ធភាពរៀបចំកិច្ចសហប្រតិបត្តិការរវាង កម្ពុជា-បារាំង លើកការងារ សន្តិសុខ រួមទាំង ប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា និងឧក្រិដ្ឋកម្មឆ្លងដែន។** ក្នុងជំនួបពិភាក្សាការងារជាមួយ លោក ហ្សាក់ ប៉ីឡេត (Jacques Pellet) ឯកអគ្គរដ្ឋទូតបារាំងថ្មី ប្រចាំកម្ពុជា នារសៀលថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១ សម្តេច ស ខេង បានថ្លែងថា «ស្នើពិនិត្យលទ្ធភាពរៀបចំនូវកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ គឺក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធនៃភាគីបារាំង លើការងារកិច្ចសហប្រតិបត្តិការ សន្តិសុខ រួមទាំងការងារប្រយុទ្ធប្រឆាំងបទល្មើសបច្ចេកវិទ្យា ឧក្រិដ្ឋកម្មឆ្លងដែន និងការកសាងសមត្ថភាព»។

ជាការឆ្លើយតប លោក ហ្សាក់ ប៉ីឡេត បានឯកភាពចំពោះការលើកឡើងរបស់ សម្តេច ហើយក៏មានគោលបំណងបង្កើនថែមទៀតនូវកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងនោះ ក៏មានកិច្ចសហប្រតិត្តិការរវាងក្រសួងមហាផ្ទៃកម្ពុជា និងស្ថាប័នពាក់ព័ន្ធរបស់ប្រទេសបារាំង ផងដែរ។ លោក ក៏បានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាពនៃការអភិវឌ្ឍកម្ពុជា ពិសេសក្នុងវិស័យសេដ្ឋកិច្ច សង្គម ដែលកត្តានេះ លោក បានលើកឡើងថា ជាចំណុចមួយដែលភាគីទាំងពីរត្រូវតែយកចិត្តទុកដាក់បង្កើន និងពង្រឹងកិច្ចសហប្រតិបត្តិការសន្តិសុខឲ្យកាន់តែសកម្មថែមទៀត ដើម្បីរួមចំណែកជានាការអភិវឌ្ឍ៕

## កុងស៊ុលកម្ពុជា សហការជាមួយថៃ បញ្ជូនពលរដ្ឋខ្មែរ ៤០នាក់ ដែលចាញ់បោកមេខ្យល់ ត្រឡប់មកមាតុប្រទេសវិញ

https://dap-news.com/national/ ByPH104 Posted on November 26, 2021

**ភ្នំពេញ៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសខ្មែរ បានឲ្យដឹងថា ស្ថានអគ្គកុងស៊ុលកម្ពុជា នៅប្រទេសថៃ បានអន្តរាគមន៍ទៅអាជ្ញាធរថៃ ដើម្បីសម្របសម្រួល បញ្ជូនពលរដ្ឋខ្មែរចំនួន ៤០នាក់ ដែលត្រូវមេខ្យល់បោកបញ្ឆោតយកឆ្លងដែនខុសច្បាប់ ត្រឡប់មកកម្ពុជាវិញ ។ លោក កុយ គួង បានបញ្ជាក់ថា នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០២១ ស្ថានអគ្គកុងស៊ុលកម្ពុជា នៅប្រទេសថៃបានអន្តរាគមន៍ ទៅនគរបាលអន្តោប្រវេសន៍ថៃ ដើម្បីសម្របសម្រួល បញ្ជូនពលរដ្ឋខ្មែរចំនួន ១១នាក់ (ស្រី ២នាក់ និងកូនក្មេង ២នាក់) ឲ្យបានវិលត្រឡប់មកកម្ពុជាវិញ តាមច្រកព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែតយកទៅប្រគល់ជូនអាជ្ញាធរកម្ពុជាដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល។

លោកបន្តថា ដោយឡែកកាលពីថ្ងៃទី២៥ វិច្ឆិកា អាជ្ញាធរមានសមត្ថកិច្ចថៃ បានឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន ២៩នាក់ (ស្រី១៤នាក់) ដែលត្រូវបានមេខ្យល់ បោកបញ្ឆោតយកឆ្លងដែន ចូលប្រទេសថៃដោយខុសច្បាប់។ ភ្លាមៗស្ថានអគ្គកុងស៊ុលកម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ ក៏បានចុះទៅអន្តរាគមន៍ ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើ មកមាតុប្រទេសវិញ នៅរសៀលថ្ងៃដដែល តាមច្រកទ្វារព្រំដែនអន្តរជាតិខ្លងលឹក-ប៉ោយប៉ែត ដោយប្រគល់ជូនអាជ្ញាធរកម្ពុជា ដើម្បីដំណើរការតាមនីតិវិធីសុខាភិបាល ៕

## ថៃនឹងទទួលយកពលករចំណាកស្រុកស្របច្បាប់ ៤0ម៉ឺននាក់ពីប្រទេសជិតខាង ក្នុងនោះមានកម្ពុជាផងដែរ

https://khmernote.com.kh/ November 27, 2021 Pheakdey

ថៃ៖ យោងតាមការចុះផ្សាយនៅក្នុងបណ្តាញសារព័ត៌មាន National Thailand បានឲ្យដឹងថា ប្រទេសថៃនឹងបើកទទួលយកពលករចំណាកស្រុកស្របច្បាប់ចំនួន ៤០០,០០០ នាក់ពីប្រទេសជិតខាងចំនួន ៣ រួមមាន ឡាវ មីយ៉ាន់ម៉ា និងកម្ពុជា។ បើតាមលោកវេជ្ជបណ្ឌិត Taweesilp Visanuyothin ដែលជាអ្នកនាំពាក្យឲ្យមជ្ឈមណ្ឌលគ្រប់គ្រងជំងឺកូវីដ ១៩ ថៃបានបញ្ជាក់ថា ការសម្រេចបើកទទួលយកពលករចំណាកស្រុកស្របច្បាប់នេះគឺត្រូវបានធ្វើឡើងដើម្បីកាត់បន្ថយចំនួនពលករឆ្លងដែនខុសច្បាប់ ដែលព្យាយាមចូលទៅកាន់ទឹកថៃដោយពុំបានពិនិត្យសុខភាពត្រឹមត្រូវនោះទេ។ លោកវេជ្ជបណ្ឌិតរូបនេះបានបញ្ជាក់ថា នាពេលកន្លងអាជ្ញាធរថៃបានរកឃើញពលករចំណាកស្រុកខុសច្បាប់ជាច្រើនវិជ្ជមានជំងឺកូវីដ ១៩ ហើយក្នុងករណីដែលអាជ្ញាធរថៃមិនបានឃាត់ខ្លួនពួកគេទាន់ពេលវេលានៅចំណុចច្រកព្រំដែននោះទេ គឺពួកគេនឹងនាំយកជំងឺកូវីដ ១៩ ទៅចម្លងយ៉ាងសកម្មនៅក្នុងប្រទេសថៃ។

បើតាមលោក Suchart Chomklin រដ្ឋមន្ត្រីក្រសួងការងារថៃបានឲ្យដឹងថា ពេលនេះក្រុមអ្នកជំនាញថៃកំពុងធ្វើការសិក្សាជុំវិញបញ្ហានេះជាមួយភាគីទាំង ៣ ប្រទេសខាងលើហើយ ដើម្បីកំណត់ចំនួនពលករមកពីប្រទេសនីមួយៗនិងពេលវេលាជាក់លាក់នៃការធ្វើដំណើរទៅកាន់ទឹកដីថៃ។ លោករដ្ឋមន្ត្រីរូបនេះបានបញ្ជាក់ថា ភាគីថៃសង្ឃឹមយ៉ាងមុតមាំថាពលករស្របច្បាប់ទាំង ៤០ម៉ឺននាក់នោះគឺគ្មានជំងឺកូវីដ ១៩ នោះទេ ហើយពួកគេនឹងរួមចំណែកយ៉ាងសកម្មក្នុងការជួយលើកកម្ពស់សេដ្ឋកិច្ចជាតិថៃឲ្យងើបឡើងវិញ៕

## ស្ថានអគ្គកុងស៊ុលប្រចាំខេត្តស្រះកែវ សហការជាមួយ មូលនិធិបណ្តាញលើកកម្ពស់សិទ្ធិពលករ ចុះសួរសុខទុក្ខកម្មករខ្មែរនិងចែកអំណោយ

https://cen.com.kh/ Posted ByPen Srey NeatNovember 27, 2021

ភ្នំពេញ ៖ អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាឯកឧត្តម កុយ គួង បាន ឲ្យដឹងថា នៅថ្ងៃទី២៧ ខែវិច្ឆិកានេះក្រុមការងាររបស់ស្ថានអគ្គកុងស៊ុលប្រចាំខេត្តស្រះកែវ ប្រទេសថៃ បានសហការជាមួយអាជ្ញាធរ ខេត្តសាកែវ និង តំណាងមូលនិធិបណ្តាញលើកកម្ពស់សិទ្ធិពលករ (Labour Rights Promotion Network Foundation) ចុះសួរសុខទុក្ខបងប្អូនកម្មករខ្មែរ ដែលពួកគាត់កំពុងធ្វើចត្តាឡីស័កតាមផ្ទះ ព្រមទាំងបាននាំយក អំណោយឧបត្ថម្ភមានដូចជា អង្ករ ត្រីខកំប៉ុង ទឹកដោះគោ បាយកញ្ចប់ នំប៉ុង ទឹកសុទ្ធ និងសម្ភារៈមួយចំនួនទៀត ចែកជូនពួកគាត់នៅតាមខ្ទង់ផ្ទះចាំចំការចំនួនប្រាំពីរកន្លែង (៤២គ្រួសារ ស្មើ ១២៦នាក់) ដើម្បីជួយសំរាលទុក្ខលំបាកដល់ពួកគាត់ដែលកំពុងទទួលរងផលប៉ះពាល់ដោយ សារការរីករាលដាលជម្ងឺ កូវីដ-១៩។ ឯកឧត្តម កុយ គួង បានបន្តថា បន្ថែមពីនេះ ក្រុមការងារបានធ្វើការណែនាំអប់រំ និងរំលឹកបន្ថែមដល់ បងប្អូនខ្មែរទាំងអស់ត្រូវចេះថែទាំសុខភាពជាប្រចាំ

ព្រោះជម្ងឺកូវីដ-១៩ មិនទាន់បាត់នៅឡើយ ដោយត្រូវពាក់ម៉ាស់ជាប្រចាំពេលចេញធ្វើដំណើរ ក្រៅ ឧស្សាហ៍លាងដៃនឹងសាប៊ូ អាកុល ឬជែល មិនត្រូវទៅកន្លែងណា ដែលមានមនុស្សច្រើន ឬកន្លែងដែលមានខ្យល់ចេញចូលតិច ព្រមទាំង អនុវត្តតាមវិធានការសុខាភិបាលថៃដែលអាជ្ញាធរថៃបានណែនាំ៕ រក្សាសិទ្ធិដោយ ៖ ចេស្តារ

## ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១

### ចាប់បានពលរដ្ឋខ្មែរ លួចឆ្លងដែនខុសច្បាប់ ចំនួន ៣២នាក់

https://cen.com.kh/ Posted ByPen Srey Neat November 29, 2021

ខេត្តស្រះកែវ ៖ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ប្រជាពលរដ្ឋខ្មែរចំនួន ៣២ នាក់ លួចឆ្លងដែនខុសច្បាប់តាមច្រកធម្មជាតិ ត្រូវបានរកឃើញនៅភូមិណងសាម៉េត ឃុំខុកស៊ុង ស្រុកខូកស៊ុង ខេត្តស្រះកែវ តាមការសួរនាំបានបង្ហាញថា ពួកគេទាំងអស់មកពី ខេត្តបន្ទាយមានជ័យ, ខេត្តកំពង់ចាម, ខេត្តបាត់ដំបង, ខេត្តក្រចេះ, ខេត្តសៀមរាប, ខេត្តត្បូងឃ្មុំ, ខេត្តឧត្តរមានជយ និងខេត្តព្រៃវែង ។ ពួកគេចង់ធ្វើដំណើរទៅរកការងារធ្វើក្នុងតំបន់ ទីក្រុងបាងកក ខេត្តឆាក់ជើងសាវ ខេត្តសាមុទ្របាកាន ខេត្តរ៉ាក់យ៉ង និងខេត្ត ឈុនបុរី ទើបសមត្ថកិច្ចឃាត់ខ្លួនពួកគេដើម្បីចាត់ការបន្តតាមច្បាប់៕ រក្សាសិទ្ធិដោយ ៖ កូលាប

### រដ្ឋាភិបាលថៃ អនុញ្ញាតឲ្យពលករបរទេសរាប់សែននាក់ ដើម្បីដំណើរការសេដ្ឋកិច្ច និងទប់ស្កាត់ការជួញដូរមនុស្ស

https://cen.com.kh/ Posted ByPen Srey NeatNovember 29, 2021

រាជធានីបាងកក ៖ ចាប់តាំងពីចាប់ផ្តើមបើកទ្វារប្រទេសឡើងវិញមក រដ្ឋាភិបាលថៃ គ្រោងអនុញ្ញាតដល់ពលករបរទេស ប្រហែល៤០ម៉ឺននាក់ មកពីប្រទេសកម្ពុជា ឡាវ និង មីយ៉ាន់ម៉ា ចូលមកធ្វើការ ដោយសារស្រប ច្បាប់ ដើម្បីដំណើរការសេដ្ឋកិច្ចឡើងវិញ និង ទប់ស្កាត់ការជួញដូរមនុស្ស ដោយខុសច្បាប់។

លោក Suchart Chomklin រដ្ឋមន្ត្រីក្រសួងការងារថៃ បានបញ្ជាក់ថា លោកគ្រោងនឹងជួបពិភាក្សាជាមួយក្រសួងការងារកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា អំពីករណីកម្លាំងពលកម្មនេះ ព្រោះថៃ ត្រូវការពលករកាន់តែច្រើនឡើងសម្រាប់ជួយដល់វិស័យសេដ្ឋកិច្ចរបស់ខ្លួន។ ថៃអនុញ្ញាតដល់ពលករ មកពីប្រទេសជិតខាងទាំង៣នេះ។

លោកវេជ្ជបណ្ឌិត Taweesilp Visanuyothin អ្នកនាំពាក្យ មជ្ឈមណ្ឌលគ្រប់គ្រងស្ថានការណ៍កូកូវីដ-១៩ ហៅកាត់ CCSA បានបញ្ជាក់ថា រដ្ឋាភិបាលថៃ គ្រោងនឹងអនុញ្ញាតឱ្យពលករប្រែល៤០០ ០០០នាក់ មកពីប្រទេសជិតខាង ចូលមកធ្វើការងារក្នុងប្រទេសថៃ ដោយស្របច្បាប់។ ថៃត្រូវការពលករបរទេសជាច្រើន ដើម្បីជួយដល់សេដ្ឋកិច្ចរបស់ប្រទេសជាតិឲ្យដំណើរការឡើងវិញ និង ទប់ស្កាត់ការជួញដូរមនុស្សដោយខុសច្បាប់ ឆ្លងព្រំដែន និងទប់ស្កាត់ការឆ្លងរាលដាលពីជំងឺកូវីដ-១៩ផងដែរ។

បើតាមគេហទំព័រ Worldometer ចេញផ្សាយ កាលពីព្រឹក ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ថា ថៃ មានអ្នកឆ្លងកូវីដ-១៩ សរុប ជាង២,១លាននាក់ ហើយក្នុងនោះមានអ្នកស្លាប់ ២០ ៧០៥នាក់ និង មានអ្នកជាសះស្បើយជាង២លាននាក់៕រក្សាសិទ្ធិដោយ ៖សារាយSN

## អគ្គកុងស៊ុលកម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ បន្តអន្តរាគមន៍បញ្ជូនពលករខ្មែរ ៣២នាក់ មកមាតុភូមិវិញ

http://freshnewsasia.com/ 2021-11-29 11:41am

**(ភ្នំពេញ)៖** លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងថា ស្ថានអគ្គកុងស៊ុលកម្ពុជា នៅខេត្តស្រះកែវ ប្រទេសថៃ បានបន្តអន្តរាគមន៍បញ្ជូនពលករខ្មែរ ៣២នាក់ ឱ្យបានមាតុភូមិនិវត្តន៍វិញ។ លោក កុយ គួង បានបញ្ជាក់ថា នៅថ្ងៃទី២៨ ខែវិច្ឆិកា ២០២១ អាជ្ញាធរមានសមត្ថកិច្ចថៃបានឃាត់ខ្លួនពលរដ្ឋខ្មែរចំនួន៣២នាក់ ដែលត្រូវបានមេខ្យល់បោកបញ្ឆោតយកឆ្លងដែនចូលប្រទេសថៃ ដោយខុសច្បាប់។ ស្ថានអគ្គកុងស៊ុលកម្ពុជានៅខេត្តស្រះកែវប្រទេសថៃ បានចុះទៅអន្តរាគមន៍ជាមួយអាជ្ញាធរថៃ ដើម្បីបញ្ជូនពលរដ្ឋខ្មែរខាងលើមកមាតុប្រទេសវិញនៅរសៀលថ្ងៃដដែល តាមច្រកទ្វារព្រំដែនអូរបីជាន់ខេត្តបន្ទាយមានជ័យ៕

## នគរបាលព្រំដែន និងយោធា រួមគ្នាទប់ស្កាត់ពលករមិនឲ្យឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ បន្ទាយមានជ័យ ២៩ ខែ វិច្ឆិកា ឆ្នាំ ២០២១ ម៉ោង ១៤:១៨

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ និងយោធាផ្នែកសឹករងស្រុកម៉ាឡៃ កាលពីយប់ថ្ងៃទី២៨ ខែវិច្ឆិកា បានរួមគ្នាទប់ស្កាត់ពលករប្រុសស្រីចំនួន២៣នាក់មិនឲ្យឆ្លងដែនខុសច្បាប់។ ករណីទប់ស្កាត់ខាងលើនេះ បានធ្វើឡើងនៅក្បែរបន្ទាត់ព្រំដែន ចំណុចប៉ាតង់ទឹក ស្ថិតក្នុងភូមិបឹងរាំង ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ខណៈពេលកម្លាំងសមត្ថកិច្ចទាំង២ បានចុះល្បាតការពារសន្តិសុខ និងសុវត្ថិភាពជូនពលរដ្ឋ ហើយក៏ជួបប្រទះនឹងពលករបំរុងឆ្លងដែនខុសច្បាប់ចំនួន២៣នាក់ ក្នុងនោះមានស្រី១៣នាក់ និងកុមា៣នាក់ ហើយពួកគេគឺមកពីខេត្តសៀមរាប។

លោកវរសេនីយ៍ឯក សួង សៅ មេបញ្ជាការរងនគរបាលការពារព្រំដែនគោកលេខ៨១៥ បានប្រាប់តាមបណ្ដាញសង្គមហ្វេសប៊ុកថា ករណីចុះល្បាត និងទប់ស្កាត់ពលករឆ្លងដែនខុសច្បាប់នេះ គឺធ្វើតាមបទបញ្ជាណែនាំរបស់លោកឧត្តមសេនីយ៍ទោ សិទ្ធ ឡោះ ស្នងការនគរបាលខេត្ត ។ លោកមេបញ្ជាការបន្តថា ក្រោយពេលចាប់ខ្លួនពលករទាំងនេះ បាននាំមកធ្វើការអប់រំ និងធ្វើកិច្ចសន្យា រួចក៏បានបញ្ជូនបន្តទៅឲ្យនគរបាលជំនាញនៃអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ ដើម្បីចាត់ការបន្តតាមនីតិវិធី៕

## ពលរដ្ឋរិះគន់អាជ្ញាធរខ្មែរថា មិនជួយដល់ពលករខ្មែរដែលសមត្ថកិច្ចថៃចាប់ដាក់គុកនៅតំបន់ព្រំដែនខេត្តបន្ទាយមានជ័យ

https://www.rfa.org/khmer/news/ ដោយ ជាតិ ចំណាន 2021-11-29

ពលរដ្ឋមួយចំនួន រិះគន់អាជ្ញាធរពាក់ព័ន្ធថា មិនអើពើជួយអន្តរាគមន៍ដល់ពលករខ្មែរដែលសមត្ថកិច្ចថៃចាប់ខ្លួន ដោយសារពួកគេឆ្លងដែនខុសច្បាប់នៅតំបន់ព្រំដែនជាប់ខេត្តបន្ទាយមានជ័យនោះទេ។ ប្រតិកម្មរបស់ពលករនេះ ធ្វើឡើងក្រោយពីពួកគេត្រូវបានអាជ្ញាធរថៃចាប់ដាក់ពន្ធនាគារនៅតំបន់ព្រំដែនខេត្តស្រះកែវយ៉ាងលំបាកវេទនា ហើយពុំមានអាជ្ញាធរខ្មែរជួយដល់ពួកគាត់ឡើយ។ ពលរដ្ឋដែលអាជ្ញាធរថៃទើបបញ្ជូនត្រឡប់មកកម្ពុជាវិញ ថ្លែងថា មានពលករខ្មែរជាច្រើននាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ដាក់ឃុំជារៀងរាល់ថ្ងៃនៅក្នុងមន្ទីរឃុំឃាំងនៅតំបន់ព្រំដែនខេត្តស្រះកែវ។

ប្រជាពលរដ្ឋរស់នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យលោក សួរ ពិសិដ្ឋ ប្រាប់វិទ្យុអាស៊ីសេរី នៅថ្ងៃទី២៩ វិច្ឆិកាថាលោកនិងពលករខ្មែរចំនួន៧នាក់ត្រូវបានទាហានថៃចាប់ដាក់គុកនៅស្រុកអារញ្ញ (Aranyaprathet) ខេត្តស្រះកែវ (Sra kao) រយៈពេល ៤ថ្ងៃយ៉ាងលំបាកវេទនាកាលពីសប្ដាហ៍កន្លងទៅ ។ ពលករវ័យ៣៧ឆ្នាំរូបនេះ បន្តថា នៅក្នុងគុកនោះមានពលករខ្មែរប្រមាណ ៥០នាក់ ក៏ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនក្នុងពេលពួកគេធ្វើដំណើរឆ្លងដែនខុសច្បាប់នៅតំបន់ព្រំដែនខេត្តស្រះកែវដែរ។ លោកបន្ថែមថា អាជ្ញាធរថៃបានឃុំឃាំងពួកលោកក្នុងគុកណែនចង្អៀត និងផ្ដល់អាហារហូបចុកមិនបានគ្រប់គ្រាន់នោះទេ៖ «បើអត់មានលុយសម្រាប់ទិញបាយហូបទេគឺលំបាកខ្លាំង នៅថ្ងៃចុងក្រោយមួយថ្ងៃពេញគឺវាអត់ឱ្យបាយហូបបណ្ដោយ។ ពេលហ្នឹងខ្ញុំរត់បានប្រហែលជា ២០ម៉ែត្រដែរ ប៉ុន្តែដល់ពេលគេបាញ់កេតស្លឹកត្រចៀក ហើយគេស្រែកថា បើរត់គេបាញ់សម្លាប់ចោល ខ្ញុំខ្លាចព្រោះអីឃើញឈើយស្លឹកត្រចៀក ខ្ញុំក៏ខ្ជិលរត់បណ្ដោយទៅ។ វេទនាខ្លាំងជាងសម័យមុនទៅ សម័យនេះមិនគួរដល់ថ្នាក់ហ្នឹង ឥឡូវវាចង់លើសពីមុនទៅទៀត។ បងឯងគិតមើលគ្នាសំពះឡើងដល់បាតជើងហើយ ទាត់គ្នាឡើងដួលនិយាយទៅពីរនាក់ទាត់ម្នាក់គិតមើលទៅ»។

ស្រដៀងគ្នានេះដែរ ពលរដ្ឋម្នាក់ទៀតដែលទើបអាជ្ញាធរថៃចាប់បញ្ជូនត្រឡប់ទៅកម្ពុជាវិញ លោកស្រី ច្រឹប ណារីន ថ្លែងថា លោកស្រី និងពលករខ្មែរជិត ២០នាក់ត្រូវបានទាហានថៃចាប់ដាក់គុកនៅតំបន់ព្រំដែនខេត្តស្រះកែវរយៈពេល ៣ថ្ងៃ។ លោកស្រីបន្តថា អាជ្ញាធរថៃបានបង្ខំឱ្យពួកលោកស្រីបង់ប្រាក់ម្នាក់៦៣ពាន់បាត ឬស្មើប្រមាណ ១៩០ដុល្លារ ជាថ្នូរចាប់ពួកគេត្រឡប់មកកម្ពុជាវិញកាលពីថ្ងៃទី១៥ វិច្ឆិកា៖ «គេថា បើសិនជាយើងមិនបង់លុយ យើងនឹងត្រូវជាប់គុក ២ខែ ទៅ ៣ខែ បើមានលើកទី២ លើកទី៣ ទោសយើងកាន់តែធ្ងន់ គេថា យើងទៅខុសច្បាប់ ។ ប្រឈមតឹងរ៉ឹងមែន ចុះបើយើងជំពាក់ធនាគារយើងមិនដឹងធ្វើម៉េចទៅរកណាបានរកស្រុកខ្មែរអត់មានការងារធ្វើ ហើយស្រូវលិចទឹកអស់អីចឹង»។ ពលករទាំងនេះឆ្លងដែនទៅប្រទេសថៃខុសច្បាប់ ដើម្បីទៅរកការងារធ្វើនៅទីក្រុងបាងកក ហើយត្រូវបានទាហានថៃចាប់ខ្លួននៅតំបន់ព្រំដែនជាប់ខេត្តបន្ទាយមានជ័យ។ ពួកគាត់សង្កេតឃើញថា ពលករខ្លះត្រូវបានទាហានថៃចាប់វាយទាត់ធាក់ដួលសន្លប់ ដោយសារពួកគេរត់គេចត្រឡប់មកកម្ពុជា ហើយត្រូវទាហានថៃដេញបាញ់ស្ទាក់ចាប់បាន។ ពួកគេអះអាងថា បើទោះបីជាមានពលករខ្មែរជាច្រើននាក់ត្រូវបានអាជ្ញាធរថៃចាប់ដាក់គុកនិងវាយធ្វើបាបយ៉ាងនេះក្ដីក៏ពុំមានមន្ត្រីស្ថានទូត និងអាជ្ញាធរខ្មែរណាចុះសួរសុខទុក្ខ និងជួយអន្តរាគមន៍ដល់ពួកគាត់ឡើយ។

ទាក់ទងនឹងបញ្ហានេះស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់វិទ្យុអាស៊ីសេរីថា ពលករដែលថៃចាប់ខ្លួននៅតំបន់ព្រំដែនភាគច្រើនត្រូវបានអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញភ្លាមៗ ក្រោយពេលសាកសួរពួកគេធ្វើកំណត់ហេតុរួចរាល់។ ចំពោះករណីដែលថាអាជ្ញាធរថៃវាយធ្វើធ្វើបាបពលករនោះ លោកថា ពុំទទួលព័ត៌មានជុំវិញរឿងនេះនៅឡើយទេ៖ «អត់ទេដូចអត់មានទេ ខ្ញុំអត់បានសួរព័ត៌មាននឹងដែរ។ ប៉ុន្តែកាលដែលខ្ញុំទំនាក់ទំនងទៅថៃហ្នឹងគាត់ចាប់អត់ទុកទេ ចាប់ហើយគាត់បញ្ជូនមកវិញភ្លាម។ លុះត្រាណាតែគាត់ចាប់បានមេខ្យល់ខាងថៃ ដែលគាត់នាំមនុស្សឆ្លងដែនបានគាត់ទុក បើសិនអត់ចាប់បានមេខ្យល់ដឹកជញ្ជូនទេគាត់អត់ទុកទេ គាត់បញ្ជូនមកវិញភ្លាម»។ មេប៉ូលិសផ្កាយ ១រូបនេះឱ្យដឹងថា នៅថ្ងៃដដែលនេះអាជ្ញាធរថៃបានបញ្ជូនពលករខ្មែរជាង ៦០នាក់ត្រឡប់មកកម្ពុជាវិញតាមច្រករបៀងព្រំដែនអូរបីជាន់ ស្រុកអូរជ្រៅនិងច្រករបៀងព្រំដែនក្នុងស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទង មន្ត្រីកុងស៊ុលខ្មែរប្រចាំនៅខេត្តស្រះកែវ ដើម្បីសុំអត្ថាធិប្បាយបន្ថែមអំពីការរិះគន់របស់ក្រុមពលករទាំងនោះបានទេនៅថ្ងៃទី២៩ វិច្ឆិកា។

ជុំវិញរឿងនេះមន្ត្រីផ្នែកការពារសិទ្ធពលករចំណាកស្រុក នៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន សង្កេតឃើញថា អំឡុងពេលនេះមានពលករខ្មែរឆ្លងដែនទៅប្រទេសថៃកាន់តែច្រើនឡើង ដោយសារពួកគេអត់ការងារធ្វើនៅក្នុងស្រុក និងជំពាក់ប្រាក់ធនាគារ។ លោកយល់ថា ការណ៍ដែលអាជ្ញាធរថៃវាយធ្វើបាបពលករដែលឆ្លងដែនខុសច្បាប់ដោយសារការអត់ឃ្លាននេះជាទង្វើអមនុស្សធម៌ និងជាការរំលោភសិទ្ធិមនុស្ស។ មន្ត្រីសង្គមស៊ីវិលរូបនេះ និយាយថា រដ្ឋាភិបាលខ្មែរគួរតែអន្តរាគមន៍ទៅភាគីថៃឱ្យបញ្ឈប់វាយដំលើពលរដ្ឋខ្មែរដែលឆ្លងដែនខុសច្បាប់បន្តទៀត និងស្នើឱ្យបញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញភ្លាមៗ ក្រោយពេលចាប់ខ្លួន៖ «គួរណាតែសម្រួលហើយឱ្យពលករគាត់ត្រឡប់ទៅប្រទេសកំណើតវិញដោយសន្តិវិធី ដើម្បីឱ្យពួកគាត់ចូលមកថៃដោយស្របច្បាប់។ សម្រាប់ពលករដែរ គឺគេមិនទាន់បើកឱ្យមកខុសច្បាប់ទេ យើងរង់ចាំមើលថាតើរដ្ឋាភិបាលប្រទេសទាំងពីរបើកច្រកព្រំដែននៅណា តែគេនឹងបើកច្រកឱ្យពលករចូលមកក្នុងពេលឆាប់ៗ ខាងមុខ»។

របាយការណ៍អាជ្ញាធរថៃឱ្យដឹងថា រយៈពេល ១សប្តាហ៍ នៅដើមខែវិច្ឆិកា មានពលករខ្មែរ ៩៩៦នាក់ ត្រូវបានសមត្ថកិច្ចថៃចាប់ខ្លួនក្នុងពេលពួកគេឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់។ ក្នុងនោះ ពលករភាគច្រើនឆ្លងដែនតាមច្រករបៀងព្រំដែនក្នុងខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។ ក្រុមពលករឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរប្រមាណ ២.០០០នាក់ កំពុងជាប់ឃុំនៅមន្ទីរឃុំឃាំងក្នុងខេត្តស្រះកែវ ហើយអ្នកជាប់គុកជិតមួយខែមកហើយក៏មានដែរ។ ពួកគេបន្តថា ពលករភាគច្រើនត្រូវបានអាជ្ញាធរថៃចាប់ខ្លួនក្នុងពេលពួកគាត់ឆ្លងដែនទៅរកការងារធ្វើដោយខុសច្បាប់៕

---